CHILD SAFE TOURISM CST

# សៀវភៅបណ្តុះបណ្តាល

ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ

និងកម្លាំងពលកម្ម នៅក្នុងឧស្សាហកម្មទេសចរណ៍នៅកម្ពុជា

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងទេសចរណ៍

ក្រសួងមហាផ្ទៃ

អគ្គស្នងការដ្ឋាននគរបាលជាតិ

ឧបត្ថម្ភដោយ អង្គការពលកម្មអន្តរជាតិ គម្រោងអនុតំបន់មេគង្គប្រឆាំងការជួញដូរកុមារ និងស្ត្រី

បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០០៧

# សៀវភៅបណ្ណុះបណ្ដាល

សម្រាប់ផែនការយុទ្ធសាស្ត្រ ២០០៦_២០០៨

ស្ដីពី

ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់

ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម

នៅក្នុងឧស្សាហកម្មទេសចរណ៍កម្ពុជា

## ផ្នែកទី ៣៖ សៀវភៅបណ្ណុះបណ្ដាល

RBHraCaNacRkkmCa
Cati sasna RBHmhakSRt

RksgeTscrN

Garmÿka

]sSahkmeTscrNkmCa)ancMrmcENkyagsxanceBaHcNMCati ng)anbegItt»kaskargar CaeRcInsRmabGaCIvkmkgRsk ngRbCaCnRkRk. cnnePÁveTscrCati ngGnrCati mankarekIneLIgCa MdaB CaBessry³eBMBrqaMcgeRkayenH cnnePÁveTscrekIneLIgCamFümRbmaN 25% kgmyqa. edaysarEttfamPaBénvsyeTscrN )aneFI[raCrdaP)aMkmCacatTkvsyenH CavsyGaTPaBmykg ceNamvsyGaTPaBTag 6 rbsxn kgkarGPvDÆnesdækic ngsgm. karBRgIg ngkarpSBpSaynvvsy eTscrN KCayTsa®sdsxanmykgceNamyTsa®ssxan²CaeRcInrbsraCrdaP)aM edIm,QaneqaH eTArkkarTTYl)annveKaMkarN ngeKaMedArbsyTsa®sCati katbnyPaBRkRk eKaMedAGPvDÆn shsSvtSrbsRbeTskmCa ngEpnkarGPvDÆnyTsa®sfakCatf² CaeRcIneTot.

EteTaHbICayagNakeday karrIkceRmInrbs]sSahkmeTscrN k)annamknvpMbHBaM GvCmanmycnntc enAkgsgmrbseyIgpgEdr. ehtpl énkarCÁjdr ngBMkmeMkmarEdMekItman CajkjaB KvaTakTgCvÁj ngPaBRkRkenAtamTCnbT ngkareFInKrbnykmenATRbCCn ngTRkg enAkg RbeTs ngenAtamtbnnanaenAkgRbeTsCtxag. edIm,eqIytbceBaHbBaaTagGsenH RksgeTscrN)an pcepImnvKntdsxanmy eday)anerIbcbegItkmvFI svtPaBkmarkgvsyeTscrN ¬s>k>T¦. cab taMgBIqa 2001 mk kmvFIenHKsbBaakBpMbHBaMGvCmanénkarrIkceRmIn ngkarGPvDÆnrbsvsy eTscrN edayepateTAelIvFankarTbsati ngkarBarenAkgtbn bshKmneTscrN. cNcsxanén karGnvtnkmvFIenH KkcxtxRbgERbgbegIt[manEpnkarCatcnn 2 rmman EpnkarskmPaBCati sBI karCÁjdrmnsS ngekgRbvBapvePT ngEpnkarskmPaBCati sBIkarMbb)atTRmgFnFr énBMkm kmar. ktaca)acceBaHkaryMdgrbsEpnkarenH KkcshRbtbtkarrvagRksgBakBndcCa Rksg mhaép Rksgkargar bNHbNaMvCaCv³ RksgsgmkcGttyTCn ngyvntsm,Ta Rksgkckarnari ngGgkarCati GnrCati EdMrmman GgkarTsSn³BPBeMakkmCa GgkarGkpatkmCa GgkarmtsLaj Ggkar Friends International Ggkar Child Wise Australia GgkarEGedT»»»»»»»».

kmvFIsvtPaBkmarenAkgvsyeTscrN )aneFIkarsICeRmAeTAelIbBaakarCÁjdrenAkgvsy eTscrN. RksgeTscrNedaymankarCy]btmBIsNakGgkarBMkmGnrCati kgKeRmagMbb)at BMkmkmar (ILO-IPEC) )anbegIt ngcabepImGnvtnvEpnkaryTsa®sry³eBM3qa ¬2007-2009¦ sBI kareMIkkmssvtPaBkmarkgvsyeTscrN edIm,TbsatkarCÁjdr®s ngkmar kgeKaMbNgekg RbvBakmagBMkm ngpvePT enAkg]sSahkmeTscrN edIm,GPvDÆKntpcepIm ngsmTpMTagLay rbsxn. GnraKmnsRmabEpnkaryTsa®senHngRtv)aneKsRmbsRmMenAfakCati ngtamtbnsakM,g

Ed l Rtv)aneRCserscnnbK extesmrab raCFanPeB j ngRkgRBHshn. kcxtxRbgERbgTagenHng Rtv)aneFeLg edaymankarc l rmyagxagkaBsNaksmaKmneyaCk shBnshCB EpkÉkCn ext-Rkg ngshKmnEd l manp l bHBa l. karENnanvGnraKmnTagenH KmanesvePAeKa l karNRbtbt ng esvePAbNHbNa l Ed l PabmkCamyesvePAEpnkaryTsa®s.

cabtagBGnvtkargareTAe l kmvFsvtPaBkmarkgvsyeTscrNmk RksgeTscrN)an TT l nvbTBesaFnCaeRcn ngbnernsRtedm,Gnvt [kanEtmanRbsTPaBEfmeTt. tamry³Epnkar yTsa®s 2007-2009 rbsxn RksgeTscrNsmebCactCyc l rmkatbny ng l bb)atnvbBaa karC j dr®s ngkmar kgeKa l bNgekgRbvBapvePT ngB l km. eygsme l kTkctceBaHGkEd l edrtnaTyagsxankgergenH [rkSanvkarc l rmceBaHKntpcepmenH ehyc l rmeFkarCamyeygkg crt l kN³énkarrbrmKa edm,eqytbeTAngbBaaénkarC j drrbssgm ngenAkgdeNrkarCRm j [man karcabGarmNkanEtxageLgceBaHCnEd l gayrgeRKaH enAkgRbeTs.

rdaenp

efag xu

# មាតិកា


១. សេចក្តីផ្តើមចំពោះសៀវភៅបណ្តុះបណ្តាល ..... ១

សាវតាទូទៅ ..... ១

ហេតុអ្វីបានជាត្រូវបង្កើតសៀវភៅបណ្តុះបណ្តាលនេះ? ..... ៣

តើសៀវភៅបណ្តុះបណ្តាលនេះបង្កើតឡើងសម្រាប់នរណា? ..... ៥

តើសៀវភៅបណ្តុះបណ្តាលនេះអាចប្រើបានដោយរបៀបណា? ..... ៥

តើសៀវភៅបណ្តុះបណ្តាលនេះមានអ្វីខ្លះ? ..... ៦

២. ការប្រើប្រាស់សៀវភៅបណ្តុះបណ្តាល ..... ៨

៣. បរិបទទូទៅ ..... ១៨

ម៉ូឌុល ១ - វិស័យទេសចរណ៍ ..... ១៨

ក. និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងវិស័យទេសចរណ៍ ..... ២០

ខ. ស្ថានភាពទូទៅនៃវិស័យទេសចរណ៍កម្ពុជា ..... ២៤

គ. ផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច ..... ២៦

ឃ. ស្ថានភាពទូទៅនៃកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍ ..... ៣០

ម៉ូឌុល ២ - ការជួញដូរ ..... ៣៥

ក. និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងការជួញដូរ ..... ៣៦

ខ. ស្ថានភាពទូទៅនៃការជួញដូរកុមារ និង ស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍កម្ពុជា ..... ៣៨

គ. កន្លែងដែលឃើញមានការជួញដូរកុមារ និងស្ត្រី ..... ៤១

ឃ. ហេតុអ្វីបានជាកុមារ និងស្ត្រីរងគ្រោះដោយការជួញដូរ តែងតែត្រូវបានគេរំលោភសិទ្ធិរបស់ខ្លួន ..... ៤៥

ង. កត្តាជំរុញ និង កត្តាអូសទាញដែលនាំឱ្យមានការជួញដូរកុមារ និងស្ត្រី ..... ៤៥

ច. ឥទ្ធិពលនៃការជួញដូរកុមារ និង ស្ត្រីវ័យក្មេង ..... ៤៩

៤. ខ្លឹមសារ ..... ៥៣

ម៉ូឌុល ៣ - ការទប់ស្កាត់ការជួញដូរ ..... ៥៣

ក. ស្ថានភាពទូទៅស្តីពីកិច្ចខិតខំទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងក្នុងប្រទេសកម្ពុជា ..... ៥៤

ខ. បញ្ហាដែលបានជួបប្រទះ និង ការគស្ញមតិសាធារណៈ ..... ៥៨

គ. កម្មវិធី និង បទអន្តរាគមន៍គន្លឹះ ..... ៥៩

ម៉ូឌុល ៤ - លើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ............................................... ៧៦
ក. លើកកម្ពស់ទេសចរណ៍សុវត្ថិភាពដើម្បីទប់ស្កាត់ការជួញដូរមនុស្ស .................................... ៧៧
ខ. គាំទ្រសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព .......................................... ៨០
គ. ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពការងារ និង ស្ថានភាពរស់នៅរបស់កុមារ និង ស្ត្រីធ្វើការ.............. ៨១
ឃ.ធ្វើឱ្យប្រសើរឡើងចំពោះការអនុវត្តន៍បទបញ្ញត្តិវិស័យទេសចរណ៍..................................... ៨៧
ង. ធ្វើឱ្យប្រសើរឡើងនូវការការពារ និង សេវាសង្គម.................................................... ៩១
ច. កិច្ចសហការ និង សហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សហព័ន្ធសហជីព និយោជក និង អង្គការមិនមែនរដ្ឋាភិបាល ............................. ៩៣

## បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank |
| | ធនាគារអភិវឌ្ឍន៍អាស៊ី |
| APSO | Action Programme Summary Outline |
| | ការបង្ហាញកម្មវិធីសកម្មភាពសង្ខេប |
| AR | Awareness raising |
| | ការលើកកម្ពស់ការយល់ដឹង |
| ARCPPT | Asia Regional Cooperation to Prevent People Trafficking |
| | កិច្ចសហការតំបន់អាស៊ីដើម្បីទប់ស្កាត់ការជួញដូរមនុស្ស |
| ASEAN | Association of South East Asian Nations |
| | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( អាស៊ាន) |
| ASEANTA | ASEAN Travel Agency Association |
| | សមាគមទីភ្នាក់ងារទេសចរណ៍អាស៊ាន |
| AFESIP | Agir Pour les Femmes En Situation Precaire |
| | អង្គការ AFESIP |
| CAMFEBA | Cambodian Federation of Employers and Business Association |
| | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CATA | Cambodian Association of Travel Agents |
| | សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា |
| CB | Capacity Building |
| | ការកសាងសមត្ថភាព |
| CDW | Child Domestic Workers |
| | កុមារបម្រើការងារតាមផ្ទះ |
| CEDAW | Convention on the Elimination of all forms of Discrimination Against Women |
| | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី |
| CHA | Cambodian Hotel Association |
| | សមាគមសណ្ឋាគារកម្ពុជា |
| CL | Child labour |
| | ពលកម្មកុមារ |

| | |
|---|---|
| CMDG | Cambodia Millennium Development Goals<br>គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា |
| CNCC | Cambodian National Council for Children<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| COMMIT | Coordinated Mekong Ministerial Initiative Against Trafficking<br>ការផ្តួចផ្តើមអន្តរក្រសួងក្នុងកិច្ចសម្របសម្រួលតំបន់ទន្លេមេគង្គប្រឆាំងនឹងការជួញដូរ |
| COSECAM | NGO Coalition to Address Sexual Exploitation of Children in Cambodia<br>សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដោះស្រាយការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា |
| CPET | Child Peer Education Team<br>ក្រុមមិត្តអប់រំមិត្តរបស់កុមារ |
| CPN | Child Protection Network<br>បណ្តាញការពារកុមារ |
| CRC | Convention on the Rights of the Child<br>អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CST | Child Safe Tourism<br>សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ |
| CSTC | Child Safe Tourism Commission<br>គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ |
| CTSWF | Cambodian Tourism and Service Workers Federation<br>សហព័ន្ធកម្មករ និងសេវាកម្មទេសចរណ៍កម្ពុជា |
| CWDA | Cambodia Women's Development Association<br>សមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា |
| CWT | Child Wise Training<br>វគ្គបណ្តុះបណ្តាលស្តីពី ភាពវៃឆ្លាតរបស់កុមារ |
| DAHTJP | Department of Anti-Human Trafficking and Juvenile Protection<br>នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| DCL | Department of Child Labour<br>នាយកដ្ឋានពលកម្មកុមារ |
| DLI | Department of Labour Inspector<br>នាយកដ្ឋានអធិការកិច្ចការងារ |

| | |
|---|---|
| DoLVT | Department of Labour and Vocational Training<br>មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| DoSVY | Department of Social Affairs, Veterans and Youth Rehabilitation<br>មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| DoWA | Department of Women's Affairs<br>មន្ទីរកិច្ចការនារី |
| ECPAT-Cambodia | End Child Prostitution, Pornography and Trafficking of Children for Sexual Purposes<br>គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងជួញដូរកុមារនៅកម្ពុជា ( អង្គការអ៊ិកផាត កម្ពុជា) |
| FI | Friends International<br>អង្គការមិត្តសំឡាញ់អន្តរជាតិ |
| GDP | Gross Domestic Product<br>ផលទុនក្នុងស្រុកសរុប |
| HCT | Hotel, Catering and Tourism sector<br>វិស័យសណ្ឋាគារ អាហារដ្ឋាន និង ទេសចរណ៍ |
| HIV/AIDS | Human Immuno-deficiency Virus/ Acquired Immune Deficiency Syndrome<br>មេរោគអេដស៍/ជំងឺអេដស៍ |
| IEC | Information Education Campaign<br>យុទ្ធនាការផ្សព្វផ្សាយព័ត៌មានស្តីពីការអប់រំ |
| ILO | International Labour Organisation<br>អង្គការពលកម្មអន្តរជាតិ |
| IO | International Organisation<br>អង្គការអន្តរជាតិ |
| IOM | International Organisation of Migration<br>អង្គការទេសន្តប្រវេសន៍អន្តរជាតិ |
| IPEC | International Programme on the Elimination of Child labour<br>កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ |
| LEASEC | Law Enforcement Against Sexual Exploitation and Trafficking of Children<br>ការអនុវត្តន៍ច្បាប់ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |
| LICADHO | Ligue Cambodgienne de Defense des Droits de l'Homme/ Cambodian League for the Promotion and Defense of Human Rights<br>អង្គការលីកាដូ |

| | |
|---|---|
| MDoSVY | Municipal Directorate of Social Affairs, Veterans and Youth Rehabilitation<br>មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង |
| MoC | Ministry of Commerce<br>ក្រសួងពាណិជ្ជកម្ម |
| MoEYS | Ministry of Education, Youth and Sport<br>ក្រសួងអប់រំ យុវជន និងកីឡា |
| MIME | Ministry of Industry, Mines and Energy<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MoI | Ministry of Interior<br>ក្រសួងមហាផ្ទៃ |
| MoJ | Ministry of Justice<br>ក្រសួងយុត្តិធម៌ |
| MoLVT | Ministry of Labour and Vocational Training<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation (formerly Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation or MoSALVY)<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ( អតីត ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា) |
| MoT | Ministry of Tourism<br>ក្រសួងទេសចរណ៍ |
| MOU | Memorandum of Understanding<br>អនុស្សរណៈនៃការយោគយល់ |
| MoWA | Ministry of Women's Affairs (formerly Ministry of Women's and Veteran Affairs or MoWVA)<br>ក្រសួងកិច្ចការនារី ( អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន) |
| NCSTC | National Child Safe Tourism Commission<br>គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ថ្នាក់ជាតិ |
| NGOs | Non-Government Organisations<br>អង្គការមិនមែនរដ្ឋាភិបាល |
| NPA-TSEC | National Plan of Action Against Trafficking and Sexual Exploitation of Children<br>ផែនការសកម្មភាពជាតិប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |

| | |
|---|---|
| NPA-TIPSE | National Plan of Action on Trafficking In Person and Sexual Exploitation<br>ផែនការសកម្មភាពជាតិស្តីពី ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ |
| NPA-WFCL | National Plan of Action on the Elimination of the Worst Forms of Child Labour<br>ផែនការជាតិស្តីពី ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ |
| NPRS | National Poverty Reduction Strategy<br>យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| NSDP | National Strategic Development Plan<br>ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ |
| NSOE | National Stakeholder Ownership Exercise<br>ភាពជាម្ចាស់ការរបស់ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ (សិក្ខាសាលាថ្នាក់ជាតិ) |
| OHCHR | Office of the High Commissioner on Human Rights<br>ការិយាល័យគណៈកម្មការជាន់ខ្ពស់ស្តីពី សិទ្ធិមនុស្ស |
| OHS | Occupational Health & Safety<br>សុខភាព និង អនាម័យការងារ |
| PCSTC | Provincial Child Safe Tourism Commission<br>គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ថ្នាក់ខេត្ត |
| PPC | Project Proposal Concepts<br>គោលគំនិតសំណើរបស់គម្រោង |
| RGC | Royal Government of Cambodia<br>រាជរដ្ឋាភិបាលកម្ពុជា |
| SARS | Severe Acute Respiratory Syndrome<br>ជំងឺសារ |
| SCA | Save the Children – Australia<br>អង្គការជួយសង្គ្រោះកុមារ - អូស្ត្រាលី |
| SPA | Sub-regional Plan of Action<br>ផែនការសកម្មភាពថ្នាក់អនុតំបន់ |
| TBP | Time-Bound Programme<br>កម្មវិធីមានពេលកំណត់ |
| TCRAM | Technical Cooperation Resource Allocation Mechanism<br>យន្តការបែងចែកធនធានសហការបច្ចេកទេស |

| | |
|---|---|
| TICW | Trafficking in Children and Women Project<br>គម្រោងប្រឆាំងការជួញដូរកុមារ និងស្រ្តី |
| TOT | Training of Trainers<br>វគ្គបណ្តុះបណ្តាលគ្រូបង្គោល |
| TSEC | Trafficking and Sexual Exploitation of Children<br>ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |
| UCW | Understanding Children's Work<br>ស្វែងយល់ពីការងារកុមារ |
| UNCOHCHR | United Nations Cambodia Office of the High Commissioner for Human Rights<br>ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា |
| UNESCO | United Nation Educational, Scientific and Cultural Organisation<br>អង្គការយូណេស្កូ |
| UNIAP | United Nations Inter-Agency Project<br>គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិ (អង្គការ UNIAP) |
| UNICEF | United Nations Children's Fund<br>មូលនិធិកុមារនៃអង្គការសហប្រជាជាតិ |
| UNTAC | United Nations Transitional Authority in Cambodia<br>អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) |
| USAID | United States Assistance for International Development<br>ជំនួយសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| US PRM | United States Bureau of Population, Refugees and Migration<br>ការិយាល័យប្រជាជន ជនភៀសខ្លួន និងទេសន្តរប្រវេសន៍របស់សហរដ្ឋអាមេរិក |
| VDC | Village Development Committee<br>គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| VCAO | Vulnerable Children Assistance Organisation<br>អង្គការជួយសង្គ្រោះកុមារងាយទទួលរងគ្រោះ |
| VSA | Victim support agency<br>ភ្នាក់ងារជួយគាំទ្រដល់ជនរងគ្រោះ |
| WTTC | World Travel and Tourism Council<br>ក្រុមប្រឹក្សាធ្វើដំណើរ និងទេសចរណ៍ពិភពលោក |

| | |
|---|---|
| WTO | World Tourism Organisation<br>អង្គការទេសចរណ៍ពិភពលោក |
| WDA | Women in Development Association<br>សមាគមអភិវឌ្ឍន៍ស្ត្រី |
| WV-C | World Vision-Cambodia<br>អង្គការទស្សនៈពិភពលោក-កម្ពុជា |

## បញ្ជីអក្សរខ្មែរ

| | |
|---|---|
| *Moto/ motodup* | *អ្នករត់ម៉ូតូឌុប* |
| *Prakas* | *ប្រកាស/សេចក្តីណែនាំថ្នាក់ជាតិ/បទបញ្ជាថ្នាក់ក្រសួង/បញ្ញត្តិ* |

# ១. សេចក្តីផ្តើមចំពោះសៀវភៅបណ្តុះបណ្តាល

## សារវតាទូទៅ

ប្រទេសកម្ពុជាមានការទាក់ទាញយ៉ាងខ្លាំងដល់ភ្ញៀវទេសចរ ដោយសារតែកេរ្តិ៍ដំណែលវប្បធម៌ និងធនធានធម្មជាតិដ៏សំបូរបែប ដែលអាចទាក់ទាញឱ្យមានការកើនឡើងនូវចំនួនភ្ញៀវទេសចរយ៉ាងច្រើន ក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយនេះ ដោយមានចំនួនភ្ញៀវទេសចរអន្តរជាតិចំនួន ១.៤២១.000 នាក់ នៅក្នុងឆ្នាំ ២00៥ ឬមានការកើនឡើង ៣៤,៧២% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ វិស័យទេសចរណ៍ គឺជាវិស័យដែលអាចរកប្រាក់បានដល់ទៅរាប់លានដុល្លារ និងជាឧស្សាហកម្មមួយក្នុងចំណោមឧស្សាហកម្មដែលរីកចម្រើនលឿនជាងគេបង្អស់។ មានការរីកចម្រើនវិស័យទេសចរណ៍យ៉ាងធំធេងទាក់ទងទៅនឹងការបង្កើតកន្លែងអាជីវកម្មនានា ដោយសារតែតម្រូវការផ្នែកសេវាកម្មមានទំហំធំធេង។ ដោយសារប្រការនេះ ការបង្កើតការងារដោយវិស័យឧស្សាហកម្មក៏មានការកើនឡើងផងដែរ ហើយអត្ថប្រយោជន៍ដែលទទួលបានពីវិស័យទេសចរណ៍បានរួមចំណែកដល់ការរីកចម្រើនមួយផ្នែកនៅក្នុងសង្គមជាតិ ជាពិសេសអ្នកដែលមានលុយអាចធ្វើដំណើរទស្សនាកេរ្តិ៍ដំណែលផ្សេងៗដែលមាននៅក្នុងប្រទេស ។

ដោយសារតែតម្លាតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា តំបន់ទេសចរណ៍នានាគឺជាហេតុផលសម្រាប់ទាក់ទាញដល់ប្រជាជនក្រីក្រជាច្រើន ដូចជាបុរស ស្ត្រី និងកុមារ ឱ្យធ្វើដំណើរផ្សងព្រេងទៅកាន់តំបន់ទាំងនេះដោយសារតែភាពក្រីក្រ ដោយមានគោលដៅមួយគឺរកប្រាក់ចិញ្ចឹមជីវិត។ ប៉ុន្តែដោយសារតែកង្វះខាតជំនាញ និងការអប់រំពួកគេតែងតែធ្លាក់ចូលទៅក្នុងការកេងប្រវ័ញ្ច។ សមាមាត្រស្ត្រី និងកុមារជាច្រើន ត្រូវបានធ្លាក់ចូលទៅក្នុងកណ្តាប់ដៃរបស់អ្នកកេងប្រវ័ញ្ច និងអ្នកជួញដូរ។ បញ្ហានៃកំណើនវិស័យឧស្សាហកម្មទេសចរណ៍ គឺការកើនឡើងនូវវិស័យដែលឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ជនល្មើស និងភ្ញៀវទេសចរផ្លូវភេទ ។

ភស្តុតាងបានបង្ហាញថា ចំនួនកុមារ (អាយុក្រោម ១៨ ឆ្នាំ) និងស្ត្រីក្មេង (អាយុ ១៨-២៤ ឆ្នាំ) ជាច្រើនកំពុងត្រូវបានជួញដូរ ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅតាមតំបន់ទេសចរណ៍នៃប្រទេសកម្ពុជា។ វាទាមទារឱ្យមានការចាត់វិធានការជាបន្ទាន់ ដើម្បីដកហូតពួកគេចេញពីការកេងប្រវ័ញ្ចពលកម្ម ក្នុងទម្រង់ធ្ងន់ធ្ងរបែបនេះ និងត្រូវបន្តលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ឱ្យបានប្រុងប្រយ័ត្ន ព្រមទាំងដាក់ទណ្ឌកម្មទៅលើអ្នកកេងប្រវ័ញ្ចលើកុមារ។

ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងការជួញដូរត្រូវបានបង្ហាញតាមការផ្តល់សច្ចាប័នទៅលើអនុសញ្ញាការងារអន្តរជាតិមួយចំនួន ដូចជាអនុសញ្ញាលេខ ២៩ ស្តីពីការងារ

ដោយបង្ខំ អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពបង្កើតសមាគម និងការពារសិទ្ធិរៀបចំជាក្រុម អនុសញ្ញាលេខ៩៨ ស្តីពីសិទ្ធិធ្វើការប្រមូលផ្តុំ និងការតវ៉ាជាសមូហភាព អនុសញ្ញាលេខ១០០ ស្តីពីការទូទាត់ប្រកបដោយសមភាព អនុសញ្ញាលេខ១១១ ស្តីពីការប្រឆាំងការរើសអើងក្នុងការងារ អនុសញ្ញាលេខ១០៥ស្តីពី ការលុបបំបាត់ពលកម្មដោយបង្ខំ អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលបំពេញការងារ និងអនុសញ្ញាលេខ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ ប្រទេសកម្ពុជា គឺជាប្រទេសសមាជិកមួយក្នុងគម្រោងមហាអនុតំបន់ទន្លេមេគង្គរបស់អង្គការ ILO-IPEC ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រី ដំណាក់កាលទី២ (គម្រោង ILO-IPEC TICW)។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានអនុវត្ត និងបានធ្វើការប៉ាន់ប្រមាណលើផែនការ NPA-TSEC ឆ្នាំ ២០០០-២០០០៤។ ក្នុងខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាមួយប្រទេសចំនួន៥ ក្នុងតំបន់ទន្លេមេគង្គ ដោយចុះហត្ថលេខាទៅលើអនុស្សរណៈស្តីពី ការផ្តួចផ្តើមអន្តរក្រសួង ក្នុងកិច្ចសម្របសម្រួលតំបន់ទន្លេមេគង្គ ប្រឆាំងនឹងការជួញដូរមនុស្ស COMMIT ។ ការប្តេជ្ញាទាំងនេះបានត្រួសត្រាយផ្លូវសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ថ្នាក់តំបន់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ។

ទាក់ទងនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ តាមរយៈគំនិតផ្តួចផ្តើមរួមគ្នារបស់ក្រសួងទេសចរណ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។ គំនិតផ្តួចផ្តើមទាំងនេះរួមមាននូវបទអន្តរាគមន៍ ដូចខាងក្រោម:

ក) ពង្រឹងកម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការប្រឆាំងនិងការកេងប្រវ័ញ្ចពលកម្ម និងការជួញដូរ

ខ) កសាងសមត្ថភាព

គ) លើកកម្ពស់ការយល់ដឹង (ឧទា. យុទ្ធនាការសាធារណៈតាមរយៈកម្មវិធីទូរទស្សន៍)

ឃ) ផ្តល់សេវាសង្គមដល់ជនរងគ្រោះ និងអ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យទេសចរណ៍

ដើម្បីធានាឱ្យមានកម្មវិធី និងវិធីសាស្ត្ររួមប្រកបដោយអត្ថន័យ ក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ក្នុងគោលបំណងទប់ស្កាត់ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មលើកុមារ និងស្ត្រី ក្រសួងទេសចរណ៍ ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី បានស្នើសុំជំនួយបច្ចេកទេសពីអង្គការ ILO ក្នុងការបង្កើត ១) **ផែនការយុទ្ធសាស្ត្រ** ២) **គោលការណ៍**

**ប្រតិបត្តិ រួមទាំងបញ្ជីត្រួតពិនិត្យ និង ៣) សៀវភៅបណ្តុះបណ្តាល** សម្រាប់ប្រើនៅក្នុងតំបន់សាកល្បងទាំង៣ គឺក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ។

**ហេតុអ្វីបានជាត្រូវបង្កើតសៀវភៅបណ្តុះបណ្តាលនេះ?**

សៀវភៅបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍ មានគោលបំណងដើម្បីត្រួសត្រាយផ្លូវសម្រាប់អនុវត្តយុទ្ធនាកាស្ត្រីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ឱ្យបានសកម្ម និងប្រកបដោយនិរន្តរភាព ព្រមទាំងដើម្បីអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រ និងគោលការណ៍ប្រតិបត្តិស្តីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃក្រសួងទេសចរណ៍ឆ្នាំ២០០៦-២០០៨។ សៀវភៅបណ្តុះបណ្តាលនេះ គឺជាឯកសាររួមជាមួយឯកសារ ២ ទៀត ដែលបានបង្កើតឡើង ដើម្បីជំរុញការផ្សព្វផ្សាយគោលការណ៍ណែនាំទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ តាមរយៈគ្រូបណ្តុះបណ្តាលដែលមានមកពីតំណាងក្រសួងពាក់ព័ន្ធនានា ព្រមទាំងមានគោលបំណងដើម្បីបំផុសការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធប្រកបដោយនិរន្តរភាពដើម្បីទប់ស្កាត់ និងការពារការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រីវ័យក្មេង។ ឯកសារនេះត្រូវបង្កើតឡើងដោយមានការចូលរួមយ៉ាងសកម្មពីភ្នាក់ងាររដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ។

យើងទទួលស្គាល់ថា មានគំនិតផ្តួចផ្តើមជាច្រើន និងមានសៀវភៅបណ្តុះបណ្តាលជាច្រើនបានបង្កើតឡើងស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (ឧទា.ក្រសួងទេសចរណ៍ អង្គការទស្សនៈពិភពលោកកម្ពុជា ក្រសួងកិច្ចការនារី ជាមួយអង្គការ IOM, Oxfam Hong Kong, Child-Wise Australia ។ល។) ដែលរួមមានបញ្ហាស្តីពីការអនុវត្តន៍បទបញ្ញត្តិជាតិ និងអន្តរជាតិ ការពារសង្គម សេវាសង្គម ការសហការ និងកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ (រូបភាព ១)។ សៀវភៅបណ្តុះបណ្តាលនេះមានគោលបំណងដើម្បីដាក់បញ្ចូលបញ្ហាការការពារផ្នែកពលកម្មៈ ការលើកកម្ពស់ និងការត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិស្តីពីការងារនៅកន្លែងធ្វើការ ដើម្បីលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម។ គោលបំណងមួយទៀត គឺបំពេញបន្ថែមទៅលើធនធានដែលមានស្រាប់ទាំងនេះពាក់ព័ន្ធនឹងបញ្ហាស្តីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

**រូបភាព ១.** ធនធាននានាស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ( សៀវភៅបណ្តុះបណ្តាលរបស់ក្រសួងទេសចរណ៍ និង អង្គការ ILO-IPEC: គោលបំណង អំណះអំណាង និងផលប៉ះពាល់)



## តើសៀវភៅបណ្តុះបណ្តាលនេះបង្កើតឡើងសម្រាប់នរណា?

សៀវភៅបណ្តុះបណ្តាលនេះ ត្រូវបានបង្កើត ចងក្រង និងសរសេរឡើង ជាពិសេសសម្រាប់អ្នកសម្របសម្រួលដែលពាក់ព័ន្ធនឹងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

សៀវភៅនេះ ត្រូវបានបង្កើតសម្រាប់អ្នកបណ្តុះបណ្តាល បុគ្គលិកអភិវឌ្ឍន៍សហគមន៍ អ្នកសម្របសម្រួល និងគ្រូបង្រៀន ដើម្បីលើកកម្ពស់ការយល់ដឹង និងចាត់វិធានការនៅតាមសហគមន៍ ។ សៀវភៅនេះត្រូវបានសរសេរឡើងជាពិសេសសម្រាប់អ្នកដែលចង់ប្រើវិធីសាស្ត្រតាមបែបចូលរួម ក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ ក្រៅពីការចែកចាយព័ត៌មាន និងការលើកកម្ពស់ការយល់ដឹងគោលដៅរយៈពេលវែងគឺ ដើម្បីធ្វើឱ្យមានការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្នុងគោលបំណងទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ។

គោលដៅចំបងនៃសៀវភៅបណ្តុះបណ្តាលនេះ គឺសម្រាប់អ្នកបណ្តុះបណ្តាល និងអ្នកសម្របសម្រួលតាមសហគមន៍។ សៀវភៅនេះក៏អាចប្រើប្រាស់បានដោយសមាជិកក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលចង់ស្វែងយល់ និងដែលចង់ចូលរួមក្នុងវិធីសាស្ត្រតាមបែបចូលរួមសម្រាប់លើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម នៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៃប្រទេសកម្ពុជា។ នៅក្នុងសៀវភៅបណ្តុះបណ្តាលទាំងមូលនេះ យើងត្រូវចាត់ទុកថាអ្នកសម្របសម្រួល និងអ្នកបណ្តុះបណ្តាលគឺជា "អ្នកសម្របសម្រួលពិតប្រាកដ" ។

## តើសៀវភៅបណ្តុះបណ្តាលនេះអាចប្រើបានដោយរបៀបណា?

សៀវភៅបណ្តុះបណ្តាលនេះ ត្រូវបានបង្ហាញជាកញ្ចប់សកម្មភាព ដែលអ្នកសម្របសម្រួលអាចជ្រើសរើសតាមសេចក្តីត្រូវការជាក់លាក់របស់អ្នកចូលរួមរបស់ខ្លួន។ នៅពេលអនុវត្តតាមសកម្មភាពដែលបានពិពណ៌នាអ្នកសម្របសម្រួលត្រូវចេះប្រើនូវភាពបត់បែនរបស់ខ្លួន។ អ្នកសម្របសម្រួលត្រូវបានលើកទឹកចិត្តឱ្យកំណត់ពី តម្រូវការនៃការកសាងសមត្ថភាពជាមុន ហើយបន្ទាប់មកទៀតធ្វើការឆ្លើយតបឱ្យបានសមស្របចំពោះសេចក្តីត្រូវការទាំងនេះ។ ភាពច្នៃប្រឌិតក៏ត្រូវបានសង្កត់ធ្ងន់ផងដែរ ព្រោះឧបករណ៍ទាំងនេះអាចបត់បែន និងមិនចាំបាច់អនុវត្តតាមដោយត្រឹមត្រូវឥតខ្ចោះនោះទេ។ ការចូលរួម និងភាពជាម្ចាស់ការនៃដំណើរការអភិវឌ្ឍន៍ គឺជាគោលការណ៍គន្លឹះ ដែលយើងត្រូវយកចិត្តទុកដាក់ដោយប្រើប្រាស់នូវភាពបត់បែន និងភាពច្នៃប្រឌិតរបស់ខ្លួនក្នុងនាមជាអ្នកសម្របសម្រួល ។

សកម្មភាពទាំងនេះអាចអនុវត្តបានតាមរបៀបជាច្រើន ព្រោះអ្នកសម្របសម្រួលមានជម្រើសច្រើន ក្នុងការរៀបចំរបៀបវារៈនៃវគ្គបណ្តុះបណ្តាល និងមេរៀនដែលត្រូវបង្រៀន ។ ការរៀបចំទាំងនេះភាគច្រើនត្រូវគិតទៅលើពេលវេលា និងសមត្ថភាពសិក្សារបស់អ្នកចូលរួម ។

## តើសៀវភៅបណ្តុះបណ្តាលនេះមានអ្វីខ្លះ?

នៅក្នុងការបណ្តុះបណ្តាលតាមបែបចូលរួម យើងចាប់ផ្តើមពី **បរិបទទូទៅ** របស់អ្នកចូលរួមដែលរួមមាន ដូចជាស្ថានភាពរស់នៅរបស់ពួកគេ បញ្ហាដែលពួកគេជួបប្រទះ តម្រូវការដែលពួកគេត្រូវការ ទំនាក់ទំនងសង្គម ដែលមាននៅតាមសហគមន៍ ប្រពៃណី ទំនៀមទម្លាប់ ការសម្រេចចិត្តនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ ឱកាសទទួលបានការអប់រំក្រៅ និងក្នុងប្រព័ន្ធ សកម្មភាពពេលសំរាក ជំនឿសាសនា និងគុណតម្លៃរបស់ពួកគេ។ ក្នុងការបណ្តុះបណ្តាលអ្នកចូលរួមយើងព្យាយាមស្វែងរកឱ្យឃើញពីស្ថានភាពទូទៅរបស់អ្នកចូលរួមដូចជា អាយុ យេនឌ័រ (ភេទ) ការអប់រំ ការបណ្តុះបណ្តាល កម្រិតអក្ខរកម្ម តម្រូវការសិក្សា ការរំពឹងទុក និងបញ្ហាព្រួយបារម្ភ ។ល។

ដោយផ្អែកទៅលើចំណេះដឹងពីសហគមន៍ ឬបរិបទទូទៅរបស់អ្នកចូលរួម យើងអាចកំណត់ **ខ្លឹមសារ** នៃវគ្គបណ្តុះបណ្តាល និងវគ្គសិក្សារបស់យើង។ យើងអាចកំណត់បញ្ហា និងប្រធានបទដែលទាក់ទងនឹងពួកគេ ប្រធានបទដែលពួកគេចាប់អារម្មណ៍ក្នុងការពិភាក្សា និងចាប់អារម្មណ៍ចង់រៀនបន្ថែម។ ទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅពេលដែលយើងដឹងពីកម្រិតនៃការយល់ដឹងរបស់អ្នកចូលរួម ពេលនោះយើងនឹងអាចជ្រើសរើសប្រធានបទ ដែលត្រូវចាប់ផ្តើមពិភាក្សា និងបញ្ជាក់វែកញែក។

**វិធីសាស្ត្រ** មានន័យថា "តើយើងអាចសម្រេចគោលដៅសិក្សារបស់យើង បានដោយរបៀបណា?" មានវិធីសាស្ត្រ និងឧបករណ៍ជាច្រើនដែលយើងអាចប្រើប្រាស់ក្នុងការអប់រំតាមបែបចូលរួម។ ការយល់ដឹងពីបរិបទទូទៅរបស់អ្នកចូលរួម និងការកំណត់ខ្លឹមសារវគ្គបណ្តុះបណ្តាលបានច្បាស់លាស់នឹងជួយណែនាំដល់អ្នកសម្របសម្រួល ឱ្យជ្រើសរើសនូវវិធីសាស្ត្រសម្រាប់ប្រើប្រាស់ប្រកបដោយភាពច្នៃប្រឌិត។ អ្វីដែលសំខាន់ត្រូវចាំនោះគឺថា ការបណ្តុះបណ្តាលតាមបែបចូលរួមគឺជាដំណើរការនៃការពិភាក្សាគ្នា។ វាគឺជាការផ្លាស់ប្តូរគំនិតយោបល់អារម្មណ៍ សួរសំណួរ និងចែករំលែកគំនិតជាមួយគ្នាទៅវិញទៅមក។ វិធីសាស្ត្រនេះមានការទាក់ទងទៅនឹងការអនុវត្តន៍បែបប្រជាធិបតេយ្យ និងការអនុវត្តន៍តាមការចូលរួម ។ វាមានន័យថាជាការគោរពដល់អ្នកចូលរួមទាំងអស់គ្នានិយាយ និងស្តាប់គ្នាទៅវិញទៅមក និងចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សា។

សៀវភៅបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយចំពោះបញ្ហាខាងលើ។ សៀវភៅនេះបានផ្តល់ជូននូវឧបករណ៍សម្រាប់ធ្វើការសម្របសម្រួលដល់គ្រូបណ្តុះបណ្តាល និងអ្នកសម្របសម្រួល ព្រមទាំងបង្ហាញពីវិស័យ

ការងារមួយចំនួនផ្សេងទៀត ដើម្បីដោះស្រាយចំពោះបញ្ហាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ សៀវភៅបណ្តុះបណ្តាលនេះត្រូវបានបង្ហាញជូនដូចខាងក្រោម៖

## បរិបទទូទៅ

**ម៉ូឌុល១** មានបទពិសោធន៍/សកម្មភាពសិក្សា ដែលអាចជំរុញឱ្យអ្នកចូលរួមយល់កាន់តែច្បាស់ពីវិស័យទេសចរណ៍ (វិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា រួមទាំងផលប៉ះពាល់នៃវិស័យទេសចរណ៍លើវិស័យសេដ្ឋកិច្ច)។ ម៉ូឌុលនេះក៏មានបង្ហាញពីស្ថានភាពទូទៅរបស់កុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ផ្នែកកំសាន្ត កន្លែងសេវាផ្លូវភេទក្នុងវិស័យទេសចរណ៍ និងអ្នកដែលធ្វើការនៅតាមកន្លែងអាជីវកម្មទេសចរណ៍សំខាន់ៗមានដូចជា នៅតាមតំបន់ឆ្នេរសមុទ្រ និងតំបន់ជុំវិញប្រាង្គប្រាសាទ។ ម៉ូឌុលនេះនឹងមានបង្ហាញពីករណីសិក្សាស្តីពី កុមារ និងស្ត្រីវ័យក្មេងដែលធ្វើការនៅក្នុងវិស័យទេសចរណ៍។

**ម៉ូឌុល២** បង្ហាញពីឧបករណ៍ដែលអ្នកសម្របសម្រួលអាចប្រើប្រាស់បាន ដើម្បីបង្កើនការយល់ដឹងទៅលើស្ថានភាពនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍។ ម៉ូឌុលនេះក៏មានបង្ហាញពីស្ថានភាពទូទៅ ស្តីពីការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងផលប៉ះពាល់នៃការជួញដូរកុមារ និងស្ត្រីវ័យក្មេង។ ជាចុងក្រោយម៉ូឌុលនេះនឹងបង្ហាញពីករណីសិក្សាស្តីពី កុមារ និងស្ត្រីវ័យក្មេង ដែលត្រូវបានគេជួញដូរនៅក្នុងវិស័យទេសចរណ៍។

## ខ្លឹមសារ

**ម៉ូឌុល៣** បង្ហាញពីស្ថានភាពទូទៅស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ។ ម៉ូឌុលនេះរួមមាន *បទបញ្ញត្តិ និង វិធានការគោលនយោបាយនានា* ដូចជា៖ សិទ្ធិកុមារ សិទ្ធិស្ត្រី អនុសញ្ញាអន្តរជាតិស្តីពី ការជួញដូរកុមារ និងស្ត្រី ព្រមទាំងច្បាប់ និងបទបញ្ញត្តិនានាទាក់ទងនឹងការជួញដូរកុមារ និងស្ត្រី ។ ម៉ូឌុលនេះក៏បានបង្ហាញពីបញ្ហា និងការតស៊ូមតិជាសាធារណៈផងដែរ។ ដូចគ្នានេះដែរគោលបំណងនៅក្នុងម៉ូឌុលនេះគឺដើម្បីពិភាក្សាទៅលើ*បទអន្តរាគមន៍ និងកម្មវិធីសំខាន់ៗ* ក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម នៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍។

**ម៉ូឌុល៤** បង្ហាញពីបទអន្តរាគមន៍នានាស្តីពី ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម។

## វិធីសាស្ត្រ

ផ្នែកនេះផ្តោតសំខាន់ទៅលើឧបករណ៍សម្រាប់ធ្វើការសម្របសម្រួល។ ផ្នែកនេះមាន ២ ភាគធំៗគឺ៖

**ភាគ ១** បង្ហាញពីចំណុចចាប់ផ្ដើមនៃការបង្រៀនដែលមានដូចជា: របៀបបង្កើតស្ថានភាព ដែលបង្កឱ្យមានការចូលរួម ការលើកឡើងពីការរំពឹងទុករបស់អ្នកចូលរួម ការពន្យល់ពីគោលបំណងនៃសកម្មភាពបណ្ដុះបណ្ដាល ការកំណត់យល់ព្រមទៅលើវិន័យវគ្គបណ្ដុះបណ្ដាល និងការធានាឱ្យគ្រប់អ្នកចូលរួមទាំងអស់យល់ច្បាស់ពីបញ្ហាភស្តុភា។ ភាគនេះក៏មានគោលបំណងបង្កើតក្របខ័ណ្ឌការងារតាមបែបចូលរួម និងធ្វើឱ្យអ្នកសម្របសម្រួល ឬអ្នកបណ្ដុះបណ្ដាលមើលឃើញខ្លួនឯងថាជាអ្នកសម្របសម្រួលក្នុងដំណើរការសិក្សាអប់រំ។ ភាគនេះក៏មានការពន្យល់ពីគោលការណ៍នៃការសិក្សាតាមបែបចូលរួម ព្រមទាំងការកំណត់ពីតួនាទី និងលក្ខណៈសម្បត្តិនៃអ្នកសម្របសម្រួលល្អ។ ជំហានជាច្រើនក្នុងការបង្កើតការបណ្ដុះបណ្ដាលតាមបែបចូលរួមក៏ជាចំណុចសំខាន់ដែលមាននៅក្នុងភាគនេះផងដែរ។ ភាគនេះពន្យល់ពីដំណាក់កាលនានាដែលមាននៅក្នុងវដ្ដនៃវគ្គបណ្ដុះបណ្ដាលផ្ដល់ការណែនាំដល់អ្នកបណ្ដុះបណ្ដាល/អ្នកសម្របសម្រួល នៅពេលបង្កើតកម្មវិធីកសាងសមត្ថភាព និងនៅពេលបង្កើតសកម្មភាពបណ្ដុះបណ្ដាលសម្រាប់សហគមន៍ និងក្រុមគោលដៅ ។

**ភាគ ២** ភាគនេះផ្ដល់ឱ្យអ្នកបណ្ដុះបណ្ដាលនូវឧបករណ៍ និងវិធីសាស្ត្រតាមបែបចូលរួម។ មានវិធីសាស្ត្រ ឧបករណ៍ និងលំហាត់ជាច្រើន ដែលអ្នកសម្របសម្រួលអាចប្រើប្រាស់បានក្នុងដំណើរការសិក្សាតាមបែបចូលរួម។

## ២. ការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាល

ការប្រើប្រាស់សៀវភៅបណ្ដុះបណ្ដាលនេះ ដោយអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលការណ៍ប្រតិបត្តិឆ្នាំ ២០០៦-២០០៨ ទាមទារការយល់ដឹងឱ្យបានច្បាស់ថា តើពេលណាត្រូវប្រើភាគមួយណាជាមួយភ្នាក់ងារមួយណា (អ្នកបណ្ដុះបណ្ដាលនៅតាមសហគមន៍ ឬអ្នកសម្របសម្រួលនៅកន្លែងការងារ សមាជិកសហគមន៍/កន្លែងការងារ កុមារ និងស្ត្រីវ័យក្មេង អាជ្ញាធរដែនដី) ។ល។ ស្ថាប័នពាក់ព័ន្ធខុសគ្នាត្រូវប្រើមេរៀន ចំណេះដឹង និងដំណើរការរៀនសូត្រខុសៗគ្នា ដើម្បីសម្របសម្រួល និងបង្កើនការប្ដេជ្ញាក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក្នុងគោលបំណងទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យទេសចរណ៍។ សៀវភៅបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងប្រើប្រាស់ក្នុងក្របខ័ណ្ឌការងារ **បរិបទ-ខ្លឹមសារ-វិធីសាស្ត្រ** (CCM) ដូចដែលបានពិភាក្សាផ្នែកខាងលើនៅក្នុងសៀវភៅបណ្ដុះបណ្ដាលនេះ។ ក្របខណ្ឌការងារនេះបានផ្ដល់ជូននូវរូបមន្ត នៃលទ្ធផលដែលរំពឹងទុកផ្សេងៗនូវអ្វីដែលបានគ្រោងទុក ដែលបានរៀនសូត្រដោយអ្នកចូលរួមបន្ទាប់ពីម៉ូឌុលនីមួយៗ។ ការរំពឹងទុកនូវលទ្ធផលសម្រាប់ម៉ូឌុលនីមួយៗនៃសៀវភៅបណ្ដុះបណ្ដាលនេះត្រូវបានបង្ហាញជូន ដូចខាងក្រោម:

### ម៉ូឌុល១

នៅក្នុងដំណើរការបណ្ដុះបណ្ដាលសិក្ខាសាលាដោយមានការចូលរួម វាគឺជាការចាំបាច់ដើម្បីចាប់ផ្ដើមជាមួយអ្នកចូលរួមដែលមានប្រជាប្រិយ ឬចំណេះដឹងស្រាប់ សាវតាពួកគេ កាលៈទេសៈ ស្ថានភាព ទស្សនៈ និងមុខរបរ

ជាក់លាក់ពួកគេ។ ជាទូទៅ ម៉ូឌុលនេះមានគោលបំណងចង់ធ្វើឱ្យអ្នកចូលរួមយល់ដឹងកាន់តែប្រសើរនូវវិស័យទេសចរណ៍ ហើយជាពិសេសស្ថានភាពវិស័យទេសចរណ៍នៅកម្ពុជា។ នៅចុងបញ្ចប់ម៉ូឌុលនេះអ្នកចូលរួមបានរំពឹងទុកៈ

- ជំរុញឱ្យអ្នកចូលរួមយល់កាន់តែច្បាស់ពីវិស័យទេសចរណ៍ជាមួយនឹងការអនុវត្តជាក់លាក់នូវវិស័យទេសចរណ៍ នៅកម្ពុជា (វិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា រួមទាំងផលប៉ះពាល់នៃវិស័យទេសចរណ៍លើវិស័យសេដ្ឋកិច្ច)។
- បានយល់ប្រសើរឡើងនូវការពាក់ព័ន្ធរបស់កុមារ និងស្ត្រីវ័យក្មេងក្នុងវិស័យទេសចរណ៍។
- នាំមកនូវទស្សនៈរបស់ពួកគេផ្ទាល់ពីបញ្ហាផ្សេងៗ ក្នុងវិស័យទេសចរណ៍តាមរយៈករណីសិក្សា និងការពិភាក្សា។

## ម៉ូឌុល២

ឆ្លងតាមរយៈការប្រើប្រាស់ឧបករណ៍ចូលរួមផ្សេងៗនេះ អ្នកចូលរួមបានយល់ដឹងប្រសើរដោយផ្ទាល់នូវស្ថានភាពការជួញដូរកុមារ និងស្ត្រីវ័យក្មេងក្នុងវិស័យទេសចរណ៍។ នៅចុងបញ្ចប់ម៉ូឌុលនេះអ្នកចូលរួមបានរំពឹងទុកៈ

- អត្ថន័យ និងពិភាក្សាតាមរយៈគំនិតស៊ីជម្រៅនៃការជួញដូរ និងការពាក់ពន្ធ័របស់កុមារ និងស្ត្រីវ័យក្មេង។
- កត់សម្គាល់នូវសារៈសំខាន់នៃការជួញដូរកុមារ និងស្ត្រីវ័យក្មេង។
- បានយល់ដឹងប្រសើរនូវស្ថានភាពដែលប្រឈមមុខដោយកុមារ និងស្ត្រីវ័យក្មេង ដែលត្រូវបានគេជួញដូរនៅក្នុងវិស័យទេសចរណ៍។

## ម៉ូឌុល ៣

ម៉ូឌុលនេះផ្តល់នូវទស្សនៈនៃកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា។ ម៉ូឌុលនេះក៏បានបង្ហាញពីបញ្ហា និងការតស៊ូមតិជាសាធារណៈផងដែរ ទៅលើបទអន្តរាគមន៍ និងកម្មវិធីសំខាន់ៗ ក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៅកម្ពុជា។ នៅចុងបញ្ចប់ម៉ូឌុលនេះអ្នកចូលរួមបានរំពឹងទុកៈ

- បង្ហាញនិងពិភាក្សានូវកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងស្ថាប័នអន្តរជាតិដែលមានស្រាប់នៅក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅកម្ពុជា។
- មានការយល់ដឹងកម្មវិធីផ្សេងៗ (ការផ្សព្វផ្សាយ, កសាងសមត្ថភាព, ការអន្តរាគមន៍, បង្កើតគោលនយោបាយ ។ល។ ស្តីពីប្រឆាំងការជួញដូរក្នុងឧស្សាហកម្មទេសចរណ៍នៅកម្ពុជា។

## ម៉ូឌុល ៤

បង្ហាញពីបទអន្តរាគមន៍នានាស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងវិស័យទេសចណ៍។ នៅចុងបញ្ចប់ម៉ូឌុលនេះ អ្នកចូលរួមបានរំពឹងទុកៈ

- បង្ហាញពីកម្មវិធីផ្សេងៗនិងសកម្មភាពក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។
- អាចមានចំណេះដឹងស្តីពី តួអង្គសំខាន់ៗក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ របស់អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជននានា។
- បង្ហាញលទ្ធភាពកម្មវិធីអន្តរាគមន៍នៃកិច្ចប្រឹងប្រែងរបស់អង្គការនានា ប្តេជ្ញាលើកកម្ពស់សុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេង សម្រាប់ការកេងប្រវ័ញ្ចកម្លាំង ពលកម្ម និងផ្លូវភេទ ក្នុងវិស័យទេសចរណ៍។

*តារាង ១ ខាងក្រោមផ្តល់នូវការណែនាំជាក់លាក់ចំពោះម៉ូឌុលបណ្តុះបណ្តាលនេះ។ ខ្លឹមសារ និងដំណើរការណែនាំ (ឧ. សកម្មភាពជាក់លាក់ ឬទិន្នន័យពិភាក្សា) បានបង្ហាញនៅក្នុងម៉ូឌុល ចំពោះក្រុមគោលដៅទទួលផលផ្សេងគ្នា ពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដែលទាក់ទងទៅនឹងសិក្ខាសាលា ឬការព្យាយាម បណ្តុះបណ្តាល។*

## តារាង ១. សេចក្តីណែនាំស្តីពីរបៀបប្រើប្រាស់សៀវភៅបណ្តុះបណ្តាល

| ម៉ូឌុល និងភាគដែលមាននៅក្នុងសៀវភៅបណ្តុះបណ្តាល | អ្នកទទួលផលគោលដៅ | | | | |
|---|---|---|---|---|---|
| | អ្នកបណ្តុះបណ្តាល MoT, MoSAVY, MoWA, MoI, MoLVT (ភ្នាក់ងារថ្នាក់ជាតិ និងថ្នាក់ខេត្ត) | ម្ចាស់អាជីវកម្ម/ និយោជក បុគ្គលិក រដ្ឋាភិបាល | និយោជិត (ស្ត្រីធ្វើការ) | ឪពុកម្តាយ និងសហគមន៍ នៅតាមតំបន់ ទេសចរណ៍ | កុមារ ប្រឈម មុខនឹង គ្រោះថ្នាក់ |
| **ម៉ូឌុល ១ - វិស័យទេសចរណ៍** | √ | √ | √ | √ | √ |
| សកម្មភាព ១ រឿងរូប | √ | √ | √ | √ | √ |
| **មេរៀន ក.** និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងវិស័យទេសចរណ៍ | | | | | |
| ១. ទេសចរណ៍ | √ | √ | √ | √ | √ |
| ២. វិស័យទេសចរណ៍ | √ | √ | √ | | |
| ៣. ទេសចរណ៍ និងសេដ្ឋកិច្ច | √ | √ | √ | | |
| ៤. ទេសចរ | √ | √ | | | |
| a. ទេសចរអន្តរជាតិ | √ | √ | √ | √ | √ |
| b. ទេសចរជាតិ | √ | √ | √ | √ | √ |
| c. អ្នកទស្សនកិច្ចក្នុងថ្ងៃតែមួយ | √ | √ | √ | √ | √ |
| ៥. ប្រភេទនៃការរៀបចំធ្វើដំណើរ និងសម្បទា | √ | √ | | | |

| | | | | | |
|---|---|---|---|---|---|
| a. ភ្ញៀវសាក់កាដូ | √ | √ | √ | | |
| b. ភ្ញៀវមកជាក្រុម | √ | √ | √ | | |
| ខ. ស្ថានភាពនៃវិស័យទេសចរណ៍កម្ពុជា | √ | √ | | | |
| គ. ផលប៉ះពាល់នៃវិស័យទេសចរណ៍ | √ | √ | | | |
| ១. ផលប៉ះពាល់របស់វិស័យទេសចរណ៍លើវិស័យសេដ្ឋកិច្ច | √ | √ | √ | √ | √ |
| ២. ផលប៉ះពាល់របស់វិស័យទេសចរណ៍លើវិស័យវប្បធម៌សង្គម | √ | √ | | | |
| ឃ. ស្ថានភាពនៃកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍ | √ | √ | √ | | |
| ១. សណ្ឋាគារ | √ | √ | √ | | |
| ២. ផ្ទះសំណាក់ | √ | √ | √ | √ | √ |
| ៣. ភោជនីយដ្ឋាន | √ | √ | √ | √ | √ |
| ៤. ស្ត្រីរកស៊ីផ្លូវភេទ | √ | √ | √ | √ | √ |
| ៥. ផ្នែកកម្សាន្ត | √ | √ | √ | √ | √ |
| ៦. មគ្គុទ្ទេសក៍ទេសចរ | √ | √ | √ | | |
| **សកម្មភាព ២: សកម្មភាពបន្ថែម- ករណីសិក្សា** | √ | √ | √ | √ | √ |
| **មេរៀន ក:** ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍ | √ | √ | √ | √ | √ |
| **ម៉ូឌុល ២ - ការជួញដូរ** | √ | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| **សកម្មភាព ១** ល្បែងប្រដេញពាក្យ - ការជួញដូរ<br>**មេរៀន** ក. និយមន័យនៃពាក្យទាក់ទងនឹងការជួញដូរ | √<br>√ | √<br>√ | √<br>√ | √<br>√ | √<br>√ |
| ១. ការជួញដូរ | √ | √ | √ | √ | √ |
| ២. មនុស្សដែលត្រូវបានគេជួញដូរ | √ | √ | √ | √ | √ |
| ៣. អ្នកជួញដូរ | √ | √ | √ | √ | √ |
| ខ. ស្ថានភាពទូទៅនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍កម្ពុជា | √ | √ | | | |
| គ. កន្លែងដែលឃើញមានការជួញដូរកុមារ និង ស្ត្រីវ័យក្មេង | √ | √ | √ | √ | √ |
| ឃ. ហេតុអ្វីបានជាកុមារ និងស្ត្រីរងគ្រោះដោយការជួញដូរ តែងតែត្រូវបានគេរំលោភសិទ្ធិរបស់ខ្លួន? | √ | √ | √ | √ | √ |
| ង. កត្តាជំរុញ និង កត្តាអូសទាញដែលនាំឱ្យមានការជួញដូរកុមារ និងស្ត្រី | √ | √ | | | |
| ច. ឥទ្ធិពលនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេង | √ | √ | | | |
| **សកម្មភាព ២: សកម្មភាពបន្ថែម- ករណីសិក្សា** | √ | √ | √ | √ | √ |
| **មេរៀន ក:** ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍ | √ | √ | √ | √ | √ |
| **ម៉ូឌុល ៣- ការទប់ស្កាត់ការជួញដូរ** | √ | √ | √ | √ | √ |
| **សកម្មភាព ១** ការដើរតួសម្តែង | √ | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| **មេរៀន** ក. ស្ថានភាពទូទៅស្តីពី កិច្ចខិតខំទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងក្នុងប្រទេសកម្ពុជា | √ | √ | | | |
| ១. បទបញ្ញត្តិ និងវិធានការគោលនយោបាយ | √ | √ | √ | √ | √ |
| ២. សិទ្ធិកុមារ | √ | √ | | √ | √ |
| ៣. សិទ្ធិស្ត្រី | √ | √ | √ | √ | |
| ៤. ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអន្តរជាតិទាក់ទងនឹងការជួញដូរកុមារ និងស្ត្រី | √ | √ | √ | √ | √ |
| ៥. ច្បាប់ និងបទបញ្ញត្តិថ្នាក់ជាតិទាក់ទងទៅនឹងការជួញដូរកុមារ និងស្ត្រី | √ | √ | √ | √ | √ |
| ខ. បញ្ហាដែលបានជួបប្រទះ និងការតស៊ូមតិសាធារណៈ | √ | √ | | | |
| គ. កម្មវិធី និងបទអន្តរាគមន៍គន្លឹះ | √ | √ | | | |
| ១. ក្រសួងរដ្ឋាភិបាល | √ | √ | | | |
| ក. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) | √ | √ | √ | √ | √ |
| ខ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) | √ | √ | √ | √ | √ |
| គ. ក្រសួងកិច្ចការនារី MoWA | √ | √ | √ | √ | √ |
| ឃ. ក្រសួងមហាផ្ទៃ MoI | √ | √ | √ | √ | √ |
| ង. ក្រសួងទេសចរណ៍ MoT | √ | √ | √ | √ | √ |

| | | | | | |
|---|---|---|---|---|---|
| ២. អង្គការពលកម្មអន្តរជាតិ-កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ | √ | √ | √ | √ | √ |
| **ម៉ូឌុល ៤ - លើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍** | √ | √ | √ | √ | √ |
| **សកម្មភាព ១** ហៅធ្វើសកម្មភាព | √ | √ | √ | √ | √ |
| **មេរៀន** ក. លើកកម្ពស់សុវត្ថិភាពទេសចរណ៍ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស | √ | √ | | | |
| ខ. គាំទ្រសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព | √ | √ | | | |
| គ. ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពការងារ និងស្ថានភាពរស់នៅរបស់កុមារ និងស្ត្រីធ្វើការ | √ | √ | √ | √ | √ |
| ឃ. ធ្វើឱ្យប្រសើរឡើងចំពោះការអនុវត្តន៍បទបញ្ញត្តិវិស័យទេសចរណ៍ | √ | √ | √ | √ | √ |
| ង. ធ្វើឱ្យប្រសើរឡើងនូវការការពារ និងសេវាសង្គម | √ | √ | √ | √ | √ |
| ច. កិច្ចសហការ និងសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សហព័ន្ធសហជីព និយោជក និងអង្គការមិនមែនរដ្ឋាភិបាល | √ | | | | |
| ១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាស៊ីក្នុងការទប់ស្កាត់ការជួញដូរមនុស្ស (ARCPPT) | √ | √ | | | |
| ២. សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA) | √ | √ | | | |
| ៣. សហព័ន្ធនិយោជកកម្ពុជា និងសមាគមពាណិជ្ជកម្ម (CAMFEBA) | √ | √ | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៤. សមាគមសណ្ឋាគារកម្ពុជា (CHA) | √ | √ | √ | | |
| ៥. សហព័ន្ធសហជីពសេវាកម្មទេសចរណ៍កម្ពុជា (CTSWF) | √ | √ | √ | √ | √ |
| ៦. អង្គការ (COSECAM) | √ | √ | √ | √ | √ |
| ៧. គម្រោងភាពវៃឆ្លាតរបស់កុមារ (ECPAT) | √ | √ | √ | √ | √ |
| ៨. គម្រោងការពារសិទ្ធិកុមារក្នុងវិស័យទេសចរណ៍ - Mith Samlanh/ Friends International | √ | √ | √ | √ | √ |
| ៩. គម្រោងកម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃអង្គការ World Vision Cambodia, Child Safe Tourism Project | √ | √ | √ | √ | √ |

## តើម៉ូឌុលបណ្តុះបណ្តាលនេះផ្សារភ្ជាប់ទៅជាមួយផែនការយុទ្ធសាស្ត្រ និងគោលការណែនាំប្រតិបត្តិយ៉ាងដូចម្តេច?

សៀវភៅបណ្តុះបណ្តាល ផែនការយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំប្រតិបត្តិប្រើប្រាស់ជាទិសដៅរួមតែមួយ គឺការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី សម្រាប់កេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទនៅក្នុងឧស្សាហកម្មទេសចរណ៍នៅកម្ពុជា ។

ដើម្បីសម្រេចបានគោលដៅនេះ ជំហានដំបូង ផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំ ត្រូវបានរៀបចំឡើងតាមរយៈការប្រឹក្សាយោបល់ជាដៃគូនានា (រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន) នៅក្នុងវិស័យទេសចរណ៍ ។

ជំហានបន្ទាប់ពីផែនការយុទ្ធសាស្ត្រនេះ គឺបានរៀបចំឡើងនូវគោលការណ៍ប្រតិបត្តិ ដែលបានផ្តោតទៅលើបទបញ្ញត្តិ ដែលពាក់ព័ន្ធដូចជា ការការពារពលកម្ម, បទបញ្ញត្តិទេសចរណ៍ និងការការពារសង្គម និងសេវាសង្គម ។

សៀវភៅបណ្តុះបណ្តាលនេះប្រើប្រាស់ ដែលជាឧបករណ៍សម្រាប់ឯកសារទាំងពីរខាងលើ និងជាមួយឧបករណ៍ចាំបាច់នានា ផ្តល់ការកសាងសមត្ថភាពដល់គ្រូបណ្តុះបណ្តាល ដើម្បីបណ្តុះបណ្តាលផ្សព្វផ្សាយឱ្យយល់ដឹងកាន់តែប្រសើរឡើងនូវសមាសភាពនៃគម្រោងនេះ ។

ទំនាក់ទំនងរវាងឯកសារទាំងបីនេះគឺ បានធ្វើការណែនាំក្នុងសៀវភៅបណ្តុះបណ្តាល និងការបង្ហាញជា ស្លាយ (Power Point Presentation) ។

# ៣. បរិបទទូទៅ

## ម៉ូឌុល ១ - វិស័យទេសចរណ៍

### គោលបំណងនៃម៉ូឌុល:

១. ដើម្បីកំណត់និយមន័យ និងពិភាក្សាពីវិស័យទេសចរណ៍

២. ដើម្បីស្វែងយល់បន្ថែមលើវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា

## សកម្មភាព ១ - រឿងរូប

## មេរៀន

ក. និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងវិស័យទេសចរណ៍

១. ទេសចរណ៍

២. វិស័យទេសចរណ៍

៣. ទេសចរណ៍ និងសេដ្ឋកិច្ច

៤. ទេសចរ

a. ទេសចរអន្តរជាតិ

b. ទេសចរជាតិ

c. អ្នកទស្សនកិច្ចក្នុងថ្ងៃតែមួយ

៥. ប្រភេទនៃការរៀបចំធ្វើដំណើរ និងសម្បទា

a. ភ្ញៀវសាក់កាដូ

b. ភ្ញៀវមកជាក្រុម

ខ. ស្ថានភាពនៃវិស័យទេសចរណ៍កម្ពុជា

គ. ផលប៉ះពាល់នៃវិស័យទេសចរណ៍

១. ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចរបស់វិស័យទេសចរណ៍

២. ផលប៉ះពាល់ផ្នែកវប្បធម៌សង្គមរបស់វិស័យទេសចរណ៍

ឃ. ស្ថានភាពនៃកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍

១. សណ្ឋាគារ

២. ផ្ទះសំណាក់

៣. ភោជនីយដ្ឋាន

៤. ផ្នែកកម្សាន្ត
៥. ស្ត្រីរកស៊ីផ្លូវភេទ
៦. មគ្គុទ្ទេសក៍ទេសចរ

## សកម្មភាព ២: សកម្មភាពបន្ថែម

## ករណីសិក្សា: ស្ថានភាពកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍

មេរៀន ក: ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍

## ម៉ូឌុល ១ — វិស័យទេសចរណ៍

សកម្មភាព ១: *រឿងរូប*[1]

គោលបំណង: ដើម្បីស្វែងយល់ពីអត្ថន័យនៃពាក្យ "វិស័យទេសចរណ៍ និងភ្ញៀវទេសចរ"

រយៈពេល ៤៥ នាទី

សំភារៈដែលត្រូវការ: រូបមនុស្ស (សមាជិកសហគមន៍) ផ្ទះ មធ្យោបាយធ្វើដំណើរ ប្រភពជីវភាព អាជីវកម្ម ស្ថាប័នផ្សេងៗ កន្លែងទេសចរណ៍

*របៀបធ្វើ*

១. បែងចែកអ្នកចូលរួមជា ៣ ក្រុម

២. ចែករូបភាពដល់ក្រុមនីមួយៗ និងស្នើឱ្យក្រុមស្វែងយល់ពីអត្ថន័យនៃពាក្យ "ទេសចរណ៍ វិស័យទេសចរណ៍ និងឧស្សាហកម្មទេសចរណ៍"

៣. ស្នើអ្នករាយការណ៍ពីក្រុមនីមួយៗឱ្យរាយការណ៍ដល់ក្រុមទាំងមូលនូវលទ្ធផលនៃការពិភាក្សា

៤. អ្នកសម្របសម្រួលត្រូវសរសេរនូវលើក្រដាសផ្ទាំងធំពីនិយមន័យ កំណត់ដោយអ្នកចូលរួមស្តីពី "ទេសចរណ៍វិស័យទេសចរណ៍ និងឧស្សាហកម្មទេសចរណ៍" ដោយកត់ចំណាំទៅលើចំណុចសំខាន់ៗ

[1] ដកស្រង់ចេញពី: Carmela Millado, Jo Hann Tan, POP: A Training Manual for Community Organiser Facilitators, Southeast Asia Popular Communication s Programmes (Sea-PCP)

៥. ទុកពេលសម្រាប់ពិភាក្សា និងសួរបញ្ជាក់

៦. សរុបដំណើរការ និងលើកឡើងនូវចំណុចសិក្សា

## មេរៀន

### *ក. និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងវិស័យទេសចរណ៍*

### ១. ទេសចរណ៍

ទេសចរណ៍ អាចត្រូវបានឱ្យន័យថា រាល់សម្បទា សេវាកម្ម និងសកម្មភាពដែលទាក់ទងនឹងការធ្វើដំណើររបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ សម្បទា និងសេវាកម្មទាំងនេះក៏អាចបម្រើក្នុងគោលបំណងផ្សេងក្រៅពីវិស័យទេសចរណ៍[២] ផងដែរ ។

ប្រទេសនីមួយៗបានផ្តល់និយមន័យ ដល់ពាក្យទេសចរណ៍ផ្សេងៗពីគ្នា។ នេះជាកត្តាមួយដែលបង្កឱ្យមានបញ្ហាក្នុងការប្រៀបធៀបស្ថិតិទេសចរណ៍នៅទូទាំងប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះការផ្តួចផ្តើមមួយចំនួនតាមទិសដៅនេះត្រូវបានអនុវត្តដោយអង្គការទេសចរណ៍ពិភពលោក (WTO) ក្រុមប្រឹក្សាទេសចរណ៍ និងធ្វើដំណើរពិភពលោក (WTTC) ការិយាល័យស្ថិតិសហគមន៍អឺរ៉ុប (EUROSTAT) និងអង្គការសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)។ បច្ចុប្បន្ននេះ ការប្រៀបធៀបស្ថិតិអន្តរជាតិធ្វើឡើង តាមរយៈការចូលមកដល់នូវភ្ញៀវទេសចរអន្តរជាតិ ការទទួលភ្ញៀវទេសចរអន្តរជាតិ ការចំណាយលើការប្រើប្រាស់នានាក្នុងវិស័យទេសចរណ៍ (ដោយផ្ទាល់ និងដោយប្រយោល) ការវិនិយោគដែលពាក់ព័ន្ធ ការនាំចេញសុទ្ធ និងការចំណាយរបស់រដ្ឋាភិបាល។

អង្គការ WTO បានឱ្យនិយមន័យនៃពាក្យ *ការធ្វើដំណើរ* និង *ទេសចរណ៍* ថាជាសកម្មភាពទាំងឡាយណាដែលមនុស្សធ្វើដំណើរចេញពីកន្លែងរបស់ខ្លួនទៅស្នាក់នៅកន្លែងផ្សេងទៀតក្រៅពីបរិស្ថានជាធម្មតារបស់ខ្លួន ដោយមិនលើសពី ១ឆ្នាំ ហើយមានគោលបំណងធ្វើទស្សនកិច្ចកំសាន្តជាជាងរកប្រាក់ចំណូលពីប្រទេសដែលខ្លួនទៅទស្សនា។

ដោយយោងទៅតាម WTTC ឧស្សាហកម្មទេសចរណ៍ត្រូវបានកំណត់និយមន័យថា ជាសកម្មភាពផ្នែកសេដ្ឋកិច្ចទាក់ទងនឹងការធ្វើដំណើរ (ផ្ទាល់ខ្លួន ការវិនិយោគ រដ្ឋាភិបាល អាជីវកម្ម និងការនាំចេញសុទ្ធ)។ វិស័យទេសចរណ៍ អាចបានវាស់ដោយចំណាយចរន្ត ចំណាយមូលធន ឬអត្ថប្រយោជន៍ដែលអ្នកធ្វើដំណើរទទួលបានមុនពេល ក្នុងពេល និងក្រោយពេលការធ្វើដំណើរ[៣] ។

---

[២] សៀវភៅកម្មវិធីបណ្តុះបណ្តាលស្តីពីការទប់ស្កាត់កុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ - គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (MOT-WVC-CAMP)

[៣] សេវាប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារក្នុងវិស័យឧស្សាហកម្មទេសចរណ៍ NUWHRAIN-APL-IUF សហជីពកម្មករជាតិនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន និង កន្លែងឧស្សាហកម្ម

## ២. វិស័យទេសចរណ៍

ម្យ៉ាងវិញទៀត អង្គការពលកម្មអន្តរជាតិ (ILO) បានបែងចែកវិស័យទេសចរណ៍ជា ៣ ក្រុមដូចជា *សណ្ឋាគារ កន្លែងហូបចុក និងវិស័យទេសចរណ៍* (HCT)។ HCT គឺជាវិស័យសកម្មភាពសេដ្ឋកិច្ចសាំញ៉ាំ និងជាវិស័យគ្របដណ្តប់ទៅលើវិស័យសេដ្ឋកិច្ចផ្សេងទៀតដែលមានដូចជា ការបង្កើតផលិតផលកសិកម្ម ផលិតផលឧស្សាហកម្ម សិប្បកម្ម ការធ្វើដំណើរ សន្តិសុខ វប្បធម៌ សេវាសុខភាព ការស្នាក់នៅ ការហូបចុក ការធ្វើដំណើរកម្សាន្ត ការធ្វើអាជីវកម្មសួនឧទ្យាន សួនសត្វ អេកូទេសចរណ៍ ។ល។

*អនុផ្នែកសណ្ឋាគារ* រួមមានប្រភេទកន្លែងស្នាក់នៅជាច្រើន (សណ្ឋាគារ រមណីយដ្ឋាន ក្លឹប បារ កន្លែងស្នាក់នៅតាមតំបន់ជនបទ ផ្ទះសំណាក់ ផ្ទះល្វែងជួល កន្លែងកំសាន្តដែលមានផាសុកភាព ។ល។) មានទំហំ និងស្តង់ដារផ្សេងៗគ្នាទៅតាមសហគមន៍ជនបទ និងសហគមន៍ជាយក្រុង។

*អនុផ្នែកអាហារដ្ឋាន* រួមមានកន្លែងភោជនីយដ្ឋានដែលមានទំហំ ប្រភេទ ក្រុម និងស្តង់ដាផ្សេងៗគ្នា។ ក្រុមសំខាន់ត្រូវបែងចែកជា២ក្រុមគឺ ក្រុមសហគ្រាសធ្វើអាជីវកម្មក្នុងទីផ្សារដោយចំហ និងក្រុមសហគ្រាសដែលមិនមែនធ្វើអាជីវកម្ម ឬក្រុមសហគ្រាសដែលមានកិច្ចសន្យា។ ក្រុមទីមួយរួមមាននូវគ្រប់ប្រភេទនៃភោជនីយដ្ឋាន និងកន្លែងអាហារដ្ឋានដែលនៅដាច់ដោយឡែកពីសណ្ឋាគារ ឬនៅក្នុងសណ្ឋាគារ (ភោជនីយដ្ឋានបុរាណ ភោជនីយដ្ឋានក្រុមជនជាតិម្ហូបពិសេស អាហាររហ័ស ហាងកាហ្វេ ហាងបារ កន្លែងលក់អាហារ អាហារលក់តាមតុ ។ល។) ជាទូទៅមានទំហំតូច ឬមធ្យម។ រចនាសម្ព័ន្ធនៃការគ្រប់គ្រងមានលក្ខណៈស្រដៀងគ្នាទៅនឹងសណ្ឋាគារ (ដូចជាការគ្រប់គ្រងរួមគ្នាការគ្រប់គ្រងតាមក្រុមស្ម័គ្រចិត្តស្ថិតនៅជាឯករាជ្យទិញឈ្មោះពីគេ ។ល។) ហើយវាក៏អាចជាផ្នែកមួយនៃកន្លែងស្នាក់នៅផងដែរ ។

ក្រុមទី ២ រួមមាននូវកន្លែងអាហារធំៗ។ បន្ថែមពីលើនេះទៀត មានកន្លែងអាហារសម្រាប់បុគ្គលិកដែលធ្វើការនៅក្បែរនោះដោយមានលក្ខខណ្ឌគួរឱ្យពេញចិត្តគឺទាក់ទងនឹងគុណភាព និងតម្លៃ។ មានកន្លែងអាហារសាធារណៈផងដែរដូចជាកន្លែងអាហារបម្រើដល់កងកម្លាំងប្រដាប់អាវុធ កន្លែងអាហារនៅតាមសាលារៀន និងនៅតាមមន្ទីរឃុំឃាំងជាដើម។ ស្រដៀងគ្នានេះដែរ នៅតាមមន្ទីរពេទ្យសាធារណៈ ជាទូទៅមានបម្រើជាអាហារពេទ្យ និងអាហារតាមបែបប្រពៃណីផងដែរ ។

***អនុផ្នែកទេសចរណ៍*** រួមមានទូវសកម្មភាពដែលទាក់ទងនឹងការធ្វើដំណើរជាច្រើន ប៉ុន្តែសំដៅជាចម្បងទៅលើការធ្វើដំណើរដែលមានសមាសធាតុធំៗចំនួន ២ គឺ ភ្នាក់ងារធ្វើដំណើរ និងអាកាសចរធ្វើដំណើរ ។ វិស័យផ្សេងទៀតដូចជា ការជួលឡាន រថភ្លើង និងការធ្វើដំណើរតាមសមុទ្រ ។ល។ មិនត្រូវបានគ្របដណ្តប់នោះទេ[៤] ។

## ៣. ទេសចរណ៍ និងសេដ្ឋកិច្ច

វិស័យទេសចរណ៍ បានចូលរួមចំណែកយ៉ាងចម្បងចំពោះសេដ្ឋកិច្ចពិភពលោក។ ដោយយោងទៅតាមការប៉ាន់ប្រមាណរបស់អង្គការ WTO ទេសចរណ៍អន្តរជាតិអាចរកប្រាក់ចំណូលបាន ៣៨១ ពាន់លានដុល្លារ ពីការទទួលភ្ញៀវអន្តរជាតិ (១,៤៦%នៃផលទុនក្នុងស្រុកសរុបពិភពលោក) ក្នុងឆ្នាំ១៩៩៥ ។ម្យ៉ាងវិញទៀត ការប៉ាន់ស្មានរបស់ WTTC បានបង្ហាញថាវិស័យទេសចរណ៍នឹងផ្តល់ផលក្នុងកម្រិតខ្ពស់ ទៅលើវិស័យសេដ្ឋកិច្ចព្រោះការប៉ាន់ស្មាននេះបូកបញ្ចូលទាំងទេសចរណ៍ក្នុងស្រុក។

ដូចបានរាយការណ៍ដោយ WTTC វិស័យទេសចរណ៍ក្នុងឆ្នាំ១៩៩៥ បានបង្កើតការងារដល់មនុស្សប្រមាណជា ២១២ លាននាក់ ឬបុគ្គលិកកម្មករ ១ នាក់ក្នុងចំណោម ១០នាក់ អាចរួមចំណែកបាន ១០,៩% ដល់ GDP ពិភពលោក និងបានរួមចំណែកចំនួនសរុប១,៦សែនកោដិ (trillion)ដុល្លាដល់កម្រិតប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ ឬស្មើនឹង១១,៤% នៃបញ្ជីប្រាក់ខែពិភពលោក (the global payroll)។ ការប៉ាន់ស្មានរបស់ WTTC សម្រាប់ឆ្នាំ១៩៩៥ បានបង្ហាញថាវិស័យទេសចរណ៍នឹងរួមចំណែកដល់ការចំណាយរបស់អ្នកប្រើប្រាស់សរុបចំនួន ១១,៤% ការចំណាយរបស់រដ្ឋាភិបាលសរុបចំនួន ៦,៦% ការវិនិយោគជាមូលធនសរុបចំនួន ១១,៤% និងការលក់ដូរអាជីវកម្មសរុបចំនួន ១១,៧%។

ដោយយោងទៅតាមអង្គការ WTO សកម្មភាពទេសចរណ៍អាចរកប្រាក់ចំណូលបានប្រមាណជា ៣៨១ ពាន់លានដុល្លានៅទូទាំងពិភពលោកក្នុងឆ្នាំ១៩៩៥។ ក្នុងឆ្នាំ១៩៩៣ ការទទួលភ្ញៀវទេសចរនៅលើពិភពលោកមានចំនួនខ្ពស់ដូចជាស្មើនឹង៨% នៃការនាំទំនិញចេញសរុប និងស្មើនឹងចំនួន ៣០%នៃការនាំសេវាចេញសរុប។ ដូច្នេះវិស័យទេសចរណ៍ទទួលបានចំណាត់ថ្នាក់លេខ១ បើប្រៀបធៀបទៅនឹងការនាំចេញលើពិភពលោកដែលមានដូចជា ការនាំចេញ ប្រេងឥន្ធនៈ គ្រឿងយន្ត និងឧបករណ៍អេឡិចត្រូនិក។

WTTC បានប៉ាន់ប្រមាណថា ឧស្សាហកម្មទេសចរណ៍នឹងបង្កើនលទ្ធផលសរុបច្រើនជាង ៧,១ សែនកោដិ (trillion) ដុល្លា ក្នុងឆ្នាំ២០០៦ ពីចំនួន ៣,៩សែនកោដិ (trillion) ដុល្លា ដែលបានប៉ាន់ប្រមាណក្នុងឆ្នាំ១៩៩៦។ វិស័យ

---

[៤] សេវាប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ក្នុងវិស័យឧស្សាហកម្មទេសចរណ៍ NUWHRAIN-APL-IUF សហជីពកម្មករជាតិ នៅតាមសណ្ឋាគារ ភោជនីយដ្ឋាន និងកន្លែងឧស្សាហកម្ម

ទេសចរណ៍នឹងផ្តល់ការងារចំនួន៣៨៥លាននាក់ ក្នុងឆ្នាំ២០០៦ ប្រសិនបើប្រៀបធៀបទៅនឹងការងារចំនួន២៥៥លាននាក់ ដែលបានប៉ាន់ស្មានកាលពីឆ្នាំ ១៩៩៦។ អង្គការ WTO បានព្យាករណ៍ថាប្រាក់ចំណូលបានពីវិស័យទេសចរណ៍អន្តរជាតិនឹងទៅដល់ ៦២១ ពាន់លានដុល្លារ ក្នុងឆ្នាំ២000 ហើយអាចកើនដល់ ១,៥៥សែនកោដិ (trillion)ដុល្លារនៅឆ្នាំ២០១០។

## ៤. ភ្ញៀវទេសចរ[៥]

### *ក-ភ្ញៀវទេសចរអន្តរជាតិ*

ភ្ញៀវទេសចរអន្តរជាតិត្រូវបានកំណត់និយមន័យថាជា បុគ្គលទាំងឡាយណាដែលធ្វើដំណើរក្រៅប្រទេសរបស់ខ្លួនសម្រាប់រយៈពេលលើសពី ២៤ ម៉ោង (ស្នាក់នៅមួយយប់) ប៉ុន្តែមិនលើសពីមួយឆ្នាំ ដោយមានគោលបំណង:

- វិស្សមកាល
- ការសម្រាក និងការលំហែកាយ
- មូលហេតុសុខភាព
- មូលហេតុសាសនា
- ការចូលរួមកីឡា
- ការទៅលេងមិត្តភក្តិ និងសាច់ញាតិ
- សកម្មភាពពាណិជ្ជកម្ម និងអាជីព
- ការចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងវគ្គហ្វឹកហ្វឺន

បុគ្គលទាំងឡាយណាដែលធ្វើអន្តោប្រវេសន៍ទៅធ្វើការនៅប្រទេសដទៃមិនត្រូវបានរាប់បញ្ចូលថាជាភ្ញៀវទេសចរឡើយ ។

### *ខ-ភ្ញៀវទេសចរជាតិ/ក្នុងស្រុក*

ភ្ញៀវទេសចរជាតិ/ក្នុងស្រុក គឺជាបុគ្គលទាំងឡាយណាដែលធ្វើដំណើរចេញពីផ្ទះក្នុងប្រទេសរបស់ខ្លួន សម្រាប់រយៈពេលលើសពី ២៤ ម៉ោង (ស្នាក់នៅមួយយប់) ដោយមានមូលហេតុដូចបានរៀបរាប់ខាងលើ។ បុគ្គលទាំងឡាយណាដែលផ្លាស់ប្តូរទីលំនៅមិនត្រូវបានរាប់បញ្ចូលថាជាភ្ញៀវទេសចរជាតិទេ។

[៥] សៀវភៅកម្មវិធីបណ្តុះបណ្តាលស្តីពីការទប់ស្កាត់កុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ - គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ (MOT-WVC-CAMP)

*គ-អ្នកទស្សនកិច្ចក្នុងថ្ងៃតែមួយ*

អ្នកទស្សនកិច្ចអន្តរជាតិក្នុងថ្ងៃតែមួយ គឺជាបុគ្គលទាំងឡាយណាដែលធ្វើដំណើរទៅកាន់ប្រទេសដទៃ ប៉ុន្តែមិនសម្រាកយប់ឡើយ (ស្នាក់នៅតិចជាង ២៤ ម៉ោង)។ អ្នកទស្សនកិច្ចក្នុងស្រុកក្នុងថ្ងៃតែមួយ គឺជាបុគ្គលទាំងឡាយណាដែលធ្វើដំណើរចេញពីកន្លែងស្នាក់នៅរបស់ខ្លួន ប៉ុន្តែមិនសម្រាកយប់ឡើយ (ស្នាក់នៅតិចជាង ២៤ ម៉ោង)។

## ៥. ប្រភេទនៃការរៀបចំការធ្វើដំណើរ និងសម្បទា

ភ្ញៀវទេសចរ ត្រូវបានចាត់ចំណាត់ថ្នាក់ទៅតាមប្រភេទនៃការរៀបចំការធ្វើដំណើរ និងសម្បទាដែលពួកគេប្រើប្រាស់។ ប្រភេទភ្ញៀវទេសចរមាន៖

ក. ភ្ញៀវសាក់កាដូ

- ធ្វើដំណើរដោយឯករាជ្យ និងដោយសំចៃ
- ស្វែងរកបទពិសោធន៍ធ្វើដំណើរដោយជាក់ស្តែង
- ចង់ស្នាក់នៅឱ្យបានយូរនៅក្នុងកន្លែងគោលដៅ
- ទាក់ទងជាមួយប្រជាជនតាមមូលដ្ឋាន និងរៀនសូត្រពីវប្បធម៌របស់ប្រជាជនទាំងនោះជាប្រចាំ
- ចង់ធ្វើដំណើរទៅកាន់កន្លែងដែលមិនស្គាល់
- មិនព្រួយបារម្ភចំពោះការប្រថុយនឹងគ្រោះថ្នាក់

ខ. ភ្ញៀវទេសចរបែបប្រមូលផ្តុំ/ជាក្រុម

- សេវាទេសចរណ៍ជាច្រើនត្រូវបានបញ្ចូលជាកញ្ចប់
- ពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យឧស្សាហកម្មទេសចរណ៍
- ចង់ស្នាក់នៅខ្លីៗ និងធ្វើដំណើរជុំវិញ
- ធ្វើដំណើរទៅកាន់កន្លែងដែលទើបបង្កើត និងកន្លែងដែលភ្ញៀវទេសចរស្គាល់
- មិនប្រថុយនឹងគ្រោះថ្នាក់
- ចង់បានសេវាកម្មដូចគ្នានឹងសេវាកម្មដែលមាននៅក្នុងស្រុកកំណើត

## *ខ. ស្ថានភាពទូទៅនៃវិស័យទេសចរណ៍កម្ពុជា*

ភាពទាក់ទាញរបស់ប្រទេសកម្ពុជា ជាគោលដៅទេសចរណ៍មួយសម្រាប់ភ្ញៀវទេសចរបានកំពុងកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវការមកទស្សនារបស់ភ្ញៀវទេសចរ ចាប់ពីចំនួន

២០០,០០០ នាក់ ក្នុងឆ្នាំ១៩៩៥ ដល់១.៤២១.៦១៥ នាក់ ក្នុងឆ្នាំ២០០៥ ប៉ុន្តែគេបានរាយការណ៍ថាមានការធ្លាក់ចុះចំនួនភ្ញៀវទេសចរបន្តិចបន្តួច ដោយសារតែបញ្ហាភ័យខ្លាចចំពោះជំងឺសារ (SARS) ក្នុងឆ្នាំ២០០៣។ ដូចគ្នានេះដែរចំនួនភ្ញៀវទេសចរក្នុងស្រុកក៏ស្ថិតក្នុងការកើនឡើងផងដែរ។ មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្លា ចំពោះការទៅទស្សនាតាមតំបន់ប្រវត្តិសាស្ត្រ តំបន់ឆ្នេរសមុទ្រ និងតំបន់សម្រស់ធម្មជាតិប៉ែកឦសានប្រទេស ជាពិសេសនៅតាមផ្នែកវិជ្ជាជីវៈ និងផ្នែកការងារនៅតាមតំបន់ទីក្រុង។ ជាឧទាហរណ៍ក្នុងឆ្នាំ២០០៥ ចំនួនភ្ញៀវទេសចរដែលបានមកទស្សនាខេត្តសៀមរាបមានចំនួនដល់ទៅ ២០៩.៩២៤ នាក់។

តំបន់ទេសចរណ៍សំខាន់ៗនៅក្នុងប្រទេសកម្ពុជាមាន រាជធានីភ្នំពេញ ប្រាសាទអង្គរវត្ត ខេត្តសៀមរាប តំបន់ឆ្នេរពណិស នៃក្រុងព្រះសីហនុ និងតំបន់ភ្នំដ៏ស្រស់ស្អាតប្រកបដោយភាពស្រទន់នៃខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ ប្រទេសកម្ពុជាក៏មានតំបន់ទេសចរណ៍សំខាន់ៗជាច្រើន ព្រោះប្រទេសនេះមានធនធានធម្មជាតិច្រើន។

ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០២ ចំនួនភ្ញៀវទេសចរអន្តរជាតិ[៦] ដែលបានមកទស្សនាប្រទេសកម្ពុជាមានការកើនឡើងចាប់ពី ២៥-៣០% រៀងរាល់ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយចំនួនភ្ញៀវទេសចរអន្តរជាតិមានការធ្លាក់ចុះ១០,៨៧% បើប្រៀបធៀបទៅឆ្នាំ ២០០២ ដោយសារបញ្ហាជំងឺសារនៅក្នុងតំបន់។ ប៉ុន្តែនៅក្នុងឆ្នាំ ២០០៥ ចំនួនភ្ញៀវបានកើនឡើង ៣៤,៧២% បើប្រៀបធៀបទៅតួលេខនៅឆ្នាំ២០០៤ (ភ្ញៀវទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០០៤ មានចំនួន១,០៥៥,២០២ នាក់)។ ភ្ញៀវទេសចរអន្តរជាតិប្រមាណជាកន្លះលាននាក់ បានទៅទស្សនានៅខេត្តសៀមរាប។

ភ្ញៀវទេសចរអន្តរជាតិភាគច្រើនធ្វើដំណើរមកពីប្រទេសទាំង១០ ដែលមានរាយនាមដូចខាងក្រោមនេះៈ ប្រទេសកូរ៉េ ប្រទេសជប៉ុន សហរដ្ឋអាមេរិក ប្រទេសបារាំង ប្រទេសអង់គ្លេស ប្រទេសថៃ ប្រទេសចិន ប្រទេសតៃវ៉ាន់ ប្រទេសវៀតណាម និងប្រទេសអូស្ត្រាលី ។ ក្នុងរយៈពេល៦ខែដំបូងក្នុងឆ្នាំ២០០៦ ភ្ញៀវទេសចរអន្តរជាតិសរុបមានចំនួន ៨១៣.៩០២នាក់ ដោយមានកំណើនចំនួន១៩.១៩% បើប្រៀបធៀបទៅនឹងរយៈពេល៦ខែដូចគ្នា នៅក្នុងឆ្នាំ២០០៥។ ក្នុងចំណោមតួលេខទាំងនេះភ្ញៀវទេសចរអន្តរជាតិ ចំនួន ៣៩៥.៣៦០នាក់ បានធ្វើដំណើរទៅទស្សនាខេត្តសៀមរាប។ ក្រសួងទេសចរណ៍បានប៉ាន់ប្រមាណថា ចំនួនភ្ញៀវទេសចរអន្តរជាតិនឹងកើនឡើងយ៉ាងច្រើនដល់ចំនួន១.៦៩១.០៣២នាក់ នៅក្នុងឆ្នាំ២០០៦ ចំនួន២.០២៩.២៣៨នាក់ នៅក្នុងឆ្នាំ២០០៧ ចំនួន២.៤៣៥.០៨៦នាក់ នៅក្នុងឆ្នាំ២០០៨ ចំនួន ២.៩២២.១០៣នាក់ នៅក្នុងឆ្នាំ២០០៩ និងចំនួន៣.៥០៦.៥២៤នាក់ នៅក្នុងឆ្នាំ ២០១០។ ដោយសន្មត់ថាទិន្នាការពេល

[៦] របាយការណ៍ស្ថិតិទេសចរណ៍ប្រចាំឆ្នាំ — ស្ថិតិភ្ញៀវទេសចរអន្តរជាតិ មានដោយឡែកពីស្ថិតិភ្ញៀវទេសចរជាតិ

បច្ចុប្បន្ននៅតែបន្ត នោះចំនួនភ្ញៀវទេសចរជាតិ/ក្នុងស្រុកនឹងកើនឡើងពី៤,៥លាននាក់ ក្នុងឆ្នាំ២០០៥ ដល់៧លាននាក់ក្នុងឆ្នាំ ២០១០[៧] ។

នៅក្នុងឆ្នាំ២០០៥ ភ្ញៀវទេសចរជាតិសរុបមានចំនួន៥,២៧៨,១១៣នាក់ បានមកទស្សនាតំបន់ទេសចរណ៍នានាដែលមានចំនួនច្រើនជាងចំនួនភ្ញៀវទេសចរអន្តរជាតិ៥ដង ។ ក្នុងតួលេខនេះភ្ញៀវទេសចរជាតិចំនួន២,៥០០,០០០នាក់បានមកទស្សនាក្រុងភ្នំពេញ ចំនួន២០៩,៥២៤នាក់បានមកទស្សនាខេត្តសៀមរាប និងចំនួន១៥៣,៨៤២នាក់ បានមកទស្សនាក្រុងព្រះសីហនុ ។

ដោយមិនសង្ស័យ សេដ្ឋកិច្ចប្រទេសមានការកើនឡើងដោយសារតែវិស័យទេសចរណ៍ ។ ប្រការនេះត្រូវបានបង្ហាញដោយការរួមចំណែកនៃការចំណាយរបស់ជនបរទេសទៅលើផ្នែកសេដ្ឋកិច្ច និងការវិនិយោគក្នុងវិស័យទេសចរណ៍ព្រមទាំងការជួយគាំទ្រចំពោះកន្លែងសេវាកម្មនានា ។ មានការកើនឡើងជាបន្តបន្ទាប់នូវចំនួនសណ្ឋាគារ ផ្ទះសំណាក់ភោជនីយដ្ឋាន រមណីយដ្ឋាន ក្លឹបកីឡា និងភ្នាក់ងារធ្វើដំណើរទាក់ទងនឹងវិស័យទេសចរណ៍ ។ ជាលទ្ធផលប្រការនេះបានបណ្តាលឱ្យមានការកើនឡើងនូវចំនួនបុគ្គលិក/កម្មករ ធ្វើការនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍ទាំងនៅក្នុងផ្នែកសេវាកម្មរៀបរយ និងមិនរៀបរយ ។

ក្រសួងទេសចរណ៍បានប៉ាន់ប្រមាណថា ក្នុងភ្ញៀវទេសចរអន្តរជាតិម្នាក់បានចំណាយជាមធ្យមប្រមាណជា៥០០ដុល្លារអាមេរិកចំពោះការស្នាក់នៅរបស់ខ្លួន ហើយប្រាក់ចំណូលសរុបដែលប្រទេសកម្ពុជាបានទទួលពីភ្ញៀវទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០០៤ មានប្រមាណជា ៧៧៧ លានដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលថ្លៃចំណាយផ្នែកយន្តហោះ) ។ ទឹកប្រាក់ចំណូលមានប្រមាណជា២០% នៃផលទុនក្នុងស្រុកសរុប ។ មិនមានការប៉ាន់ប្រមាណជាផ្លូវការចំពោះការចំណាយជាមធ្យមក្នុងម្នាក់ៗរបស់ភ្ញៀវទេសចរជាតិ ក្នុងពេលធ្វើដំណើរនិង/ឬការទស្សនានោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយផលប៉ះពាល់ទៅលើការកើនឡើងប្រាក់ចំណូល/ការងារតាមមូលដ្ឋានក៏មានលក្ខណៈកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ។

## *គ. ផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច*[៨]

### ១. ផលប៉ះពាល់លើវិស័យសេដ្ឋកិច្ចដោយវិស័យទេសចរណ៍

---

[៧] របាយការណ៍ស្ថិតិទេសចរណ៍ប្រចាំឆ្នាំ, ទំព័រទី ៨ — ការចូលមកដល់នៃភ្ញៀវទេសចរក្នុងប្រទេសកម្ពុជា ដែលបានព្យាករណ៍ទុកចាប់ពីឆ្នាំ ២០០៥-២០១០ ។

[៨] ការទប់ស្កាត់កុមារពីការកេងប្រវ័ញ្ចលើផ្លូវភេទ ទាក់ទងនឹងវិស័យទេសចរណ៍ - *សៀវភៅកម្មវិធីបណ្តុះបណ្តាល* គណៈកម្មការទេសចរណ៍សុវត្ថិភាពលើកុមារ (MoT-WVC-CAMP)

*ប្រសិនបើរៀបចំបង្កើត និងគ្រប់គ្រងបានល្អ វិស័យទេសចរណ៍អាចបង្កឱ្យមានអត្ថប្រយោជន៍លើវិស័យសេដ្ឋកិច្ចយ៉ាងសម្បើម:*

- បង្កើនប្រាក់ចំណូល និងការរួមចំណែកដល់ផលទុនក្នុងស្រុកសរុប GDP របស់ប្រទេស
- រកប្រាក់ពីការប្តូររូបិយវត្ថុ
- បង្កើតការងារដោយផ្ទាល់ក្នុងវិស័យទេសចរណ៍ និងដោយប្រយោលក្នុងវិស័យឧបត្ថម្ភគាំទ្រ
- រួមចំណែកដល់ប្រាក់ចំណូលរបស់រដ្ឋាភិបាល
- ជួយកែតម្រូវ និងទូទាត់ការចំណាយទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតសម្បទា និងសេវាកម្មនានាក្នុងសហគមន៍
- ជំរុញការអភិវឌ្ឍន៍ក្នុងផ្នែកសេដ្ឋកិច្ចផ្សេងទៀត ដូចជាកសិកម្ម នេសាទ សិប្បកម្ម រោងចក្រ ការធ្វើដំណើរ និងការសាងសង់

*ប្រសិនបើរៀបចំបង្កើត និងគ្រប់គ្រងមិនបានល្អ វិស័យទេសចរណ៍អាចបង្កឱ្យមានបញ្ហាផ្នែកសេដ្ឋកិច្ច ឬធ្វើឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ច ដែលមានដូចខាងក្រោម:*

- ការខាតបង់អត្ថប្រយោជន៍សេដ្ឋកិច្ចតាមរយៈការហូរចូលនូវការប្តូររូបិយវត្ថុអន្តរជាតិ
- ទំនិញ និងសេវាដែលបានប្រើនៅក្នុងវិស័យទេសចរណ៍ ការទូទាត់ប្រាក់ចំណេញទៅកន្លែងអាជីវកម្មនៅក្រៅប្រទេស ការទូទាត់ប្រាក់បៀវត្សដល់ជំនាញការជនជាតិបរទេស ។ល។
- ការកើនឡើងនូវតម្លៃដី ទំនិញ និងសេវាក្នុងស្រុកដែលបង្កមកពីការអភិវឌ្ឍន៍ដែលមិនអាចគ្រប់គ្រងបាន
- ប្រសិនបើវិស័យទេសចរណ៍មានការអភិវឌ្ឍន៍នៅតាមតំបន់មួយចំនួនដោយមិនគិតពីការអភិវឌ្ឍន៍នៅតំបន់ផ្សេងទៀតនោះសេដ្ឋកិច្ចតំបន់នឹងមានការប្រែប្រួល

*ត្រូវប្រើវិធីសាស្ត្រកាត់បន្ថយបញ្ហាសេដ្ឋកិច្ច និងពង្រឹងអត្ថប្រយោជន៍សេដ្ឋកិច្ចតាមវិស័យទេសចរណ៍:*

- ពង្រឹងទំនាក់ទំនង "រវាងទេសចរណ៍ និងផ្នែកសេដ្ឋកិច្ចផ្សេងទៀត ដើម្បីកាត់បន្ថយការនាំចូលទំនិញ និងសេវាសម្រាប់ប្រើក្នុងវិស័យទេសចរណ៍"
- ជំរុញឱ្យមានភាពជាម្ចាស់ការតាមមូលដ្ឋានដើម្បីគ្រប់គ្រងទៅលើសំភារៈ និងសេវាកម្មទេសចរណ៍ក្នុងគោលបំណងដើម្បីកាត់បន្ថយការហូរចេញប្រាក់ចំណេញ និងប្រាក់បៀវត្ស
- ជំរុញឱ្យមានការងារជាអតិបរមាដល់ប្រជាជនតាមមូលដ្ឋាននៅក្នុងវិស័យទេសចរណ៍រួមមាន ការងារបច្ចេកទេស និងការងារគ្រប់គ្រងដើម្បីបង្កើនប្រាក់ចំណូលឱ្យបានជាអតិបរមានៅតាមមូលដ្ឋាន

- អភិវឌ្ឍវិស័យទេសចរណ៍តាមរបៀបមួយៗដែលអាចគ្រប់គ្រងបានដើម្បីកាត់បន្ថយនិន្នាការនៃអតិផរណាព្រមទាំងបង្កឱ្យមានការធ្វើផែនការ និងការត្រួតពិនិត្យសមស្របលើការអភិវឌ្ឍន៍វិស័យទេសចរណ៍
- លើកទឹកចិត្តឱ្យភ្ញៀវទេសចរស្នាក់នៅឱ្យបានយូរ ដោយផ្តល់នូវសកម្មភាពដែលគួរឱ្យចាប់អារម្មណ៍នានា ដូច្នេះពួកគេនឹងចំណាយលុយកាន់តែច្រើន
- លើកទឹកចិត្តឱ្យភ្ញៀវទេសចរចំណាយលុយឱ្យកាន់តែច្រើនដោយផ្តល់ឱកាសពង្រីកវិស័យសិល្បៈ វិស័យសិប្បកម្ម និងការរៀបចំឱ្យមានដំណើរកំសាន្តឱ្យបានច្រើន ។
- លើកទឹកចិត្តឱ្យភ្ញៀវទេសចរមកទស្សនាម្តងទៀត ដោយផ្តល់នូវការចាប់អារម្មណ៍ សម្បទា និងសេវាកម្មនានាប្រកបដោយគុណភាពខ្ពស់ និងធ្វើឱ្យភ្ញៀវទេសចរពេញចិត្ត ។

- ផលប៉ះពាល់នៃវិស័យទេសចរណ៍លើវិស័យសេដ្ឋកិច្ចត្រូវត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាអត្ថប្រយោជន៍ដែលទទួលបានពីវិស័យទេសចរណ៍អាចឆ្លើយតបទៅនឹងលទ្ធផលដែលរំពឹងទុក ។ ប្រសិនបើទទួលបានប្រាក់ចំណូលតិចជាងការរំពឹងទុក ឬមានបញ្ហាសេដ្ឋកិច្ចកើតឡើងដោយសារវិស័យទេសចរណ៍ នោះត្រូវធ្វើការកែសម្រួលសកម្មភាព និងវិធានការ ។

**២. ផលប៉ះពាល់របស់វិស័យទេសចរណ៍លើវប្បធម៌សង្គម** វិស័យទេសចរណ៍អាចនាំឱ្យមានទាំងអត្ថប្រយោជន៍ និងបញ្ហាចំពោះសង្គមជាតិតាមមូលដ្ឋាន និងផ្នែកវប្បធម៌ ។ ទោះបីជាលំបាកក្នុងការវាស់វែងផលប៉ះពាល់របស់វិស័យទេសចរណ៍លើវប្បធម៌សង្គមជាងការវាស់វែងផលប៉ះពាល់របស់វិស័យទេសចរណ៍លើវិស័យសេដ្ឋកិច្ច និងបរិស្ថានក៏ដោយក៏ត្រូវពិចារណាទៅលើផលប៉ះពាល់លើវប្បធម៌សង្គមក្នុងពេលអភិវឌ្ឍន៍វិស័យទេសចរណ៍ផងដែរ ។

*ប្រសិនបើវិស័យទេសចរណ៍ត្រូវបានធ្វើផែនការ អភិវឌ្ឍន៍ និងគ្រប់គ្រងបានល្អ នោះវានឹងនាំឱ្យមាននូវផលចំណេញដល់ផ្នែកវប្បធម៌សង្គមជាច្រើន ។ ផលចំណេញទាំងនេះរួមមានៈ*

- ប្រសិនបើផលប៉ះពាល់នៃវិស័យទេសចរណ៍ទៅលើវិស័យសេដ្ឋកិច្ចត្រូវបានបែងចែកបានត្រឹមត្រូវ នោះវានឹងមានការកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជន និងជួយទូទាត់ចំពោះការចំណាយលើការកែលម្អសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៍ ។
- ជួយថែរក្សាកេរ្តិ៍ដំណែលវប្បធម៌នៃតំបន់នោះ បើពុំនោះទេដែលប្រហែលជាអាចបាត់បង់ដោយសារតែមានការអភិវឌ្ឍន៍ ។ បន្ថែមទៅលើការអភិរក្សតំបន់ប្រវត្តិសាស្ត្រ ផ្នែកតន្ត្រីវប្បធម៌ របាំ ល្ខោន សិល្បៈ សិប្បកម្ម ប្រពៃណីពិធីបុណ្យទាន បែបបទជីវិត សកម្មភាពសេដ្ឋកិច្ច និងបែបបទស្ថាបត្យកម្មដែលជាភាពទាក់ទាញគឺមាន

សារៈសំខាន់ដល់ភ្ញៀវទេសចរ។ វិស័យទេសចរណ៍អាចជួយកែលម្អ និងជួយផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់ការធ្វើអភិរក្សទាំងនេះ។

- ជួយបង្កើត និងរក្សាសារៈមន្ទីរ រោងល្ខោន និងសម្បទានវប្បធម៌ផ្សេងទៀត ព្រោះវាមានការគាំទ្រមួយផ្នែកពីវិស័យទេសចរណ៍
- ពង្រឹង ឬធ្វើឱ្យថ្មីឡើងវិញទៅលើមោទនភាពរបស់ប្រជាជនមូលដ្ឋានតាមរយៈវប្បធម៌របស់ពួកគេនៅពេលដែលឃើញភ្ញៀវទេសចរសរសើរដល់ខ្លួន
- ផ្តល់ឱកាសឱ្យមានការផ្លាស់ប្តូរផ្នែកវប្បធម៌រវាងភ្ញៀវទេសចរ និងអ្នកស្នាក់នៅតាមមូលដ្ឋានដើម្បីបង្កើតឱ្យមានការគោរពវប្បធម៌គ្នាទៅវិញទៅមក

*ប្រសិនបើវិស័យទេសចរណ៍ត្រូវបានរៀបចំ បង្កើតឡើង និងគ្រប់គ្រងមិនបានល្អ នោះបញ្ហាវប្បធម៌សង្គមក៏អាចកើតឡើងផងដែរ។ បញ្ហាដែលអាចកើតមានទាំងនេះរួមមាន:*

- មានការទាក់ទាញ និងសម្បទាសម្រាប់ភ្ញៀវទេសចរច្រើនពេកដែលធ្វើឱ្យប្រជាជនតាមមូលដ្ឋានមិនអាចប្រើប្រាស់សម្បទានោះបានងាយស្រួល។ ប្រការនេះអាចបង្កឱ្យមានការអាក់អន់ចិត្តពីសំណាក់ប្រជាជនតាមមូលដ្ឋាន
- ចំណាយថ្លៃចំពោះការចូលទស្សនាកន្លែងទេសចរណ៍ ដែលអាចរារាំងដល់ការចូលកម្សាន្ត របស់ប្រជាជនតាមមូលដ្ឋានមួយចំនួនធំ និងធ្វើឱ្យមានការខកចិត្តទៀតផង
- ការខកចិត្តក្នុងចំណោមប្រជាជនតាមមូលដ្ឋាន ប្រសិនបើពួកគេយល់ឃើញថាខ្លួនមិនបានទទួលអត្ថប្រយោជន៍ពីវិស័យទេសចរណ៍
- ការធ្វើអាជីវកម្មហួសហេតុទៅលើបែបបទវប្បធម៌ប្រពៃណីមានដូចជា ទំនៀមទម្លាប់តាមមូលដ្ឋាន តន្ត្រី របាំ ពិធីបុណ្យផ្សេងៗ អាចនាំឱ្យមានការបាត់បង់នូវសារៈសំខាន់ និងភាពត្រឹមត្រូវរបស់ប្រជាជនតាមមូលដ្ឋាន
- បង្ហាញពីផលប៉ះពាល់ទៅលើប្រជាជនមូលដ្ឋាន ជាពិសេសមនុស្សវ័យក្មេង ដោយធ្វើត្រាប់តាមការប្រព្រឹត្តិ និងការស្លៀកពាក់របស់ភ្ញៀវទេសចរដោយមិនយល់ពីវប្បធម៌របស់ភ្ញៀវទេសចរ
- ការយល់ច្រឡំគ្នាកើតឡើងរវាងភ្ញៀវទេសចរ និងប្រជាជនតាមមូលដ្ឋាន ព្រោះមានភាសា និងប្រពៃណីទំនៀមទម្លាប់ផ្សេងៗគ្នា
- បញ្ហាសង្គមដូចការប្រើប្រាស់គ្រឿងញៀន ការរំលោភបំពាន គ្រឿងស្រវឹង បទឧក្រិដ្ឋ និងអំពើពេស្យាចារប្រហែលជាកើតឡើងកាន់តែធ្ងន់ធ្ងរដោយសារវិស័យទេសចរណ៍

## *ឃ. ស្ថានភាពទូទៅនៃកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍*

មានការប៉ាន់ប្រមាណមួយថា ការងារតាមមូលដ្ឋានប្រមាណជា ១០០,០០០នាក់ បានកើតឡើងដោយសារវិស័យទេសចរណ៍។ នៅក្នុងឆ្នាំ២០០៤ ប្រាក់ចំណូលវិស័យទេសចរណ៍សរុបត្រូវបានប៉ាន់ប្រមាណថា មានប្រមាណជា ៧៧៧លានដុល្លាអាមេរិក ដោយមានការងារតាមមូលដ្ឋានប្រមាណជា១៨០,០០០នាក់បានកើតឡើង។ ការប៉ាន់ប្រមាណ នៅក្នុងឆ្នាំ២០០៣ និងឆ្នាំ២០០៤មិនបានដាក់បញ្ចូលនូវការចំណាយទៅលើមុខទំនិញ និងភេសជ្ជៈដែលបាននាំចូលពីប្រទេសខាងក្រៅដើម្បីផ្គត់ផ្គង់ចំពោះសេវាទេសចរណ៍ ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានលើកកម្ពស់ការផលិត និងការប្រើប្រាស់ផលិតផលក្នុងស្រុកនៅក្នុងវិស័យទេសចរណ៍ ដើម្បីបង្កើនការងារថែមទៀត ឬបង្កើនប្រាក់ចំណូលថែមទៀតដល់ប្រជាជនតាមមូលដ្ឋាន ជាពិសេសដល់ប្រជាជនក្រីក្រ និងប្រជាជនដែលងាយទទួលរងគ្រោះនៅក្នុងវិស័យទេសចរណ៍ ។

ដោយមានការកើនឡើងនូវចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចំនួនប្រជាជនដែលធ្វើការនៅក្នុងវិស័យទេសចរណ៍ក៏បានកើនឡើងក្នុងសមាមាត្រនេះផងដែរ។ អ្នកដែលធ្វើការនៅក្នុងវិស័យទេសចរណ៍ភាគច្រើនធ្វើការនៅក្នុងផ្នែកសេវាកម្មខាងក្រោមនេះ - ដោយយោងតាមតួលេខឆ្នាំ២០០៦[៩]:

*១. សណ្ឋាគារ:* មានសណ្ឋាគារដែលបានចុះបញ្ជីប្រមាណជា ៣១៧ (១៥,៤៧១បន្ទប់) នៅក្នុងប្រទេសកម្ពុជារួមមាន:

- ក្រុងភ្នំពេញ មានសណ្ឋាគារចំនួន ១៣៣ (៦,១៤៤បន្ទប់) ដោយមានបុគ្គលិកចំនួន ៣,៥១៦នាក់ (ស្រី ១,៧៦៥ នាក់)
- ខេត្តសៀមរាប[១០] មានសណ្ឋាគារចំនួន ៨៤ (៥,៧៦៨បន្ទប់) ដោយមានបុគ្គលិកប្រមាណ ៤,៧៧៥នាក់ (ស្រី ១,៩១៨នាក់)
- ក្រុងព្រះសីហនុមានសណ្ឋាគារចំនួន ៤១ (១,៩៣២បន្ទប់) ដោយមានបុគ្គលិកប្រមាណ ៩៣៦នាក់ (ស្រី ៤១៥ នាក់)

*២. ផ្ទះសំណាក់:* មានផ្ទះសំណាក់ដែលបានចុះបញ្ជីប្រមាណជា ៦៩២ (៩,១០១ បន្ទប់) នៅក្នុងប្រទេសកម្ពុជា រួមមាន:

---

[៩] ក្រសួងទេសចរណ៍-នាយកដ្ឋានឧស្សាហកម្មទេសចរណ៍ និងធ្វើផែនការ- ស្ថិតិស្តីពីសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ហាងម៉ាស្សា ភ្នាក់ងារធ្វើដំណើរតំបន់ទេសចរណ៍ និងក្លឹបកីឡា- ខែមករា ឆ្នាំ២០០៦

[១០] បច្ចុប្បន្ននេះ ចំនួនសណ្ឋាគារនៅក្នុងខេត្តសៀមរាបបានកើនឡើងយ៉ាងរហ័ស ។ ក្រសួងទេសចរណ៍បានប៉ាន់ប្រមាណថា ចំនួនសណ្ឋាគារ នឹងកើនឡើងដល់ ៩៧ សណ្ឋាគារ (៨,៦៣២ បន្ទប់) នៅចុងឆ្នាំ ២០០៧ ។

- ក្រុងភ្នំពេញមានផ្ទះសំណាក់ចំនួន ២០២ (៣២,៥១៣បន្ទប់) ដោយមានបុគ្គលិកចំនួន ៧៥២នាក់ (ស្រី៣៨១នាក់)
- ខេត្តសៀមរាបមានផ្ទះសំណាក់ចំនួន ១៥៦ (២.១២០បន្ទប់)
- ក្រុងព្រះសីហនុមានផ្ទះសំណាក់ចំនួន ៨៨ (១.០១៥ បន្ទប់)

*៣. ភោជនីយដ្ឋាន:* មានភោជនីយដ្ឋានដែលបានចុះបញ្ជីប្រមាណជា ៧២៧ នៅក្នុងប្រទេសកម្ពុជារួមមាន:

- ក្រុងភ្នំពេញ មានភោជនីយដ្ឋានចំនួន ២៥១ ដោយមានបុគ្គលិកចំនួន ៤,៤០០នាក់ (ស្រី ២,៥៦៥នាក់)
- ខេត្តសៀមរាប មានភោជនីយដ្ឋានចំនួន ៧២
- ក្រុងព្រះសីហនុ មានភោជនីយដ្ឋានចំនួន ៥៦

*៤. ស្ត្រីរកស៊ីផ្លូវភេទនៅក្នុងវិស័យទេសចរណ៍*

របាយការណ៍គូសផែនទីនៃសេវាកម្មកម្សាន្តផ្នែកផ្លូវភេទក្នុងឆ្នាំ ២០០៤ របស់ NCHADS នៃក្រសួងសុខាភិបាល បានបង្ហាញនូវតួលេខ ខាងក្រោមនេះ:

- ផ្ទះបនមានចំនួន ៧៨៥ ( អ្នករកស៊ីផ្លូវភេទ មាន ៣,៦៣៧នាក់)
- (របាយការណ៍ក្រសួងទេសចរណ៍) កន្លែងម៉ាស្សាមានចំនួន ៥៦។ (NCHADS/ក្រសួងសុខាភិបាល) កន្លែងម៉ាស្សាមានចំនួន ៧៣ (មានកម្មករ ៧៥៦នាក់)

*៥. វិស័យកំសាន្ត*

តាមរបាយការណ៍របស់ NCHADS ឆ្នាំ ២០០៤ បានបង្ហាញនូវតួលេខដូចខាងក្រោមនេះ:

- បៀរហ្គាដិនមានចំនួន ១៥៨ (មានកម្មករ ៨៥៧នាក់)
- ខារ៉ាអូខេមានចំនួន ៣៣៩ (មានកម្មករ ២,២៨៤នាក់)
- ហាងស្រាបៀរមានចំនួន ៤៣១ (មានកម្មករ ៩២៧នាក់)

*៦. មគ្គុទ្ទេសក៍ទេសចរ*

មគ្គុទ្ទេសក៍ទេសចរចំនួន ១.៧២១នាក់ ត្រូវបានរាយការណ៍ថាបានធ្វើការ ដោយមានចុះបញ្ជីត្រឹមត្រូវថាជាមគ្គុទ្ទេសក៍ទេសចរ នៅក្នុងប្រទេសកម្ពុជា:

- មគ្គុទ្ទេសក៍ទេសចរចំនួន ២២៥នាក់ ធ្វើការនៅក្នុងទីក្រុងភ្នំពេញ
- មគ្គុទ្ទេសក៍ទេសចរចំនួន ១,៤៩៦នាក់ ធ្វើការនៅក្នុងខេត្តសៀមរាប

**សកម្មភាព ២: សកម្មភាពបន្ថែម**

**គោលបំណង:** ដើម្បីបង្កើនការយល់ដឹងស្តីពីស្ថានភាពរបស់កុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍

**ពេលវេលា:** ១ ម៉ោង ៣០ នាទី

**សំភារៈដែលត្រូវការ:**

ករណីសិក្សា ក្រដាសផ្ទាំងធំ ហ្វឺតសរសេរ

**របៀបធ្វើ**

១. បែងចែកអ្នកចូលរួមជា ៣ ក្រុម ។ ចែកករណីសិក្សាដល់ក្រុមនីមួយៗ ។
២. ស្នើឱ្យក្រុមទាំងអស់អានករណីសិក្សា ហើយពិភាក្សាពីស្ថានភាពរបស់កុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍ ។ ស្នើឱ្យក្រុមកត់ត្រាការយល់ឃើញរបស់ខ្លួន។
៣. ស្នើឱ្យតំណាងក្រុមនីមួយៗ ឡើងបង្ហាញនូវលទ្ធផលនៃការពិភាក្សារបស់ខ្លួន ។ បន្ទាប់ពីបង្ហាញចប់ គ្រប់ក្រុមហើយ ស្នើឱ្យអ្នកចូលរួមផ្តល់យោបល់ សំណួរ និងសំណូមពរនានា ។
៤. សង្ខេបលទ្ធផលនៃការពិភាក្សា

**មេរៀន:**

**ក. ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍**

ទាំងនេះគឺជាសាច់រឿងជាក់ស្តែងស្តីពី ទេសចរណ៍ផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា។ ខាងក្រោមនេះគឺជាការបង្ហាញឧទាហរណ៍ ដែលកើតឡើងពិតប្រាកដចំនួន៣។ សូមមិនជម្រាបឈ្មោះពិតប្រាកដរបស់ជនរងគ្រោះឡើយ។ សាច់រឿងរបស់ពួកគេ ត្រូវបានរាយការណ៍ដោយអ្នកសម្របសម្រួលការតស៊ូមតិសម្រាប់សិទ្ធិកុមារនៃអង្គការទស្សនៈពិភពលោកប្រចាំនៅប្រទេសកម្ពុជា និងអ្នកគ្រប់គ្រងការសង្គ្រោះនៃមជ្ឈមណ្ឌលកម្ពុជាសម្រាប់ការគាំពារសិទ្ធិរបស់កុមារ ខែ កក្កដា ឆ្នាំ ២០០០។

**ករណីសិក្សាពីខេត្តក្រចេះ**

ស្រីនុច

ស្រីនុចជាកុមារីអាយុ១៩ឆ្នាំ មកពីឃុំស្រែព្រៃ, ស្រុកទឹកដោះ, ខេត្តក្រចេះ ។ នាងជាកូនប្អូនគេបង្អស់។ នាងមានបងប្អូនបីនាក់ ។

នាងបានចាកចេញពីផ្ទះ ព្រោះឪពុកម្តាយនាងបានបង្ខំនាងឱ្យរៀបការជាមួយបុរសជំទង់ម្នាក់ ។ នាងមិនចង់រៀបការទាល់តែសោះនៅពេលនោះ ប៉ុន្តែឪពុកម្តាយនាងបានទទួចច្រំដែលពីរឿងរៀបការនេះ និងជេរស្តីស្រីនុច។

នាងបានសម្រេចចិត្តរត់ទៅឆ្ងាយជាមួយសង្សាររបស់នាង ។ ពួកគេបានមកកាន់ទីក្រុងភ្នំពេញ និងភ្លាមៗបន្ទាប់ពីពួកគេបានមកដល់ បុរសក្មេងនោះបាននាំនាងទៅកាន់ក្លឹបកំសាន្តដ៏ធំមួយដែលមានទីតាំងនៅក្នុងតំបន់អូរឬស្សី។ នាងត្រូវបានគេលក់ដោយមិនដឹងខ្លួនក្នុងតម្លៃ ១០០ដុល្លារអាមេរិក ។

ម្ចាស់ក្លឹបនោះ បានបង្ខំនាងឱ្យរួមភេទជាមួយបុរសជនជាតិបារាំងម្នាក់ចំនួនបួនលើក។ តម្លៃចន្លោះពី ២០ ទៅ៣០ដុល្លារ ក្នុងមួយលើក។ បន្ទាប់មកពួកគេបានបង្ខំនាងឱ្យទៅជាមួយជនជាតិបរទេសផ្សេងទៀតទៅក្លឹប Martini និងកន្លែងផ្សេងទៀតរៀងរាល់ល្ងាចចាប់ពីម៉ោង៧ល្ងាច រហូតដល់ម៉ោង១២យប់។ បុរសម្នាក់នោះ មិនបានប្រើស្រោមអនាម័យទេ នៅពេលដែលរួមភេទជាមួយនាង ។

ថ្ងៃមួយ ប៉ូលីសបានមករំដោះនាងខណៈពេលដែលនាងកំពុងដេកក្នុងបន្ទប់ជាមួយអ្នករួមអាជីពជាមួយនាង។ យ៉ាងហោចណាស់ក៏មាននារីចំនួន១៥នាក់ដែរ ដែលត្រូវឃាត់ខ្លួន។ ចុងបញ្ចប់នាង និងនារីផ្សេងៗទៀតត្រូវបានបញ្ជូនទៅកាន់អង្គការមួយដែលអាចជួយពួកគេបាន។

ប្រភព: *Child Sex Tourism – The Problem in Cambodia*, World Vision Cambodia in cooperation with MoT and the CNCC, 2001

**ករណីសិក្សាពីក្រុងភ្នំពេញ**

ស្រីលី

ស្រីលីជាក្មេងស្រីអាយុ ១៩ឆ្នាំ ។ នាងត្រូវបានបោកបញ្ឆោតដោយម្តាយមីងរបស់នាង និងត្រូវបានលក់ទៅឱ្យបុរសជនជាតិអាមេរិកម្នាក់ក្នុងតម្លៃ ៤០០ដុល្លារអាមេរិក សម្រាប់រយៈពេល ៤ថ្ងៃ។ បុរសនោះអាយុប្រហែលជា ៥០ឆ្នាំ។ បន្ទាប់ពីនោះមកនាងត្រូវបានបង្ខំឱ្យទៅជាមួយបុរសជនជាតិជប៉ុនម្នាក់អាយុ ២៥ឆ្នាំ ក្នុងតម្លៃ ៥០ដុល្លារ ។ បន្ទាប់មកមេបនបាននាំនាងទៅដេកជាមួយបុរសជនជាតិចិនម្នាក់ទៀតក្នុងតម្លៃ ៣០ដុល្លារ ។ ចុងបញ្ចប់ នាងបានដេកជាមួយបុរសជនជាតិបារាំងម្នាក់ដែលមានអាយុ៤០ឆ្នាំ។

បុរសនេះ បានដេកជាមួយនាងរយៈពេលមួយខែនៅឯផ្ទះជួលរបស់ខ្លួន។ បន្ទាប់ពីនោះមក នាងបានមកស្នាក់នៅក្នុងក្លឹបកម្សាន្តមួយ ។ ពីរថ្ងៃក្រោយមក នាងត្រូវបានសង្គ្រោះដោយប៉ូលីស និងបញ្ជូនមកកាន់អង្គការមួយ ។

**កុមារសម្រាប់លក់**[១]

Dateline NBC, កម្មវិធីសារព័ត៌មានអាមេរិកថ្មីៗនេះបានចូលរួមជាមួយការស៊ើបអង្កេត ដើម្បីបេសកកម្មយុត្តិធម៌អន្តរជាតិ ក្នុងបញ្ហាពេស្យាចារលើកុមារនៅតាមតំបន់បនស្រីស្វាយប៉ាក ។ អ្នកស៊ើបអង្កេតបានបង្កប់កាមេរ៉ាក្នុងផ្ទះបន។ ហើយពួកគេបានឃើញមានក្មេងស្រីអាយុប្រហែល ៨ឆ្នាំកំពុងធ្វើការរួមភេទតាមមាត់ជាមួយភ្ញៀវ ឬអតិថិជនដែលរួមមានទាំងជនជាតិអាមេរិកកាំង ដែលជាអ្នកធ្វើទេសចរផ្លូវភេទ។ Dateline បានរាយការណ៍ថា ក្មេងស្រីភាគច្រើនមកពីគ្រួសារក្រីក្រ និងត្រូវបានបោកប្រាស់ឱ្យមកធ្វើស្រីពេស្យាចារ។ ក្នុងការប៉ុនប៉ងនាំម្ចាស់បនស្រី និងអតិថិជនខ្លះឡើងតុលាការ បេសកកម្មយុត្តិធម៌អន្តរជាតិ និង Dateline បានចាត់ចែងសង្គ្រោះក្មេងស្រីមួយចំនួនពីផ្ទះបនស្រី។ ចុងបញ្ចប់ គេបានសង្គ្រោះក្មេងស្រីបានចំនួន ៣៧នាក់ ពីផ្ទះបនដែលភាគច្រើននៃក្មេងស្រីទាំងនោះមានអាយុក្រោម ១០ឆ្នាំ។ ហើយតុលាការកម្ពុជាបានរកឃើញមេបន ឬម្ចាស់បនចំនួន ៨នាក់ ថាមានកំហុស និងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររហូតដល់ ២០ឆ្នាំ។

១) ទប់ស្កាត់រាល់ទម្រង់នៃការជួញដូរស្ត្រី និងកុមារក្នុងប្រទេសកម្ពុជា ។ នេះជាគម្រោងដែលទទួលមូលនិធិពីរដ្ឋាភិបាល នៃប្រទេសហ្វាំងឡង់។

# ម៉ូឌុល ២ ៖ ការជួញដូរ

## គោលបំណងនៃម៉ូឌុល៖

១. ដើម្បីកំណត់និយមន័យ និងពិភាក្សាពីការជួញដូរ
២. ដើម្បីកសាងការយល់ដឹងពីស្ថានភាពនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេងក្នុងវិស័យទេសចរណ៍

**សកម្មភាព ១** ល្បែងប្រដេញពាក្យ - ការជួញដូរ

**មេរៀន**

ក. និយមន័យនៃពាក្យទាក់ទងនឹងការជួញដូរ
  ១. ការជួញដូរ
  ២. មនុស្សដែលត្រូវបានគេជួញដូរ
  ៣. អ្នកជួញដូរ

ខ. ស្ថានភាពទូទៅនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍កម្ពុជា

គ. កន្លែងដែលឃើញមានការជួញដូរកុមារ និងស្ត្រីវ័យក្មេង

ឃ. ហេតុអ្វីបានជាកុមារ និងស្ត្រីរងគ្រោះដោយការជួញដូរតែងតែត្រូវបានគេរំលោភសិទ្ធិរបស់ខ្លួន?

ង. កត្តាជំរុញ និងកត្តាអូសទាញដែលនាំឱ្យមានការជួញដូរកុមារ និងស្ត្រី

ច. ផលប៉ះពាល់នៃការជួញដូរកុមារ និងស្ត្រីវ័យក្មេង

**សកម្មភាព ២៖ សកម្មភាពបន្ថែម**

**ករណីសិក្សា៖ កុមារ និងស្ត្រីវ័យក្មេងដែលត្រូវបានគេជួញដូរនៅក្នុងវិស័យទេសចរណ៍**

**មេរៀន ក៖** ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍

# ម៉ូឌុល ២ ៖ ការជួញដូរ

**សកម្មភាព ១- ការបញ្ចេញពាក្យ**

**គោលបំណង:** ដើម្បីស្វែងយល់ពីអត្ថន័យនៃពាក្យ "ការជួញដូរ"

**រយៈពេល:** ១ ម៉ោង និង ៣០ នាទី

**សំភារៈដែលត្រូវការ:** ក្រដាសផ្ទាំងធំ
ប៊ិចហ្វឺតពណ៌

## របៀបធ្វើ

១. ស្នើឱ្យអ្នកចូលរួមនិយាយពាក្យដំបូងដែលមាននៅក្នុងចិត្ត ប្រសិនបើបានឃើញ/ឮពាក្យ "ការជួញដូរ"
២. ឱ្យអ្នកចូលរួមចាប់ដៃគូ និងសរសេរនូវនិយមន័យនៃ "ការជួញដូរ" ដោយខ្លួនឯង ។
៣. ផ្ដល់និយមន័យនៃការជួញដូរ និងដឹកនាំការពិភាក្សាទៅលើទិដ្ឋភាពសំខាន់ៗដែលបានលើកឡើងខាងលើដោយបង្ហាញ និងផ្ដល់នូវឧទាហរណ៍ជាក់ស្ដែង
៤. ស្នើឱ្យអ្នកចូលរួមក្រឡេកមើលនិយមន័យដែលខ្លួនសរសេរ ហើយពិនិត្យ និងកែសម្រួលឡើងវិញ។ ទទួលសំណួរ/ការបញ្ជាក់នានាដែលអ្នកចូលរួមមានពេលមើលទៅលើនិយមន័យរបស់ខ្លួន ដើម្បីធានាឱ្យមានការយល់ដឹងឱ្យបានច្បាស់ និងត្រឹមត្រូវចំពោះពាក្យ "ការជួញដូរ"
៥. អ្នកសម្របសម្រួល បូកសរុបសកម្មភាព ដោយផ្ដល់និយមន័យផ្សេងៗស្ដីពីការជួញដូរដល់អ្នកចូលរួម

## មេរៀន

### *ក. និយមន័យនៃពាក្យបច្ចេកទេសទាក់ទងនឹងការជួញដូរ*

#### ១. ការជួញដូរ[១១]

*ក)* *ការជួញដូរ* មានន័យថាជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការបញ្ជូន និងការទទួលមនុស្សតាមមធ្យោបាយនៃការគំរាមកំហែង ឬប្រើប្រាស់ទម្រង់នៃការបង្ខំផ្សេងទៀតដោយការចាប់ពង្រត់ ការក្លែងបន្លំ ការបោកប្រាស់ ការរំលោភបំពានដោយអំណាច ឬការធ្វើឱ្យមនុស្សមានភាពងាយទទួលរងគ្រោះថ្នាក់ ការផ្ដល់ ឬការទទួល ការទូទាត់ ឬអត្ថប្រយោជន៍ ដើម្បីសុំការអនុញ្ញាតពីអ្នកដែលមានការគ្រប់គ្រងលើមនុស្សម្នាក់ទៀតក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច។ ជាអប្បបរមា ការកេងប្រវ័ញ្ចរួមមានដូចជា

---

[១១] បំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋឆ្លងព្រំដែន (ឆ្នាំ ២០០០) សំដៅថាជាពិធីសាររបស់អង្គការសហប្រជាជាតិស្ដីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ។

ការកេងប្រវ័ញ្ច និងការប្រព្រឹត្តិអំពើពេស្យាចារលើអ្នកដទៃ ទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ សេវាកម្មដោយបង្ខំទាសភាព ការអនុវត្តន៍ស្រដៀងនឹងទាសភាព ឬការដោះដូរសរីរាង្គដោយអគតិ ។

ខ) ការយល់ព្រមដោយជនរងគ្រោះណាម្នាក់នៃការជួញដូរមនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចដូចដែលមានចែងក្នុងឃ្លាខាងលើគឺ (ក) មិនទាក់ទងទៅនឹងមធ្យោបាយណាមួយដែលបានចែងនៅក្នុង (ក) ដែលបានប្រើនោះឡើយ

គ) ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការបញ្ជូន និងការទទួលមនុស្សក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ចត្រូវបានចាត់ទុកថាជាការជួញដូរ ទោះបីជាវាមិនទាក់ទងទៅនឹងមធ្យោបាយដែលបានលើកឡើងនៅក្នុងឃ្លាខាងលើនៃមាត្រានេះក៏ដោយ ។

ឃ) "កុមារ" មានន័យថាជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ

និយមន័យនេះ បានចាត់ទុកការជួញដូរថាជាការសម្របសម្រួលការផ្លាស់ទីរបស់មនុស្សតាមរយៈការបោកបញ្ឆោត ឬការបង្ខំ។ល។ ក្នុងល័ក្ខខ័ណ្ឌនៃការកេងប្រវ័ញ្ច ការកេងប្រវ័ញ្ចផ្លូវភេទ ការងារដោយបង្ខំ ទាសភាព និងការអនុវត្តន៍ស្រដៀងទាសភាព ឬភាពជាខ្ញុំកញ្ជះ ។ នៅពេលដែលគិតដល់កុមារ វាមិនចាំបាច់ត្រូវបង្ហាញថា មានការបោកបញ្ឆោត និងការបង្ខំនោះទេ។ ភស្តុតាងនៃការបម្លាស់ទីក្នុងគោលបំណងកេងប្រវ័ញ្ចគ្រប់គ្រាន់នឹងអាចចាត់ទុកកុមារបានថាជាអ្នកដែលត្រូវបានគេជួញដូរ។

## ២. មនុស្សដែលត្រូវបានគេជួញដូរ

រាល់កុមារ (អាយុក្រោម ១៨ ឆ្នាំ) ទាំងឡាយណា ឬមនុស្សទាំងឡាយណាដែលត្រូវបានគេជួញដូរដោយយោងទៅតាមនិយមន័យដែលបានកំណត់ទាក់ទងនឹងការជួញដូរខាងលើ ។

## ៣. អ្នកជួញដូរ

គឺជាមនុស្សទាំងឡាយណា ដែលប្រព្រឹត្តិបទឧក្រិដ្ឋជួញដូរមនុស្ស។ កន្លែងនេះមិនមែនកម្រិតត្រឹមតែអ្នកដែលចូលរួមក្នុងការជ្រើសរើស ឬការដឹកជញ្ជូនមនុស្ស ប៉ុន្តែរួមបញ្ចូលទាំងនិយោជក និងអ្នកទាំងឡាយណាដែលចូលរួមក្នុងការកេងប្រវ័ញ្ចលើមនុស្សទៀតផង ។

## *ខ. ស្ថានភាពទូទៅនៃការជួញដូរកុមារ និង ស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍កម្ពុជា*[១២]

បញ្ហាការជួញដូរដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មគឺជាបញ្ហាដែលបានកើតឡើងយូរយារណាស់មកហើយនៅក្នុងប្រទេស ។

អំពើពេស្យាចារ ត្រូវបានរាយការណ៍ថាកើតមាននៅក្នុងសង្គមកម្ពុជាតាំងពីមុនឆ្នាំ១៩៧០ ប៉ុន្តែនៅពេលនោះវាមិនទាន់មានការរីករាលដាល[១៣] ។ ប៉ុន្តែចាប់ពីពេលនោះមកអំពើពេស្យាចារ បានកើតឡើងនៅទូទាំងរាជធានីដោយសារតែការកើនឡើងនូវភាពចលាចលនៅតាមតំបន់ជាយដែន ដែលបង្កឱ្យមានការហូរចូលជនភៀសខ្លួនមកកាន់តំបន់រាជធានី ព្រមទាំងមាននូវវត្តមាននៃទាហានសហរដ្ឋអាមេរិកដែលស្វែងរកនូវ "ការសម្រាក ការកំសាន្ត"។ ប្រការនេះកើតឡើងដោយសារតែទាហានសហរដ្ឋអាមេរិកបានធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម។ ក្នុងរបបខ្មែរក្រហម និងរហូតដល់ចុងទសវត្សឆ្នាំ១៩៨០ បញ្ហាអំពើពេស្យាចារត្រូវបានត្រួតត្រាយ៉ាងតឹងរឹង។ ប៉ុន្តែក្នុងកំឡុងពេលអភិវឌ្ឍន៍ប្រទេសគឺក្នុងទសវត្សឆ្នាំ១៩៩០ និងការធ្វើសេរីភាវូបនីយកម្មផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសអំពើពេស្យាចារបានកើនឡើងជាប្រចាំនៅតាមតំបន់ទីក្រុង និងនៅតាមតំបន់ជាយក្រុង។ នៅក្នុងឆ្នាំ១៩៩០ ស្ថិតិរដ្ឋកម្ពុជាបានបង្ហាញថា មានចំនួនស្ត្រីរកស៊ីផ្លូវភេទប្រមាណជា១៥០០នាក់ និងមានផ្ទះបនចំនួន២២៤ នៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែមកដល់ឆ្នាំ១៩៩១ ចំនួនស្ត្រីរកស៊ីផ្លូវភេទបានកើនឡើងដល់ទៅ ៦០០០នាក់។

ដោយមានការចាប់ផ្តើមនូវសម័យអ៊ុនតាក់ចុងឆ្នាំ១៩៩២ ចំនួនស្ត្រីរកស៊ីផ្លូវភេទ បានកើនឡើងដល់ទៅប្រមាណជា២០,០០០នាក់ ដោយយោងទៅតាមការអង្កេតរបស់អង្គការសហប្រជាជាតិក្នុងទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តកំពង់ចាម។ ចំនួនស្ត្រីរកស៊ីនៅថេរដដែលក្នុងសម័យអ៊ុនតាក់ ប៉ុន្តែទិន្នន័យបានបង្ហាញយ៉ាង ជាក់ស្តែងថាកុមារត្រូវបានគេជួញដូរឱ្យប្រព្រឹត្តិអំពើពេស្យាចារ។ បណ្តាញប្រព្រឹត្តិអំពើពេស្យាចារទៅលើកុមារក៏បានបង្កើតឡើងរួចទៅហើយនៅក្នុងប្រទេស។ នៅក្នុងឆ្នាំ១៩៩៣ ការសិក្សាមួយដែលបានធ្វើឡើងដោយអង្គការស្ត្រីខ្មែរនៅអូស្ត្រាលីនៅក្នុងខេត្តចំនួន៩ បានបង្ហាញថាមានស្ត្រីពេស្យាចារចំនួនប្រមាណជា២៥,០០០នាក់ ក្នុងនោះជនជាតិវៀតណាមមានចំនួន១៣,០០០នាក់ ហើយកុមារមានចំនួន៨០០នាក់ ។

នៅក្នុងឆ្នាំ១៩៩៥ ការប៉ាន់ប្រមាណបានបង្ហាញថា ចំនួនស្ត្រីរកស៊ីផ្លូវភេទបានធ្លាក់ចុះដល់១៧,០០០នាក់ ប៉ុន្តែមានការបញ្ជាក់ថា ចំនួនសមាមាត្រកុមារដែលត្រូវបានជួញដូរឱ្យធ្វើអំពើពេស្យាចារមានការកើនឡើង។ លទ្ធផលនៃ

---

[១២] ផ្នែកនេះ ដកស្រង់ចេញពីឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៦-២០០៨ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្មទៅលើកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ទំព័រ ៤-៦

[១៣] សារតាទូទៅស្តីពីការជួញដូរស្ត្រី និងកុមារដើម្បីកេងប្រវ័ញ្ចផ្លូវភេទ នៅក្នុង NPA-TSEC

ការអង្កេតរបស់ Vigilance និងអង្គការ CWDA បានបង្ហាញថាស្ត្រីរកស៊ីផ្លូវភេទប្រមាណជា ៥០%-៦០% ត្រូវបានលក់ដូរ ហើយចំនួនអ្នកដែលត្រូវបានជួញដូរភាគច្រើន (ចាប់ពី ២៥% ដល់ ៣៥%) មានអាយុក្រោម ១៨ឆ្នាំ។

នៅក្នុងឆ្នាំ ១៩៩៦-១៩៩៧ គណៈកម្មការសិទ្ធិមនុស្សនៃរដ្ឋសភាជាតិ បានធ្វើការស្រាវជ្រាវទូទាំងប្រទេស ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរ។ លទ្ធផលបានបង្ហាញថា មានស្ត្រីរកស៊ីផ្លូវភេទចំនួន១៤,៧២៥នាក់ ធ្វើការនៅក្នុងផ្ទះបននៅទូទាំង២២ ខេត្ត-ក្រុង ហើយក្នុងនោះចំនួនក្មេងដែលមានអាយុក្រោម១៨នាក់ មានចំនួន ២,២១៩នាក់ និងចំនួនក្មេងដែលមានអាយុចាប់ពី៩ ដល់១៥ឆ្នាំ[១៤] មានចំនួន១,២១២នាក់។ តួលេខទាំងនេះត្រូវបានទទួលយកដោយមិនមានការប៉ាន់ស្មានច្បាស់លាស់ ព្រោះមានការលំបាកក្នុងការប្រមូលទិន្នន័យជាក់លាក់។ ទោះបីជាយ៉ាងណាក៏ដោយ គេបានទទួលស្គាល់ថា ការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរមានការកើនឡើងជាពិសេសក្នុងចំណោមកុមារ។

នៅក្នុងឆ្នាំ ២០០១ អង្គការទស្សនៈពិភពលោក បានធ្វើការសិក្សាមួយស្តីពីបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេស[១៥]។ របាយការណ៍នេះ បានសន្និដ្ឋានថាដោយសារប្រទេសចាប់ផ្តើមបើកទ្វារចំហនៅក្នុងឆ្នាំ ១៩៩៧-១៩៩៨ លំហូរចូលនៃភ្ញៀវទេសចរបានកើនឡើងយ៉ាងខ្លាំង ហើយដោយសារតែប្រការនេះទេសចរណ៍ផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក៏កើនឡើងផងដែរជាពិសេសនៅក្នុងតំបន់ទេសចរណ៍សំខាន់ៗទាំង៣ នៅក្នុងប្រទេស ។

ដោយយោងទៅតាមក្រសួងកិច្ចការនារី និងអតីតយុទ្ធជន គេបានប៉ាន់ប្រមាណថាចំនួនស្ត្រី និងកុមារ ដែលត្រូវបានជួញដូរឱ្យធ្វើអំពើពេស្យាចារកំពុងកើនឡើង។ ការអង្កេតបានបង្ហាញថាស្ត្រីរកស៊ីផ្លូវភេទប្រមាណជា ៥០% ទៅ ៦៥% ត្រូវបានគេលក់ដូរ ហើយក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទទាំងនេះ កុមារដែលមានអាយុក្រោម ១៨ឆ្នាំ មានចំនួន ៣៥% ។ នៅពេលបច្ចុប្បន្ន ភស្តុតាងបានបង្ហាញថា កុមារ (អាយុក្រោម ១៨ឆ្នាំ) និងស្ត្រីវ័យក្មេង (១៨-២៤ឆ្នាំ) កំពុងត្រូវបានគេជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍ថែមទាំងបានបង្ហាញទៀតថា ប្រទេសកម្ពុជា គឺជាគោលដៅនៃទេសចរណ៍ផ្លូវភេទលើកុមារ ហើយក្រសួងកិច្ចការនារីក៏បានកត់ចំណាំផងដែរថា ប្រទេសកម្ពុជាត្រូវបានចុះផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ដែលបង្ហាញជាលំអិតពីរបៀបដែលបណ្តាញជួញដូរកុមារ និងជនល្មើសលើកុមារអាចរំលោភបំពានលើកុមារបានដោយមិនមានទោស (ការវាយតម្លៃ TSEC របាយការណ៍ចុងក្រោយថ្ងៃ ២៥ កុម្ភៈ ២០០៥)។

---

[១៤] ដកស្រង់ចេញពីផែនការជាតិ ៥ ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (២០០០-២០០៤) ទំព័រលេខ ៤

[១៥] ទេសចរណ៍ផ្លូវភេទលើកុមារ - បញ្ហាដែលមាននៅក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកក្នុងកិច្ចសហការជាមួយក្រសួង ទេសចរណ៍ និង CNCC ឆ្នាំ ២០០១ ។

នៅក្នុងប្រទេសកម្ពុជា ស្ត្រី និងកុមារ ត្រូវបានជួញដូរពីតំបន់ជនបទទៅតំបន់ទីក្រុង ជាពិសេសក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ ទោះជាមិនមានរបាយការណ៍ច្បាស់លាស់ស្តីពីការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចកម្លាំងពលកម្មក៏ដោយក៏គេរំពឹងថាវានឹងកើតឡើង ព្រោះគ្រួសារក្រីក្រដែលស្វែងរកគ្រប់មធ្យោបាយ ដើម្បីរកប្រាក់ចំណូលមានភាពងាយទទួលរងគ្រោះខ្ពស់។ អ្នកដែលត្រូវបានគេជួញដូរភាគច្រើនជឿថា ខ្លួននឹងត្រូវបាននាំមកកាន់តំបន់ទីក្រុងដើម្បីរកការងារស្របច្បាប់ដូចជាធ្វើជាអ្នកបម្រើតាមផ្ទះជាដើម ។ ជាអកុសល ជនរងគ្រោះទាំងនេះត្រូវបានគេបោកប្រាស់ហើយមួយចំនួនត្រូវបានគេចាប់ជំរិត និងបង្ខំឱ្យក្លាយជាទាសករផ្លូវភេទរស់នៅក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងពីម្ចាស់បន។ គេបានរាយការណ៍ថា មានស្ត្រី ក្មេងប្រុស និងក្មេងស្រីជនជាតិវៀតណាមជាច្រើននាក់ ក៏ត្រូវបានគេជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងប្រទេសកម្ពុជាផងដែរ។

ការជួញដូរឆ្លងកាត់ព្រំដែនក៏មានលក្ខណៈធ្ងន់ធ្ងរផងដែរ។ ប្រជាជនកម្ពុជាត្រូវបានជួញដូរទៅកាន់ប្រទេសថៃ និងទៅកាន់ប្រទេសឆ្ងាយៗផ្សេងទៀតមានដូចជា ប្រទេសម៉ាឡេស៊ី ម៉ាកាវ និងប្រទេសតៃវ៉ាន់។ ស្ត្រី និងក្មេងស្រីត្រូវបានគេជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ ឬឱ្យធ្វើជាអ្នកបម្រើការងារតាមផ្ទះ។ កុមារធ្វើជាអ្នកសុំទាន និង/ឬ លក់ឥវ៉ាន់តាមដងផ្លូវ ហើយបុរសធ្វើជាអ្នកនេសាទ ឬធ្វើការងារសំណង់។ ស្ត្រី បុរស និងកុមារក៏ត្រូវបានជួញដូរក្នុងទម្រង់នៃការបង្ខំ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្មផ្សេងៗ រួមមានដូចជា ធ្វើការក្នុងផ្នែកសិប្បកម្មមិនរៀបរយ និងធ្វើការងារនៅតាមចំការ។ លក្ខណៈវិនិច្ឆ័យទូទៅនៃការជួញដូរ ក្នុងទម្រង់នៃការបង្ខំ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម រួមមានដូចជាស្ថានភាពដែលទទួលបានការទូទាត់តិចតួច ឬមិនបានទទួលការទូទាត់ ការជំពាក់បំណុល ការសន្យាក្លែងបន្លំចំពោះប្រាក់បៀវត្ស និងល័ក្ខខ័ណ្ឌការងារដែលមិនបានដឹងមុន ការដាក់ទណ្ឌកម្ម ឬទារុណកម្មលើរាងកាយ ម៉ោងធ្វើការច្រើនរំលោភផ្លូវភេទ កាត់ប្រាក់ខែដោយសារមូលហេតុផ្សេងៗ និងមិនមានការគ្រប់គ្រងលើជីវិតប្រចាំថ្ងៃ (ដូចជាមិនអាចចាកចេញពីកន្លែងធ្វើការបាន)។ ពេលខ្លះបុគ្គលិកត្រូវបានបង្ខំឱ្យប្រើប្រាស់គ្រឿងញៀន ដើម្បីធ្វើការច្រើនម៉ោង ក្នុងគោលបំណងទទួលបាននូវផលិតផលច្រើន[១៦] ។

ដោយសារមិនដឹងច្បាស់ពីចំនួនកុមារ ដែលស្ថិតក្នុងការកេងប្រវ័ញ្ចផ្លូវភេទ និងដោយយោងទៅតាមអនុសញ្ញាការងារអន្តរជាតិលេខ ១៨២ អំពើពេស្យាចារលើកុមារ គឺជាទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់។ កុមារដែលមានអាយុក្រោម១៨ឆ្នាំ ត្រូវតែដកហូតចេញពីការធ្វើពេស្យាចារ ហើយមនុស្សគ្រប់គ្នាត្រូវចេះទទួលខុសត្រូវរួមទាំងភ្ញៀវ ឪពុកម្តាយ និយោជក និងអ្នកផ្សេងទៀតត្រូវតែដាក់ទណ្ឌកម្ម។ ក្នុងការចាត់វិធានការបន្ទាន់ដើម្បីលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរបំផុតនេះ វាមានសារៈសំខាន់ណាស់ដែលថាកុមារដែលពាក់ព័ន្ធនឹងអំពើពេស្យាចារ

[១៦] របាយការណ៍ប្រទេសកម្ពុជា ការពិគ្រោះយោបល់អន្តរក្រសួងថ្នាក់អនុតំបន់ស្តីពីការជួញដូរមនុស្ស ខែ ឧសភា ឆ្នាំ ២០០៥

ត្រូវចាត់ទុកថាជាជនរងគ្រោះហើយមិនត្រូវដាក់ទោសអ្វីទាំងអស់។ សម្រាប់អ្នកដែលមានអាយុលើសពី១៨ឆ្នាំ រដ្ឋត្រូវប្ដេជ្ញាប្រឆាំងនឹងទម្រង់នៃការធ្វើការងារដោយបង្ខំ ទោះបីជាការបង្ខំនោះមានលក្ខណៈស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយ ។

ជារួម គេទទួលស្គាល់ថា មូលហេតុនៃការជួញដូរ និងពលកម្មកុមារគឺកើតឡើងដោយសារតែភាពក្រីក្រនៅតាមតំបន់ជនបទព្រមជាមួយនឹងការរីកចម្រើននៅតាមតំបន់ទីក្រុងទាំងនៅក្នុងប្រទេស និងនៅក្នុងប្រទេសជិតខាង។ នេះគឺជាកត្តាចម្បងធំៗ ២ ដែលបង្កឱ្យមានការបម្លាស់ទី (អាចធ្វើតាមឆន្ទៈរបស់ខ្លួនផ្ទាល់ និង/ឬតាមរយៈការសន្យាផ្ដល់ការងារពីសំណាក់អ្នកជ្រើសរើស និងអ្នកជួញដូរ) ពីតំបន់ជនបទ (ទោះបីជាយ៉ាងណាក៏ដោយ អ្នកដែលរស់នៅតាមតំបន់ទីក្រុងក៏អាចផ្លាស់ទីទៅកាន់ទីក្រុងដទៃទៀតដែលមានការអភិវឌ្ឍន៍ ជាពិសេសផ្លាស់ទីទៅកាន់ប្រទេសជិតខាង)។ កត្តាចម្បងផ្សេងទៀតក៏ត្រូវបានលើកឡើងផងដែរ ដែលអាចរួមចំណែកដល់ការកើតឡើងនូវបាតុភាពទាំងនេះ ។

### *គ. កន្លែងដែលឃើញមានការជួញដូរកុមារ និងស្ត្រី*

ការជួញដូរ ជារឿយៗទាក់ទងនឹងបណ្ដាញនៃមនុស្សដែលធ្វើការជាមួយគ្នាក្នុងការស្វែងរក បញ្ជូន និងផ្ទេរ/ទទួល ឬផ្ដល់ទីស្នាក់នៅដល់ជនរងគ្រោះដោយសារការជួញដូរ។

ពិធីសាររបស់អង្គការសហប្រជាជាតិបានហៅមនុស្សទាំងនេះថាជាជនរងគ្រោះពីការជួញដូរ ប្រសិនបើពួកគេត្រូវបានគេប្រើល្បិច បង្ខំ ឬកេងយកផលប្រយោជន៍ក្នុងកំឡុងដំណាក់កាលណាមួយក្នុងចំណោមដំណាក់កាលទាំងបីនៃការធ្វើដំណើររបស់ពួកគេ :

- នៅខណៈនៃ **ការជ្រើសរើស**
- ក្នុងខណៈនៃ **ការបញ្ជូន** ឬ
- នៅពេលដែលពួកគេ **មកដល់** គោលដៅរបស់ខ្លួន

### ការជ្រើសរើស

មនុស្សភាគច្រើនដែលក្លាយជាជនរងគ្រោះដោយសារការជួញដូរ កើតឡើងនៅពេលពួកគេចាកចេញពីភូមិរបស់ពួកគេជាមួយនរណាម្នាក់ដែលពួកគេ ឬគ្រួសាររបស់ពួកគេស្គាល់។ ហេតុផលដ៏សាមញ្ញបំផុតសម្រាប់ការចាកចេញគឺ

ដើម្បីរកប្រាក់សម្រាប់ទ្រទ្រង់គ្រួសារ ឬសម្រាប់សងបំណុលរបស់គ្រួសារខ្លួន[១៧]។ ការចាកចេញពីភូមិរបៀបនេះគឺជារឿយៗ ជាការសម្រេចចិត្តបែបមនសិការមួយធ្វើឡើងដោយជនរងគ្រោះខ្លួនឯង ឬដោយឪពុកម្ដាយ ឬអាណាព្យាបាលរបស់ពួកគេ។ ទោះបីជាយ៉ាងណាត្រូវចាំថាទោះជាបុគ្គលនោះចាកចេញដោយស្ម័គ្រចិត្ត ឬដោយបង្ខំក៏ដោយ ក៏ពួកគេជាជនរងគ្រោះពីការជួញដូរដែរ ប្រសិនបើពួកគេបានជួបប្រទះនូវល័ក្ខខ័ណ្ឌ ដែលមាននៅក្នុងពិធីសាររបស់អង្គការសហប្រជាជាតិ។

កុមារត្រូវបានចាត់ទុកថាជាជនរងគ្រោះដោយសារការជួញដូរ ទោះបីជាពួកគេមិនត្រូវបានគំរាមកំហែង បង្ខិតបង្ខំ ចាប់ពង្រត់ ឆបោក លក់ ឬជួលក៏ដោយ។ នេះមានន័យថា នៅក្នុងក្រសែភ្នែកផ្នែកច្បាប់កុមារមិនអាចយល់ព្រមចំពោះការជួញដូរឡើយ ។

នៅទីកន្លែងដូចជា ប៉ោយប៉ែត ដែលជាទីកន្លែងសម្រាប់នាំក្មេងទៅកាន់ប្រទេសថៃ គឺជាកន្លែងទូទៅមួយដែលវាត្រូវបានគេដឹងយ៉ាងទូលំទូលាយដោយអ្នកភូមិថាស្ត្រី និងក្មេងនឹងត្រូវបាននាំដោយមេខ្យល់ទៅកាន់ក្រុងបាងកក ឬកន្លែងផ្សេងទៀតនៃប្រទេសថៃ ដើម្បីធ្វើជាអ្នកសុំទាន អ្នកលក់តាមផ្លូវ កម្មករសំណង់ អ្នកលក់ កម្លាំងពលកម្មសម្រាប់ការងារកសិកម្ម អ្នកបម្រើក្នុងស្រុក ឬពេលខ្លះជាស្រីពេស្យា។

ស្ថានភាពនេះមានលក្ខណៈស្រដៀងគ្នាសម្រាប់ប្រជាជនកម្ពុជា ដែលរស់នៅខេត្តស្វាយរៀងដែលត្រូវបានគេជួញដូរទៅកាន់ទីក្រុងហូជីមិញដើម្បីសុំទាន ។ នៅឯដំណាក់កាលនៃការជ្រើសរើស សមាជិកគ្រួសារនៃជនទាំងនេះ គឺជាទូទៅដឹងថា ពួកគេកំពុងជួលកូនរបស់ពួកគាត់ ឬសមាជិកគ្រួសារផ្សេងទៀតដែលងាយទទួលរងគ្រោះ ដូចជាមនុស្សចាស់ ឬជនពិការសម្រាប់ការសុំទាន ឬការលក់សន្លឹកឆ្នោត។ នេះសបញ្ជាក់ថាសមាជិកគ្រួសារបានចូលរួមក្នុងសកម្មភាពនៃការជួញដូរ ។

គ្រួសារទាំងនោះជាទូទៅមិនដឹងថានោះគឺជាការជួញដូរឡើយ។ ពួកគេគិតថាវាគឺសាមញ្ញដូចទៅនឹងមធ្យោបាយនៃការរស់នៅផ្សេងៗទៀត និងខុសគ្នាតិចតួចពីការជួលកូន ឬសមាជិកគ្រួសារផ្សេង ដើម្បីមើលក្របីក្នុងវាលស្រែ ឬលើកទំនិញឆ្លងកាត់ព្រំដែន។ ចំណែកឯក្នុងគំនិតរបស់ជនរងគ្រោះវិញ ការគិតគួរសំខាន់បំផុតនោះគឺហាក់ដូចជាអារម្មណ៍របស់ពួកគេចំពោះកាតព្វកិច្ច ក្នុងការជួយគ្រួសារពួកគេដែលក្រីក្រ ឬជំពាក់បំណុល[១៨]។

---

[១៧] អង្គការ IOM (2004a) របាយការណ៍ទិន្នន័យមូលដ្ឋានស្ដីពីកុមារដែលត្រូវបានជួញដូរពីប្រទេសកម្ពុជាទៅប្រទេសថៃ-អង្គការ IOM ប្រទេសថៃទំព័រ១០។ អង្គការ IOM (2004b) ការប៉ាន់ប្រមាណពីតម្រូវការ និងការវិភាគស្ថានភាពរបស់ជននិប្រវេសន៍ និងការជួញដូរពីខេត្តស្វាយរៀងនៃប្រទេសកម្ពុជា ទៅកាន់ប្រទេសវៀតណាម ដើម្បីសុំទាន-អង្គការ IOM ភ្នំពេញ ទំព័រ ១៦។

[១៨] Margallo, S and Lath, P (2002) ការពិនិត្យឡើងវិញ និងការវាយតម្លៃស្ថានភាពរបស់កុមារ និងស្ត្រីកម្ពុជាដែលជាជនរងគ្រោះដោយការជួញដូរ ធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ និង ការផ្ដល់ជំនួយសមាហរណកម្មទាន់ទាដល់ជនរងគ្រោះទាំងនេះនៅក្នុងប្រទេសកម្ពុជា-អង្គការ IOM

គេបានរាយការណ៍យ៉ាងទូលំទូលាយថាស្ត្រី និងកុមារដែលត្រូវបានជួញដូរទៅក្នុងអាជីវកម្មផ្លូវភេទ គឺជារឿយៗត្រូវបានល្បួងដោយអ្នកជួញដូរ ឬអ្នកជ្រើសរើសមនុស្ស[១៩] ជាមួយការសន្យាផ្ដល់ការងារដែលមានប្រាក់ចំណូលខ្ពស់ក្នុងទីក្រុងនៅប្រទេសផ្សេង លុយ ឬសំភារៈទំនើបៗផ្សេងៗ ។ ការបោកប្រាស់មិនមែនមានតែនៅក្នុងដំណាក់កាលនៃការជ្រើសរើសនោះទេ ។ ម្ដាយ មិត្តប្រុស ប្ដី និងសមាជិកគ្រួសារផ្សេងទៀត ពេលខ្លះជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការលក់ស្ត្រី និងកុមារទៅកាន់បនស្រីពេស្យាតែម្ដង ។

មានករណីតិចតួចដែលស្ត្រី និងកុមារយល់ព្រមមកជាមួយអ្នកជួញដូរ ព្រោះពួកគេមានទំនាស់ក្នុងគ្រួសារ ឬព្រោះពួកគេត្រូវបានអូសទាញដោយសារភាពសប្បាយរបស់ទីក្រុង ។ ការចាប់ពង្រត់ ឬការបង្ខំដោយប្រើកម្លាំងប្រដាប់អាវុធកម្រឃើញគេរាយការណ៍ណាស់[២០] ។

ស្ត្រី និងក្មេងស្រីត្រូវបាននាំមកពីប្រទេសវៀតណាមផងដែរ ហើយត្រូវបានបញ្ជូនមកកាន់ប្រទេសកម្ពុជាគោលដៅចំបងដើម្បីធ្វើស្រីពេស្យាចារ ។ ស្ថានការណ៍នៃការនាំមនុស្សស្រដៀងគ្នាទៅនឹងស្ថានការណ៍ នៃការជួញដូរប្រជាជនកម្ពុជាដែរ ។ ករណីជាច្រើនគ្រួសាររបស់ពួកគេគឺពាក់ព័ន្ធក្នុងការសម្រេចចិត្តចំពោះការចាកចេញ ។ មូលហេតុចំបងគឺសម្រាប់ការរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ឬសងបំណុលគ្រួសារ ។ មានករណីតិចតួចដែលពួកគេត្រូវបានបោកបញ្ឆោត ចាញ់ល្បិចគេទុកឱ្យនៅក្នុងស្ថានភាពដែលពោរពេញទៅដោយជម្លោះ ឬត្រូវបានបង្ខំ ឱ្យចាកចេញដោយប្រើកម្លាំងប្រដាប់អាវុធ[២១] ។

## ការបញ្ជូន

ប្រសិនបើបុគ្គលម្នាក់ ត្រូវបានគំរាមកំហែង បង្ខំ ឆបោក ឬលក់ដូរក្នុងកំឡុងពេលនៃការបញ្ជូនទៅកាន់គោលដៅមួយឆ្ងាយពីភូមិរបស់ខ្លួន បុគ្គលនោះអាចត្រូវបានគេចាត់ទុកថាជាជនរងគ្រោះដោយការជួញដូរ ។ ពេលខ្លះជនរងគ្រោះដោយការជួញដូរអាចធ្វើដំណើរពីផ្ទះទៅកាន់គោលដៅរបស់ពួកគេជាមួយនឹងអ្នកជួញដូរ ឬអ្នកសម្របសម្រួលតែម្នាក់ ។ ជនរងគ្រោះខ្លះត្រូវបានបញ្ជូនតាមរយៈមនុស្សច្រើននាក់ ក្នុងកំឡុងពេលនៃការជួញដូរ ។ ពេលខ្លះទម្រង់ធម្មតានៃ

---

ភ្នំពេញ ។ Beesey (2003) ផ្លូវត្រលប់មកផ្ទះវិញ ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មស្ត្រី និងកុមារជនជាតិវៀតណាម ពីអាជីវកម្មផ្លូវភេទនៅក្នុងប្រទេសកម្ពុជា អង្គការ IOM បាងកក ។

[១៩] Hudd (2003) លក់ដូរដូចសត្វមាន់: សំលេងរបស់កុមារីកម្ពុជាដែលត្រូវបានគេជួញដូរ-អង្គការ COSECAM, Cambodia; Beesay, (2003)

[២០] IOM & MOWVA (2004) ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន យុទ្ធនាការផ្សព្វផ្សាយព័ត៌មានប្រឆាំងនឹងការជួញដូរ-ការវិភាគពីខេត្ត ចំនួន ៦: លទ្ធផល និងអនុសាសន៍ចំបងៗ អង្គការ IOM ភ្នំពេញ

[២១] Beesey (2003)

ការបញ្ជូនដូចជារថយន្តក្រុង ឬរថយន្តឈ្នួល ម៉ូតូឌុបក្នុងតំបន់ត្រូវបានប្រើប្រាស់។ ពេលខ្លះការដឹកជញ្ជូនត្រូវបានរៀបចំឡើងជាពិសេសពីសំណាក់អ្នកជួញដូរ ។

ព្រំដែនអន្តរជាតិកម្ពុជាមានចន្លោះប្រហោងច្រើនណាស់។ ជនរងគ្រោះនៃការជួញដូរភាគច្រើនដែលធ្វើដំណើរ ពីខេត្តស្វាយរៀងទៅកាន់ទីក្រុងហូជីមិញនៃប្រទេសវៀតណាម ត្រូវបានដឹកជញ្ជូនតាមផ្លូវថ្នល់ដែលគេចពីការឆ្លងតាមបែបផ្លូវការជាលក្ខណៈអន្តរជាតិ។ ពួកគេត្រូវបានដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយការប្រើនូវផ្លូវក្នុងស្រុកមួយក្នុងចំណោមផ្លូវជាច្រើន ឬដោយការឆ្លងកាត់តាមវាលស្រែ[២២] ។ ចំណែកឯនៅខាងព្រំដែនភាគីវៀតណាម គេបានរាយការណ៍ថាមានការធ្វើដំណើរដោយម៉ូតូ និងដោយរថយន្តក្រុង ។

ព្រំដែនឆ្លងកាត់ចំបងពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃនៅប៉ោយប៉ែតគឺជាកន្លែងដែលមមាញឹកបំផុត។ ជនជាតិកម្ពុជារួមបញ្ចូលទាំងអ្នកដែលត្រូវបានជួញដូរ អាចឆ្លងព្រំដែនដោយចំហជាមួយនឹងការរត់ឯកសារតែតម្លៃ ១០បាត តែប៉ុណ្ណោះ។ ជនរងគ្រោះផ្សេងទៀតរាយការណ៍ថាឆ្លងកាត់ព្រំដែនដោយថ្មើរជើង ដោយការប្រើផ្លូវលំដែលឆ្លងកាត់ព្រំដែនទាំងផ្លូវដែលនៅក្បែរច្រកព្រំដែនផ្លូវការ ឬខ្លះនៅឆ្ងាយពីច្រកព្រំដែនច្រើនគីឡូម៉ែត្រ។ ជនរងគ្រោះពីការជួញដូរដែលបានវិលត្រឡប់មកវិញនិយាយថាការឆ្លងព្រំដែន គឺធ្វើឡើងដោយសម្ងាត់ គឺត្រូវបានគេបិទមុខជិត។ ក្នុងគ្រប់ករណីទម្រង់នៃការបញ្ជូនខ្លះ គឺត្រូវបានគេរាយការណ៍ថា កំពុងរង់ចាំពួកគេនៅឯព្រំដែនម្ខាងទៀត ។

ក្នុងប្រទេសកម្ពុជា ជនរងគ្រោះដោយសារការជួញដូរភាគច្រើនធ្វើដំណើរដោយមធ្យោបាយធម្មតាតាមរថយន្តក្រុង រថយន្តឈ្នួល ឬម៉ូតូឌុប។ នៅឯដំណាក់កាលនៃការបញ្ជូន ជនរងគ្រោះពីការជួញដូរ គឺរៀបចំឱ្យចាកចេញទៅកាន់កន្លែងផ្សេង ដែលពួកគេអាចមិនមែនជាជនរងគ្រោះដោយការជួញដូរ។ ទោះជាយ៉ាងណាក៏មានភស្តុតាងបញ្ជាក់ថាអ្នកម៉ូតូឌុប និងអ្នករត់រថយន្តឈ្នួល ក៏អាចដើរតួជាអ្នកជ្រើសរើសមនុស្សផងដែរ ។

## គោលដៅ (ការទៅដល់)

គោលដៅលេចឡើងជាទីកន្លែងដែលបុគ្គលភាគច្រើន ត្រូវបានគេបោកប្រាស់ និងក្លាយទៅជាជនរងគ្រោះដោយសារការជួញដូរ។ នោះគឺមានន័យថាបុគ្គលដែលបានចាកចេញពីផ្ទះរបស់ខ្លួន ក្នុងនាមជាជននិរប្រវេសន៍ដោយសង្ឃឹមថានឹងបានស្វែងរកការងារ ប៉ុន្តែបែរជាត្រូវស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ចនៅទីកន្លែង ដែលពួកគេបានធ្វើដំណើរទៅកាន់ទីនោះ។ ការរាយការណ៍ពីការប្រព្រឹត្តអំពើអាក្រក់ នៅឯទីកន្លែងគោលដៅដូចជា ការវាយដំ ការគំរាមកំហែង ការបង្អត់

[២២] អង្គការ IOM (2004d) ទិន្នន័យស្រាវជ្រាវនៅខេត្តស្វាយរៀងដែលមិនទាន់បានបោះពុម្ព។ គម្រោងស្ដីពីការផ្ដល់ជំនួយស្មារតីតិសម្បទា និងធ្វើសមាហរណកម្មវយៈពេលដល់កុមារ និងស្ត្រីដែលត្រូវបានគេជួញដូរ។

អាហារ ការបង្ខំឱ្យរួមភេទ និងការឃ្លាំមើលឥតដាច់ ត្រូវបានរាយការណ៍ដោយជនរងគ្រោះពីការជួញដូរជាច្រើនរូបរួមមានដូចជា អ្នកសុំទាន ស្រីពេស្យា អ្នកលក់តាមផ្លូវ និងអ្នកបម្រើតាមផ្ទះ ។

វាអាចជាការពិបាក ដើម្បីវែកញែករវាងអ្នកដែលស្ម័គ្រចិត្ត និងអ្នកដែលត្រូវបានគេបង្ខំ ឬឆបោក។ ពេលខ្លះពួកគេបញ្ចប់ក្នុងទីកន្លែងតែមួយ ជាមួយនឹងស្ថានភាពការងារ និងរស់នៅដូចគ្នា។

នៅផ្ទះបនស្រីពេស្យាក្នុងប្រទេសកម្ពុជា ក្មេងស្រី និងស្ត្រីជាច្រើនធ្លាក់ចូលទៅក្នុងទាសភាពបំណុលចំពោះម្ចាស់បន។ ប្រការនេះអាចកើតឡើងទាំងចំពោះអ្នកដែលត្រូវបានគេជួញដូរ និងស្ត្រីដែលមកធ្វើការនៅក្នុងផ្ទះបនដោយស្ម័គ្រចិត្ត ។

### *ឃ. ហេតុអ្វីបានជាកុមារ និងស្ត្រីរងគ្រោះដោយការជួញដូរ តែងតែត្រូវបានគេរំលោភសិទ្ធិរបស់ខ្លួន*

វាចាំបាច់ណាស់ដែលត្រូវចងចាំថា ក្នុងករណីជាកុមារ (បុគ្គលក្រោមអាយុ១៨ឆ្នាំ យោងទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិរបស់កុមារ) ដែលត្រូវបានគេជ្រើសរើស បញ្ជូន ផ្ទេរ ផ្តល់ទីជំរក ឬទទួលក្នុងគោលបំណងនៃការកេងប្រវ័ញ្ចនឹងតែងតែត្រូវបានចាត់ទុកថាជា " ជនរងគ្រោះដោយសារការជួញដូរ " ។

ដូចដែលបានលើកឡើងខាងលើ កុមារនឹងត្រូវបានចាត់ទុកថាជាជនរងគ្រោះ សូម្បីតែពួកគេមិនត្រូវបានគេគំរាមកំហែង បង្ខំ ឆបោក លក់ ឬជួល។ នេះមានន័យថានៅក្នុងក្រសែភ្នែកផ្នែកច្បាប់ កុមារមិនអាចយល់ព្រមចំពោះការជួញដូរឡើយ ។

ស្ថានភាពចុងក្រោយ បុគ្គលដែលរងការជួញដូរ អាចទទួលរងការឈឺចាប់ ដែលពាក់ព័ន្ធដូចខាងក្រោម:

- បុគ្គលនោះ អាចត្រូវបានកេងប្រវ័ញ្ច ដោយអំពើពេស្យាចារដោយបង្ខំ
- បុគ្គលនោះ អាចត្រូវបានកេងប្រវ័ញ្ចទាំងរាងកាយ និងផ្លូវភេទ
- បុគ្គលនោះ អាចត្រូវបានបង្ខំឱ្យអនុវត្តការប្រើកម្លាំង ឬសេវាកម្មផ្សេងទៀត ជារឿយៗទាក់ទងនឹងទាសភាពបំណុល និងល័ក្ខខ័ណ្ឌការងារគ្មានមនុស្សធម៌

### *ង. កត្តាជំរុញ និង កត្តាអូសទាញដែលនាំឱ្យមានការជួញដូរកុមារ និងស្ត្រី[២៣]*

កត្តាដែលជំរុញឱ្យមានបាតុភាពនៃការជួញដូរបានលើកឡើងជាលំអិតនៅក្នុងការសិក្សាឆ្នាំ២០០៣នៃកិច្ចសហការតំបន់អាស៊ីដើម្បីទប់ស្កាត់ការជួញដូរមនុស្សក្រោមចំណងជើងថា "យេនឌ័រ ការជួញដូរមនុស្ស និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

[២៣] ផ្នែកនេះ ដកស្រង់ចេញពីឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៦-២០០៨ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្មទៅលើកុមារ និងស្ត្រីវ័យក្មេង នៅក្នុងប្រទេសកម្ពុជាទំព័រ៦-៨

នៅក្នុងប្រទេសកម្ពុជា" ។ កត្តាដែលបានលើកឡើង ត្រូវបានបែងចែកជា២ ផ្នែក គឺផ្នែក "ផ្គត់ផ្គង់" និង ផ្នែក "តម្រូវការ" នៃការជួញដូរ ។

របាយការណ៍នេះ បានលើកឡើងនូវកត្តាចំនួន១០ ដែលបង្កឱ្យមានការជួញដូរមនុស្ស ឬងាយទទួលរងគ្រោះចំពោះការជួញដូរ។ កត្តាទាំងនេះមានដូចខាងក្រោម:

- *វិសមភាពផ្នែកសេដ្ឋកិច្ច* នៅក្នុង និងនៅក្រៅប្រទេស: ប្រការនេះគឺធ្វើឱ្យមនុស្សមានបំណងធ្វើនិរប្រវេសន៍ដើម្បីរកឱកាសការងារដែលប្រសើរជាងនេះ ដោយធ្វើដំណើរទៅតំបន់ជាយក្រុងនៅក្នុងប្រទេសនិង/ឬធ្វើដំណើរឆ្លងព្រំដែនទៅកាន់ប្រទេសជិតខាង ព្រោះយល់ឃើញថាមានឱកាសច្រើនជាងនៅក្នុងប្រទេសរបស់ខ្លួន។
- *ភាពក្រីក្រ:* ភាពក្រីក្រគឺជាបញ្ហារីករាលដាលទូទៅមួយនៅក្នុងប្រទេស និងនៅតាមតំបន់ជនបទ។ ស្ថានភាពនេះបង្កឱ្យមានការស្រាវជ្រាវរកឱកាសប្រសើរជាងនេះជាអចិន្ត្រៃយ៍ (ដោយធ្វើនិរប្រវេសន៍ទៅកាន់តំបន់ផ្សេងទៀតដោយយល់ឃើញថាមានឱកាសរកប្រាក់ចំណូល/ប្រកបរបរចិញ្ចឹមជីវិតបានប្រសើរ) ឬដោយបណ្តោះអាសន្ន (ក្នុងរដូវប្រាំង- ពេលដែលមិនអាចពឹងផ្អែកលើវិស័យកសិកម្មដើម្បីរកប្រាក់ចំណូលបាន) ។
- *ខ្វះខាតការទទួលស្គាល់ក្នុងចំណោមក្រុមជនជាតិ:* មនុស្សទាំងនេះជាទូទៅមិនមានឯកសារច្បាប់គ្រប់គ្រាន់ ហើយតែងតែជួបនឹងភាពអយុត្តិធម៌ក្នុងទម្រង់នៃការប្លន់យកដីធ្លីការរំលោភបំពានដីកើ្តតំណែល (ដែលប្រើធ្វើជាកន្លែងស្នាក់នៅ និងធ្វើជាប្រភពធនធានសម្រាប់ប្រកបរបរចិញ្ចឹមជីវិត) ការរើសអើងផ្នែកការងារ ។ល។ លទ្ធផលគឺបង្កឱ្យមានការបម្លាស់ទី/ការធ្វើនិរប្រវេសន៍ជាប្រចាំ ទៅកាន់តំបន់នានានៅក្នុងប្រទេសកម្ពុជា និងទៅកាន់ប្រទេសជិតខាង ។
- *កង្វះខាតឱកាសការងារស្របច្បាប់:* ស្ថានភាពនេះកើតឡើងជាទូទៅនៅតាមសហគមន៍ជនបទ ដែលបង្កឱ្យមានការបម្លាស់ទីទៅកាន់តំបន់ទីក្រុងដើម្បីរកឱកាសការងារដែលប្រសើរ ។
- *កង្វះខាតសន្តិសុខផ្នែកសេដ្ឋកិច្ច:* ភាគច្រើនកើតឡើងចំពោះក្រុមគ្រួសារដែលមានស្ត្រីជាមេគ្រួសារតែម្នាក់ឯងជាហេតុបង្កឱ្យមានការធ្វើនិរប្រវេសន៍ និងប្រឈមមុខចំពោះការធ្វើអាជីវកម្មផ្លូវភេទ ។
- *ស្ថានភាពគ្រួសារ:* រួមទាំងស្ថានភាពនៃការប្រើអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពាន
- *ឥរិយាបទសង្គម:* រួមទាំងឥរិយាបទផ្សេងគ្នារវាងក្មេងប្រុស និងក្មេងស្រី ។ នៅក្នុងសហគមន៍មួយចំនួនការឱ្យតម្លៃទាបទៅលើក្មេងស្រី បង្កឱ្យកើតមាននូវឱកាស ដែលមនុស្សស្រីវ័យក្មេងជាច្រើនដោយមានការអប់រំទាបចេញរកប្រាក់បានយ៉ាងច្រើនដោយពាក់ព័ន្ធទៅនឹងអាជីវកម្មផ្លូវភេទ។ ប្រការនេះបង្ហាញយ៉ាងជាក់ស្តែងថាការឱ្យតម្លៃទាបទៅលើក្មេងស្រី គឺជាគ្រឿងលើកទឹកចិត្តមួយដែលបង្កឱ្យមនុស្សស្រីវ័យក្មេង ជាច្រើនធ្លាក់ចូលទៅក្នុងស្ថានភាពនៃការកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ ។

- *ជម្លោះស៊ីវិល និងប្រដាប់អាវុធ:* ដែលបង្កឱ្យប្រជាជនរត់ភៀសខ្លួនពីផ្ទះសំបែង និងសហគមន៍របស់ខ្លួន ហើយជាទូទៅត្រូវធ្លាក់ចូលទៅក្នុងកណ្តាប់ដៃរបស់អ្នកជួញដូរ ។ ការបែកបាក់គ្រួសារ និងរចនាសម្ព័ន្ធសង្គមនៅក្នុងស្ថានភាពនេះកាន់តែធ្វើឱ្យបុគ្គលនីមួយៗ និងសហគមន៍ទាំងមូលងាយទទួលរងគ្រោះថ្នាក់ដោយសារការជួញដូរ ជាពិសេសស្ត្រី និងកុមារ ។
- *កង្វះខាតការទទួលបានការអប់រំ:* ដាក់កំហិតជាពិសេសដល់ស្ត្រី ដែលមិនអាចបង្កើនប្រាក់ចំណូលបាន ព្រោះមិនមានជំនាញ និងការងារប្រសើរ ។
- *កង្វះខាតព័ត៌មាន:* បង្កឱ្យមាននូវកម្រិតនៃការយល់ដឹងទាប/តិចតួច ស្តីពីគ្រោះថ្នាក់ និងស្ថានភាពពិតប្រាកដដែលមានការពាក់ព័ន្ធទៅនឹងការធ្វើការនៅក្នុងបរិស្ថានខាងក្រៅមួយ ។

ក្នុងពេលទន្ទឹមគ្នានេះ ក៏មានកត្តាមួយចំនួនដែលបានចូលរួមចំណែកដល់ការកើនឡើងនូវផ្នែក "តម្រូវការ" លើជនដែលត្រូវបានគេជួញដូរព្រមទាំងទំនិញ និងសេវាប្រកបដោយការកេងប្រវ័ញ្ច ។ កត្តាទាំងនេះ គឺជាការលើកទឹកចិត្តឱ្យមនុស្សធ្វើការបម្លាស់ទីជាទូទៅឆ្លងព្រំដែនដោយមិនស្របច្បាប់ទៅកាន់ប្រទេសជិតខាង ដើម្បីរកឱកាសការងារដែលប្រសើរជាងនេះ ។

- *តម្រូវការរបស់និយោជក និងសហគ្រាសនានាចំពោះកម្លាំងពលកម្មថោកប្រកបដោយការកេងប្រវ័ញ្ច:* ការប៉ាន់ប្រមាណកាលពីមុនបានបង្ហាញថា ប្រទេសថៃមានការងារយ៉ាងហោចណាស់ចំនួន១,៥លាននាក់ ដែលប្រជាជនថៃបដិសេធមិនធ្វើដោយសារតែការងារនោះ "មានភាពកខ្វក់ លំបាក និងគ្រោះថ្នាក់" ។ តម្រូវការការងារនេះអាចជាប្រភពទាក់ទាញដល់កម្មករនៅតាមប្រទេសជិតខាង ព្រោះប្រទេសជិតខាងមិនសូវមានយន្តការផ្តល់ការការពារដល់កម្មករនិរប្រវេសន៍ ។ កង្វះខាតការគោរពសិទ្ធិមនុស្សរបស់កម្មករនិរប្រវេសន៍ បានបង្កឱ្យមានភាពងាយទទួលរងគ្រោះកាន់តែខ្លាំង និងបង្កឱ្យមានការជួញដូរកាន់តែកើនឡើង ។ ខណៈពេលដែលកម្មករនិប្រវេសន៍ទាំងអស់កំពុងប្រឈមមុខនឹងគ្រោះថ្នាក់ស្ត្រីដែលធ្វើនិរប្រវេសន៍ដើម្បីរកការងារ (ធ្វើការជាអ្នកបម្រើតាមផ្ទះ និងធ្វើការនៅតាមកន្លែងកំសាន្តសប្បាយ) បានទទួលរងនូវការឱ្យតម្លៃខ្លួនទាប និងទទួលរងនូវភាពងាយរងគ្រោះថ្នាក់ដែលមិនអាចមើលឃើញ ។
- *យន្តការ និងវិធានការអនុវត្តច្បាប់នៅទន់ខ្សោយ:* ក្នុងការស៊ើបអង្កេត ការឃាត់ខ្លួន ការកាត់ទោស និងការដាក់ទណ្ឌកម្មដល់ជនល្មើស ។ ទោះបីជាមានយន្តការនៅនឹងកន្លែងក៏ដោយ ក៏កម្រិតនៃការយល់ដឹងទាបរបស់មន្ត្រីនានាអាចបង្កឱ្យមានបទព្រហ្មទណ្ឌ ស្តីពីការជួញដូរជនរងគ្រោះផងដែរ ជាពិសេសការជួញដូរស្ត្រី និងកុមារ ។ ជាទូទៅជនរងគ្រោះត្រូវបានគេចោទប្រកាន់ថា ចូលទៅកាន់ប្រទេសដទៃដោយគ្មានច្បាប់ ឬប្រព្រឹត្តិអំពើពេស្យាចារខុសច្បាប់ ។ បន្ថែមលើនេះទៀតការឃុបឃិតរវាងអ្នកជួញដូរនិងមន្ត្រីនានាក៏អាចបង្កឱ្យមានការជួញដូរជនរងគ្រោះ

ឆ្លងកាត់តំបន់ព្រំដែន។ អ្នកជួញដូរនឹងមកទទួលជនរងគ្រោះនៅតាមតំបន់ព្រំដែន ហើយធ្វើការជួញដូរបន្តម្តងទៀត ។

- *ឥរិយាបទរបស់សហគមន៍:* នៅចំណុចគោលដៅនៃការជួញដូរ ឥរិយាបទរើសអើងនៅក្នុងសហគមន៍ចំពោះជនអន្តោប្រវេសន៍ និងក្រុមជនជាតិភាគតិច រួមជាមួយនឹងការឱ្យតម្លៃទាបទៅលើស្ត្រី និង កុមារ ជាទូទៅតែងតែបង្កឱ្យមានការដាក់ទណ្ឌកម្មតិចតួច ឬមិនមានការដាក់ទណ្ឌកម្មចំពោះការជួញដូរ ។ ការជួញដូរក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ជាទូទៅងាយនឹងកើតឡើង ព្រោះសហគមន៍ព្រមទទួលយកនូវការ ឆ្លើយតបមិនសមស្រប ឬមិនគ្រប់គ្រាន់ពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។
- *ការពង្រីកឧស្សាហកម្មផ្លូវភេទ និងការកើនឡើងនូវតម្រូវការនៃសេវារកស៊ីផ្លូវភេទ:* ខណៈពេលដែលប្រទេសមួយចំនួនបានយល់ព្រមអត់ឱនចំពោះវត្តមាននៃអាជីវកម្មផ្លូវភេទដែលកំពុងតែមានការរីកលូតលាស់ គេឃើញមានការរើសអើង និងការមាក់ងាយទៅលើអ្នកដែលធ្វើការនៅក្នុងវិស័យឧស្សាហកម្មផ្លូវភេទ។ ឧទាហរណ៍ ស្ត្រីរកស៊ីផ្លូវភេទនៅកម្ពុជា ជាទូទៅត្រូវបានឃាត់ខ្លួនដោយក្រុមប៉ូលិស ទោះជាខ្លួនមិនបានរំលោភច្បាប់ក៏ដោយ។ ស្ថានភាពនេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរជាងនេះទៀត ព្រោះមានការវាយប្រហារទៅលើបុគ្គលដែលប្រព្រឹត្តិអំពើពេស្យាចាររួមទាំងកុមារ និងស្ត្រីជាជាងការគិតទៅលើស្ថានភាពប្រកបដោយការកេងប្រវ័ញ្ចរបស់ពួកគេ។ ស្ថិតក្នុងស្ថានភាពដែលមានការកេងប្រវ័ញ្ចខ្ពស់ ការប្រព្រឹត្តិទៅលើប្រជាជនអន្តោប្រវេសន៍មានលក្ខណៈកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត។ ជនអន្តោប្រវេសន៍ជាស្ត្រីដែលត្រូវបានប្រទះឃើញនៅក្នុងអាជីវកម្មផ្លូវភេទ ជាទូទៅតែងតែជំពាក់បំណុលគេ ឬមានបន្ទុកផ្នែកហិរញ្ញវត្ថុដែលបង្ខំឱ្យខ្លួនបម្រើភ្ញៀវជាច្រើននាក់ក្នុង១ថ្ងៃ និងពុំសូវមានឱកាសចរចារប្រើស្រោមអនាម័យជាមួយភ្ញៀវ ហើយប្រឈមមុខយ៉ាងខ្លាំងក្លាចំពោះការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគផ្សេងៗទៀត។

ការពង្រីកវិស័យឧស្សាហកម្មទេសចរណ៍ និងការកើនឡើងនូវទេសចរណ៍ផ្លូវភេទបានបង្កឱ្យមានការកើនឡើងនូវតម្រូវការផ្លូវភេទទៅលើកុមារពីសំណាក់ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ។ នៅក្នុងស្ថានភាពនេះទាំងក្មេងប្រុស និងក្មេងស្រីមានសភាពងាយទទួលរងគ្រោះណាស់ ទោះបីជាបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើក្មេងប្រុស មានការចាប់អារម្មណ៍តិចតួចក៏ដោយ។ ការពង្រឹងការអនុវត្តន៍ច្បាប់ និងកម្មវិធីកាត់បន្ថយភាពងាយទទួលរងគ្រោះរបស់កុមារអាចទទួលបានផលវិជ្ជមាននៅតាមមូលដ្ឋាន ប៉ុន្តែបទអន្តរាគមន៍ទាំងនេះភាគច្រើនមិនបានជួយកាត់បន្ថយបញ្ហាទាំងនោះទេ។

ការរកឃើញនៃការសិក្សារបស់អង្គការ ILO-IPEC ស្តីពី "ការធ្វើដំណើរឆ្ពោះទៅមុខ" ដែលបានធ្វើឡើងនៅឆ្នាំ ២០០៤[២៤] ជាភស្តុតាងបន្ថែមទៅលើការសិក្សាខាងលើ ព្រមទាំងបានលើកឡើងនូវកត្តាស្រដៀងគ្នានេះផងដែរទាក់ទង

[២៤] ការធ្វើដំណើរឆ្ពោះទៅមុខ: ការពិនិត្យទិន្នន័យបន្ទាប់បន្សំទៅលើតំបន់ទទួល និង បញ្ជូន និង ផ្នែកការងារក្នុងការទប់ស្កាត់ការជួញដូរ កុមារ និង ស្ត្រី នៅក្នុងប្រទេសកម្ពុជា, ILO-IPEC ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។

នឹងមូលហេតុនៃការជួញដូរស្ត្រី និងកុមារ ។

ទោះបីជាកត្តាផ្គត់ផ្គង់ និងកត្តាតម្រូវការមួយចំនួនខាងលើនេះអាចដោះស្រាយបានដោយកម្មវិធីដែលមាននៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសជិតខាង (រួមមានការលើកកម្ពស់ការយល់ដឹង ការកសាងសមត្ថភាព សហគមន៍ជនបទ ការបង្កើន/ការកែលំអការអនុវត្តន៍ច្បាប់ ការដាក់ទោស ការកែលំអប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធអប់រំ និងការរក្សាសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងប្រទេស) ក៏នៅតែមានកត្តាចម្បងមួយចំនួន ដែលមិនទាន់បានដោះស្រាយជាពិសេស ដូចជាភាពក្រីក្រ កង្វះខាតឱកាសបង្កើនប្រាក់ចំណូលរបស់គ្រួសារ ឬប្រាក់ចំណូលបុគ្គល និងការកើនឡើងនូវតម្រូវការបុគ្គលិកវ័យក្មេង ជាពិសេសនៅក្នុងវិស័យទេសចរណ៍ ។

### *ច. ឥទ្ធិពលនៃការជួញដូរកុមារ និងស្ត្រីវ័យក្មេង*

ការជួញដូរបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតរបស់កុមារ និងស្ត្រីវ័យក្មេង។ ជនរងគ្រោះជាកុមារទទួលរង**ការរំលោភបំពានផ្នែករាងកាយ និងផ្នែកស្មារតី**។ នេះគឺជាការរំលោភបំពានយ៉ាងកំរោលទៅលើសិទ្ធិរបស់ពួកគេ។ កុមារ និងស្ត្រីមិនត្រូវបានលើកកម្ពស់ទេ ហើយថែមទាំងត្រូវបានគេប្រព្រឹត្តិមកលើដូចជាទំនិញ។ បទពិសោធន៍ ការខកចិត្ត ការរងគ្រោះ ភាពឯកា ការនៅដោយឡែក និងការមាក់ងាយពីសង្គម គឺជាផលប៉ះពាល់អវិជ្ជមានចំពោះជនរងគ្រោះ។ ដោយសារតែការយល់ឃើញពីកាតព្វកិច្ចដែលត្រូវបំពេញសម្រាប់គ្រួសារដែលលិចលង់ និងមិនអាចចិញ្ចឹមខ្លួនឯងបាន កុមារទាំងនេះចាកចេញពីផ្ទះសំបែងរបស់ខ្លួនដើម្បីស្វែងរកជីវិតប្រសើរមួយ ប៉ុន្តែទីបញ្ចប់ពួកគេត្រូវធ្លាក់ចូលទៅក្នុងស្ថានភាពមួយដែលបង្កគ្រោះថ្នាក់ដល់សុខភាព និងជីវិតរបស់ខ្លួនទៅវិញ។ កុមារមិនត្រឹមតែត្រូវបានរំលោភបំពានពីសំណាក់អ្នកជួញដូរប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងត្រូវបានរំលោភបំពានពីសំណាក់អតិថិជនរបស់ខ្លួនទៀតផង។ ពួកគេប្រឈមមុខនឹងគ្រោះថ្នាក់ឆ្លងជំងឺកាមរោគ ឆ្លងមេរោគអេដស៍/ជំងឺអេដស៍ និងគ្រោះថ្នាក់ផ្សេងទៀតទាក់ទងទៅនឹងការមានផ្ទៃពោះដោយមិនចង់បាន និងការពន្លូតកូន ។

កុមារ និងស្ត្រីវ័យក្មេងដែលធ្លាប់ត្រូវបានគេជួញដូរ ជាទូទៅឱ្យតម្លៃខ្លួនទាប និងមិនទុកចិត្តអ្នកដទៃ[២៥] ។

## សកម្មភាព ២: សកម្មភាពបន្ថែម

ករណីសិក្សា[២៦] : កុមារ និងស្ត្រីវ័យក្មេងដែលត្រូវបានគេជួញដូរនៅក្នុងវិស័យទេសចរណ៍

---

[២៥] *ការបង្កើតគ្រោះថ្នាក់ - ការជួញដូរកុមារក្នុងប្រទេសហ្វីលីពីនក្នុងគោលបំណងផ្លូវភេទ* ECPAT Philippines, Terre des Hommes - Netherland

[២៦] ដកស្រង់ចេញពី Agnes Zenaida V. Camacho, Faye G. Balanon and Arnie C. Trinidad, Raising One Voice: សៀវភៅបណ្តុះបណ្តាលសម្រាប់ធ្វើការតស៊ូមតិស្តីពីសិទ្ធិរបស់កុមារបម្រើការងារតាមផ្ទះ និងសិទ្ធិរបស់កម្មករជាកុមារក្នុងទ្វីបអាស៊ី ក្រុងបាងកក ឆ្នាំ២០០៥

គោលបំណង: ដើម្បីបង្កើនការយល់ដឹងស្តីពីស្ថានភាពរបស់កុមារ និងស្ត្រីវ័យក្មេងដែលត្រូវបានគេជួញដូរ នៅក្នុងវិស័យទេសចរណ៍

ពេលវេលា: ១ ម៉ោង ៣០ នាទី

សំភារៈ: ករណីសិក្សា ក្រដាសផ្ទាំងធំ ហ្វឺតសរសេរ

របៀបធ្វើ

១. បែងចែកអ្នកចូលរួមជា ៣ ក្រុម ។ ចែកករណីសិក្សាដល់ក្រុមនីមួយៗ ។

២. ស្នើឱ្យក្រុមទាំងអស់អានករណីសិក្សា ហើយពិភាក្សាពីស្ថានភាពរបស់កុមារ និងស្ត្រីវ័យក្មេងធ្វើការនៅក្នុងវិស័យទេសចរណ៍។ ស្នើឱ្យក្រុមកត់ត្រាការយល់ឃើញរបស់ខ្លួន។

៣. ស្នើឱ្យតំណាងក្រុមនីមួយៗឡើងបង្ហាញនូវលទ្ធផលនៃការពិភាក្សារបស់ខ្លួន។ បន្ទាប់ពីបង្ហាញចប់គ្រប់ក្រុមហើយ ស្នើឱ្យអ្នកចូលរួមផ្តល់យោបល់សំណួរ និងសំណូមពរនានា ។

៤. សង្ខេបលទ្ធផលនៃការពិភាក្សា

## មេរៀន

### ក. ករណីសិក្សាស្តីពីកុមារ និងស្ត្រីវ័យក្មេងដែលត្រូវបានគេជួញដូរនៅក្នុងវិស័យទេសចរណ៍

ដូចបានលើកឡើងខាងលើ ការជួញដូរកើតឡើងដោយសារកាតព្វកិច្ចដែលត្រូវជួយដល់ក្រុមគ្រួសារ ឬដោយសារចាញ់ល្បិចកលរបស់អ្នកដទៃ ភាគច្រើនចាញ់ល្បិចកលរបស់មេខ្យល់។ ករណីសិក្សាចំនួន៣ ខាងក្រោមនេះបង្ហាញពីឧទាហរណ៍ជាក់ស្តែងស្តីពី ការជួញដូរដែលកើតឡើងដោយល័ក្ខខ័ណ្ឌខាងលើនេះ ។

**ករណីជួញដូរក្នុងខេត្តកំពង់ចាម**

**ករណីទី ១**

ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់រស់នៅក្នុងគ្រួសារក្រីក្រមួយនៅភូមិរ៉ៃលើ, ឃុំដូនទៃ, ស្រុកពញាក្រែក ខេត្តកំពង់ចាម ។ ឪពុកម្តាយគ្មានដីធ្លី ប៉ុន្តែប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែ។ ដោយសារតែស្ថានភាពក្រីក្រ ក្មេងស្រីនេះត្រូវបានធ្វើការជាអ្នកបម្រើក្នុងភោជនីយដ្ឋានហាងខារ៉ាអូខេ) មួយ តាមឪពុកម្តាយរបស់នាង ជាមួយបុរសម្នាក់រស់នៅភូមិជីមាន់, ឃុំជីមាន់, ស្រុកពញាក្រែក ខេត្តកំពង់ចាម។ ឪពុកម្តាយក្មេងស្រីនេះបើកប្រាក់មុនចំនួន៤០០.០០០រៀលក្នុងមួយឆ្នាំពីម្ចាស់ភោជនីយដ្ឋាននោះ។ ពីរបីខែក្រោយមកម្ចាស់ហាងបាននាំក្មេងស្រីនោះមកឱ្យឪពុកម្តាយវិញ និងបានទុកនាងនៅក្នុងផ្ទះមួយ ហើយគាត់បានទារប្រាក់គាត់មកវិញ ឬជំនួសដោយបងស្រីរបស់ក្មេងស្រីនោះវិញ ព្រោះក្មេងស្រីនេះធ្វើការមិនបានល្អ និងមិនចេះផ្គាប់ចិត្តម្ចាស់ផ្ទះ។ នៅពេលដឹងពីករណីនេះ ប្រធានភូមិបានជូនដំណឹង ទៅប្រធានឃុំដើម្បីជួយដោះស្រាយបញ្ហានេះ ប៉ុន្តែមេឃុំ និងប៉ូលីសប៉ុស្តិ៍គឺជាសាច់ញាតិរបស់ម្ចាស់ហាងនោះ។ មេឃុំបានសម្រេចចិត្តឱ្យឪពុកម្តាយក្មេងស្រីនោះសងប្រាក់ទៅឱ្យម្ចាស់ហាងវិញ។ ក្រោយមក ប្រធានភូមិបានជួយឪពុកម្តាយរូបនោះ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គការលីកាដូនៅក្នុងខេត្តកំពង់ចាម។ ដោយមានកិច្ចសហប្រតិបត្តិការរវាងការិយាល័យកិច្ចការនារីថ្នាក់ស្រុក និងអង្គការលីកាដូ ក្មេងស្រីនោះត្រូវបានគេធ្វើអន្តរាគមន៍ និងដោះលែងពីម្ចាស់ហាងនោះ ហើយត្រូវបានបញ្ជូនត្រឡប់ទៅកាន់គ្រួសារវិញ។

**ករណីទី២**

នៅក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មានក្រុមហ៊ុនកូរ៉េមួយ ដែលត្រូវបានណែនាំឱ្យស្គាល់ដោយបុរសជនជាតិកម្ពុជាម្នាក់។ ក្រុមហ៊ុននោះ មានទីតាំងនៅទីក្រុងភ្នំពេញ និងគ្រប់គ្រងដោយជនជាតិកូរ៉េ កំពុងស្វែងរកស្ត្រីស្អាតមួយចំនួនដែលចង់រៀបការជាមួយបុរសជនជាតិកូរ៉េ។ អ្នកស្វែងរកមនុស្សបានប្រាប់អ្នកភូមិថាក្មេងស្រីណាដែលចាប់អារម្មណ៍ អាចដាក់ពាក្យនៅក្នុងស្រុក ហើយបន្ទាប់មកទៀតពួកគេនឹងចុះមកប្រមូល និងបញ្ជូនទៅទីក្រុងភ្នំពេញ។ គ្រប់បេក្ខនារី ត្រូវបានជ្រើសរើសដោយឈរលើមូលដ្ឋាន សម្ផស្ស និងប្រវត្តិរូប។ ការជ្រើសរើសធ្វើដោយជនជាតិកូរ៉េ ។

បុគ្គលិកការិយាល័យកិច្ចការនារីស្រុកបានជូនដំណឹងពីករណីនេះទៅកាន់មន្ទីរកិច្ចការនារីខេត្ត ដើម្បីស្នើសុំដំបូន្មាន ឬយោបល់ណែនាំ បន្ទាប់មកបុគ្គលិកកិច្ចការនារីស្រុកស្ទឹងត្រង់បានសហការជាមួយប៉ូលីសស្រុកដើម្បីស៊ើបអង្កេតពីករណីជ្រើសរើសមនុស្សនេះ។ ប៉ូលីសបានស្វែងរកអត្តសញ្ញាណកម្មរបស់ក្រុមហ៊ុននោះ អាជ្ញាប័ណ្ណ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ប៉ុន្តែគ្មានរកឃើញនូវភស្តុតាងផ្លូវការណាមួយទេ។ បន្ទាប់មកទៀត ក្រុមហ៊ុនបានបញ្ឈប់សកម្មភាពរបស់ខ្លួន។

**ករណីជួញដូរនៅក្នុងខេត្តបាត់ដំបង**

ស្ត្រីអាយុ២២ឆ្នាំម្នាក់ ឈ្មោះសូស្រី កំពុងរស់នៅក្នុងភូមិកាប់គោថ្មី ឃុំអូរឆា ស្រុកបាត់ដំបង ខេត្តបាត់ដំបង។ ស្ត្រីឈ្មោះសូស្រីជាស្ត្រីមេម៉ាយ និងកំពុងរស់នៅជាមួយជីដូនរបស់នាង និងកូនពីរនាក់។ ស្ត្រីម្នាក់ឈ្មោះភី អាយុ៣៣ឆ្នាំ អតីតជាស្រីពេស្យា ប៉ុន្តែបច្ចុប្បន្នបានរៀបការរួច និងបានជួលផ្ទះស្នាក់នៅក្បែរផ្ទះរបស់ស្ត្រីរងគ្រោះនេះ។ ថ្ងៃមួយឈ្មោះភីបានបញ្ចុះបញ្ចូលស្ត្រីរងគ្រោះឱ្យទៅរកស៊ីនៅខេត្តក្រចេះជាស្រីខារ៉ាអូខេទទួលបានប្រាក់ចំណូលខ្ពស់។ បន្ទាប់មកស្ត្រីរងគ្រោះនោះ ក៏បានយល់ព្រមទៅជាមួយឈ្មោះភីនេះ ទោះបីជាជីដូន និងប្អូនថ្លៃប្រុសរបស់នាងជំទាស់ក៏ដោយ ។

តាមផ្លូវពីបាត់ដំបងទៅកាន់ក្រចេះ ពួកគេទាំងពីរត្រូវស្នាក់នៅមួយយប់នៅខេត្តកំពង់ចាម។ ឈ្មោះភីបានលក់ស្ត្រីរងគ្រោះរូបនេះទៅឱ្យស្ត្រីម្នាក់ រួចយកលុយរត់គេចខ្លួនបាត់ដោយបន្សល់ទុកតែស្ត្រីរងគ្រោះឱ្យស្នាក់នៅតែម្នាក់ឯងជាមួយនឹងអ្នកទិញនៅក្នុងខេត្តកំពង់ចាម។ ក្រោយមកស្ត្រីរងគ្រោះ បានដឹងថានាងត្រូវបានឈ្មោះភីបោកប្រាស់យកមកលក់ នាងបានព្យាយាមគេចខ្លួនហើយបានទៅជួបជាមួយបុគ្គលិកអង្គការលីកាដូឱ្យជួយនាង ។

ក្រោមការសហប្រតិបត្តិការរវាងមន្ទីរកិច្ចការនារីខេត្តកំពង់ចាម និងអង្គការលីកាដូ ស្ត្រីរងគ្រោះរូបនេះត្រូវបានបញ្ជូនត្រឡប់ទៅខេត្តបាត់ដំបងវិញ។ មន្ទីរកិច្ចការនារីខេត្តបាត់ដំបង និងសមត្ថកិច្ចខេត្តបាត់ដំបងបានជួយស្វែងរកគ្រួសារ និងផ្ទះរបស់ស្ត្រីរងគ្រោះនេះ ហើយបានបញ្ជូននាងឱ្យទៅរស់នៅក្នុងក្រុមគ្រួសាររបស់នាងវិញ ។

## ៤. ខ្លឹមសារ

## ម៉ូឌុល ៣ ៖ ការទប់ស្កាត់ការជួញដូរ

### គោលបំណង:

ដើម្បីពិភាក្សា និងស្វែងរកនូវកិច្ចខិតខំប្រឹងប្រែងផ្សេងៗ ក្នុងការទប់ស្កាត់ការជួញដូរកុមារ និងស្រ្តីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា

**សកម្មភាព ១** ការដើរតួសម្តែង

**មេរៀន**

ក. ស្ថានភាពទូទៅស្តីពីកិច្ចខិតខំទប់ស្កាត់ការជួញដូរកុមារ និងស្រ្តីវ័យក្មេងក្នុងប្រទេសកម្ពុជា

១. បទបញ្ញត្តិ និង វិធានការគោលនយោបាយ

២. សិទ្ធិកុមារ

៣. សិទ្ធិស្រ្តី

៤. ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអន្តរជាតិទាក់ទងនឹងការជួញដូរកុមារ និងស្រ្តី

៥. ច្បាប់ និងបទបញ្ញត្តិថ្នាក់ជាតិទាក់ទងទៅនឹងការជួញដូរកុមារ និងស្រ្តី

ខ. បញ្ហាដែលបានជួបប្រទះ និងការតស៊ូមតិសាធារណៈ

គ. កម្មវិធី និងបទអន្តរាគមន៍គន្លឹះ

១. ក្រសួងរដ្ឋាភិបាល

ក. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)

ខ. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY)

គ. ក្រសួងកិច្ចការនារី (MOWA)

ឃ. ក្រសួងមហាផ្ទៃ (MOI)

ង. ក្រសួងទេសចរណ៍ (MOT)

២. អង្គការពលកម្មអន្តរជាតិ – កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (ILO-IPEC)

# ម៉ូឌុល ៣ ៖ ការទប់ស្កាត់ការជួញដូរ

**សកម្មភាព ១** : ការដើរតួសម្តែង កិច្ចខិតខំទប់ស្កាត់ការជួញដូរ

**គោលបំណង** : ដើម្បីស្វែងរកបទអន្តរាគមន៍នានាក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍

**ពេលវេលា** : ១ ម៉ោង

**របៀបធ្វើសកម្មភាព**

១. បែងចែកអ្នកចូលរួមទៅជា ៥ ក្រុមតូចៗ

២. ណែនាំឱ្យពួកគេបង្កើតការសម្តែងតួខ្លីៗដែលបង្ហាញពីកិច្ចខិតខំ និងបទអន្តរាគមន៍នានា ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រីវ័យក្មេង

៣. អនុញ្ញាតឱ្យក្រុមមានពេល ៥-៧ នាទីដើម្បីបង្កើតការសម្តែងតួ

៤. ស្នើឱ្យក្រុមនីមួយៗ បង្ហាញពីការសម្តែងតួទៅដល់ក្រុមធំនៃអង្គសិក្ខាសាលា

៥. អនុញ្ញាតឱ្យមានពេលពិភាក្សា និងសួរបញ្ជាក់

៦. កត់ត្រាកិច្ចខិតខំ និងបទអន្តរាគមន៍ទាំងអស់ដែលបានលើកឡើង

៧. សំយោគដំណើរការ និងលើកឡើងពីចំណុចសិក្សា

## មេរៀន

### *ក. ស្ថានភាពទូទៅស្តីពីកិច្ចខិតខំទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងក្នុងប្រទេសកម្ពុជា*

#### ១. បទបញ្ញត្តិ និង វិធានការគោលនយោបាយ

ប្រទេសកម្ពុជា គឺជាប្រទេសហត្ថលេខីចំពោះអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស។ កិច្ចព្រមព្រៀងអន្តរជាតិទាំងនេះ បង្កើតបានជាមូលដ្ឋានសម្រាប់បង្កើតមាត្រានានានៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។ ប្រការនេះក៏មានន័យថា គ្រប់គោលការណ៍នៃអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិមានអាទិភាពទៅលើច្បាប់ជាតិ។ អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ និងកាតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នរួមមាន:

ក. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

គ. អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW)

ឃ. អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) (១៩៨៩)

ង. ពិធីសារសម្រេចចំពោះសិទ្ធិកុមារ ស្តីពីការលក់ដូរកុមារ ពេស្យាចារលើកុមារ និង រូបអាសគ្រាមលើកុមារ

ច. តុលាការព្រហ្មទណ្ឌអន្តរជាតិទីក្រុងរ៉ូម

ឆ. អនុសញ្ញាបំពេញបន្ថែមលើការលុបបំបាត់ទាសភាព អាជីវកម្មបែបទាសភាព និងការអនុវត្តន៍ស្រដៀងនឹងទាសភាព

ជ. ពិធីសារអង្គការសហប្រជាជាតិចំពោះអនុសញ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទោសចំពោះការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

ឈ. ពិធីសារអង្គការសហប្រជាជាតិប្រឆាំងនឹងការរត់ពន្ធរបស់ជនអន្តោប្រវេសន៍តាម ផ្លូវគោក សមុទ្រ និងអាកាស

ញ. អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិសំខាន់ៗមាន៖

- អនុសញ្ញាលេខ ២៩ ស្តីពីការងារដោយបង្ខំ
- អនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពបង្កើតសមាគម និងការពារសិទ្ធិរៀបចំជាក្រុម
- អនុសញ្ញាលេខ ៩៨ ស្តីពីសិទ្ធិធ្វើការប្រមូលផ្តុំ និងការតវ៉ាជាសមូហភាព
- អនុសញ្ញាលេខ ១០០ ស្តីពីការទូទាត់ប្រកបដោយសមភាព
- អនុសញ្ញាលេខ ១១១ ស្តីពីការប្រឆាំងការរើសអើងក្នុងការងារ
- អនុសញ្ញាលេខ ១០៥ ស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ
- អនុសញ្ញាលេខ ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលបំពេញការងារ
- អនុសញ្ញាលេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

## ២. សិទ្ធិកុមារ[២៧]

**ដោយសារតែកុមារគឺជាមនុស្ស ដូច្នេះពួកគេក៏ត្រូវមានសិទ្ធិផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយកុមារមិនមានសមត្ថភាពផ្នែកច្បាប់ដូចមនុស្សធំទេ ។** កុមារត្រូវការការការពារពិសេស ព្រោះពួកគេងាយនឹងទទួលរងគ្រោះថ្នាក់។ ទោះបីជាប្រការនេះត្រូវបានទទួលស្គាល់ធំធេងក៏ដោយ ក៏វាមិនអាចការពារកុមារពីការទទួលរងគ្រោះថ្នាក់ទេ ព្រោះការសម្រេចចិត្ត និងវិធានការអនុវត្តនានាត្រូវបានធ្វើឡើងដោយមនុស្សធំ ហើយកុមារពុំសូវមានអំណាច ឬមិនមានអំណាចទាល់តែសោះក្នុងការសម្រេចចិត្ត ។

[២៧] សៀវភៅកម្មវិធីបណ្តុះបណ្តាលស្តីពីការទប់ស្កាត់កុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងវិស័យទេសចរណ៍ គណៈកម្មការទេសចរណ៍សុវត្ថិភាព លើកុមារ (MoT-WVC-CAMP), AusAID

សេចក្តីមេត្តាករុណាចំពោះបញ្ហាដែលបានកើតមានទៅលើកុមារ អាចធ្វើឱ្យអ្នកដទៃចាត់ទុកការជួយដល់កុមារថាជាអំពើសប្បុរសធម៌ មិនមែនចាត់ទុកថាជាសិទ្ធិរបស់កុមារដែលសមនឹងទទួលនោះទេ។ ជាលទ្ធផលបញ្ហានៅជុំវិញកុមារតែងតែត្រូវបានមើលមិនឃើញ និងខកខានមិនបានជួយដោះស្រាយ។ ស្ថានភាពពិតប្រាកដនៃការទទួលរងគ្រោះរបស់កុមារ និងការកេងប្រវ័ញ្ចមកលើកុមារក្នុងពិភពជុំវិញខ្លួនយើង គឺជាការបញ្ជាក់ថាឧបករណ៍សិទ្ធិមនុស្សដែលមាននៅពេលបច្ចុប្បន្ននេះ មិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការរបស់កុមារទេ។

នៅក្នុងកំឡុងពេលពាក់កណ្តាលចុងសតវត្សទី២០ ការយល់ដឹងពីតម្រូវការផ្នែកចិត្តសាស្ត្ររបស់កុមារ មានការកើនឡើង និងមានការទទួលស្គាល់ថាកុមារមានតម្លៃរបស់ខ្លួន។ ការយល់ដឹងដែលថាអត្ថប្រយោជន៍របស់កុមារមិនសូវមានសារៈសំខាន់ដូចអត្ថប្រយោជន៍របស់មនុស្សធំជាអាណាព្យាបាលបានកើនឡើង ព្រោះកុមារភាគច្រើនត្រូវបានគេប្រព្រឹត្តមកលើខ្លួនយ៉ាងមិនល្អនៅក្នុងគ្រួសារ។ ដូច្នេះអនុសញ្ញាអន្តរជាតិ ត្រូវដោះស្រាយចំពោះតម្រូវការរបស់កុមារជាជាងពឹងផ្អែកទៅលើឧបករណ៍សិទ្ធិមនុស្សដែលមានស្រាប់។

**គោលការណ៍មូលដ្ឋាននៃសិទ្ធិកុមារ គឺថាសង្គមមួយមានកាតព្វកិច្ចបំពេញនូវតម្រូវការជាមូលដ្ឋានរបស់កុមារ និងផ្តល់ជំនួយដល់ការអភិវឌ្ឍន៍សមត្ថភាព និងភាពប៉ិនប្រសប់របស់កុមារ។** អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារបានកំណត់ស្តង់ដារការងារអប្បបរមាជាអន្តរជាតិ ដែលចាំបាច់សម្រាប់ធានានូវសុខមាលភាពរបស់កុមារដែលកុមារគ្រប់រូបត្រូវតែទទួលបាន។ នៅក្នុងអនុសញ្ញានេះសិទ្ធិរបស់កុមារត្រូវបានកំណត់យ៉ាងច្បាស់ និងប្រកបដោយអត្ថន័យព្រមទាំងបានកំណត់ពីល័ក្ខខ័ណ្ឌមួយចំនួនដែលត្រូវគោរព។

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ** គ្របដណ្តប់លើ **សិទ្ធិស៊ីវិល នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម**របស់កុមារ។ **អនុសញ្ញាក៏បានចែងពីការអភិវឌ្ឍន៍ពេញលេញដល់កុមារ ក្នុងបរិយាកាសដែលមានសេរីភាព ភាពថ្លៃថ្នូរ និងយុត្តិធម៌ ។**

## ៣. សិទ្ធិស្ត្រី

ទាក់ទងទៅនឹងសិទ្ធិមនុស្សនៅទូទាំងពិភពលោក[២៨] : ស្ត្រីត្រូវបានគេបដិសេធសិទ្ធិរបស់ខ្លួន គម្លាតយេនឌ័រមិនមានសមភាព ហើយអំណាចរវាងបុរស និងស្ត្រីមានលក្ខណៈខុសពីគ្នា។ ប្រជាជនពាក់កណ្តាលលើពិភពលោក គឺជាអ្នករណបចំពោះប្រជាជន ពាក់កណ្តាលទៀតទៅតាមសណ្ឋានផ្សេងៗគ្នា ដោយសារតែបញ្ហាផ្លូវភេទដែលខ្លួនមានតាំងពីកំណើតមក។ ទោះបីជាមានច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលធានាឱ្យគ្រប់មនុស្សទាំងអស់មានសិទ្ធិស្មើគ្នាដោយមិនគិតពីភេទ សញ្ជាតិ ឋានៈ តួនាទី។ល។ ក៏ដោយ ក៏ស្ត្រីត្រូវបានគេបដិសេធថាមានសិទ្ធិមិនស្មើនឹងសិទ្ធិរបស់បុរសនោះទេ ជាពិសេសសិទ្ធិទាក់ទងទៅនឹងការកាន់កាប់ដីធ្លី សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ សិទ្ធិធ្វើបម្លាស់ទី សិទ្ធិទទួលបានការអប់រំ

[២៨] Suzanne Williams, Janet Seed and Adelina Mwau, The OXFAM Gender Training Manual

សិទ្ធិទទួលឱកាសការងារ សិទ្ធិទទួលជម្រកស្នាក់នៅ សិទ្ធិទទួលអាហារ សិទ្ធិធ្វើការ និងសិទ្ធិការពារជីវិតកូនរបស់ខ្លួន ។ សូម្បីតែសិទ្ធិទាក់ទងទៅនឹងការគ្រប់គ្រង ការត្រួតពិនិត្យ ការថែទាំសុខភាពរាងកាយ និងការថែទាំសិរីរៈផ្លូវភេទរបស់ស្ត្រីក៏ត្រូវបានគេបដិសេធផងដែរ ។

## ៤. ការប្ដេជ្ញារបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអន្តរជាតិទាក់ទងនឹងការជួញដូរកុមារ និងស្ត្រី

រាជរដ្ឋាភិបាលកម្ពុជា បានប្ដេជ្ញាប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ រួមបញ្ចូលទាំងការជួញដូរ និងបានបង្ហាញនូវឆន្ទៈរបស់ខ្លួន ដោយផ្ដល់សច្ចាប័នទៅលើអនុសញ្ញាការងារអន្តរជាតិមួយចំនួន ដូចបានលើកឡើងខាងលើ។ ប្រទេសកម្ពុជា គឺជាប្រទេសសមាជិកមួយក្នុងគម្រោងអនុតំបន់ទន្លេមេគង្គរបស់អង្គការ ILO-IPEC ស្ដីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រីដំណាក់កាលទី២ (គម្រោង ILO-IPEC TICW)[២៩] ។ គម្រោង ILO-IPEC TICW មានគោលបំណងចូលរួមចំណែកក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រីដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មតាមរយៈវិធានការបង្ការមួយចំនួននៅតាមតំបន់ទទួល តំបន់បញ្ជូន និងតំបន់សំចត។

ដោយមានការជួយគាំទ្រពីគម្រោង ILO-IPEC TICW និងអង្គការ UNICEF ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) បានចាប់ផ្ដើមធ្វើការប៉ាន់ប្រមាណ និងពិនិត្យឡើងវិញទៅលើផែនការ៥ឆ្នាំ (២០០០-២០០៤) ស្ដីពីការប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ ដោយផ្ដោតទៅលើបទអន្តរាគមន៍ចំនួន៤ គឺការទប់ស្កាត់ ការការពារ ការស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្ម។ ការប៉ាន់ប្រមាណ និងការពិនិត្យឡើងវិញនេះមានគោលបំណងដើម្បីបង្កើតផែនការសកម្មភាពជាតិ៥ឆ្នាំមួយថ្មីទៀត ដោយផ្ដោតការយកចិត្តទុកដាក់សំខាន់ទៅលើការជួញដូរមនុស្ស និងយុទ្ធនាការប្រឆាំងនឹងការកេងប្រវ័ញ្ច អាជីវកម្មផ្លូវភេទលើមនុស្ស ។ ផែនការ៥ឆ្នាំខាងមុខនេះមានគោលបំណងដើម្បីឆ្លុះបញ្ចាំងទៅលើការរីកចម្រើន ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន និងឆ្លុះបញ្ចាំងទៅលើស្ថានភាពជាក់ស្ដែងដែលបានកើតឡើង និងបញ្ហានានាដែលប្រទេសកំពុងតែប្រឈមមុខ ក្នុងខណៈដែលខ្លួនព្យាយាមលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

នៅក្នុងខែតុលា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាមួយនឹងប្រទេស៥ ទៀតនៅក្នុងអនុតំបន់ទន្លេមេគង្គ ដោយចុះហត្ថលេខាទៅលើអនុស្សរណៈ COMMIT (គំនិតផ្ដួចផ្ដើមអន្តរក្រសួង ក្នុងកិច្ចសម្របសម្រួលតំបន់ទន្លេមេគង្គ ប្រឆាំងនឹងការជួញដូរ) ស្ដីពីកិច្ចសហប្រតិបត្តិការប្រឆាំងនឹងការជួញដូរមនុស្ស (MOU)។ អនុស្សរណៈនេះគឺជាឯកសារដ៏មានអត្ថន័យ ដោយគ្របដណ្ដប់ទៅលើការជួញដូរមនុស្សគ្រប់ប្រភេទ និងគ្រប់ទម្រង់នៃការជួញដូរ។

---

[២៩] ការអនុវត្តន៍ល្អ និង មេរៀនបទពិសោធន៍នៃសកម្មភាពគម្រោងនៅក្នុងដំណាក់កាលទី ១ និង របាយការណ៍នៃកិច្ចប្រជុំ NSOE នៅថ្ងៃទី ៤-៥ ខែមិនា ឆ្នាំ ២០០៤ ស្ដីពីការកំណត់ខេត្ត និង ផ្នែកគោលដៅ ។

អនុស្សរណៈនេះបានទទួលស្គាល់នូវភាពងាយទទួលរងគ្រោះរបស់ស្ត្រី និងកុមារចំពោះការជួញដូរ និងបានទទួលស្គាល់នូវស្ថានការណ៍ពិតប្រាកដ ដែលត្រូវជួយដោះស្រាយចំពោះភាពងាយទទួលរងគ្រោះថ្នាក់របស់ក្រុមប្រជាជនទាំងនេះ។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាអនុវត្តសកម្មភាពចំនួន១៨ ដែលមាននៅក្នុងឯកសារក្របខ័ណ្ឌការងារ និងផែនការសកម្មភាពថ្នាក់អនុតំបន់។ រាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវដឹកនាំកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ។

### ៥. ច្បាប់ និង បទបញ្ញត្តិថ្នាក់ជាតិទាក់ទងទៅនឹងការជួញដូរកុមារ និងស្ត្រី

ក្របខ័ណ្ឌផ្នែកច្បាប់ដែលគ្រប់គ្រងទៅលើការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងពលកម្មទៅលើស្ត្រី និងកុមារនៅពេលបច្ចុប្បន្ននេះ មានចែងនៅក្នុង **រដ្ឋធម្មនុញ្ញជាតិ មាត្រា ៤៦** ដែលចែងជាពិសេសស្តីពីការហាមប្រាម "ការធ្វើអាជីវកម្មលើមនុស្ស ការកេងប្រវ័ញ្ចដោយអំពើពេស្យាចារ និងការថតរូបអាសអាភាសដែលប៉ះពាល់ដល់កិត្យានុភាពរបស់ស្ត្រី"។ វាក៏មានចែងនៅក្នុង **ច្បាប់ស្តីពីការបង្ក្រាបការចាប់ពង្រាត់ ការជួញដូរ និងការកេងប្រវ័ញ្ចមនុស្ស ឆ្នាំ១៩៩៦** និង **ច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៩២** ដែលមានបទបញ្ញត្តិស្តីពីការដាក់ទណ្ឌកម្មដល់អ្នកពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការឃុំខ្លួនមនុស្សដោយខុសច្បាប់ ការបង្ករបួសស្នាម ការធ្វើឃាដមនុស្ស និងអ្នកដែលពាក់ព័ន្ធនឹងការចាប់រំលោភ មនុស្ស[៣០] ។

ដោយយោងទៅតាមសេចក្តីប្រកាស ដែលបានចែងថាផែនការជាតិ NPA-TSEC គឺជាយន្តការរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ និងដោយយោងទៅតាមល័ក្ខខ័ណ្ឌរបស់ម្ចាស់ជំនួយក្នុងការធ្វើកំណែទម្រង់ច្បាប់ ក្រសួងយុត្តិធម៌បានធ្វើការពិនិត្យឡើងវិញទៅលើច្បាប់ និងក្របខ័ណ្ឌការងារ ផ្នែកច្បាប់នានាដែលមានស្រាប់ទាក់ទងទៅនឹងការជួញដូរមនុស្ស។ លទ្ធផលសំខាន់ដែលទទួលបានគឺថាសេចក្តីព្រាងច្បាប់ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទសម្រាប់ធ្វើអាជីវកម្មលើកុមារ ត្រូវបានធ្វើវិសោធនកម្មឡើងវិញនៅក្នុងខែតុលា ឆ្នាំ២០០៤។ នៅពេលដែលរាជរដ្ឋាភិបាលប្រកាសឱ្យប្រើប្រាស់ច្បាប់នេះជាផ្លូវការ នោះច្បាប់នានាដែលមានស្រាប់ស្តីពីការជួញដូរ និងការកេងប្រវ័ញ្ចលើកុមារនឹងត្រូវរំលាយចោល ។

### *ខ. បញ្ហាដែលបានជួបប្រទះ និងការតស៊ូមតិសាធារណៈ*[៣១]

គម្រោងគោលនយោបាយ និងតស៊ូមតិរបស់អង្គការ IOM បានអនុវត្តដោយមានការសហការជាមួយក្រសួងកិច្ចការនារី។ អង្គការ IOM បានផ្តល់នូវជំនួយបច្ចេកទេសដល់ការការពារផ្នែកច្បាប់ អំពើហឹង្សាក្នុងគ្រួសារ និងផ្នែក

[៣០] របាយការណ៍ថ្នាក់ជាតិស្តីពីការជួញដូរស្ត្រី និងកុមារ ២០០០-២០០៤

[៣១] Danille C. Butler, ការពិនិត្យលើកម្មវិធីប្រឆាំងការជួញដូរ ការកេងប្រវ័ញ្ចផ្លូវភេទ និង អំពើហឹង្សាប្រឆាំងកុមារ Save the Children - Australia

ព័ត៌មានដល់ក្រសួងកិច្ចការនារី ។ ការផ្តោតសំខាន់គឺស្តីពី ការសម្របសម្រួលការកែលំអសេចក្តីព្រាងច្បាប់ថ្មី របស់ប្រទេសកម្ពុជា ស្តីពីការជួញដូរ និងការផ្តល់សច្ចាប័នលើពិធីសារអង្គការសហប្រជាជាតិស្តីពី ការជួញដូរ ព្រមទាំងការកែលំអការត្រួតពិនិត្យ និងការអនុវត្តច្បាប់បច្ចុប្បន្ន ទាក់ទងទៅនឹងការជួញដូរកុមារ និងស្រ្តី ។ លើសពីនេះទៀត អង្គការ IOM បានផ្តល់ជំនួយដល់ក្រសួងកិច្ចការនារី ក្នុងការគូសផែនទី សេវាច្បាប់/សង្គម និងសេវាសុខាភិបាលដែលមាននៅក្នុងប្រទេសកម្ពុជាជួយពង្រឹងការសម្របសម្រួល និងការធ្វើផែនការ ព្រមទាំងជួយប្រមូល និងចែកចាយព័ត៌មាន ។

អង្គការ UNICEF ផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការបង្កើតគោលនយោបាយ និងការអនុវត្តន៍គោលនយោបាយទាក់ទងទៅនឹងបទបញ្ញត្តិអ្នកថែទាំរួមទាំងស្ថាប័ន និងមជ្ឈមណ្ឌលថែទាំ ។ នៅថ្នាក់មជ្ឈឹម អង្គការផ្តល់ជំនួយក្នុងការធ្វើផែនការកម្មវិធី ការសម្របសម្រួលការត្រួតពិនិត្យ ការវាយតម្លៃ ការបណ្តុះបណ្តាល និងការគ្រប់គ្រងបុគ្គលិកខេត្ត។ អង្គការក៏មានផ្តល់ជាជំនួយដល់ក្រសួងផែនការ ក្នុងការបង្កើតការពិភាក្សាសម្រាប់ត្រួតពិនិត្យការជួញដូរ និងកេងប្រវ័ញ្ចលើកុមារ ។

## *គ. កម្មវិធី និង បទអន្តរាគមន៍គន្លឹះ*

### ១. ក្រសួងរដ្ឋាភិបាល

#### *១.១ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)*[៣២]

នាយកដ្ឋានការងារកុមារ គឺជាស្ថាប័នសម្របសម្រួលបញ្ហាទាក់ទងទៅនឹងពលកម្មកុមារ។ អាណត្តិចំបងនៃនាយកដ្ឋាននេះ គឺផ្តោតទៅលើក្របខ័ណ្ឌការងារផ្នែកច្បាប់។ នាយកដ្ឋាននេះបានបង្កើតផែនការសកម្មភាពស្តីពីការលុបបំបាត់ពលកម្មកុមារ និងប្រកាសផ្សេងៗទាក់ទងនឹងពលកម្មកុមារ។ ផែនការជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ គឺជាផែនការរួមមួយសម្រាប់ស្ថាប័នដែលធ្វើការពាក់ព័ន្ធទៅនឹងពលកម្មកុមារទាំងអស់ ហើយផែនការនេះនឹងចូលរួមចំណែកជាចុងក្រោយដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រជាតិរបស់រដ្ឋាភិបាល ។ ការជួញដូរត្រូវបានចាត់ទុកថាជាទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ហើយផែនការនេះបានដាក់ចេញនូវយុទ្ធសាស្រ្ត និងវិធានការនានាដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាដ៏ធ្ងន់ធ្ងរនេះ ។

[៣២] ការពិពណ៌នាពីការងាររបស់ក្រសួងស្តីពីទេសចរណ៍សុវត្ថិភាពលើកុមារ ឬ ទាក់ទងទៅនឹងបញ្ហានេះ ទទួលបានពីកិច្ចប្រជុំជាមួយក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០០៥ ។ វត្តមានពេលនោះមាន លោក វេង ហ៊ាង ប្រធាននាយកដ្ឋាន ពលកម្មកុមារ លោក ស៊ិន វីសុទ្ធ អ្នកស្រី តុង សុភាព លោក ទី ជាតិវិសុទ្ធ និង លោក ឃី សារិន អនុប្រធាននាយកដ្ឋានពលកម្មកុមារ ។

នៅពេលបច្ចុប្បន្ន មានប្រកាសចំនួន៧ ស្តីពីពលកម្មកុមារ ត្រូវបានបង្កើតជាសេចក្តីព្រាងរួចទៅហើយ (ប្រកាសលេខ ១២៤ ស្តីពីការលើកដាក់ទម្ងន់របស់កុមារលីសែង ត្រូវបានអនុម័តនាថ្ងៃទី ១៩ មិថុនា ២០០១) ហើយសារាចរ និងគោលការណ៍ណែនាំនានាស្តីពី ពលកម្មកុមារក៏បានបង្កើតឡើងរួចផងដែរ។ អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពី ទម្រង់ធ្ងន់ធ្ងរនៃពលកម្មបានផ្តល់សច្ចាប័នរួចហើយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។ ដោយមានការផ្តល់សច្ចាប័នចុងក្រោយនេះ ផែនការជាតិ NPA-WFCL ត្រូវបានអនុម័តជាយន្តការរបស់រដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ ភ្នាក់ងាររដ្ឋាភិបាល និងអង្គការជាដៃគូនានាត្រូវដើរតាមយុទ្ធសាស្ត្រ និងវិធានការទាំងនេះ ។

ការរីកចម្រើនសំខាន់ៗនៅក្នុងនាយកដ្ឋានការងារកុមារ មានដូចខាងក្រោមនេះ:

- ក្នុងខែមិថុនាឆ្នាំ២០០៥ នាយកដ្ឋានបានរៀបចំសិក្ខាសាលារួមមួយជាមួយអង្គការ NGO ស្តីពី ពេស្យាចារលើកុមារ ដោយផ្តោតទៅលើការឆ្លើយតបរយៈពេលវែងចំពោះបញ្ហានេះ។
- នាយកដ្ឋាននេះបានបង្កើតការិយាល័យចំនួន៣ ដើម្បីរក្សាព័ត៌មាន និងឯកសារទាំងអស់ពាក់ព័ន្ធនឹងបញ្ហាពលកម្មកុមារ។ ការផ្តួចផ្តើមនេះនឹងធ្វើឡើងស្របជៀងគ្នាទៅនឹងគម្រោងរបស់អង្គការមូលនិធិអាស៊ី Asia Foundation ដែលបានបង្កើតវេបសាយ និងអ៊ីនធឺណេតសម្រាប់ផ្ទុកឯកសារ និងរបាយការណ៍ស្រាវជ្រាវទាំងអស់ស្តីពីការជួញដូរ ហើយ យើងអាចចូលមើលវេបសាយ និងអ៊ីនធឺណេតទាំងនេះបានទៀតផង ។
- ការពិនិត្យ និងការកែសម្រួលកំពុងបន្តធ្វើទៅលើច្បាប់ស្តីពីការងារ ក្រោមជំនួយបច្ចេកទេសពីអង្គការ ILO-IPEC
- ក្នុងពេលកិច្ចប្រជុំថ្មីៗនេះនៅទីក្រុងបាងកក COMMIT ដែលដឹកនាំដោយក្រសួងកិច្ចការនារី បានសម្រេចចេញជាក្រិត្យមួយដាក់បញ្ចូលក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក១រូបនៃ COMMIT ចាប់ពីកិច្ចប្រជុំលើកក្រោយ នាថ្ងៃទី ១០-១២ ខែឧសភា ឆ្នាំ២០០៦ តទៅ។

នៅពេលបច្ចុប្បន្ន នាយកដ្ឋានមិនទាន់មានសកម្មភាព/គម្រោងដោះស្រាយ ចំពោះសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នោះទេ ។

### ១.២ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY)[៣៣]

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ( កសអយ ) បានទទួលបេសកម្មពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងដឹកនាំ និងអនុវត្តការងារលើវិស័យធំៗ៣ គឺវិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិ

---

[៣៣] ការពិពណ៌នាការងារក្រសួងសអយ ទាក់ទងទៅនឹងទេសចរណ៍សុវត្ថិភាពលើកុមារ ទទួលបានពីបទសំភាសន៍ជាមួយអ្នកស្រី នុត ណាង អនុប្រធាននៃមន្ទីរសអយក្រុងភ្នំពេញ និង ជាមន្ត្រីកម្មវិធីនៃទេសចរណ៍សុវត្ថិភាពលើកុមារ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ។

សម្បទា ជាពិសេសកិច្ចការពារ និងស្តារនីតិសម្បទាជនរងគ្រោះ និងក្រុមជនងាយរងគ្រោះក្នុងសង្គមជាតិ ដែលក្នុងនោះមានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសកុមារ និងស្ត្រី ជនអនាថា ទារកកំព្រា កុមារកំព្រា ជនពិការ កុមារ យុវកុមារប្រើប្រាស់គ្រឿងញៀន មានទំនាស់នឹងច្បាប់កុមារ និងស្ត្រីរងគ្រោះ ឬប៉ះពាល់ដោយមេរោគអេដស៍ ។ល។

ក្នុងគោលបំណងសម្រេចបានទិសដៅយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាននិងកំពុងបំពេញភារកិច្ចសំខាន់ៗដូចខាងក្រោម :

- បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី សុំកូនអន្តរប្រទេស និងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច
- ចេញប្រកាសស្តីពី គោលនយោបាយស្តីពី ការថែទាំជំនួសសម្រាប់កុមារកំព្រា
- រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី គោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅតាមមជ្ឈមណ្ឌលរដ្ឋ និងបានដាក់ជូនអង្គប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី ម្តងរួចហើយ
- ដឹកនាំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) រៀបចំផែនការជាតិ០៥ឆ្នាំបន្ត ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (២០០៦-២០១០) ដែលនឹងស្នើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេចនាពេលខាងមុខនេះ
- បានបង្កើតផែនការជាតិ០៣ឆ្នាំ (២០០៥-២០០៧) សម្រាប់ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ
- បានចេញប្រកាសស្តីពីការបង្កើតក្រុមការងារថ្នាក់ខេត្ត/ក្រុង ប្រយុទ្ធប្រឆាំងការជួញដូរកុមារ និងស្ត្រី ដែលក្រុមការងារថ្នាក់ខេត្ត/ក្រុងនេះ មានតំណាងមកពីស្ថាប័នពាក់ពន្ធ័ នៅក្នុងខេត្តមួយចំនួនដូចជា: អភិបាលខេត្ត/ក្រុង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្នងការដ្ឋាននគរបាលខេត្ត មន្ទីរកិច្ចការនារី មន្ទីរទេសចរណ៍ មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសុខាភិបាល និងតុលាការខេត្ត
- អនុវត្តតាមកិច្ចព្រមព្រៀងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ក្រសួងកំពុងសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័រៀបចំឱ្យមានយន្តការ និងផែនការជាតិសម្រាប់ធ្វើឱ្យមានដំណើរការសហប្រតិបត្តិការទ្វេភាគី ។
- ក្រសួងរៀបចំបង្កើតការិយាល័យប្រឆាំងការជួញដូរមនុស្ស ចំណុះនាយកដ្ឋានសុខមាលភាពសង្គមនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

នៅក្នុងឆ្នាំ២០០៥នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបន្តអនុវត្តគម្រោងកម្មវិធី ដោយបានសង្គ្រោះ ស្តារនីតិសម្បទា សមាហរណកម្ម និងតាមដានជនរងគ្រោះ សរុបចំនួន ១,៨៥៨ នាក់ ក្នុងនោះមានៈ

- ការបញ្ជូនត្រលប់ និងសមាហរណកម្មកុមារ និងស្ត្រីកម្ពុជារងគ្រោះដោយសារការជួញដូរ និងដោយប្រការផ្សេងៗទៀតពីប្រទេសថៃឡង់ដ៏មកកម្ពុជាវិញចំនួន ១៨៦ នាក់ (ក្នុងនោះ មាតុភូមិនិវត្តន៍ចំនួន ៩៨ នាក់ និងនិរទេសចំនួន ៨៨នាក់) ដែលកម្មវិធីនេះបានទទួលការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកា ពីអង្គការ IOM ប្រចាំនៅកម្ពុជា
- ការទទួលកុមារ និងស្ត្រីងាយរងគ្រោះដោយប្រការផ្សេងៗ ជាជនជាតិខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃឡង់ដ៏ មកកម្ពុជាវិញចំនួន ៣លើក សរុបចំនួន ១១៦ នាក់ ដែលបានឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា
- ការធ្វើមាតុភូមិនិវត្តន៍ក្មេងស្រីវៀតណាមរងគ្រោះដោយសារការជួញដូរផ្លូវភេទ ពីកម្ពុជាទៅវៀតណាមវិញ ចំនួន ១០ នាក់ ដែលកម្មវិធីនេះបានទទួលការឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកាពីអង្គការ IOM ប្រចាំនៅកម្ពុជា
- ការទទួលនិងធ្វើសមាហរណកម្ម ជនអនាថាកម្ពុជារងគ្រោះដោយសារការជួញដូរ កេងប្រវ័ញ្ចសុំទាន នៅប្រទេសវៀតណាមសរុបចំនួន ១,២១៦ នាក់ (កុមារ ៨៥៤ នាក់) ដែលបានឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា
- ក្រសួងបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក្នុងការផ្តល់សេវាស្តារនីតិសម្បទា ដល់ស្ត្រី និងកុមាររងគ្រោះដោយអំពើជួញដូរផ្លូវភេទ ដូចជាៈ អង្គការ AFESIP អង្គការ CWCC ។ល។ ដែលមានមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ អប់រំថែទាំសុខភាព ការពិគ្រោះយោបល់ ការសម្របសម្រួលមុខរបរ និងការធ្វើសមាហរណកម្មទៅជួបជុំគ្រួសារសហគមន៍ សរុបចំនួន៣៣០ នាក់
- ដោយជំនួយបច្ចេកទេស និងថវិកាពីអង្គការ UNICEF និងកិច្ចសហប្រតិបត្តិការជាមួយ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបន្តអនុវត្តកម្មវិធីសមាហរណកម្ម និងតាមដានស្ថានភាពជីវភាពរបស់អតិថិជននៅតាមសហគមន៍ ក្នុងគោលបំណងធ្វើឱ្យអតិថិជនទាំងនោះ ព្រមទាំងគ្រួសារផងទទួលបានការគាំទ្រសេវា ការស្តារជីវភាពរស់នៅឱ្យប្រសើរឡើងជាបណ្តើរៗ និងទទួលបានការយល់ដឹងអំពីអនាគតរបស់ពួកគេ តាមរយៈភ្នាក់ងារសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន។ កម្មវិធីនេះពិតជាបានរួមចំណែកទប់ស្កាត់ភាពរងគ្រោះឡើងវិញ ជាពិសេសជនរងគ្រោះដោយអំពើជួញដូរ កេងប្រវ័ញ្ចគ្រប់រូបភាព។

បច្ចុប្បន្ននេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានមណ្ឌលសំចតមួយនៅប៉ោយប៉ែត ដើម្បីផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្នដល់កុមារ និងស្ត្រីដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃ។ នៅក្នុងមជ្ឈមណ្ឌលនេះជនរងគ្រោះអាចស្នាក់នៅបានចំនួន១យប់ ដូច្នេះបុគ្គលិកមណ្ឌលអាចមានពេលសំភាសន៍ពួកគេ និងបញ្ជូនពួកគេទៅតាមអង្គការនានាដែលធ្វើការនៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប និងក្រុងភ្នំពេញ។ នៅពេលអនាគតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងបង្កើតនូវមណ្ឌលសំចតមួយទៀតនៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តកោះកុងសម្រាប់ជនរងគ្រោះ និងជនងាយទទួលរងគ្រោះថ្នាក់ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានអនុវត្តគម្រោង២ទាក់ទងទៅនឹងពលកម្មកុមារ ប៉ុន្តែមិនទាក់ទងដោយផ្ទាល់ទៅនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នោះទេ។ គម្រោងទី១ផ្តោតទៅលើកុមារប្រឈមមុខ

នឹងគ្រោះថ្នាក់ដែលបានទទួលមូលនិធិពីអង្គការ UNICEF និងគម្រោងទី២ គឺគម្រោងពលកម្មកុមារបម្រើតាមផ្ទះ ដែលបានទទួលមូលនិធិ ពីអង្គការ ILO-IPEC[34] ។

គម្រោងពលកម្មកុមារបម្រើតាមផ្ទះ រួមមានកម្មវិធីផ្តល់សេវាសង្គមដល់កុមារបម្រើការងារតាមផ្ទះ ការដកហូតកុមារចេញពីកន្លែងការងារ និងការទប់ស្កាត់កុមារមិនឱ្យចូលធ្វើការងារប្រកបដោយគ្រោះថ្នាក់នេះ។ កម្មវិធីនេះត្រូវបានអនុវត្តរួមគ្នាដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុងភ្នំពេញ អង្គការ VCAO, CC និងអង្គការ WDA ក្នុងក្របខ័ណ្ឌការងាររយៈពេល ៣ ឆ្នាំ។ កម្មវិធីសកម្មភាពត្រូវបានបង្កើតឡើងជាមួយដៃគូអនុវត្ត ។

សកម្មភាពនៅក្នុងគម្រោងនេះរួមមាន ការបណ្តុះបណ្តាល ការបង្កើតកាតតារា[៣៥] ការអប់រំថ្នាក់មត្តេយ្យ ការធ្វើសន្និសីទករណីកុមារ ការថតវីដេអូ និងក្លឹបឃ្លាំមើលកុមារ។ លទ្ធផលចំបងមួយនៃគម្រោងពលកម្មកុមារបម្រើតាមផ្ទះ គឺការបង្កើតរចនាសម្ព័ន្ធជួយគាំទ្រដែលអាចប្រើប្រាស់ ជាចំណុចចាប់ផ្តើមសម្រាប់សកម្មភាព/គម្រោងប្រឆាំងនឹងពលកម្មកុមារ និងការជួញដូរ។ រចនាសម្ព័ន្ធទាំងនេះ រួមមាន:

- ក្រុម Task Force (ក្រុមអង្គការមិនមែនរដ្ឋាភិបាល ប៉ូលីស CNCC មន្ទីរក្រុង និងសេវាបញ្ជូនបន្ត) ប្រជុំរៀងរាល់ ២ខែម្តង
- បណ្តាញការពារកុមារ (នៅក្នុងខ័ណ្ឌដែលបានជ្រើសរើស)
- ក្រុមឃ្លាំមើលតាមសហគមន៍ (នៅក្នុងឃុំដែលបានជ្រើសរើស)
- ក្រុមកុមារសកម្ម និងក្លឹបឃ្លាំមើលតាមសហគមន៍ក្នុងចំណោមកុមារ និងយុវជនក្នុងសាលា

នៅពេលបច្ចុប្បន្ន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកំពុងអនុវត្តការងារក្រោមគម្រោង ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃក្រសួងទេសចរណ៍។ ក្រសួងបានចាប់ផ្តើមការងារនេះតាំងពី ខែសីហា ឆ្នាំ២០០៥ ដោយមានកិច្ចសហការជាមួយក្រសួងទេសចរណ៍ ក្រោមមូលនិធិអង្គការ ILO-IPEC គម្រោង TICW ។

សកម្មភាពមួយ ក្នុងចំណោមសកម្មភាពសំខាន់ៗនៃគម្រោង គឺការប្រមូលទិន្នន័យស្តីពី អាជីវកម្មនានា (រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងកន្លែងទេសចរណ៍ផ្សេងទៀត) និងពីបុគ្គលិកនៅតាមកន្លែងអាជីវកម្មទាំងនេះ

---

៣៤ របាយការណ៍នៃគម្រោងនេះមាននៅអង្គការ UNICEF យោងទៅតាមមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ហើយក្នុងពេលរៀបចំផែនការនេះ មិនមានរបាយការណ៍នេះទេ ។

៣៥ កាតតារាគឺជាឧបករណ៍សម្រាប់លើកកម្ពស់ការយល់ដឹងរបស់គម្រោងកុមារបម្រើការងារតាមផ្ទះ TCRAM ដែលអនុវត្តដោយអង្គការ VCAO និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ចាប់ពីឆ្នាំ ២០០៣ ដល់២០០៥ ។ កាតតារា មានរូបភាពតារាភាពយន្ត និងតារាចំរៀងល្បីៗ ហើយផ្ទាំងម្ខាងទៀត នៃកាតតារាមានលេខទូរស័ព្ទសម្រាប់ទាក់ទងនៅពេលដែលត្រូវជួយ ឬត្រូវរាយការណ៍ពីករណីដែលកុមារមានគ្រោះថ្នាក់។ (Matsuno and Blagbrough, 2005:65)

ក្នុងទីក្រុងភ្នំពេញ។ ការប្រមូលទិន្នន័យ ឬការអង្កេតនេះនឹងធ្វើនៅក្នុងខេត្តសៀមរាប និងក្រុងព្រះសីហនុ ក្រោមកម្មវិធីសកម្មភាពមួយផ្សេងទៀតរបស់មន្ទីរសង្គមកិច្ចខេត្តសៀមរាប និងក្រុងព្រះសីហនុ។ ការអង្កេតនេះ បានចាប់ផ្តើមឡើងក្នុងខែសីហា ឆ្នាំ២០០៥ និងបញ្ចប់ក្នុងខែកុម្ភៈ ឆ្នាំ២០០៦[៣៦] ប៉ុន្តែលទ្ធផលមិនទាន់បានសរសេរជារបាយការណ៍នៅឡើយទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ការអង្កេតនេះមានដែនកំណត់សំភាសន៍តែកន្លែងអាជីវកម្មដែលបានចុះបញ្ជីត្រឹមត្រូវ ហើយផ្តោតតែទៅលើនិយោជក និងនិយោជិតដែលមានប្រាក់បៀវត្សធម្មតាតែប៉ុណ្ណោះ។ មានកន្លែងអាជីវកម្ម និងសេវាកម្មជាច្រើនបានប្រើប្រាស់ស្ត្រីវ័យក្មេងសម្រាប់បម្រើដល់ភ្ញៀវទេសចរ[៣៧] ។ ការអង្កេតពុំបានរកឃើញនូវបញ្ហាទាំងនេះទេ។

ក្រុមគោលដៅនៃការអង្កេតនេះ គឺមាននិយោជកចំនួន ៤៨០នាក់ និងកម្មករចំនួន ២០០នាក់។ ក្រុមការងារដែលធ្វើការអង្កេតនេះរួមមាន សមាជិកមកពីបណ្តាញការពារកុមារចំនួន ៨នាក់។ ការអង្កេតនេះបានកំណត់ជ្រើសរើសក្រុមគោលដៅដោយជ្រើសរើសក្រុមនិយោជក និងបុគ្គលិកដែលត្រូវបានសំភាសន៍សម្រាប់ផ្តល់ការបណ្តុះបណ្តាលស្តីពី យេនឌ័រ សេវាសង្គម និងការបណ្តុះបណ្តាលផ្សេងទៀតស្តីពី ពលកម្មកុមារ និងការជួញដូរ ។

នៅភ្នំពេញ ក្រុងព្រះសីហនុ និងសៀមរាប មានក្រុមនិយោជក និងកម្មករនិយោជិតគោលដៅចំនួន ២៤៤០នាក់ នឹងទទួលបានការបណ្តុះបណ្តាល ក្នុងនោះមាននិយោជកចំនួន៤៤០នាក់ និងបុគ្គលិកចំនួន២០០០នាក់។ ក្នុងចំណោមនិយោជកទាំង ៤៤០នាក់នេះ មានមកពីសណ្ឋាគារចំនួន ៧០នាក់ មកពីផ្ទះសំណាក់ចំនួន១៧០នាក់ និងមកពីភោជនីយដ្ឋានចំនួន២០០នាក់ ហើយម្យ៉ាងទៀតមាន ៦៥០កម្មករនិយោជិតមកពីសណ្ឋាគារ ចំនួន ៥៥០នាក់ មកពីផ្ទះសំណាក់ និងចំនួន ៨០០នាក់ មកពីភោជនីយដ្ឋាន ។

ការបណ្តុះបណ្តាលដំបូងនឹងត្រូវបានផ្តល់ជូនមន្ត្រីនៅទីក្រុងបន្ទាប់មកទៀត ក្រុម Task Force និងបណ្តាញការពារកុមារ ។ មន្ត្រីនៅទីក្រុងមានចំនួន ១២នាក់ (ឧទាហរណ៍: មកពីមន្ទីរទេសចរណ៍២នាក់ មកពីមន្ទីរកិច្ចការនារី ២នាក់ មកពីនាយកដ្ឋានពលកម្មកុមារ២នាក់ និងមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុងភ្នំពេញ៦នាក់។ បន្ទាប់មកទៀតធ្វើការបណ្តុះបណ្តាលដល់សមាជិកក្រុម Task Force ក្រុងភ្នំពេញចំនួន៣០នាក់ ។ សមាជិកបណ្តាញការពារកុមារចំនួន២នាក់ ក៏ត្រូវចូលរួមក្នុងការបណ្តុះបណ្តាលដែរ។ ១រូបមកពីខ័ណ្ឌដូនពេញ និង១រូបទៀតមកពីខ័ណ្ឌឫស្សីកែវ។ គ្រប់ខ័ណ្ឌទាំងអស់មានបណ្តាញការពារកុមារដែលមានសមាសភាគដូចជាអភិបាលរងខ័ណ្ឌ មន្ទីរកិច្ចការនារី ក្រុមប្រឹក្សាឃុំ និងប៉ូលីស ។

[៣៦] បទសំភាសន៍ជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុងភ្នំពេញ

[៣៧] ការសិក្សាស្តីពីស្ត្រីលក់ស្រាបៀរ បានបង្ហាញថា ស្ត្រីលក់ស្រាបៀរ អាចរកប្រាក់ខាងក្រៅបានច្រើនជាងប្រាក់បៀវត្សពីក្រុមហ៊ុន ដូច្នេះទំនាក់ទំនងរវាងនិយោជក និងបុគ្គលិក នៅមានកម្រិតទាប ។

មកដល់ពេលបច្ចុប្បន្ននេះ វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានរៀបចំឡើង ដូចដែលបានបង្ហាញនៅក្នុង តារាង ២ ។

តារាង ២. សេចក្តីសង្ខេបនៃវគ្គបណ្តុះបណ្តាលដែលបានរៀបចំ និងអ្នកចូលរួម

| វគ្គបណ្តុះបណ្តាល | កាលបរិច្ឆេទ | ទីតាំង | អ្នកចូលរួម |
|---|---|---|---|
| វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ | ០១-០៣ មិនា ២០០៦ | ភ្នំពេញ | អ្នកចូលរួម ២០ នាក់មកពីក្រសួងទាំង ៥ សមាគម CHA, CATA សហព័ន្ធសហជីពទេសចរណ៍ និងអង្គការដែលពាក់ព័ន្ធ |
| វគ្គបណ្តុះបណ្តាលគ្រូបង្គោល | ០៩-១០ មិនា ២០០៦ | ក្រុងព្រះសីហនុ | អ្នកចូលរួម ២០ នាក់មកពីមន្ទីរទាំង ៥ អាជ្ញាធរដែនដី និងអង្គការដែលពាក់ព័ន្ធ (e.g., LICADHO, KWCD, etc) |
| វគ្គបណ្តុះបណ្តាលគ្រូបង្គោល | ១៣-១៤ មិនា ២០០៦ | សៀមរាប | អ្នកចូលរួម ២១ នាក់មកពីមន្ទីរទាំង ៥ សមាគម CHA និងអង្គការដែលពាក់ព័ន្ធ (e.g., LICADHO, ADHOC, CWCC, CPCSO, Friends International) |
| វគ្គបណ្តុះបណ្តាលគ្រូបង្គោល | ១៦-១៧ មិនា ២០០៦ | ភ្នំពេញ | អ្នកចូលរួម ២០ នាក់មកពីមន្ទីរទាំង ៥ អាជ្ញាធរដែនដីផ្នែកទេសចរណ៍ និងអង្គការដែលពាក់ព័ន្ធ (e.g., LICADHO, HCC, CWCC, etc) |

### *១.៣ ក្រសួងកិច្ចការនារី (MOWA)*

កម្មវិធីចំបងរបស់ក្រសួងកិច្ចការនារីដែលផ្តោតទៅលើការជួញដូរស្ត្រី និងកុមារមានបង្ហាញនៅក្នុងយុទ្ធសាស្ត្រ តស៊ូមតិឆ្នាំ២០០១-២០០៥នៃក្រសួងកិច្ចការនារី ។ ក្រសួងមានកម្មវិធីមួយឈ្មោះថាកម្មវិធីគាំពារផ្នែកច្បាប់ដល់ស្ត្រី និងកុមារ ។ កម្មវិធីនេះសង្កត់ធ្ងន់ទៅលើសកម្មភាពប្រឆាំងនឹងការជួញដូរមនុស្ស ។ គោលបំណងសំខាន់នៃកម្មវិធីនេះគឺដើម្បីកាត់បន្ថយឧប្បត្តិហេតុនៃការជួញដូរមនុស្ស ជាពិសេសការជួញដូរស្ត្រី និងកុមារ[៣៨] ។ ក្រសួងកិច្ចការនារីបានលើកឡើងនូវវិស័យការងារសំខាន់ៗចំនួន ២ គឺ ទី១- ការប្រយុទ្ធប្រឆាំងនឹងការជួញដូរ តាមរយៈការបង្កើតច្បាប់ និងអនុក្រឹត្យនានា និង ទី២- ការចុះអនុស្សរណៈស្តីពីការយោគយល់គ្នាជាមួយប្រទេសជិតខាង ។

សកម្មភាពប្រយុទ្ធប្រឆាំងនឹងការជួញដូររួមមាន ដូចជា:

[៣៨] ក្រសួងកិច្ចការនារី ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០០៤-២០០៨)

- បង្កើតសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងការជួញដូរ និងតស៊ូមតិអនុម័តសេចក្តីព្រាងច្បាប់នេះជាមួយក្រសួងយុត្តិធម៌
- បង្កើតសេចក្តីព្រាងអនុក្រឹត្យសម្រាប់ច្បាប់ស្តីពី ការប្រឆាំងនឹងការជួញដូរ ជាមួយក្រសួងយុត្តិធម៌
- តស៊ូមតិចំពោះអនុក្រឹត្យស្តីពី ការទប់ស្កាត់ និងការគាំពារជនរងគ្រោះដោយសារការជួញដូរ ព្រមទាំងផ្តល់ជំរកឱ្យពួកគេស្នាក់នៅ
- បន្តធ្វើការតស៊ូមតិ ដើម្បីឱ្យរាជរដ្ឋាភិបាលផ្តល់សច្ចាប័នទៅលើពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ និងការដាក់ទណ្ឌកម្មលើអំពើជួញដូរស្ត្រី និងកុមារបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីបទឧក្រិដ្ឋកម្មឆ្លងព្រំដែន

ការធ្វើវិសោធនកម្មលើច្បាប់ស្តីពី ការបង្ក្រាបការចាប់ពង្រត់ ការជួញដូរ និងការកេងប្រវ័ញ្ចលើមនុស្សកំពុងរង់ចាំការសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រី ។ ច្បាប់ពីមុនដែលមានចំនួន ១០ មាត្រា ឥឡូវនេះត្រូវបានពង្រីកបន្ថែមដល់ទៅ៥២មាត្រា។ ក្រសួងកិច្ចការនារីធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធដើម្បីធ្វើវិសោធនកម្មលើច្បាប់នេះ ។ គេសង្ឃឹមថាច្បាប់នេះនឹងអាចប្រើប្រាស់បាននៅពាក់កណ្តាលឆ្នាំ ២០០៦ ។

វិស័យការងារសំខាន់ទី២ គឺការបង្កើត និងការពង្រឹងទំនាក់ទំនងការងារដោយចុះហត្ថលេខាលើ អនុស្សរណៈស្តីពីការយោគយល់ជាមួយប្រទេសជិតខាង ។ សកម្មភាពជាក់លាក់សម្រាប់អនុវត្តសកម្មភាពនេះមាន ដូចខាងក្រោម៖

- ចូលរួមក្នុងការបង្កើតអនុស្សរណៈស្តីពី ការយោគយល់ជាមួយប្រទេសជិតខាង និងប្រទេសក្នុងតំបន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ
- រៀបចំអនុស្សរណៈស្តីពី ការយោគយល់ទ្វេភាគីជាមួយប្រទេសវៀតណាម និងប្រទេសម៉ាឡេស៊ី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- រៀបចំ និងអនុវត្តផែនការសកម្មភាពរយៈពេល៣ឆ្នាំ ដើម្បីឆ្លើយតបចំពោះអនុស្សរណៈស្តីពីការយោគយល់ទ្វេភាគីជាមួយប្រទេសថៃ
- អនុវត្តយុទ្ធនាការប្រឆាំងការជួញដូរស្ត្រី និងកុមារ (យុទ្ធនាការតស៊ូមតិ យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន យុទ្ធនាការនៅតាមសហគមន៍ និងការស្វែងរកមូលនិធិនៅតាមភូមិ)
- រៀបចំរបាយការណ៍ថ្នាក់ជាតិស្តីពី ការជួញដូរស្ត្រី និងកុមារសម្រាប់អង្គការសហប្រជាជាតិ
- បង្កើតក្រុមការងារ Task Force ថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ ព្រមទាំងធ្វើការពង្រឹង និងពង្រីកកិច្ចសហការជាមួយស្ថាប័ន អង្គការជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ
- សម្របសម្រួលកែប្រែប្រព័ន្ធទិន្នន័យទាក់ទងនឹងឧប្បត្តិហេតុ និងសកម្មភាពអាទិភាព

- យុទ្ធនាការ IEC ប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ
- សម្របសម្រួលការបង្កើត និងការកសាងសមត្ថភាពចែករំលែកព័ត៌មាន តាមរយៈបញ្ជីអាស័យដ្ឋាន
- សម្របសម្រួលគំនិតផ្តួចផ្តើមនានាស្តីពី ការប្រយុទ្ធប្រឆាំងនឹងការជួញដូរនៅថ្នាក់តំបន់ (ប្រទេសកម្ពុជា ប្រទេសវៀតណាម ប្រទេសឡាវ ប្រទេសចិន ប្រទេសថៃ និងប្រទេសភូមា)
- ដើរតួជាលេខាធិការដ្ឋានសម្រាប់អនុវត្តផែនការការងារនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ
- សម្របសម្រួលសកម្មភាពតស៊ូមតិនៅថ្នាក់តំបន់
- ផ្តល់ឱកាសចងក្រងជាឯកសារនូវករណីនៃការជួញដូរនៅថ្នាក់តំបន់ និងថ្នាក់ពិភពលោក

សម្រាប់ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២០០៤-២០០៨ នារីរតនៈទី២ ក្រសួងកិច្ចការនារីមានគោលបំណងកាត់បន្ថយអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រី និងក្មេងស្រី ។

- សហការជាមួយក្រសួងយុត្តិធម៌ ក្នុងការរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស រៀបចំថ្មី និងស្វែងរកការគាំទ្រមតិឱ្យមានការអនុម័ត ។
- សហការជាមួយក្រសួងយុត្តិធម៌ ក្នុងការធ្វើសេចក្តីព្រាងអនុក្រឹត្យស្តីពី ច្បាប់ប្រឆាំងការជួញដូរមនុស្ស ។
- ស្វែងរកកាគាំទ្រមតិក្នុងការរៀបចំអនុក្រឹត្យ ប្រកាសស្តីពីកិច្ចការពារ និងជួយឧបត្ថម្ភជនរងគ្រោះដោយសារការជួញដូរ និងការអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្នបញ្ចូលក្នុងច្បាប់ប្រឆាំងនឹងការជួញដូរ ។
- បន្តស្វែងរកការគាំទ្រមតិ ក្នុងការផ្តល់សច្ចាប័នលើពិធីសារ អង្គការសហប្រជាជាតិ ដើម្បីរារាំងទប់ស្កាត់ និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារបន្ថែមចំពោះអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង ។
- រៀបចំអនុស្សរណៈទ្វេភាគី ស្តីពី ការលុបបំបាត់ការជួញដូរស្ត្រី និងកុមារជាមួយប្រទេសជិតខាង និងតំបន់ ។
- រៀបចំអនុស្សរណៈទ្វេភាគីជាមួយប្រទេសម៉ាឡេស៊ី ស្តីពី ការលុបបំបាត់ការជួញដូរស្ត្រី និងកុមារ

សមិទ្ធិផលសំខាន់ៗពីមុនមានដូចជា ការអនុវត្តន៍ការទប់ស្កាត់គ្រប់ទម្រង់នៃការជួញដូរស្ត្រី និងកុមារនៅក្នុងប្រទេសកម្ពុជា និងការអនុវត្តន៍កម្មវិធីរយៈពេល៣ឆ្នាំដែលទទួលការជួយឧបត្ថម្ភគាំទ្រដោយអង្គការ IOM និងរដ្ឋាភិបាលហ្វាំងឡង់។ កម្មវិធីនេះរួមមាននូវសមាសភាគ៣ចំបងគឺ ការយល់ដឹងផ្នែកច្បាប់ ការតស៊ូមតិគោលនយោបាយ និងការចែកចាយផ្សព្វផ្សាយព័ត៌មាន។ កម្មវិធីនេះត្រូវបានអនុវត្តនៅក្នុងខេត្ត-ក្រុងចំនួន៦(ខេត្តបន្ទាយមានជ័យ ក្រុងប៉ៃលិន ខេត្តកោះកុង ក្រុងព្រះសីហនុ ខេត្តស្វាយរៀង និងក្រុងភ្នំពេញ)។ អង្គការ USAID ក៏បានជួយឧបត្ថម្ភដល់កម្មវិធីស្តីពីការផ្សព្វផ្សាយព័ត៌មានប្រឆាំងនឹងការជួញដូរ។ កម្មវិធីនេះ រួមមានសមាសភាគដូចជា ការលើកកម្ពស់ការយល់ដឹង

សកម្មភាពផ្សព្វផ្សាយព័ត៌មានតាមមូលដ្ឋាន ការប្រមូលព័ត៌មានតាមមូលដ្ឋាន គោលនយោបាយ និងការតស៊ូមតិ។ គម្រោងនេះត្រូវបានអនុវត្តនៅក្នុងខេត្ត-ក្រុងចំនួន ១៨ ក្នុងភូមិដែលមានសកម្មភាពជួញដូរចំនួន ៩០០ ។

ក្នុងកិច្ចសហការជាមួយអង្គការ UNIAP ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៤ ក្រសួងកិច្ចការនារីតាងនាមឱ្យក្រសួងសម្របសម្រួលថ្នាក់ជាតិ បានអនុវត្តនូវសកម្មភាពដូចខាងក្រោមនេះ:

- បង្កើតមូលដ្ឋានចំណេះដឹងស្តីពីការជួញដូរមនុស្សនៅក្នុងប្រទេស។ ប្រព័ន្ធទិន្នន័យនេះរួមមានទីតាំង និងសកម្មភាពនានារបស់គម្រោងដែលទាក់ទងនឹងការដោះស្រាយចំពោះការជួញដូរមនុស្ស។ គោលបំណងសំខាន់ គឺដើម្បីផ្តល់ព័ត៌មានសមស្របដល់អ្នកបង្កើតកម្មវិធីថ្មីៗស្តីពីការជួញដូរ ដូច្នេះវាអាចជៀសវាងនូវការងារជាន់គ្នា ព្រមទាំងអាចបំពេញបន្ថែមចំពោះកង្វះខាតនានា និងអាចសម្របសម្រួលនូវកិច្ចសហការ និងកិច្ចប្រតិបត្តិការល្អ។ ប្រការនេះក៏អាចនឹងជំរុញឱ្យម្ចាស់ជំនួយ ធានាមិនឱ្យមានការងារជាន់គ្នា ចំពោះគោលការណ៍ផ្តល់មូលនិធិរបស់ខ្លួន ។
- កំណត់ និងជួយគាំទ្រចំពោះសកម្មភាពអាទិភាពទាក់ទងទៅនឹងការជួញដូរ
- ជួយគាំទ្រចំពោះបទអន្តរាគមន៍នានាដែលឆ្លើយតបចំពោះកង្វះខាតទាំងនេះ
- សម្របសម្រួល និងពង្រឹងនូវការតស៊ូមតិរវាងដៃគូ រដ្ឋាភិបាល និង អង្គការ/ស្ថាប័នផ្សេងទៀត

### *១.៤ ក្រសួងមហាផ្ទៃ (MOI)*

ក្រសួងមហាផ្ទៃ គឺជាភ្នាក់ងារ/ស្ថាប័នក្នុងរដ្ឋាភិបាលដែលមានភារកិច្ច/ការទទួលខុសត្រូវទប់ស្កាត់ ស៊ើបអង្កេត និងបង្ក្រាបករណីស្តីពីការជួញដូរដោយគោរពទៅតាមច្បាប់ស្តីពី ការបង្ក្រាបការចាប់ពង្រត់ និងការជួញដូរមនុស្សដែលបានអនុម័តនៅថ្ងៃទី ០២ ខែមករា ឆ្នាំ១៩៩៦ ព្រមទាំងគោរពទៅតាមផែនការសកម្មភាពជាតិ ៥ឆ្នាំ ប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារឆ្នាំ២០០០-២០០៤ (NPA-TSEC)។ ក្រសួងមហាផ្ទៃមានស្នងការដ្ឋាននគរបាលជាតិទៅដល់ថ្នាក់ខេត្ត ដោយមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន កងរាជអាវុធហត្ថ ប៉ូលីសព្រំដែន និងអាជ្ញាធរថ្នាក់ជាតិ និងអន្តរជាតិនានាទៀត ដើម្បីធ្វើការលើកកម្ពស់ការយល់ដឹងស្តីពី ច្បាប់ទាក់ទងទៅនឹងការជួញដូរមនុស្ស ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីប៉ូលីសដែលទទួលបន្ទុកការងារនេះ។

យោងតាមរបាយការណ៍លេខ២២១ រ.ប.ក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥ របស់អគ្គស្នងការនគរបាលជាតិ **ក្រសួងមហាផ្ទៃ** បានដាក់ចេញនូវ **ផែនការសកម្មភាពលេខ ០២៣ ផ.ក ចុះថ្ងៃ ទី១៣ ខែ កក្កដា ឆ្នាំ ២០០៥** ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ក្នុងនោះក្រសួងមហាផ្ទៃ បានសម្រេចនូវគោលបំណងសំណូមពរដូចខាងក្រោម :

- អនុវត្តឱ្យកាន់តែមានប្រសិទ្ធិភាពនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។
- ការពារប្រជាពលរដ្ឋ ពលករ ជាពិសេសស្ត្រី និងកុមារឱ្យរួចចាកផុតពីការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទ។
- លើកកម្ពស់ការចូលរួមយ៉ាងសកម្មពីសហគមន៍ ពីសង្គមស៊ីវិល និងបណ្តាស្ថាប័ន ក្នុងវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើមនុស្សតាមគ្រប់រូបភាព ។
- ចូលរួមយ៉ាងសកម្មក្នុងចលនារួមរបស់សហគមន៍តំបន់ និងអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមទាក់ទិនទៅនឹងការជួញដូរ ការរត់ពន្ធមនុស្ស និងការធ្វើអាជីវកម្មលើស្ត្រី និងកុមារ ។
- លើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការអនុវត្តន៍ច្បាប់ គោរពត្រឹមត្រូវតាមនីតិវិធី និងមានតម្លាភាព ក្នុងការស៊ើបអង្កេតលើករណីជួញដូរ រត់ពន្ធមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដើរទន្ទឹមនឹងការជំរុញឱ្យមានដំណើរការក្តីតាមផ្លូវតុលាការលើករណីខាងលើនេះបានជាអតិបរិមា។ ខិតខំលុបបំបាត់ចោលបាតុភាពអសកម្ម ក្នុងចំណោមមន្ត្រីអនុវត្តច្បាប់ដោយអនុវត្តម៉ឺងម៉ាត់វិន័យផ្ទៃក្នុង និងច្បាប់ជាធរមាន ។

ក្រសួងមហាផ្ទៃមានផែនការសកម្មភាពជាច្រើនៈ

១. វិធានការគ្រប់គ្រងមុខសញ្ញា ( **មាន ០៥ចំណុចសម្រាប់អនុវត្ត** )

២. វិធានការបង្ការ ទប់ស្កាត់ ( **មាន ០៨ចំណុចសម្រាប់អនុវត្ត** )

៣. វិធានការបង្ក្រាប ( **មាន ០៦ចំណុចសម្រាប់អនុវត្ត** )

៤. កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ - អន្តរជាតិ និងការកសាងសមត្ថភាព ( **មាន ០៧ចំណុច សម្រាប់អនុវត្ត** )

ផែនការសកម្មភាពនេះសម្រាប់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការពង្រត់មនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តអនុក្រឹត្យលេខ ៤០ សជ.បក ស្តីពីការបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (DAHTJP)។ មួយឆ្នាំក្រោយមក ការិយាល័យប្រឆាំងនឹងការជួញដូរមនុស្ស និងកាពារអនីតិជន ត្រូវបានបង្កើតឡើងនៅទូទាំង ២៤ ខេត្ត-ក្រុង ដោយមានប្រព័ន្ធខ្សែទូរស័ព្ទ ២៤ម៉ោងលើ ២៤ម៉ោង ដែលមានលេខ ០២៣ ៧២០ ៥៥៥ និង០២៣ ៩៩៤ ៩៥៥។ ការិយាល័យទាំងនេះមានផ្នែកចំនួន១៧ និងមន្ត្រីបុគ្គលិកចំនួន៧រូប។ មកដល់ពេលបច្ចុប្បន្ននេះ ស្នងការប៉ូលីសនៃក្រសួងមហាផ្ទៃមានការិយាល័យប្រឆាំង នឹងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន១០ បន្ថែមទៀត ។

បច្ចុប្បន្ននេះ មានប្រព័ន្ធខ្សែទូរស័ព្ទ២៤ម៉ោង លើ២៤ម៉ោង ក្រោមការជួយគាំទ្រដោយអង្គការ WVI និង UNICEF ក្នុងខេត្តៈ

- ស្នងការនគបាលខេត្ត សៀមរាប លេខៈ ០១២ ១៨១៧ ២៨០
- ស្នងការនគបាលខេត្តបន្ទាយមានជ័យ លេខៈ ០១២ ១៨១៧ ២៨១
- ស្នងការនគបាលក្រុងព្រះសីហនុ លេខៈ ០១២ ១៨១៧ ២៨២

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន (DAHTJP) មានភារកិច្ច និងការទទួលខុសត្រូវទប់ស្កាត់ និងអនុវត្តវិធានការប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរមនុស្ស ការចាប់រំលោភ និងសកម្មភាពអសីលធម៌ផ្សេងទៀត។ នាយកដ្ឋាននេះមានមន្ត្រីបុគ្គលិកប្រមាណជា ១៦០នាក់ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធាននាយកដ្ឋានប៉ូលីសភេទស្រី ០១រូប។ រចនាសម្ព័ន្ធរបស់នាយកដ្ឋាននេះមានដូចតទៅៈ ការិយាល័យប្រតិបត្តិចំនួន៥នៅថ្នាក់ជាតិ (ការិយាល័យរដ្ឋបាល ការិយាល័យការពារអនីតិជន ការិយាល័យប្រឆាំងការកេងប្រវ័ញ្ចលើមនុស្ស ការិយាល័យព័ត៌មានបច្ចេកវិទ្យា និងការិយាល័យច្បាប់) ប្រព័ន្ធទូរស័ព្ទ ២៤ ម៉ោងលើ ២៤ ម៉ោង (ភ្នំពេញ ០២៣ ៧២០ ៥៥៥-០២៣ ៩៩៤ ៩៥៥-០១២ ៩៩៩ ៩៩៩-ក្រុងព្រះសីហនុ ០១៦ ៨៤០ ៥៦៥-០១៦ ៨៤០ ៦៥៦-០១៦ ៩៥១ ៦៨៤-០១២ ៨១៧ ២៨១) ដែលអាចឆ្លើយបានជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាវៀតណាម ការិយាល័យប្រឆាំងការកេងប្រវ័ញ្ចលើមនុស្សនៅថ្នាក់ខេត្តចំនួន៧ ព្រមទាំងការិយាល័យខេត្ត-ក្រុងផ្សេងទៀតចំនួន ១៧ ។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានកម្មវិធីកំពុងបន្តមួយដែលធ្វើការលើកកម្ពស់ការយល់ដឹងនៅតាមសាលារៀននៅក្នុងទីក្រុងភ្នំពេញ។ បច្ចុប្បន្ន កម្មវិធីនេះបានធ្វើនៅក្នុងសាលារៀនចំនួន៩ ដោយមានអ្នកតំណាងសាលារៀនចំនួន២នាក់ធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីប៉ូលីស។ ក្នុងកិច្ចសហការជាមួយបេសកកម្មយុត្តិធម៌អន្តរជាតិ នាយកដ្ឋាននេះក៏បានធ្វើការបង្រៀនលើកកម្ពស់ការយល់ដឹង ដល់ក្មេងប្រមាណជា៩០០នាក់ ដែលទៅលេងនៅស្វាយប៉ាក ដែលជាកន្លែងពេស្យាចារ ដ៏ល្បីឈ្មោះមួយនៅក្រុងភ្នំពេញ។ នៅក្នុងឆ្នាំ២០០៤ នាយកដ្ឋានបានស៊ើបអង្កេតករណីចំនួន១០៦ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទ ការចាប់ពង្រត់ អំពើអបាយមុខ និងការជួញដូរឆ្លងព្រំដែន។ ក្នុងចំណោមករណីទាំងអស់នេះ អ្នកជួញដូរចំនួន ១១៤នាក់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់តុលាការ ហើយជនរងគ្រោះចំនួន ៣៦៦នាក់ ត្រូវបានជួយសង្គ្រោះ (ជនរងគ្រោះភាគច្រើន គឺជាកុមារដែលមានអាយុតិចជាង ១៨ ឆ្នាំ)[៣៩] ។

ក្នុងឆ្នាំ ២០០៣ នាយកដ្ឋានបានសម្រេចនូវលទ្ធផលខាងក្រោមនេះ (រួមមានការជួញដូរ និងការរំលោភផ្លូវភេទជាពិសេសទៅលើកុមារ)ៈ មានករណីបណ្តឹងចំនួន ២៥៧ សំណុំរឿង ហើយសំណុំរឿងចំនួន ១៧៧ ត្រូវបានប្តឹងតាម

[៣៩] របាយការណ៍ប្រទេសកម្ពុជា ការពិគ្រោះយោបល់អន្តរក្រសួងថ្នាក់អនុតំបន់ស្តីពីការជួញដូរមនុស្ស ខែឧសភា ឆ្នាំ ២០០៥

ទូរស័ព្ទ។ ក្នុងចំណោមករណីបណ្តឹងទាំងអស់ មានករណីចំនួន ២២៧ ត្រូវបានតាមដាន (ករណីចំនួន ២១៣ ត្រូវបានស៊ើបអង្កេតយ៉ាងសកម្ម ចំណែកឯករណីចំនួន១៤ មិនត្រូវបានស៊ើបអង្កេតដោយសកម្មនោះទេ)។ ជារួមជនសង្ស័យចំនួន ២៧១នាក់ ត្រូវបានឃាត់ខ្លួន និងបានបញ្ជូនទៅតុលាការ ហើយជនរងគ្រោះចំនួន៤២៧នាក់ត្រូវបានជួយសង្គ្រោះ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានការលំបាកក្នុងការស្វែងរកព័ត៌មានស្តីពី ពាក្យបណ្តឹងដែលទទួលបានជោគជ័យ និងព័ត៌មានស្តីពីចំនួនអ្នកជួញដូរដែលត្រូវបានកាត់ទោស[៤០] ។

ក្រសួងមហាផ្ទៃ ក៏បានផ្តល់ការបណ្តុះបណ្តាលស្តីពី បញ្ហាផ្នែកច្បាប់ និងបច្ចេកទេសនៃការស៊ើបអង្កេតដល់ប៉ូលីស និងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ជ្រាបបញ្ហានៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ។ ក្រសួងក៏បានធ្វើការផ្សព្វផ្សាយពីច្បាប់ និងបញ្ហានៃការជួញដូរ ដល់សិស្សនៅតាមសាលារៀន សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ បារ រង្គសាល ហាងម៉ាស្សា និងហាងកាត់សក់ នៅទូទាំងប្រទេស។

### ១.៥ ក្រសួងទេសចរណ៍ (MOT)

កម្មវិធីចំបងនៅពេលបច្ចុប្បន្ននៅក្នុងវិស័យទេសចរណ៍ ដែលដោះស្រាយចំពោះបញ្ហាការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺកម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃក្រសួងទេសចរណ៍។ គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ឬ "គណៈកម្មការស្តីពី ការទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍" ត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ ២០០១ ដោយមានការសហការរវាងក្រសួងទេសចរណ៍ និងអង្គការទស្សនពិភពលោកកម្ពុជា World Vision-Cambodia។ គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីប្រកាស ដែលមានសមាជិកភាពពីមន្ត្រីជាន់ខ្ពស់នានានៅក្នុងក្រសួង។ ក្នុងខែមិនា ឆ្នាំ២០០៥ ប្រកាសលេខ ៣៧ប្រក-អរហ បានពង្រឹងបន្ថែមទៅលើការបង្កើតដំណើរការ និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

កម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍មានគោលបំណង២គឺ បង្កើនចំណេះដឹង និងការយល់ដឹងស្តីពី បញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ និងធ្វើឱ្យប្រសើរឡើងនូវការទប់ស្កាត់ និងការពារកុមារនៅតាមកន្លែងអាជីវកម្ម និងសេវាកម្មទេសចរណ៍តាមតំបន់ទេសចរណ៍គោលដៅ ។ ការទទួលខុសត្រូវរបស់កម្មវិធីមានដូចខាងក្រោម៖

- "សហការជាមួយអង្គការ World Vision និងអង្គការផ្សេងទៀត ព្រមទាំងក្រុម/ស្ថាប័នដែលពាក់ព័ន្ធនានា ដើម្បីអនុវត្តគោលការណ៍ និងច្បាប់រដ្ឋាភិបាលឱ្យមានប្រសិទ្ធិភាពក្នុងការលើកកម្ពស់ការយល់ដឹងស្តីពី សិទ្ធិកុមារ"

---

[៤០] តួនាទីរបស់ភ្នាក់ងារជួយគាំទ្រដល់ជនរងគ្រោះ នៅក្នុងការឆ្លើយតបយុត្តិធម៌ផ្នែកព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស - មេរៀនបទ ពិសោធន៍ទទួលបានពីប្រទេសថៃ ប្រទេសកម្ពុជា សាធារណៈរដ្ឋឡាវ និង ប្រទេសមីយ៉ាន់ម៉ា, ARCPPT ខែ មិថុនា ឆ្នាំ ២០០៤

- បង្កើតផែនការ និងដោះស្រាយចំពោះរាល់ទម្រង់នៃការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- ធ្វើការឆ្លុះបង្ហាញផ្តួចផ្តើម និងផ្តល់ព័ត៌មានដល់ក្រសួងពាក់ព័ន្ធ ដើម្បីគ្រប់គ្រង/សង្កេត ត្រួតពិនិត្យ និងអនុម័តទៅលើគោលនយោបាយទប់ស្កាត់ស្តីពី ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- កសាងសមត្ថភាពបុគ្គលិកដើម្បីលើកកម្ពស់ការយល់ដឹងស្តីពី សិទ្ធិកុមារ ការទប់ស្កាត់ និងការជួញដូរកេងប្រវ័ញ្ចលើកុមារនៅក្នុងវិស័យទេសចរណ៍ដល់មន្ត្រីពាក់ព័ន្ធនានា រួមមានដូចជាម្ចាស់ផ្ទះសំណាក់ និងសហគមន៍ទេសចរណ៍នានា

គណៈកម្មការ មានលេខាធិការដ្ឋានរបស់ខ្លួន ដែលមានភារកិច្ចសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអង្គការ World Vision Cambodia និងអង្គការជាតិ និងអន្តរជាតិផ្សេងទៀត ដែលធ្វើការងារទាក់ទងទៅនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។ ក្រៅពីផ្នែករដ្ឋបាល លេខាធិការដ្ឋានក៏មានភារកិច្ចដូចខាងក្រោមនេះៈ

- ចងក្រងផលិត និងលើកកម្ពស់សៀវភៅណែនាំបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់កុមារពីការកេងប្រវ័ញ្ច និងការជួញដូរនៅក្នុងវិស័យទេសចរណ៍
- លើកកម្ពស់សិទ្ធិកុមារ និងផ្សព្វផ្សាយពីគុណវិបត្តិដែលកើតឡើងពីការកេងប្រវ័ញ្ច និងការជួញដូរកុមារនៅតាមផ្ទះសំណាក់ សណ្ឋាគារ និងសហគមន៍ទេសចរណ៍នានា
- ស្វែងរកមធ្យោបាយ និងបង្កើតផែនការសកម្មភាពដើម្បីកាត់បន្ថយការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរលើកុមារ
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃសកម្មភាពរបស់គណៈកម្មការ និងផ្តួចផ្តើមសរសេរសំណើសុំថវិកា

ក្នុងខែមេសា ឆ្នាំ២០០២ រដ្ឋមន្ត្រីនៃក្រសួងទេសចរណ៍ ស្នើសុំឱ្យមានការបង្កើតគណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅទូទាំង ២៤ ខេត្ត-ក្រុង។ គណៈកម្មការទាំងនេះនឹងធ្វើជាយន្តការចូលរួមចំណែកអនុវត្តច្បាប់ និងគោលការណ៍ថ្នាក់ជាតិនានាស្តីពី ការការពារកុមារចេញពីការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទឱ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងវិស័យទេសចរណ៍។ ប្រការនេះអាចធ្វើឡើងតាមរយៈការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពដល់មន្ត្រីរាជការក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៅតាមកន្លែងអាជីវកម្ម នៅតាមកន្លែងប្រមូលផ្តុំភ្ញៀវទេសចរ និងនៅតាមសហគមន៍ទេសចរណ៍នានាស្តីពី សិទ្ធិកុមារ អនុសញ្ញាអន្តរជាតិនានាទាក់ទងនឹងកុមារ គោលនយោបាយជាតិ និងយន្តការរដ្ឋាភិបាលនានាដែលមាន ព្រមទាំងការប្តេជ្ញានានារបស់រដ្ឋាភិបាលចំពោះកិច្ចព្រមព្រៀង និងពិធីសារអន្តរជាតិនានាដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មទៅលើកុមារ ។

ក្នុងឆ្នាំនោះដែរ ផែនការសកម្មភាពត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាបដើម្បីលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

នៅក្នុងវិស័យទេសចរណ៍។ ផែនការសកម្មភាពនេះ គឺជាគម្រោងសាកល្បងរបស់ក្រសួងទេសចរណ៍ ក្រោមកម្មវិធីស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

រហូតមកឆ្នាំ២០០៥ សមិទ្ធិផលសំខាន់ៗនៃគម្រោងរបស់ក្រសួងទេសចរណ៍ មានដូចខាងក្រោមនេះ:

- ធ្វើការបណ្តុះបណ្តាលជនបង្គោលចំនួន ៦លើក ដល់អ្នកចូលរួមសរុបចំនួន៣៦០នាក់ នៅថ្នាក់ជាតិក្នុងចំណោមអ្នកប្រតិបត្តិការផ្នែករដ្ឋ និងផ្នែកឯកជននៅក្នុងវិស័យទេសចរណ៍
- ផ្តល់ការបណ្តុះបណ្តាលនៅថ្នាក់សហគមន៍ដល់:
  - កុមារចំនួន ២.៤៩២ នាក់ ( ស្រី ១.៣៨០) និង ឪពុកម្តាយចំនួន ១៤៥ នាក់
  - អាជ្ញាធរដែនដីចំនួន៩៩នាក់ និងគ្រូបង្រៀនចំនួន៥៦នាក់
  - ក្រុមមិត្តអប់រំមិត្តចំនួន៤៤ ក្រុម
- ក្នុងកិច្ចសហការជាមួយអង្គការ Child Wise Australia
  - ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ភាពវៃឆ្លាតរបស់កុមារ ដល់អ្នកចូលរួមចំនួន៧០នាក់ នៅក្នុងខេត្តបន្ទាយមានជ័យ
  - ធ្វើការបណ្តុះបណ្តាលស្តីពីភាពវៃឆ្លាតរបស់កុមារ ដល់អ្នកចូលរួមចំនួន៦០នាក់ នៅក្នុងខេត្តក្រចេះ
  - ដាក់រូបភាព និង ផ្លាកសញ្ញានៅតាមដងផ្លូវធំៗ និងនៅតាមតំបន់ទេសចរណ៍នៅក្នុងខេត្ត
  - ផលិតស្លាកស្អិត Stickers ប័ណ្ណផ្សព្វផ្សាយ Posters សៀវភៅតូច CST booklets

គម្រោងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នឹងបន្តក្នុងរយៈពេល៣ឆ្នាំខាងមុខ ដោយមានភាពជាដៃគូជាមួយអង្គការ World Vision Cambodia ដែលមាននៅក្នុងការអនុម័តលើប្រកាសលេខ ០៣៧ ប្រក-អរហ ចុះថ្ងៃទី ០៧ ខែមិនា ឆ្នាំ២០០៥ ។

នៅពេលបច្ចុប្បន្ន មានការព្រួយបារម្ភមួយចំនួន ដែលជំរុញឱ្យក្រសួងទេសចរណ៍បន្តពង្រឹង និងកែលំអលើកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នក្នុងការជំរុញ និងសម្រេចឱ្យបាននូវគោលដៅស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ ការព្រួយបារម្ភទាំងនេះគឺជាចក្ខុវិស័យរបស់រដ្ឋមន្ត្រី[៤១] ក្រសួងទេសចរណ៍នៅពេលបច្ចុប្បន្នដោយសង្កត់ធ្ងន់ទៅលើខ្លឹមសារនៃសេចក្តី

[៤១] ការពិភាក្សាជាមួយឯកឧត្តម ឡាយ ព្រហស្ស រដ្ឋមន្ត្រីក្រសួងទេសចរណ៍ លោក K.B. Thuraising Ham ទីប្រឹក្សាក្រសួងទេសចរណ៍ លោក សៀង គឹមហាន អគ្គនាយករងទេសចរណ៍ លោក សៅ សារឿន អធិការ និង លោក អ៊ុំ ឃឹម អនុប្រធាននាយកដ្ឋានឧស្សាហកម្ម នាថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៥

ព្រាងច្បាប់ទេសចរណ៍ និងការកែប្រែ/ការកែលំអជាចាំបាច់ទៅលើ សេចក្តីប្រកាសនានាស្តីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

- ខ្លឹមសារចំបងនៃការចងក្រងប្រកាសរបស់ក្រសួងទេសចរណ៍ សង្កត់ធ្ងន់ទៅលើនីតិវិធីផ្តល់អាជ្ញាប័ណ្ណ ដល់កន្លែងអាជីវកម្មទេសចរណ៍។ នីតិវិធីផ្តល់អាជ្ញាប័ណ្ណទេសចរណ៍បច្ចុប្បន្នមាន ១១ ជំហានជាផ្លូវការ ដែលបង្កើតឱ្យមានភាព "ស្មុគស្មាញ" និងជាហេតុបង្កឱ្យមានការខកខានពេលវេលាដល់ដំណើរការផ្តល់អាជ្ញាប័ណ្ណ។ ដូច្នេះត្រូវពិចារណាទៅលើវិធានការកែលំអដំណើរការទាំងនេះឱ្យមានភាពសាមញ្ញ។ រឿងដែលកំពុងត្រូវបានពិចារណាមាន២ចំណុចគឺ:
  -ទី១ត្រូវធ្វើឱ្យអាជីវកម្មទាំងឡាយគោរពច្បាប់ឱ្យបានត្រឹមត្រូវ និងជួយគាំទ្រដល់ការប្រឆាំងនឹងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មទៅលើកុមារ និង
  -ទី២ គឺត្រូវធានាមិនលើកទឹកចិត្តចំពោះកុមារដែលធ្វើពលកម្ម ។

- គោលគំនិតដែលចង់ឱ្យបុគ្គលិកកម្មករមានសៀវភៅការងារកំពុងស្ថិតនៅក្រោមការពិចារណាផងដែរ។ ប្រការនេះក៏អាចស្ថិតនៅក្នុង ដំណើរការដ៏ស្មុគស្មាញមួយ។ ទោះបីជាមានការគោរពទៅលើប្រព័ន្ធធ្វើអត្តសញ្ញាណ/ប័ណ្ណគ្រួសារសម្រាប់ប្រជាជនក៏ដោយ ក៏ដំណើរការនៃការចុះឈ្មោះនៅតាមមូលដ្ឋាន និងនៅតាមក្រុមប្រឹក្សាឃុំ សង្កាត់មិនទាន់បានបញ្ចប់នៅឡើយទេ។ ដូច្នេះក្រសួងទេសចរណ៍អាចស្វែងរកមធ្យោបាយចុះឈ្មោះបុគ្គលិកកម្មករ តាមរបៀបផ្សេងសម្រាប់ធ្វើបណ្ណ័ការងារ។ ប្រការនេះត្រូវមានការចុះឈ្មោះតាមប្រព័ន្ធ Hardware (ទាមទារឱ្យមានម៉ាស៊ីនថតរូបឌីជីតាល់ និងម៉ាស៊ីនស្កេន)។ ការផ្តល់អាជ្ញាប័ណ្ណក៏អាចធ្វើបានតាមរយៈអ៊ីនធឺណែត/គេហ៍ទំព័រផងដែរ ប៉ុន្តែដំណើរការនេះអាចធ្វើបាន លុះត្រាតែមានការសម្របសម្រួលជាមួយស្ថាប័ននៅតាមមូលដ្ឋាន (តំបន់សាកល្បង) និងការជួយគាំទ្រយ៉ាងសកម្មពីសំណាក់មន្ត្រីប៉ូលីស ។

- ការត្រួតពិនិត្យលើបុគ្គលិកកម្មករ និងកន្លែងអាជីវកម្មនានាចាំបាច់ត្រូវតែមានប្រព័ន្ធអធិការកិច្ច ដែលរឹងមាំជាងនេះ។ ប្រការនេះទាមទារឱ្យមានការចុះអនុស្សរណៈស្តីពីការយោគយល់គ្នាជាមួយក្រសួងផ្សេងទៀត ។

### ២. អង្គការពលកម្មអន្តរជាតិ- កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (ILO-IPEC)

អង្គការ ILO/IPEC កំពុងធ្វើការទប់ស្កាត់ការជួញដូរ និងកេងប្រវ័ញ្ចពលកម្មលើកុមារ និងស្ត្រី ទន្ទឹមពេលនេះដែរធ្វើការលើកកម្ពស់ការងារសីលធម៌ និងការនិរប្រវេសន៍ប្រកបដោយប្រសិទ្ធិភាពនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសនានា នៅក្នុងមហាអនុតំបន់មេគង្គ ។

ដោយមានការជួយគាំទ្រពីគម្រោង ILO-IPEC TICW និងអង្គការ UNICEF ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) បានចាប់ផ្តើមធ្វើការប៉ាន់ប្រមាណ និងពិនិត្យឡើងវិញទៅលើផែនការ ៥ឆ្នាំ (២០០០-២០០៤) ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ ដោយផ្តោតទៅលើផ្នែកចំនួន៤ គឺការទប់ស្កាត់ ការការពារ ការស្តារឡើងវិញ និងការធ្វើសមាហរណកម្ម ។ ការរកឃើញ[៤២] ដែលទទួលបានពីការប៉ាន់ប្រមាណនេះមាន៖

- ត្រួតពិនិត្យ និងវាយតម្លៃការរីកចម្រើន
  - ផែនការលើកទី១ មិនបានបង្ហាញពីក្របខ័ណ្ឌការងារសម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃការរីកចម្រើន ការផ្លាស់ប្តូរ និងផលប៉ះពាល់ទៅលើ TSEC
- គ្រប់គ្រង និងសម្របសម្រួល
  - មានការយកចិត្តទុកដាក់តិចតួច ក្នុងការបង្កើតយន្តការសម្រាប់កែលំអការសម្របសម្រួល
- ប្រមូល និងចែកចាយព័ត៌មាន
  - មានព័ត៌មាន និងទិន្នន័យស្តីពី TSEC ប៉ុន្តែមិនត្រូវបានរៀបចំឱ្យបានល្អ និងមិនមានប្រភពច្បាស់លាស់

ការប៉ាន់ប្រមាណ និងការពិនិត្យឡើងវិញនេះមានគោលបំណង ដើម្បីបង្កើតផែនការសកម្មភាពជាតិ៥ឆ្នាំមួយថ្មីទៀត ដោយផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការជួញដូរមនុស្ស និងយុទ្ធនាការប្រឆាំងនឹងការកេងប្រវ័ញ្ចអាជីវកម្មផ្លូវភេទលើមនុស្ស។ ផែនការ៥ឆ្នាំខាងមុខនេះ មានគោលបំណងដើម្បីឆ្លុះបញ្ចាំងទៅលើការរីកចម្រើនដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន និងឆ្លុះបញ្ចាំងទៅលើស្ថានភាពជាក់ស្តែងដែលបានកើតឡើង និងបញ្ហានានាដែលប្រទេសកំពុងតែប្រឈមមុខ ក្នុងខណៈដែលខ្លួនព្យាយាមលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

ប្រទេសកម្ពុជា គឺជាប្រទេសសមាជិកមួយក្នុងគម្រោងអនុតំបន់ទន្លេមេគង្គរបស់អង្គការ ILO-IPEC ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រីដំណាក់កាលទី ២ (គម្រោង ILO-IPEC TICW)[៤៣] ។ គម្រោង ILO-IPEC TICW មានគោលបំណងចូលរួមចំណែកក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រីដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកេងប្រវ័ញ្ចពលកម្ម តាមរយៈវិធានការទប់ស្កាត់មួយចំនួននៅតាមតំបន់ទទួល តំបន់បញ្ជូន និងតំបន់សំចត។

[៤២] សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍ប៉ាន់ប្រមាណវាយតម្លៃទៅលើ NPA-TSEC

[៤៣] ការអនុវត្តន៍ល្អ និង មេរៀនបទពិសោធន៍នៃសកម្មភាពគម្រោងនៅក្នុងដំណាក់កាលទី ១ និង របាយការណ៍នៃកិច្ចប្រជុំ NSOE នៅថ្ងៃទី ៤-៥ ខែមិនា ឆ្នាំ ២០០៤ ស្តីពីការកំណត់ខេត្ត និង ផ្នែកគោលដៅ ។

# ម៉ូឌុល ៤ ៖ លើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

## គោលបំណងនៃម៉ូឌុល

១. ដើម្បីកំណត់កម្មវិធី និងសកម្មភាពនានា ក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

**សកម្មភាព ១** ហៅធ្វើសកម្មភាព

**មេរៀន**

ក. លើកកម្ពស់ទេសចរណ៍សុវត្ថិភាព ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស

ខ. គាំទ្រសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព

គ. ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពការងារ និងស្ថានភាពរស់នៅរបស់កុមារ និង ស្ត្រីធ្វើការ

ឃ. ធ្វើឱ្យប្រសើរឡើងចំពោះការអនុវត្តន៍បទបញ្ញត្តិវិស័យទេសចរណ៍

ង. ធ្វើឱ្យប្រសើរឡើងនូវការការពារ និងសេវាសង្គម

ច. កិច្ចសហការ និងសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សហជីព និយោជក និងអង្គការមិនមែនរដ្ឋាភិបាល

១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាស៊ីក្នុងការទប់ស្កាត់ការជួញដូរមនុស្ស (ARCCPT)

២. សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)

៣. សហព័ន្ធនិយោជកកម្ពុជា និងសមាគមពាណិជ្ជកម្ម CAMFEBA

៤. សមាគមសណ្ឋាគារកម្ពុជា (CHA)

៥. សហព័ន្ធសហជីពសេវាកម្មទេសចរណ៍កម្ពុជា (CTSWF)

៦. អង្គការ COSECAM

៧. គម្រោងភាពវៃឆ្លាតលើកុមារ ECPAT

៨. គម្រោងការពារសិទ្ធិកុមារក្នុងវិស័យទេសចរណ៍ - *អង្គការមិត្តសំឡាញ់- FI*

៩. គម្រោងកម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃអង្គការ World Vision Cambodia

## ម៉ូឌុល ៤ ៈ ការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

សកម្មភាព ៤.១: ហៅឱ្យធ្វើសកម្មភាព

ពេលវេលា ៣០ នាទី

របៀបអនុវត្តសកម្មភាពនេះ

១.អ្នកចូលរួមត្រូវបានស្នើឱ្យចាត់ជាក្រុមទៅតាមព័ត៌មានដែលអ្នកសម្របសម្រួលប្រាប់។ ឧទាហរណ៍នៅពេលដែលអ្នកសម្របសម្រួលនិយាយថា "ចាត់ក្រុមដោយយោងទៅតាមអាយុ អ្នកដែលមានអាយុក្រោម ២០ឆ្នាំ ជា ១ក្រុម អាយុក្រោម ៣០ឆ្នាំ ជា ១ក្រុមទៀត អាយុក្រោម ៤០ឆ្នាំ ជា ១ក្រុមទៀត និងអ្នកដែលមានអាយុ ៥០ឆ្នាំ និងលើសពីនេះ..." "ចាត់ក្រុមតាមពណ៌ខោអាវ...."

២.បន្ទាប់មកទៀត អ្នកចូលរួមត្រូវស្វែងរកក្រុមដែលដូចនឹងខ្លួន។ នៅពេលដែលក្រុមត្រូវបានបង្កើតឡើងអ្នកសម្របសម្រួលនឹងសួរក្រុមនីមួយៗឱ្យគិតពីឃ្លាស្តីពី "លើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីវ័យក្មេងនៅក្នុងវិស័យទេសចរណ៍..."

៣.ផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗ សម្រាប់តែងឃ្លាសម្រាប់ក្រុមរបស់ខ្លួន។ ស្នើឱ្យក្រុមនីមួយៗ ទន្ទេញ និងត្រៀមអានឃ្លារបស់ខ្លួនឱ្យបានឮៗ និងឱ្យច្បាស់ជាក្រុម

៤.អ្នកសម្របសម្រួលត្រូវកត់ត្រានូវឃ្លាទាំងអស់ និងត្រូវសរសេរនៅលើក្រដាសផ្ទាំងធំ។ សំយោគសកម្មភាពទាំងនេះដោយស្នើឱ្យអ្នកចូលរួមទាំងអស់ផ្តល់យោបល់បន្ថែមចំពោះឃ្លានីមួយៗ

### មេរៀន[៤៤]

### *ក. លើកកម្ពស់ទេសចរណ៍សុវត្ថិភាពដើម្បីទប់ស្កាត់ការជួញដូរមនុស្ស*

គម្រោងមហាអនុតំបន់មេគង្គប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រីរបស់អង្គការ ILO-IPEC (TICW) គឺជាការផ្តួចផ្តើមថ្នាក់តំបន់មួយដែលរួមចំណែកចំពោះបញ្ហានៃការជួញដូរ ដែលមាននៅក្នុងរបៀបវារៈអភិវឌ្ឍន៍នៃប្រទេសទាំង៥ រួមទាំងប្រទេសកម្ពុជា។ ការវាយតម្លៃមួយដែលបានធ្វើឡើងក្នុងដំណាក់កាលទី១ បានកត់ចំណាំជាពិសេសថាការជួញដូរអាចត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាតិ និងសង្កត់ធ្ងន់ទៅលើគោលការណ៍មួយចំនួន

[៤៤] ចំណុច ក ដល់ចំណុច ង ដកស្រង់ចេញពីឯកសាស្ត្រីពីគោលការណ៍ប្រតិបត្តិស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្មទៅលើកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា

ដែលត្រូវអនុវត្តបន្តនៅប្រទេសផ្សេងទៀត ព្រមទាំងអាចប្រើប្រាស់ជាចំណុចចាប់ផ្តើមនៃផែនការយុទ្ធសាស្ត្រដែលបានស្នើឡើងសម្រាប់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅក្នុងប្រទេស ។

ការពិនិត្យឡើងវិញលើគោលដៅ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពអភិវឌ្ឍន៏វិស័យទេសចរណ៍ ឆ្នាំ ២០០៦-២០០៩ បានបញ្ជាក់ពីការប៉ាន់ប្រមាណនៃគម្រោង TICW ដែលក្រសួងទេសចរណ៍ត្រូវសម្របសម្រួលសកម្មភាពដោយស្របជាមួយនឹងយុទ្ធសាស្ត្រលុបបំបាត់ភាពក្រីក្រ តាមរយៈយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់បង្កើនការងារ បង្កើនភាពស្មើគ្នា និងបង្កើនប្រសិទ្ធិភាពនៅក្នុងប្រទេសកម្ពុជា... ក្នុងគោលបំណងអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យមាននិរន្តរភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន... សម្រាប់គុណភាពវិស័យទេសចរណ៍ដោយផ្អែកលើកេរ្តិ៍ដំណែលវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ និងប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនកម្ពុជា ព្រមទាំងជំរុញឱ្យប្រទេសកម្ពុជាចូលរួមចំណែកធ្វើឱ្យតំបន់អាស៊ានក្លាយជាគោលដៅទេសចរណ៍មួយដោយទប់ស្កាត់ និងរារាំង មិនឱ្យកើតមានផលប៉ះពាល់អវិជ្ជមាននៅក្នុងវិស័យទេសចរណ៍ ដោយប្រឆាំងយ៉ាងខ្លាំងលើការជួញដូរ និងការរំលោភបំពានផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ និងប្រឆាំងចំពោះការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងវិស័យនេះ[៤៥] ។

ការប៉ាន់ប្រមាណរបស់គម្រោង TICW បានលើកឡើងនូវគោលការណ៍មួយចំនួនដែលត្រូវបន្តជាគោលការណ៍ណែនាំ ក្នុងការអនុវត្តន៏ផែនការយុទ្ធសាស្ត្រដែលមានដូចខាងក្រោមនេះ:[៤៦]

- **វិធីសាស្ត្រផ្អែកតាមសិទ្ធិ:** សិទ្ធិរបស់ជនរងគ្រោះដោយការជួញដូរ និងសិទ្ធិរបស់អ្នកធ្វើការនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍ គឺជាបញ្ហាសំខាន់ដែលត្រូវដោះស្រាយដោយអនុវត្តផែនការយុទ្ធសាស្ត្រ។ កិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរ និងពលកម្មកុមារ គួរតែបញ្ជាក់ឱ្យច្បាស់នៅក្នុងច្បាប់អន្តរជាតិថា វាជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ប៉ុន្តែក៏ត្រូវគិតទៅលើអត្ថប្រយោជន៏របស់ជាតិផងដែរ។ វិធានការអនុវត្តមិនត្រូវប៉ះពាល់ដល់សិទ្ធិ និងភាពថ្លៃថ្នូររបស់មនុស្ស ជាពិសេសអ្នកដែលជាជនរងគ្រោះដោយសារការជួញដូរ និងអ្នកដែលទទួលរងការកេងប្រវ័ញ្ចនៅតាមកន្លែងធ្វើការ ព្រមទាំងមិនត្រូវប៉ះពាល់ដល់បទដ្ឋាន និងស្តង់ដាការងាររបស់ខ្លួន ។

- **ការកាត់បន្ថយភាពក្រីក្រ និងភាពងាយទទួលរងគ្រោះ-** យុទ្ធសាស្ត្រស្តីពី ការជួញដូរ ត្រូវដោះស្រាយផ្អែកតម្រូវការជាមុន ព្រោះផ្អែកតម្រូវការនេះ ជាផ្នែកដែលបង្កឱ្យមានការរំលោភបំពាន និងការកេងប្រវ័ញ្ចទៅលើប្រជាជនដែលងាយទទួលរងគ្រោះ។ ឆ្ពោះទៅបញ្ចប់បញ្ហានេះ ការទប់ស្កាត់ និងការការពារត្រូវសង្កត់ធ្ងន់ទៅលើការជំរុញឱ្យមាន

---

[៤៥] ក្រសួងទេសចរណ៍ - ផែនការអភិវឌ្ឍន៏វិស័យទេសចរណ៍ ២០០៥-២០០៩

[៤៦] គោលការណ៍នេះក៏មានលក្ខណៈស្របទៅនឹងគោលការណ៍របស់ការិយាល័យគណៈកម្មការសិទ្ធិមនុស្សជាន់ខ្ពស់ សូមមើល OHCHR ស្តីពីគោលការណ៍ណែនាំសិទ្ធិមនុស្ស និង ការជួញដូរមនុស្ស, អង្គការសហប្រជាជាតិ ក្រុងញូវយ៉ក និង ហ្សឺណែវ ២០០២

ការគាំទ្រពីជាសមូហភាពពីសហគមន៍ ក្នុងការលើកកម្ពស់សុត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងដើម្បីកាត់បន្ថយឱ្យបានជាអប្បបរមានូវទេសចរណ៍ផ្លូវភេទ និងទេសចរណ៍កេងប្រវ័ញ្ច។ ទោះបីជាយ៉ាងណាក៏ដោយការខិតខំទប់ស្កាត់ និងការពារត្រូវផ្សារភ្ជាប់ជាមួយនឹងយុទ្ធសាស្ត្រដែលដោះស្រាយចំពោះកត្តា ដែលបង្កឱ្យមានភាពងាយទទួលរងគ្រោះរួមមានដូចជា វិសមភាព ភាពក្រីក្រ និងរាល់ទម្រង់នៃការរើសអើង។ វិធានការពង្រឹងផលិតភាពការងារ ត្រូវប្រើប្រាស់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញចិញ្ចឹមជីវិត ប្រកបដោយនិរន្តរភាពនៅក្នុងគ្រប់យុទ្ធសាស្ត្រទាំងអស់ ។

- **ការចូលរួមៈ** កិច្ចខិតខំប្រឹងប្រែងត្រូវសង្កត់ធ្ងន់ទៅលើការចូលរួមគាំទ្រ ដោយភ្នាក់ងារជាច្រើនចាប់ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាននៅក្នុងដំណើរការបង្កើតគម្រោងទាំងមូល រួមទាំងការអនុវត្តន៍ និងការវាយតម្លៃ ។
- **ការបញ្ជ្រាបៈ** កិច្ចខិតខំប្រឹងប្រែងត្រូវសង្កត់ធ្ងន់ទៅលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដោយទទួលស្គាល់តួនាទីសំខាន់ៗនៃស្ថាប័នដែលជួយសង្គ្រោះដល់ជនរងគ្រោះនៅតាមសហគមន៍ និងនៅតាមតំបន់គោលដៅ (រដ្ឋាភិបាលថ្នាក់ខេត្ត-ក្រុង ឃុំ និងសហគមន៍)។ កសាងសមត្ថភាពអ្នកអនុវត្តក្នុងវិស័យទេសចរណ៍ និងពង្រឹងកិច្ចសហការជាមួយភ្នាក់ងារផ្សេងទៀត (អង្គការដៃគូតាមមូលដ្ឋាន ស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិល តាមរយៈគម្រោងដែលពាក់ព័ន្ធ និងគណៈកម្មការដែលពាក់ពន្ធ័នៅក្នុងតំបន់។ ការផ្តួចផ្តើមត្រូវធ្វើឡើងដោយមានគោលបំណងបង្កើនទំនាក់ទំនងរវាងសហគមន៍ ភ្នាក់ងារជាតិ និងថ្នាក់ស្រុកជាមួយអ្នកតំណាងមកពីក្រុមប្រជាជនងាយរងគ្រោះ មនុស្សវ័យក្មេង បញ្ហាគ្រឿងញៀន បញ្ហាមេរោគអេដស៍ បញ្ហាសិទ្ធិទាក់ទងនឹងពលកម្ម ។ល។)
- បង្កើតទំនាក់ទំនងរវាងការលើកកម្ពស់ការយល់ដឹង ការកសាងសមត្ថភាព និងការអនុវត្តន៍សកម្មភាពផ្ទាល់ ដើម្បីដោះស្រាយចំពោះកត្តាជំរុញ និងកត្តាអូសទាញដែលនាំឱ្យមានការជួញដូរ និងពលកម្មកុមារ ។
- **ត្រូវមានការពង្រឹងនូវការទទួលខុសត្រូវរួម** (សង្គម) មិនត្រឹមតែក្នុងផ្នែករៀបរយទេ ប៉ុន្តែថែមទាំងស្ថិតក្នុងផ្នែកមិនរៀបរយទៀតផង។ ដូចដែលរដ្ឋមន្ត្រីក្រសួងទេសចរណ៍នៅពេលបច្ចុប្បន្នបានលើកឡើងហើយថា សកម្មភាពសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ត្រូវជួយគាំទ្រដោយក្រសួងទេសចរណ៍ ដោយសង្កត់ធ្ងន់ទៅលើភាពរមទម្យរបស់ប្រជាជនកម្ពុជា សម្រស់ធម្មជាតិ និងគុណភាពនៃសេវាកម្មជាជាងការផ្តល់ឱ្យមិនសមស្របដល់ភ្ញៀវទេសចរនូវទេសចរណ៍ផ្លូវភេទនៅតាមតំបន់គោលដៅ ។
- **បង្កើនគំនិតផ្តួចផ្តើមសម្រាប់យកទៅអនុវត្តបន្ត-** ផែនការសកម្មភាពជាតិ NPA-TSEC/TICW និង NPA-WFCL បានបង្កើតនូវយន្តការ និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយចំពោះបញ្ហាការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនិងពលកម្មលើកុមារ និងស្ត្រី។ ការចូលរួមរបស់រដ្ឋាភិបាលក្នុងពិធីសារអន្តរជាតិនានាជាមួយប្រទេស

ជិតខាង និងជាមួយអង្គការអន្តរជាតិនានាក្នុងការដោះស្រាយបញ្ហាការជួញដូរឆ្លងព្រំដែន បានបង្កើតឱ្យមានទូវគំនិតផ្តួចផ្តើមជាច្រើនដែលកំពុងអនុវត្តដោយស្ថាប័នរដ្ឋាភិបាល និងស្ថាប័នអង្គការមិនមែនរដ្ឋាភិបាល ។ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តគម្រោងស្តីពី ការដោះស្រាយចំពោះបញ្ហាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។ ត្រូវសិក្សាទៅលើគម្រោងត្រឹមត្រូវដែលអាចអនុវត្តបាន និងជោគជ័យដើម្បីរៀនពីបទពិសោធន៍ល្អៗសម្រាប់អនុវត្តបន្ត ប៉ុន្តែត្រូវផ្តល់ពេលវេលាសម្រាប់បង្កើតនូវវិធីសាស្ត្រ ប្រកបដោយភាពច្នៃប្រឌិតនានា ។

- **សកម្មភាពជាក់លាក់ គ្រប់គ្រងបាន សម្រេចបានពិតប្រាកដ និងមានពេលវេលាត្រឹមត្រូវ**- ដោយសារតែមានគំនិតផ្តួចផ្តើម និងតួនាទីរបស់ស្ថាប័នអនុវត្តជាច្រើនកំពុងធ្វើការងារពាក់ព័ន្ធនឹងបញ្ហាការជួញដូរ និងការកេងប្រវ័ញ្ច ក្រសួងទេសចរណ៍បានកំណត់នូវគោលដៅដែលអាចសម្រេចបាននៅក្នុងអណត្តិការងាររបស់ខ្លួន និងទៅតាមជំនាញរបស់ខ្លួន ។
- **និរន្តរភាព**- សក្តានុពលនៃវិស័យទេសចរណ៍ដែលរួមចំណែកដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពគឺជាការងារយូរអង្វែង ហើយបញ្ហាសុវត្ថិភាពលើកុមារក្នុងវិស័យទេសចរណ៍ក៏ត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រនេះផងដែរ ។ ដូច្នេះវិធានការប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងការកេងប្រវ័ញ្ចលើកុមារត្រូវធ្វើមួយជំហានម្តងៗ ។ ដើម្បីធានាឱ្យមាននិរន្តរភាពត្រូវបង្កើត និងពង្រឹងនូវយន្តការអនុវត្តន៍កម្មវិធី ដើម្បីឆ្លើយតបចំពោះលក្ខខ័ណ្ឌដែលមាន ។ ចុងក្រោយការកសាងសមត្ថភាពដល់ស្ថាប័នពាក់ព័ន្ធ និងដល់អ្នកទទួលផល គឺជាចំណុចសំខាន់សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រនេះ ។

## *ខ. គាំទ្រសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព*

មានយុទ្ធសាស្ត្រចំនួន៥ ដែលបានស្នើឡើងទាក់ទងទៅនឹងអណត្តិរបស់ក្រសួងទេសចរណ៍ និងស្របជាមួយល័ក្ខខ័ណ្ឌ ដែលបានចែងនៅក្នុងផែនការ NPA-TSEC និងផែនការ NPA-WFCL ។ ដូចគ្នានេះដែរគោលការណ៍ COMMIT ក៏ត្រូវបានពិចារណាយ៉ាងសំខាន់ផងដែរ ។ យុទ្ធសាស្ត្រទាំង ៥ នេះមាន:

- ការសិក្សាស្រាវជ្រាវស្តីពី ការជួញដូរស្ត្រី និងកុមារដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម នៅក្នុងសហគមន៍ទេសចរណ៍
- គោលនយោបាយ និងការអភិវឌ្ឍន៍ស្ថាប័នសម្រាប់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
- ការពិនិត្យ ការតាក់តែង និងការអនុវត្តន៍ច្បាប់ បទបញ្ញត្តិ និងសេចក្តីប្រកាសថ្នាក់ជាតិ
- ការទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីដើម្បីកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្មនៅតាមតំបន់ទេសចរណ៍
- ការការពារ

បទអន្តរាគមន៍ដែលទាក់ទងនឹងយុទ្ធសាស្ត្រចំនួន៥ ជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងអ្វីដែលបានកំណត់ក្រោមគម្រោងនៃអង្គការ ILO-IPEC ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ (TICW)[47] ក្នុងតំបន់ទន្លេមេគង្គដែលរួមមានដូចជាការលើកកម្ពស់ការយល់ដឹង, ការកសាងសមត្ថភាព និងការអនុវត្តន៍សកម្មភាពផ្ទាល់ (ABCD) ដែលមានលំអិត ដូចខាងក្រោម៖

- **ការលើកកម្ពស់ការយល់ដឹង៖** ធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីមូលហេតុនៃការជួញដូរ និងពលកម្មកុមារ អំពីល័ក្ខខ័ណ្ឌការងារ និងកន្លែងការងាររបស់ស្ត្រី និងកុមារ និងអំពីវិធានការរបស់រដ្ឋក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងពលកម្មកុមារក្នុងវិស័យទេសចរណ៍។ វិធានការទាំងនេះ រួមមានដូចជា គោលនយោបាយជាតិសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ការកែលំអប្រព័ន្ធផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ក្នុងចំណោមអ្នកពាក់ព័ន្ធ និងអ្នកទទួលផល និងការផ្លាស់ប្តូរឥរិយាបថលើជនរងគ្រោះ និងលើអ្នកបម្រើ ។
- **ការកសាងសមត្ថភាព៖** ការជំរុញការគ្រប់គ្រងកម្មវិធី រួមមាន ការរៀបចំគម្រោង, ការអនុវត្តន៍គម្រោង, ការត្រួតពិនិត្យ និងវាយតម្លៃ, ការសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមអ្នកពាក់ព័ន្ធ, រចនាសម្ព័ន្ធការងារស្តីពី ទីកន្លែងការងារថ្នាក់សហគមន៍-ខេត្ត-ជាតិ និងការបង្កើតបណ្តាញការងារ ក្នុងចំណោមបណ្តាទីភ្នាក់ងារ, ហេដ្ឋារចនាសម្ព័ន្ធដែលបានបង្កើតឡើង (មជ្ឈមណ្ឌលកុមារ, ស្ថាប័នបណ្តុះបណ្តាល), ការជំរុញ ចំណេះដឹង និងជំនាញទាក់ទងនឹងការគ្រប់គ្រង និងការអនុវត្តន៍គម្រោងទាំងមូល (ការត្រួតពិនិត្យ, ការរៀបចំឯកសារ, ការបណ្តុះបណ្តាល) ។
- **សកម្មភាពផ្ទាល់៖** បទអន្តរាគមន៍ទាំងឡាយ មានគោលបំណងលើកកម្ពស់អត្ថប្រយោជន៍ពិតប្រាកដជាក់ស្តែងក្នុងចំណោមអ្នកពាក់ព័ន្ធ ជាពិសេសអ្នកទទួលផល ដូចជា ការរៀបចំគម្រោងចូលរួម, ការអនុវត្តន៍, ការត្រួតពិនិត្យ និងវាយតម្លៃ, គម្រោងជំនួយផ្ទាល់ (សេដ្ឋកិច្ចសង្គម, ការសន្សំ, ការអប់រំ, សេវាសុខភាព, សេវាច្បាប់, ការព្យាបាលរបួស ។ល។)

## *គ. ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពការងារ និង ស្ថានភាពរស់នៅរបស់កុមារ និង ស្ត្រី*

### *១. បទបញ្ញត្តិសំខាន់ៗសម្រាប់ការការពារផ្នែកពលកម្មដល់កុមារ និង ស្ត្រីធ្វើការ*

ច្បាប់ស្តីពីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ដើរតួជាបទបញ្ញត្តិមូលដ្ឋានមួយដែលការពារដល់ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរ ឬបានពាក់ព័ន្ធនឹងការធ្វើពលកម្មនៅក្នុងវិស័យទេសចរណ៍។ បទបញ្ញត្តិជាក់លាក់ ដែលបានលើកឡើងមាន៖

[៤៧] ឯកសារបទបង្ហាញ គម្រោងប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និង ស្ត្រី - តំបន់ទន្លេមេគង្គ (ប្រទេសកម្ពុជា) ដំណាក់កាលទី ២ របស់ អង្គការ ILO-IPEC

- **ជំពូក១ ផ្នែក៥ មាត្រា១៥-១៦:** ពលកម្មដោយបង្ខំ ឬ ខានមិនបាន គឺត្រូវបានហាមប្រាមជាដាច់ខាតដោយស្របជាមួយអនុសញ្ញាអន្តរជាតិលេខ ២៩ ស្តីពីពលកម្មដោយបង្ខំ ឬកាតព្វកិច្ចដូចដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី ២៤ កុម្ភៈ ១៩៦៩ ។ ការជួលមនុស្សឱ្យធ្វើការដើម្បីសងបំណុលក៏ត្រូវហាមឃាត់ផងដែរ ។
- **ជំពូក២ ផ្នែក៤ ស្តីពីសៀវភៅការងារ:** ប្រជាជនកម្ពុជាគ្រប់រូបដែលធ្វើការជាបុគ្គលិកឱ្យនិយោជកណាម្នាក់ ត្រូវមានអត្តសញ្ញាណការងារ...(បង្កើតឡើង និងចេញដោយអធិការកិច្ចការងារ តាមការស្នើសុំពីនិយោជិត)
- **ជំពូក៦ ផ្នែក៨ ស្តីពីពលកម្មកុមារ និងពលកម្មស្ត្រី** រួមមានបទបញ្ញត្តិជាច្រើនដូចខាងក្រោម:
  - *មាត្រា ១៧២:* គ្រប់និយោជក និងអ្នកគ្រប់គ្រងកន្លែងអាជីវកម្មដែលមានពលកម្មកុមារ ឬការអនុវត្តន៍របស់កុមារអាយុក្រោម ១៨ ឆ្នាំ ឬការងាររបស់ស្ត្រី ត្រូវពិនិត្យទៅលើការប្រព្រឹត្តិល្អ និងការរក្សាភាពសមរម្យជាសាធារណៈ ។ គ្រប់ទម្រង់នៃការរំលោភផ្លូវភេទ (ការរំខាន) ត្រូវបានហាមឃាត់ជាដាច់ខាត។
  - *មាត្រា ១៧៥:* កុមារ និយោជិត កម្មករ ឬការអនុវត្តន៍ដោយមនុស្សអាយុក្រោម ១៨ ឆ្នាំ មិនអាចជួលឱ្យធ្វើការងារពេលយប់នៅក្នុងសហគ្រាសណាមួយបានទេ នេះមានចែងនៅក្នុងមាត្រា ១ នៃច្បាប់នេះ។
  - *ជំពូករង ខ: ពលកម្មកុមារ* - អាយុអប្បបរមាសម្រាប់ធ្វើការគឺ ១៥ឆ្នាំ ចំណែកឯការងារដែលមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌ ត្រូវមានអាយុ ១៨ឆ្នាំ ។ ការងារដែលធ្វើដោយមនុស្សធំ អាយុ ១៥ឆ្នាំ និងលើសពីនេះ ត្រូវស្ថិតក្នុងល័ក្ខខ័ណ្ឌដែលធានាបានពេញលេញចំពោះសុខភាព សុវត្ថិភាព និងសីលធម៌របស់ពួកគេ ហើយពួកគេអាចទទួលធ្វើសកម្មភាពនៅតាមវិស័យនោះ ដោយមានការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈបានជាក់លាក់ និងគ្រប់គ្រាន់។ កុមារដែលមានអាយុចាប់ពី ១២-១៥ ឆ្នាំ អាចជួលឱ្យធ្វើការងារស្រាលបាន ប្រសិនបើការងារនោះមិនមានគ្រោះថ្នាក់ដល់សុខភាព ឬ ការអភិវឌ្ឍន៍ផ្នែកស្មារតី និងរាងកាយ ព្រមទាំងមិនប៉ះពាល់ដល់ការចូលរៀនក្នុងសាលា ការចូលរួមកម្មវិធី ថែទាំ ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

បទបញ្ញត្តិទាំងនេះ មានស្ថិតនៅក្នុងមាត្រា៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ ដែលបានលើកឡើងជាពិសេសថា "រដ្ឋត្រូវការពារសិទ្ធិកុមារដូចមានចែងនៅក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារនៃអង្គការសហប្រជាជាតិ"[៤៨] ។

ច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា ក៏បានចែងផងដែរថា កុមារត្រូវមានអាយុក្រោម ១៨ឆ្នាំ សម្រាប់គ្រប់ប្រភេទនៃការងារទាំងអស់ ។ បទបញ្ញត្តិលេខ២ មាត្រា១៧៧ នៃច្បាប់ស្តីពីការងារបានចែងថា អាយុអនុញ្ញាតឱ្យធ្វើការ

[៤៨] ប្រទេសសមាជិក ត្រូវប្តេជ្ញាការពារសិទ្ធិកុមារដូចមានចែងនៅក្នុងមាត្រា ៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលធ្វើឱ្យរដ្ឋភាគីត្រូវទទួលខុសត្រូវការពារកុមារពី "ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និង ពីការធ្វើការងារដែលទំនងជាមានគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់ការអប់រំរបស់កុមារ ឬមានគ្រោះថ្នាក់ដល់សុខភាពកុមារ ឬការអភិវឌ្ឍន៍ផ្នែករាងកាយ ស្មារតី សតិបញ្ញា និង សង្គមរបស់កុមារ"

ជាអប្បបរមាសម្រាប់គ្រប់ប្រភេទនៃការងារទាំងអស់ ដោយមានស្ថានភាពមិនបង្កគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌ គឺត្រូវមានអាយុ ១៨ ឆ្នាំ ។ ច្បាប់ស្ដីពីការងារ ក៏បានចែងទៀតថា កុមារដែលមានអាយុចាប់ពី ១២-១៥ ឆ្នាំ អាចចូលរួមធ្វើការងារស្រាលបាន ប្រសិនបើ (១) ការងារនោះមិនមានគ្រោះថ្នាក់ ដល់ការអភិវឌ្ឍន៍ សុខភាព និងផ្នែកស្មារតី (២) ការងារនោះមិនប៉ះពាល់ដល់ការចូលរៀននៅសាលា ឬការចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាល វិជ្ជាជីវៈនានា ដែលបានយល់ស្របដោយអាជ្ញាធរមានសមត្ថកិច្ច ។

បទបញ្ញត្តិនៃច្បាប់ស្ដីពីការងារ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយប្រកាស (សេចក្ដីណែនាំថ្នាក់ក្រសួង) បំពេញបន្ថែមដែលនឹងត្រូវបង្កើតឡើងដោយរដ្ឋសភាជាតិ ។ ដោយសារតែបទបញ្ញត្តិនៅក្នុងច្បាប់ស្ដីពី ការងារមានលក្ខណៈមិនច្បាស់លាស់ ដូច្នេះត្រូវដាក់បញ្ចូលការតស៊ូមតិបំពេញបន្ថែមចំពោះបទបញ្ញត្តិនានា ជាផ្នែកមួយនៃកម្មវិធីសកម្មភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

- ប្រកាសស្ដីពីការងារប្រកបដោយគ្រោះ ត្រូវបានអនុម័តនៅពេលថ្មីៗនេះដោយក្រុមប្រឹក្សាបច្ចេកទេសស្ដីពី ការងារ (LAC) និងអនុម័តសម្រាប់អនុវត្ត ក្នុងពេលប្រជុំលើកដំបូងក្នុងខែមិនា ឆ្នាំ ២០០៤ ។ ប្រកាសស្ដីពី ការងារស្រាលសម្រាប់កុមារអាយុ ១២-១៥ឆ្នាំ ក៏ត្រូវបានអនុម័ត និងយល់ស្របក្នុងខែមេសា ឆ្នាំ២០០៤ ។ មានបទបញ្ញត្តិមួយចំនួនស្ដីពី ការដោះស្រាយចំពោះបញ្ហាពលកម្មកុមារត្រូវបានអនុម័ត ។ បទបញ្ញត្តិទាំងនោះរួមមានសារាចរ ស្ដីពីការអនុវត្តន៍អនាម័យ និងសន្តិសុខការងារ សេចក្ដីណែនាំស្ដីពី ការចុះឈ្មោះចូលរៀនរបស់កុមារនៅតាមភូមិ នៅក្នុងចំការកៅស៊ូជប់ និងសេចក្ដីណែនាំស្ដីពី ការហាមប្រាមមិនឱ្យកុមារលើកដាក់របស់ធ្ងន់ដោយប្រើកម្លាំងពលកម្ម ។ល ។
- បច្ចុប្បន្ននេះ មានប្រកាសចំនួន ៦ ក្រោមផែនការ NPA-WFCL ដែលមានគោលបំណងដើម្បីលុបបំបាត់ពលកម្មកុមារនៅក្នុងផ្នែកការងារតាមចំការ ការងារនេសាទ ឡឥដ្ឋ ការដ្ឋានអំបិល រោងចក្រកាត់ដេរ និងរោងចក្រផលិតស្បែកជើង ព្រមទាំងការកំណត់ប្រភេទអាជីវកម្មសម្រាប់កុមារដែលមានអាយុចាប់ពី១២-១៤ ឆ្នាំ ។ ប្រកាសទាំង ៦ នេះ បច្ចុប្បន្នស្ថិតនៅក្នុងទម្រង់ជាសេចក្ដីព្រាង ហើយមិនទាន់ទទួលបានការអនុម័តនៅឡើយទេ ។

### *២. បញ្ហាលំបាកក្នុងការអនុវត្តន៍បទបញ្ញត្តិស្ដីពី ការការពារផ្នែកពលកម្ម*

មានបញ្ហាប្រឈមមុខជាច្រើនដែលបានរារាំងដល់ការអនុវត្តន៍បទបញ្ញត្តិស្ដីពី ការការពារផ្នែកការងារ ។ មានជាអាទិ៍ ដូចជា ដំណើរការអនុម័ត និងយល់ស្របទៅលើប្រកាសស្ដីពី ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ មានលក្ខណៈយឺតយ៉ាវ ។ មានដំណើរការពាក់ព័ន្ធជាច្រើន មុននឹងអាចអនុម័ត និងយល់ស្របទៅលើប្រកាសបាន ។ ការឆ្លើយតបជាបន្ទាន់ទាក់ទងទៅនឹងជំនួយផ្នែកច្បាប់ចំពោះភ្នាក់ងារអនុវត្ត មិនអាចរំពឹងទុកបានទេ ។

បច្ចុប្បន្ននេះ មិនមានបទបញ្ញត្តិ ឬប្រកាសដែលអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចចូលពិនិត្យនៅក្នុងផ្នែកមិនរៀបរយនោះទេ។ អធិការកិច្ចលើលក្ខខ័ណ្ឌការងារ ត្រូវបានធ្វើឡើងមិនត្រឹមតែស្ថិតនៅក្នុងផ្នែករៀបរយទេ ប៉ុន្តែថែមទាំងស្ថិតនៅក្នុងផ្នែកមិនរៀបរយទៀតផង ដែលមានអ្នកធ្វើការជាកុមារកំពុងតែត្រូវបានធ្វើមិនដឹងមិនឮ។ កង្វះខាតធនធានមនុស្សសម្រាប់ការធ្វើអធិការកិច្ច ក៏ត្រូវបានលើកឡើងថាជាបញ្ហារបស់ក្រសួងការងារផងដែរ[៤៩] ។

ដំណើរការផ្តល់អាជ្ញាប័ណ្ណនៅពេលបច្ចុប្បន្នដល់កន្លែងអាជីវកម្ម មិនត្រូវបានដាក់បញ្ចូលទេ ។ ប្រការនេះរួមមាននូវការស្នើសុំវិញ្ញាបនប័ត្រពីភ្នាក់ងារចំនួន ១១ (ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន)។ អ្នកដែលចេញវិញ្ញាបនប័ត្រមិនបានយល់ដឹងពីលក្ខខ័ណ្ឌទាំងនេះទេ[៥០] ដូច្នេះទើបមិនមានកន្លែងចេញអាជ្ញាប័ណ្ណរួមមួយសម្រាប់ដំណើរការគ្រប់ជំហាន (កន្លែងចេញអាជ្ញាប័ណ្ណរួម) និងមិនមានកម្មវិធីកំណត់ច្បាស់លាស់ ។ ការចូលរួមរបស់ក្រសួងការងារ កើតឡើងក្រោយពេលកន្លែងអាជីវកម្មបានបង្កើតរួចទៅហើយ។ បទបញ្ញត្តិក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការងារ ត្រូវកែសំរួលដើម្បីធានាឱ្យមានប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណមួយ ដែលហាមប្រាមចំពោះការប្រើប្រាស់ពលកម្មកុមារ ។

ប្រព័ន្ធអធិការកិច្ច ត្រូវតែកែលំអ។ អធិការកិច្ចនៅពេលបច្ចុប្បន្ន មានការទាក់ទងទៅនឹងការអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណដល់កន្លែងអាជីវកម្មដែលប្រើប្រាស់ពលកម្ម ។ មានការផ្តួចផ្តើមសម្រាប់ការធ្វើអធិការកិច្ចលើសុវត្ថិភាពការងារ និងអនាម័យ ប៉ុន្តែមន្ត្រីអធិការកិច្ចការងារមានចំនួនមិនស្មើនឹងចំនួនកន្លែងអាជីវកម្មនៅពេលបច្ចុប្បន្ននេះទេ ។

ការអនុវត្តន៍ច្បាប់ស្តីពីការងារដែលមានស្រាប់ នៅមានភាពទន់ខ្សោយ និងនៅមានកម្រិត។ ខណៈពេលដែលច្បាប់ស្តីពីការងារចែងថា កុមារត្រូវមានអាយុយ៉ាងហោចណាស់ ១៨ឆ្នាំ សម្រាប់គ្រប់ប្រភេទការងារ ប៉ុន្តែមានកុមារជាច្រើនដែលមានអាយុក្រោម ១៨ ឆ្នាំ តែងតែកុហកពីអាយុផ្ទាល់ខ្លួនដើម្បីចូលធ្វើការ។ ការអនុវត្តន៍គោលការណ៍ណែនាំសម្រាប់ការងារស្រាល និងសម្រាប់សកម្មភាពក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់ ក៏មានលក្ខណៈទន់ខ្សោយផងដែរ ។ ច្បាប់ស្តីពីការងារមិនបានកំណត់យ៉ាងច្បាស់ពីប្រភេទការងារ និងល័ក្ខខ័ណ្ឌការងារ ដែលត្រូវបានចាត់ទុកថាជាទម្រង់ធ្ងន់ធ្ងរ ឬទម្រង់ប្រកបដោយគ្រោះថ្នាក់ នៃពលកម្មកុមារ ដូច្នេះច្បាប់នៅតែអនុញ្ញាត ឱ្យកុមារធ្វើការ ។

ផ្នែកមួយនៃការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ គឺកង្វះខាតទិន្នន័យទូលំទូលាយស្តីពី កន្លែងអាជីវកម្មដែលប្រើប្រាស់ពលកម្ម ជាពិសេសកម្លាំងពលកម្មរបស់ស្ត្រី និងកុមារដែលត្រូវបានគេជួញដូរ។ ដូចបានលើកឡើងខាងលើក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងអនុវត្តកម្មវិធីសកម្មភាពជាមួយអង្គការ ILO-IPEC ដោយមានកិច្ចសហការពីក្រសួងទេសចរណ៍ ក្រសួងកិច្ចការនារី និងក្រសួងការងារ នៅក្នុងទីក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ដើម្បីប្រមូលទិន្នន័យស្តីពី កន្លែងអាជីវកម្ម (សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ។ល។) និងទិន្នន័យ ស្តីពីចំនួនបុគ្គលិក។

[៤៩] ត្រូវបានលើកឡើងជាបញ្ហាលំបាកមួយក្នុងសិក្ខាសាលា ថ្ងៃ ២៤-២៥ មករា ២០០៦

[៥០] Ibid

ទោះបីជាយ៉ាងណាក៏ដោយ ការប្រមូលទិន្នន័យនេះធ្វើបានតែទៅលើកន្លែងអាជីវកម្មដែលបានចុះបញ្ជីត្រឹមត្រូវប៉ុណ្ណោះ គឺសំដៅទៅលើទំនាក់ទំនងធម្មតារវាងនិយោជក និងកម្មករនិយោជិត ដោយមានការទទួលបាននូវប្រាក់បៀវត្សត្រឹមត្រូវ។[៥១] មានកន្លែងអាជីវកម្ម និងសេវាកម្មជាច្រើនបានប្រើប្រាស់ស្ត្រីវ័យក្មេង ជាពិសេសកន្លែងអាជីវកម្មក្នុងផ្នែកមិនរៀបរយនៅក្នុងវិស័យទេសចរណ៍ ប៉ុន្តែកន្លែងអាជីវកម្មទាំងនោះមិនត្រូវបានគូសបង្ហាញនោះទេ។ នេះគឺជាគម្រោងថ្មីមួយក្នុងខែសីហា ឆ្នាំ២០០៥ ហើយនឹងចាប់ផ្តើមក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ ដល់ខែកុម្ភៈ ឆ្នាំ២០០៦[៥២]។ ការសិក្សាស្រាវជ្រាវនេះបានបញ្ចប់ កំពុងដំណើរការបូកសរុប និងរហូតមកដល់ថ្ងៃនេះ លទ្ធផលបញ្ចប់ពុំទាន់បានផ្សព្វផ្សាយនៅឡើយ ។

### *៣ បទអន្តរាគមន៍ដែលបានស្នើឡើង*

បទបញ្ញត្តិនៅក្នុងផែនការយុទ្ធសាស្ត្រស្តីពី CST ដោយលើកកម្ពស់ និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពី ការងារ និង បទបញ្ញត្តិការងារនៅតាមកន្លែងធ្វើការ មានដូចខាងក្រោមនេះ:

| ប្រភេទនៃបទអន្តរាគមន៍ | សកម្មភាព |
|---|---|
| ការអភិវឌ្ឍន៍ស្ថាប័ន | ▪ ពិនិត្យ និងកែលំអបទបញ្ញត្តិ/សារាចរផ្នែកការងារ<br>▪ កែលំអឧបករណ៍ត្រួតពិនិត្យ/បញ្ជីត្រួតពិនិត្យ<br>▪ ពិនិត្យលើគោលការណ៍ចេញអាជ្ញាប័ណ្ណ<br>▪ ធ្វើសិក្ខាសាលាស្តីពីគោលការណ៍ប្រតិបត្តិសម្រាប់ច្បាប់/បទបញ្ញត្តិនានា |
| ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ | ▪ រៀបចំសំភារៈលើកកម្ពស់ការយល់ដឹង<br>▪ ធ្វើយុទ្ធនាការចែកចាយព័ត៌មានដល់កន្លែងអាជីវកម្មទេសចរណ៍ សហជីព កម្មករ និង សហគមន៍ |
| ការបង្កើនចំណេះដឹង | ▪ ចុះបញ្ជីកន្លែងអាជីវកម្មទេសចរណ៍<br>▪ ចុះបញ្ជី និងចេញបណ្ណការងារ/ប្រព័ន្ធផ្តល់អត្តសញ្ញាណបណ្ណ័ដល់បុគ្គលិក |

[៥១] ឧទាហរណ៍ ការសិក្សាស្តីពីស្ត្រីលក់ស្រាបៀរ ពឹងផ្អែកទៅលើកំរៃជើងសារនៃការលក់ ជាជាងប្រាក់ចំណូលជាប្រចាំ ដូច្នេះទំនាក់ទំនងរវាងនិយោជក-និយោជិត នៅមានកម្រិតទន់ខ្សោយ ។

[៥២] បទសំភាសន៍ជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុងភ្នំពេញ

គោលការណ៍ណែនាំលំអិតស្តីពីការកសាងសមត្ថភាព ស្តីពីការកែលំអប្រព័ន្ធអធិការកិច្ចការងារ និងស្តីពី ការលើកកម្ពស់ការយល់ដឹង មានបង្ហាញនៅក្នុងគោលការណ៍ណែនាំស្តីពី ការប្រតិបត្តិ។

### *៤. ការពិនិត្យ និងការអនុវត្តន៍ច្បាប់ការងារ និងបទបញ្ញត្តិពាក់ព័ន្ធ*

គោលបំណងសម្រាប់សកម្មភាពនេះ គឺដើម្បីដាក់ចេញនូវក្របខ័ណ្ឌការងារស្របច្បាប់សម្រាប់សកម្មភាពទប់ស្កាត់ប្រឆាំងនឹងការជួញដូរ និងពលកម្មកុមារក្នុងក្រសួងពាក់ព័ន្ធ និងនៅតាមទីកន្លែងទេសចរណ៍ និងដើម្បីសាកល្បង ពីការប្រើប្រាស់នូវក្របខ័ណ្ឌការងារទាំងនេះតាមរយៈបទបញ្ញត្តិនានា ព្រមទាំងដើម្បីលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ និងបទបញ្ញាទាំងឡាយដល់បុគ្គលិកសំខាន់របស់ស្ថាប័នដែលពាក់ព័ន្ធ។ គេបានកត់សំគាល់ថា នាពេលបច្ចុប្បន្ន ច្បាប់ការងារត្រូវបានពិនិត្យ និងកែសំរួលឡើងវិញ ដូច្នេះត្រូវពិចារណាទៅលើបទបញ្ញត្តិទាំងនេះ នៅពេលដែលធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ។

បុគ្គលិកសំខាន់ៗសម្រាប់អនុវត្តសកម្មភាពនេះមាន បុគ្គលិកមកពីនាយកដ្ឋានការងារកុមារ នៃក្រសួងការងារនាយកដ្ឋានអធិការកិច្ចការងារ អនុគណៈកម្មការជាតិត្រួតពិនិត្យលើច្បាប់របស់ CNCC អ្នកតំណាងមកពី DOJ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងក្រុមជំនាញការផ្នែកច្បាប់។

សកម្មភាពដែលត្រូវពិចារណា មានដូចខាងក្រោម៖

- កំណត់នូវបុគ្គលសំខាន់ ដើម្បីចូលរួមក្នុងការពិនិត្យច្បាប់ និងកែលំអគោលនយោបាយ និងនីតិវិធី។ ត្រូវមានតំណាងមកពីអ្នកច្បាប់ និងអ្នកអនុវត្តការងារទាំងនៅក្នុងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល។
- ពិនិត្យឡើងវិញទៅលើច្បាប់ការងារថ្មី៖កត់ចំណាំនូវបញ្ញត្តិនានា ដែលត្រូវការបង្កើតនូវគោលការណ៍ណែនាំ/ សារាចរណែនាំបន្ថែម និងបទបញ្ញត្តិដែលត្រូវការការបង្កើតគោលនយោបាយសម្រាប់អនុមត័ ក្នុងកន្លែងការងារទាក់ទងនឹងវិស័យទេសចរណ៍។ ច្បាប់ការងារបច្ចុប្បន្ន មិនបានកំណត់នូវការងារដែលអនុញ្ញាតឱ្យកុមារអាចធ្វើការងារបាននៅក្នុងវិស័យទេសចរណ៍ឡើយ។
- សេចក្តីព្រាងគោលការណ៍ណែនាំ ដើម្បីអនុម័តឱ្យក្លាយជាប្រកាស-សារាចរ [៥៣]

[៥៣] ប្រសិនបើមិនបានបញ្ជាក់ដោយច្បាប់ស្តីពីការងារ ឬ ច្បាប់ទេសចរណ៍ទេ នោះយន្តការអនុវត្តប្រកាស/សារាចរនឹងត្រូវបានអនុម័តដោយការិយាល័យរដ្ឋមន្ត្រី

- អំពាវនាវផ្សព្វផ្សាយប្រកាស-សារាចរជាសាធារណៈ ព្រោះប្រកាស-សារាចរទាំងនេះត្រូវបានអនុម័តរួមគ្នាដោយក្រសួងទេសចរណ៍ និងក្រសួងការងារ។ កំណត់ពីរបៀបអនុម័តនូវប្រកាស-សារាចរទាំងនេះសម្រាប់ក្រសួងទាំងពីរនេះ។
- ស្នើសុំការអនុម័តទៅលើសេចក្តីព្រាងប្រកាស-សារាចរទាំងនេះពីរដ្ឋមន្រ្តី
- បញ្ចូលបទបញ្ញត្តិដែលមាននៅក្នុងច្បាប់ស្តីពី ការងារថ្មី និងបទបញ្ជានានា ដែលបានអនុម័តរួចទៅក្នុងសៀវភៅបណ្តុះបណ្តាល
- ជំរុញការយល់ដឹងបទបញ្ជាទាំងឡាយ (ប្រកាស-សារាចរ) ដោយផ្សព្វផ្សាយទៅកាន់នាយកដ្ឋានផ្សេងៗ (ថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង) និងអ្នកពាក់ព័ន្ធផ្សេងៗ តាមរយៈ ឧបករណ៍ IEC និងតាមរយៈការបណ្តុះបណ្តាល ។
- បញ្ជ្រាបយន្តការពិនិត្យ និងវាយតម្លៃដើម្បីលើកកម្ពស់ និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងការងារ ក្នុងគោលបំណងដើម្បីប្រមូលមេរៀនបទពិសោធន៍ និងការអនុវត្តន៍ល្អសម្រាប់ទុកយកទៅអនុវត្តបន្ត ។

## *ឃ. ការធ្វើឱ្យប្រសើរឡើងចំពោះការអនុវត្តន៍បទបញ្ញត្តិវិស័យទេសចរណ៍*

### *១. បទបញ្ញត្តិ និង គោលការណ៍ណែនាំក្នុងវិស័យទេសចរណ៍*

សេចក្តីព្រាងច្បាប់ទេសចរណ៍ មិនទាន់បានអនុម័តដោយរដ្ឋសភាជាតិនៅឡើយទេ។ ដូច្នេះបទបញ្ញត្តិគ្រប់គ្រងលើកន្លែងអាជីវកម្មនៅតាមតំបន់ទេសចរណ៍ កំពុងតែត្រូវបានអនុវត្តយ៉ាងពេញលេញ។ មកដល់ខែវិច្ឆិកា ឆ្នាំ២០០០ សេចក្តីប្រកាសខាងក្រោមនេះមានប្រសិទ្ធិភាពនៅក្នុងឧស្សាហកម្មទេសចរណ៍នៃប្រទេសកម្ពុជា ហើយប្រកាសនីមួយៗត្រូវបានគាំទ្រដោយសារាចរក្រសួងដែលកំពុងស្ថិតក្រោមការគ្រប់គ្រង/ការអនុវត្តន៍ ឬដែលបាន និងកំពុងស្នើឡើង។ ប្រកាសទាំងនេះ ចេញបទបញ្ញត្តិឱ្យមានការបង្កើត និងការធ្វើប្រតិបត្តិការអាជីវកម្មដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅក្នុងប្រទេស ។

១- ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់សណ្ឋាគារ និងផ្ទះសំណាក់/សារាចរស្តីពី ការគ្រប់គ្រងសណ្ឋាគារ និងផ្ទះសំណាក់

២- ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់រង្គសាល និងបារឱសូ / សារាចរស្តីពី ការគ្រប់គ្រងរង្គសាល និងបារឱសូ

៣- ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណដល់កន្លែងទេសចរណ៍ និងក្លឹបកំសាន្ត/ សារាចរស្តីពី ការគ្រប់គ្រងកន្លែងទេសចរណ៍ និងក្លឹបកំសាន្ត

៤- ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់ការធ្វើដំណើរទេសចរណ៍តាមផ្លូវទឹក/សារាចរ ស្តីពីការគ្រប់គ្រងការធ្វើដំណើរទេសចរណ៍តាមផ្លូវទឹក

៥- ប្រកាសស្តីពីការចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់ការធ្វើដំណើរទេសចរណ៍តាមផ្លូវគោក / សារាចរ (សេចក្តីណែនាំ) ស្តីពី ការគ្រប់គ្រងការធ្វើដំណើរទេសចរណ៍តាមផ្លូវគោក

៦- ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណដល់កន្លែងម៉ាស្សា / សារាចរស្តីពី ការគ្រប់គ្រងកន្លែងម៉ាស្សា

៧- ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណដល់ភោជនីយដ្ឋាន / សារាចរស្តីពី ការគ្រប់គ្រងភោជនីយដ្ឋាន

៨- ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណដល់កន្លែងខារ៉ាអូខេ / សារាចរស្តីពី ការគ្រប់គ្រងកន្លែងខារ៉ាអូខេ

៩- ប្រកាសស្តីពីការចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់មគ្គុទ្ទេសក៍ទេសចរ/សារាចរ ស្តីពីការគ្រប់គ្រងអាជីវកម្មមគ្គុទ្ទេសក៍ទេសចរ ។

១០-ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់ទីភ្នាក់ងារទេសចរណ៍ / សារាចរ ស្តីពី ការគ្រប់គ្រងអាជីវកម្មទីភ្នាក់ងារទេសចរណ៍

១១-ប្រកាសស្តីពី ការចេញអាជ្ញាប័ណ្ណទេសចរណ៍ដល់រមណីយដ្ឋានទេសចរណ៍ / សារាចរស្តីពី ការគ្រប់គ្រងអាជីវកម្មរមណីយដ្ឋានទេសចរណ៍

ការពិនិត្យឡើងវិញទៅលើបទបញ្ញត្តិទាំងនេះ បង្ហាញថាសារាចរទាំងអស់នេះគោរពទៅតាមបទបញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម ព្រោះសារាចរទាំងនេះគឺជាមធ្យោបាយនៃការអនុវត្តន៍ នូវបទញ្ញត្តិទាំងនេះ ។លើសពីនេះទៀតសារាចរទាំងអស់នេះរួមមាននូវបទបញ្ញត្តិស្តីពីការហាមប្រាមចំពោះវត្តមាន/ភស្តុតាងនៃការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារនៅក្នុងអាជីវកម្មទាំងនេះ ។

បញ្ហាដែលបានលើកឡើងក្នុងការអនុវត្តន៍បទបញ្ញត្តិទាំងនេះស្រដៀងគ្នាទៅនឹងបញ្ហាលំបាក ដែលបានលើកឡើងនៅក្នុងការអនុវត្តបទបញ្ញត្តិស្តីពីការងារ ។ ការពិភាក្សាមួយស្តីពីបទបញ្ញត្តិវិស័យទេសចរណ៍បច្ចុប្បន្ន[៥៤] បានលើកឡើងនូវចំណុចដូចខាងក្រោមនេះ:

- ខ្លឹមសារចំបងនៃការចងក្រងប្រកាសក្រសួងទេសចរណ៍ ផ្តោតលើនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ។ ដំណើរការនេះមានរហូតដល់ទៅ១១ជំហានជាផ្លូវការ។ ត្រូវពិចារណាទៅលើវិធានការដែលអាចធ្វើឱ្យដំណើរការនេះមានលក្ខណៈងាយស្រួល។
- ការពិចារណាដ៏សំខាន់មួយ គឺការធ្វើឱ្យអាជីវកម្មមានលក្ខណៈស្របច្បាប់ ដោយមានការគាំទ្រលើការប្រឆាំងពលកម្មកុមារ វិធានការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ (ដើម្បីចេញជាអាជ្ញាប័ណ្ណ) និងការធានាមិនលើកទឹកចិត្តចំពោះពលកម្មកុមារ

[៥៤] បទសំភាសន៍ជាមួយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ឯកឧត្តម **ឡាយ ព្រហស្ស** ទីប្រឹក្សាក្រសួងទេសចរណ៍ អធិការកិច្ច និងនាយកដ្ឋានឧស្សាហកម្ម ថ្ងៃ ១៣ តុលា ២០០៥

- សម្រាប់កម្មករនិយោជិត ការទាមទារ និងការបង្ហាញសៀវភៅការងារត្រូវតែពិចារណា។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការចេញអត្តសញ្ញាណការងារ ក៏មានលក្ខណៈស្មុគស្មាញដោយប្រើប្រាស់នូវសៀវភៅគ្រួសារ។ ប្រការនេះកើតឡើងដោយសារតែក្រុមប្រឹក្សាឃុំ (CC) និងប្រព័ន្ធចុះបញ្ជីតាមមូលដ្ឋានមិនទាន់បានបង្កើតឡើងតាមស្ថាប័ន និងមិនទាន់មានប្រសិទ្ធិភាពល្អ ។
- បទបញ្ញត្តិ ត្រូវបានប្រើប្រាស់យ៉ាងច្បាស់ ក្នុងពេលចេញអាជ្ញាប័ណ្ណ ប៉ុន្តែការប្រតិបត្តិការជាក់ស្តែង ក្នុងពេលទទួលបានការអនុញ្ញាតហើយ មិនត្រូវបានដោះស្រាយឱ្យមានប្រសិទ្ធិភាពទេ
- មិនមានបទបញ្ញត្តិច្បាស់លាស់ សម្រាប់ដាក់ទោស ឬផាកពិន័យដល់ជនល្មើស [៥៥]
- ច្បាប់ពាក់ព័ន្ធពីការជួញដូរ ពីបញ្ហាការងារ និងបញ្ហាផ្សេងទៀត តែងតែលើកពីច្បាប់កម្ពុជាជាអំណះអំណាង ប៉ុន្តែមិនមានការបញ្ជាក់ច្បាស់លាស់ពីមាត្រាណានោះទេ

លើសពីនេះទៀត មានការព្រួយបារម្ភចំពោះសមត្ថភាពនៃអធិការកិច្ចក្រសួងទេសចរណ៍ និងនាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ដើម្បីពិនិត្យមើល និងអធិការកិច្ចទៅលើកន្លែងអាជីវកម្មដែលទាក់ទងនឹងសេវាទេសចរណ៍មួយចំនួនធំ ដោយពិចារណាទៅលើការកើនឡើងយ៉ាងរហ័ស ដោយសារតែល័ក្ខខ័ណ្ឌក្នុងវិស័យឧស្សាហកម្មទេសចរណ៍។ វានៅតែត្រូវធ្វើការពង្រឹងការសម្របសម្រួលជាមួយប៉ូលិស និងអាជ្ញាធរដែនដី ព្រមទាំងស្វែងរកកិច្ចសហការពីសំណាក់ម្ចាស់អាជីវកម្មក្នុងវិស័យទេសចរណ៍។

### *២. បទអន្តរាគមន៍ដើម្បីលើកកម្ពស់ និង ត្រួតពិនិត្យការអនុវត្តន៍/បទបញ្ញត្តិសម្រាប់ CST*

ការកែលំអប្រព័ន្ធលើកកម្ពស់ និងត្រួតពិនិត្យបទបញ្ញត្តិការពារដល់កម្មករវិស័យទេសចរណ៍ និងទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចលើស្ត្រី និងកុមារត្រូវមានវិធានការចំនួន ២ គឺត្រូវកែលំអប្រព័ន្ធបទបញ្ញត្តិបច្ចុប្បន្ន និងពង្រឹងប្រសិទ្ធិភាពនៃការត្រួតពិនិត្យ និងអនុវត្តប្រព័ន្ធអធិការកិច្ច ។

[៥៥] ថ្ងៃ ២៤-២៥ មករា សិក្ខាសាលាស្ថាប័នពាក់ព័ន្ធ ស្តីពីផ្នែកទប់ស្កាត់ និង ការពារ

| ប្រភេទបទអន្តរាគមន៍ | សកម្មភាព |
|---|---|
| ការអភិវឌ្ឍន៍គោលនយោបាយ និងស្ថាប័ន | ▪ ពិនិត្យ និង កែលំអសេចក្ដីព្រាងច្បាប់ទេសចរណ៍ និងប្រកាស/សារាចរដែលមានស្រាប់ ដើម្បីដាក់បញ្ចូលបទបញ្ញត្តិទាក់ទងនឹងការប្រឆាំងការជួញដូរ និង ពលកម្មកុមារ<br>▪ អនុម័តបទបញ្ញត្តិផ្សេងទៀត ដែលធានាចំពោះសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍សម្រាប់កន្លែងអាជីវកម្មដែលទាក់ទងទៅនឹងវិស័យទេសចរណ៍<br>▪ ពង្រីក និង ពង្រឹង NCSTC/PCSTC |
| ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ | ▪ លើកកម្ពស់ការយល់ដឹងស្ដីពីការជួញដូរ WFCL និងច្បាប់ដែលពាក់ព័ន្ធនានា<br>▪ ធ្វើសិក្ខាសាលា/វគ្គបណ្ដុះបណ្ដាលស្ដីពីគោលការណ៍ប្រតិបត្តិសម្រាប់ច្បាប់ និង បទបញ្ញត្តិដែលបានកែសំរួល<br>▪ យុទ្ធនាការផ្សព្វផ្សាយព័ត៌មានដល់កន្លែងអាជីវកម្មទេសចរណ៍ សហជីព កម្មករនិយោជិត និងសហគមន៍កម្មករនិយោជិត<br>▪ អនុវត្តច្បាប់ និងបទបញ្ញត្តិ ឱ្យបានតឹងរ៉ឹង ព្រមទាំងការអនុវត្តន៍ស្ដីពី CST<br>▪ ពង្រីកអធិការកិច្ច ការអនុវត្តន៍ច្បាប់ និងការត្រួតពិនិត្យដល់ផ្នែកមិនរៀបរយ |

គោលការណ៍ណែនាំស្ដីពី ការកែលំអប្រព័ន្ធបទបញ្ញត្តិវិស័យទេសចរណ៍ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃក្រុមការងារអន្តរក្រសួង NCSTC/PCSTC និងគោលការណ៍ណែនាំស្ដីពីការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាព មានបង្ហាញលំអិតនៅក្នុងគោលការណ៍ប្រតិបត្តិ ។

## ង. ការធ្វើឱ្យប្រសើរឡើងនូវការការពារ និង សេវាសង្គម

ទិដ្ឋភាពនៃការការពារសង្គមនៃផែនការ NPA-TSEC និងផែនការ NPA-WFCL កំពុងត្រូវបានអនុវត្តយ៉ាងធំធេងជាផ្នែកមួយនៃយុទ្ធសាស្ត្រទប់ស្កាត់ ដែលដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ និងតាមរយៈការផ្តួចផ្តើមរបស់ភ្នាក់ងារមិនមែនរដ្ឋាភិបាលជាច្រើន ដូចជាអង្គការ IOM, UNICEF, UNESCO, USAID, Save the Children Network, WV-C និងអង្គការក្រៅរដ្ឋាភិបាលនានា ។

កម្មវិធីសម្រាប់ការការពារ និងការទប់ស្កាត់ផ្នែកសង្គម រួមបញ្ចូលសកម្មភាពនៅទីកន្លែងកំណើតរបស់ស្ត្រី និងកុមារដែលត្រូវបានជួញដូរ សកម្មភាពនៅតាមតំបន់គោលដៅដូចជាតំបន់ទេសចរណ៍ និងតំបន់ព្រំដែន និងសកម្មភាពដែលធ្វើជាមួយអ្នកទទួលផលគោលដៅរួមមានជនរងគ្រោះដោយសារការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ នៅតាមសហគមន៍របស់គ្រួសារកុមារដែលប្រឈមមុខនឹងគ្រោះថ្នាក់ ។

ផែនការយុទ្ធសាស្ត្រនៃក្រសួងទេសចរណ៍ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ត្រូវបានប្រើប្រាស់ជាកម្មវិធីបំពេញបន្ថែមចំពោះការផ្តួចផ្តើមនានាដែលមានរបស់ស្ថាប័នពាក់ព័ន្ធនានា ។

### ១ ការផ្តួចផ្តើមបច្ចុប្បន្ន

សមាសភាគក្នុងផែនការ TSEC/TIPSE ប្រឆាំងនឹងការជួញដូរ រួមមាននូវកម្មវិធី និងសកម្មភាពជាច្រើន ដែលមានការពាក់ព័ន្ធទៅនឹងការការពារសង្គម និងការទប់ស្កាត់។ សកម្មភាពទាំងនេះ ត្រូវបានកំណត់បង្ហាញយ៉ាងច្បាស់ជាមួយក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ដោយមានការជួយគាំទ្រពីក្រសួងសុខាភិបាល ក្រសួងអប់រំ អង្គការជាតិ និងអង្គការអន្តរជាតិនានា។ កម្មវិធីដែលដឹកនាំដោយក្រសួងទេសចរណ៍ត្រូវពិចារណាទៅលើការចូលរួមពីគ្រប់វិស័យ។ ការបង្ក្រាបការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងផ្នែកទេសចរណ៍ ដែលជាគោលដៅចម្បងសម្រាប់ជនរងគ្រោះ និងជាចំណុចគោលដៅរបស់ជនប្រព្រឹត្តិល្មើសនៅក្នុងផ្នែកទេសចរណ៍។ សម្រាប់មូលហេតុនេះ ផែនការយុទ្ធសាស្ត្ររបស់ក្រសួងទេសចរណ៍ ដែលមានយុទ្ធសាស្ត្រនានាត្រូវសង្កត់ធ្ងន់ទៅលើភ្ញៀវទេសចរកន្លែងអាជីវកម្មទេសចរណ៍ និងវិធានការប្រកបដោយភាពច្នៃប្រឌិតផ្សេងៗ ដើម្បីភ្ជាប់ជម្រើសផ្នែកសេដ្ឋកិច្ច ទៅនឹងវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព និងផលិតភាព។ កិច្ចសហការជិតស្និទ្ធិជាមួយភ្នាក់ងារ ដែលបានជ្រើសរើសសម្រាប់ការជួញដូរក៏ត្រូវពិចារណាផងដែរ រួមមានកិច្ចខិតខំក្នុងការធ្វើយុទ្ធនាការស្តីពី មេរោគអេដស៍ /ជំងឺអេដស៍ នៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍ ។

បញ្ហាលំបាកចំពោះបទអន្តរាគមន៍ស្តីពីការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពសម្រាប់ទប់ស្កាត់ និងការពារកុមារ និងស្ត្រីវ័យក្មេង មានដូចខាងក្រោមនេះ[៥៦] :

---

[៥៦] ថ្ងៃ ២៤-២៥ មករា សិក្ខាសាលាស្ថាប័នពាក់ព័ន្ធ ស្តីពីផ្នែកទប់ស្កាត់ និង ការពារ

- មានការខ្វះខាតព័ត៌មានទិន្នន័យស្តីពីស្ត្រី និងកុមារប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះការជួញដូរ និងពលកម្មកុមារ
- អ្នកចូលរួមសកម្មភាពកសាងសមត្ថភាព មិនមែនជាមនុស្សដែលចង់បាន។ មិនមានប្រព័ន្ធតាមដាន ចែកចាយព័ត៌មានស្តីពីចំណេះដឹងដែលបានរៀន ជាពិសេសក្នុងចំណោមកម្មករ ។
- កិច្ចសហការក្នុងចំណោមម្ចាស់អាជីវកម្មទេសចរណ៍ នៅមានកម្រិត
- យន្តការអនុវត្តច្បាប់ ត្រូវភ្ជាប់ជាមួយនឹងការកសាងសមត្ថភាព
- ការអនុវត្តន៍សកម្មភាពរបស់ក្រុមឃ្លាំមើលតាមសហគមន៍ ឬបណ្តាញការពារកុមារតាមសហគមន៍ នៅមានកម្រិត

*២. បទអន្តរាគមន៍ដែលបានស្នើឡើងសម្រាប់ការទប់ស្កាត់ និងការការពារ*

| *ប្រភេទនៃបទអន្តរាគមន៍* | *សកម្មភាព* | *សេវាបញ្ជូនបន្ត* |
|---|---|---|
| ការអភិវឌ្ឍន៍ស្ថាប័ន | កំណត់អាទិភាពតំបន់ទេសចរណ៍ដែលមានគ្រោះថ្នាក់ខ្ពស់ | |
| | កសាងសមត្ថភាពដល់ CPN និង មន្ត្រីមូលដ្ឋាន | |
| | សហការជាមួយក្រុមការងារអន្តរក្រសួង MOI/MOJ | |
| | សម្របសម្រួលជាមួយភ្នាក់ងារអនុវត្តច្បាប់ | |
| | សម្របសម្រួលយន្តការបញ្ជូនបន្តដល់ជនរងគ្រោះដោយសារការជួញដូរ | |
| | បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាញបំណិនជីវិត និង កម្មវិធីបង្ហាត់បង្រៀន | |
| ការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពសម្រាប់ធ្វើការទប់ស្កាត់ | លើកកម្ពស់ការយល់ដឹង-កសាងសមត្ថភាពជាមួយក្រុមនិយោជក និង សហជីពនៅតាមសហគមន៍ ទេសចរណ៍ ក្នុងចំណោមមន្ត្រីមូលដ្ឋាន មន្ត្រីថ្នាក់ជាតិ ម្ចាស់អាជីវកម្ម និង កម្មករនិយោជិត | |
| | ចែកចាយព័ត៌មានដល់ភ្ញៀវទេសចរ | |
| | តស៊ូមតិប្រឆាំងនឹងកន្លែងអាជីវកម្មទេសចរណ៍ និងប្រឆាំងនឹងសេវាកម្មនានាដែលមិនគាំទ្រចំពោះ CST | |
| | ធ្វើសិក្ខាសាលាជាមួយ MOI/MOJ | |
| | តស៊ូមតិក្នុងចំណោមនិយោជក ដើម្បីអនុញ្ញាតឱ្យបុគ្គលិកដែលជាកុមារ និង ស្ត្រីវ័យក្មេងអាចចូលរៀនពេញម៉ោង | |
| | **លើកកម្ពស់ការយល់ដឹង និង កសាងសមត្ថភាពដល់កុមារនិងស្ត្រីវ័យក្មេងដែលធ្វើការនៅក្នុងវិស័យទេសចរណ៍** | |

គោលការណ៍ប្រតិបត្តិសម្រាប់ការអភិវឌ្ឍន៍ស្ថាប័ន ការលើកកម្ពស់ការយល់ដឹង ការតស៊ូមតិ ការប្រកបការងារចិញ្ចឹមជីវិតទាក់ទងនឹងវិស័យទេសចរណ៍ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការបង្ហាត់បង្រៀនមានបង្ហាញនៅក្នុងសៀវភៅគោលការណ៍ប្រតិបត្តិ ។

## *ច. កិច្ចសហការ និងសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សហព័ន្ធសហជីព និយោជក និងអង្គការមិនមែនរដ្ឋាភិបាល*[៥៧]

### ១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់អាស៊ីក្នុងការទប់ស្កាត់ការជួញដូរមនុស្ស (ARCCPT)[៥៨]

គម្រោង ARCPT គឺជាកម្មវិធីរយៈពេល ២ឆ្នាំ ដែលទទួលមូលនិធិពី AusAID បានបញ្ចប់នៅខែមិនា ឆ្នាំ ២០០៦។ គម្រោងនេះគឺជាកម្មវិធីបណ្តុះបណ្តាលដល់តុលាការ អ្នកកាត់ទោស និងប៉ូលិស ដោយមានការសហការជាមួយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ។ ការផ្តោតជាសំខាន់ គឺសង្កត់ធ្ងន់ទៅលើទិដ្ឋភាពផ្នែកបច្ចេកទេសនៃការស៊ើបអង្កេត និងការប្រមូលភស្តុតាងជាមួយជនរងគ្រោះ ជាប្រភពចំបង[៥៩] ។

នៅពេលបច្ចុប្បន្ន គម្រោងបានធ្វើការបណ្តុះបណ្តាលដល់តុលាការ ១០រូប និងក្រឡាបញ្ជី ១០រូប ហើយវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីប៉ូលិស ក៏កំពុងស្ថិតក្នុងដំណើរការផងដែរ។ មុនផ្តល់វគ្គបណ្តុះបណ្តាល ការប៉ាន់ប្រមាណពីតម្រូវការវគ្គបណ្តុះបណ្តាល ត្រូវបានធ្វើឡើងដោយផ្នែកអនុវត្តនៃអង្គការ UNICEF ។ ការកសាងសមត្ថភាព ក៏ត្រូវបានសម្របសម្រួលដោយសាលាភូមិន្ទតុលាការ ក្នុងគោលបំណងដើម្បីបញ្ជ្រាបវិធីសាស្ត្រនៃការស៊ើបអង្កេត ទៅក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្ន ។

ទិដ្ឋភាពដែលត្រូវធ្វើការកែលំអនៅក្នុងវគ្គបណ្តុះបណ្តាល មានក្រមសីលធម៌ និងក្របខ័ណ្ឌការងារផ្នែកច្បាប់ (ឧទា. ច្បាប់ស្តីពីការជួញដូរ សេចក្តីព្រាងច្បាប់ស្តីពីស្តង់ដារតុលាការ និងក្រឡាបញ្ជីដែលសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវផ្នែកក្រមសីលធម៌/ការទទួលខុសត្រូវផ្នែកសង្គម ក្នុងចំណោមតុលាការ និងក្រឡាបញ្ជីត្រូវបញ្ជ្រាបទៅក្នុងវគ្គសិក្សា) ។

---

[៥៧] ផ្នែកនេះ ដកស្រង់ចេញពីឯកសារផែនការយុទ្ធសាស្ត្រឆ្នាំ ២០០៦-២០០៨ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្មទៅលើកុមារ និងស្ត្រីវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ទំព័រ ២៤-៣០

[៥៨] ពីការពិភាក្សាជាមួយមន្ត្រីកម្មវិធី ARCPTT ឈ្មោះ Ashby ប្រធានគ្រប់គ្រងគម្រោងប្រចាំនៅកម្ពុជា និង ឈ្មោះ Yi Yuth Virak អនុប្រធានគ្រប់គ្រងគម្រោង ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥

[៥៩] បទបង្ហាញរបស់ Janet Ashby នៅក្នុងសិក្ខាសាលាអង្គការ WV ខែកុម្ភៈ ឆ្នាំ ២០០៥

## ២. សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)[៦០]

សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា CATA ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ ២០០៤ ដោយមានសមាជិកចំនួន ៧៥ រូប ។ សមាជិកនៃសមាគមនេះ រួមមាន ភ្នាក់ងារធ្វើដំណើរ និងភ្នាក់ងារទេសចរណ៍ ។ នៅពេលបច្ចុប្បន្ន CATA មានការិយាល័យសរុបចំនួន ១២០ រួមទាំងការិយាល័យធំ និងការិយាល័យសាខា ។

សមាជិករបស់ CATA ចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាការជួញដូរ និងការកេងប្រវ័ញ្ចពលកម្ម ជាពិសេសនៅក្នុងវិស័យទេសចរណ៍។ អ្វីដែលបានរៀន និង/ឬ បានទទួល (សំភារៈសិក្ខាសាលា) ពីវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានឹងត្រូវបានផ្សព្វផ្សាយបន្តទៅដល់សមាជិកផ្សេងទៀតនៃសមាគម ។ CATA មិនផលិតសំភារៈសម្រាប់កសាងសមត្ថភាព ឬលើកកម្ពស់ការយល់ដឹងស្តីពីការជួញដូរ និងបញ្ហាពលកម្មដោយផ្ទាល់ខ្លួននោះទេ ។

CATA ធ្វើការជាមួយក្រសួងទេសចរណ៍ និងក្រសួងផ្សេងទៀត ដើម្បីបង្កើតចំនួនភ្ញៀវទេសចរជាក់លាក់ដែលមាននៅក្នុងប្រទេសកម្ពុជា។ ផែនការសំខាន់មួយនៃផែនការរបស់ CATA គឺបង្កើតសមាគមមគ្គុទ្ទេសក៍ទេសចរកើតចេញពីក្រុមមគ្គុទ្ទេសក៍ទេសចរតូចៗ ដែលបានបង្កើតឡើងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ នៅក្នុងប្រទេស ។

## ៣. សហព័ន្ធនិយោជកកម្ពុជា និងពាណិជ្ជកម្ម CAMFEBA[61]

សហព័ន្ធនិយោជកកម្ពុជា និងសមាគមអាជីវកម្ម ជាសមាគមអាជីវកម្មឯករាជ្យ និងស្វយ័តទទួលស្គាល់ និងបានចុះបញ្ជីត្រឹមត្រូវក្នុងរដ្ឋាភិបាលកម្ពុជាមានទស្សនះវិស័យធ្វើការបង្រួបបង្រួម និងពង្រឹងផ្នែកឯកជន តាមរយៈកិច្ចសហការ និងធ្វើជាតំណាងឱ្យរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានាលើពិភពលោក។ សមាគមនេះកើតឡើងក្នុងឆ្នាំ ២០០០ ដោយសារតែផ្នែកឯកជនត្រូវធ្វើការបង្រួបបង្រួមគ្នា ។ CAMFEBA បានក្លាយជាសមាគមនិយោជកធំជាងគេនៅក្នុងប្រទេសកម្ពុជា។ សមាគមនេះត្រូវបានទទួលស្គាល់ដោយអង្គការពលកម្មអន្តរជាតិ និងភ្នាក់ងារអន្តរជាតិនានា លើពិភពលោក ក្នុងនាមជាសំឡេងរបស់និយោជកនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ CAMFEBA មានតំណាងអាជីវកម្មច្រើនជាង ៧០០ មុខរបរ ។

CAMFEBA ផ្តល់សេវាសំខាន់ដូចខាងក្រោមដល់កន្លែងអាជីវកម្មនានានៅក្នុងប្រទេសកម្ពុជា:

- **សម្របសម្រួលផ្នែកឯកជនក្រោមឆ័ត្របង្រួបបង្រួមមួយ**
- ដោះស្រាយបញ្ហាប៉ះពាល់នឹងសុខមាលភាព និងអត្ថប្រយោជន៍របស់និយោជកជាសមាជិក

---

[៦០] ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ ការពិភាក្សាជាមួយលោក ហូ វណ្ណី ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា

[៦១] ដកស្រង់ពី the Web Site of Cambodian Federation of Employers and Business Association

  - សម្របសម្រួលផ្សព្វផ្សាយច្បាប់ និង បញ្ញត្តិថ្មីៗ
  - ផ្តល់ឱកាសកសាងទំនាក់ទំនង និង បណ្តាញការងារ
- **លើកកម្ពស់ទំនាក់ទំនងផ្នែកឧស្សាហកម្ម ដើម្បីធានាឱ្យមានបរិយាកាសអាជីវកម្មតាមបែបប្រូម**
  - លើកកម្ពស់បរិស្ថានអាជីវកម្មតាមក្រមសីលធម៌ ក្នុងចំណោមនិយោជក និង កម្មករនិយោជិត
  - លើកកម្ពស់សុវត្ថិភាព និង សុខភាពនៅកន្លែងការងារ
- **តំណាងឱ្យសមាជិកដែលមានបញ្ហាច្រើន**
  - ស្វែងរកការទទួលស្គាល់ និងបង្កើតទំនាក់ទំនងឱ្យមានប្រសិទ្ធិភាពជាមួយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងដែលពាក់ព័ន្ធ
  - ស្វែងរកកៅអីជាតំណាងស្ថាប័នត្រីភាគីថ្នាក់ជាតិ
  - សម្របសម្រួលជាមួយដៃគូសហព័ន្ធសហជីព
  - តំណាងឱ្យផ្នែកអាជីវកម្មនៅថ្នាក់តំបន់ និង ថ្នាក់អន្តរជាតិ
- **ផ្តល់ដំបូន្មាន កសាងសមត្ថភាព និង ចែកចាយព័ត៌មាន**
  - ផ្តល់ដំបូន្មាន យោបល់ និងការណែនាំដល់រដ្ឋាភិបាលស្តីពី គោលនយោបាយសេដ្ឋកិច្ចសង្គម
  - ផ្តល់ការបណ្តុះបណ្តាលនានាដល់សមាជិក
  - ផ្តល់ព័ត៌មានថ្មីៗស្តីពីអាជីវកម្ម និងបរិស្ថានសង្គម
  - ផ្តល់ដំបូន្មាន និងប្រឹក្សាផ្នែកច្បាប់ដល់សមាជិករបស់ខ្លួន

### ៤. សមាគមសណ្ឋាគារកម្ពុជា[62] (CHA)

សមាគមសណ្ឋាគារកម្ពុជា CHA បង្កើតឡើងក្នុងខែមិថុនា ២០០៥ ដោយមានសមាគម២ គឺសមាគមសណ្ឋាគារភ្នំពេញ PPHA និងសមាគមសណ្ឋាគារ និងផ្ទះសំណាក់ខេត្តសៀមរាប SRAHGA ដែលចាប់អារម្មណ៍លើការអភិវឌ្ឍន៍វិស័យឧស្សាហកម្មទេសចរណ៍ប្រកបដោយនិរន្តរភាព និងការរីកចម្រើនវិស័យទេសចរណ៍ នៅក្នុងប្រទេសកម្ពុជា ។ CHA គឺជាសមាគមដែលមិនរកប្រាក់កំរៃ និងជាស្ថាប័នស្របច្បាប់បម្រើប្រយោជន៍រួម ដល់គ្រប់សមាជិកទាំងអស់នៅក្នុងប្រទេសកម្ពុជា ។

ទិសដៅរបស់សមាគមនេះ គឺដើម្បីលើកកម្ពស់សមាជិករបស់ខ្លួននៅថ្នាក់ជាតិ និងអន្តរជាតិ និងដើម្បីការពារអត្ថប្រយោជន៍ផ្នែកច្បាប់របស់សមាជិក។ ទស្សនៈវិស័យរបស់សមាគម គឺដើម្បីទទួលយកការទទួលស្គាល់ទូទាំងពិភព-

[៦២] ដកស្រង់ពី Cambodian Hotel Association’s profile

លោកនូវស្តង់ដា និងគុណភាពសេវាកម្ម និងសម្បទានរបស់សមាជិករបស់ខ្លួន។ ប្រព័ន្ធទីផ្សារ ដូចជាប្រព័ន្ធអ៊ីនធឺណែត ត្រូវបានប្រើប្រាស់សម្រាប់ជាអត្ថប្រយោជន៍ដល់ដៃគូរបស់ខ្លួន ។

សមាគមសណ្ឋាគារកម្ពុជា ជាផ្នែកមួយនៃបណ្តាញការងារ ដែលមានទំនាក់ទំនងជាមួយសមាគមនានា នៅថ្នាក់តំបន់ដូចជា នៅប្រទេសឡាវ និងប្រទេសវៀតណាម។ សមាគមនេះទទួលបានការគាំទ្រ និងការណែនាំពី Mekong Private Sector Development Facility (MPDF) ដែលជាភ្នាក់ងារផ្តល់ជំនួយចំរុះក្រោមការដឹកនាំរបស់សាជីវកម្ម International Finance Corporation (IFC) ដែលជាផ្នែកឯកជនមួយរបស់ World Bank ។

CHA ផ្តល់នូវសេវា និង អត្ថប្រយោជន៍ខាងក្រោមនេះដល់សមាជិករបស់ខ្លួនៈ

- មានគេហទំព័ររបស់សមាគមៈ www.phnompenh-hotels.org និង www.angkorhotels.org
- ទាក់ទងដោះស្រាយចម្ងល់នានាមួយម្តងៗ ដោយការិយាល័យមូលដ្ឋានមួយ ហើយបុគ្គលិកចេះច្រើនភាសាយ៉ាងស្ទាត់ជំនាញ និងមានបទពិសោធន៍ទំនាក់ទំនងជាមួយភ្ញៀវជាតិ និងអន្តរជាតិ
- ការបង្ហាញដល់ភ្ញៀវជាតិ និង អន្តរជាតិតាមអ៊ីនធឺណែត តាមសៀវភៅមគ្គុទ្ទេសក៍ធ្វើដំណើរ និងតាមសារព័ត៌មាន
- ជាតំណាងឱ្យការតាំងពិពណ៌ពាណិជ្ជកម្មជាតិ និងអន្តរជាតិ
- ចេញផ្សាយព្រឹត្តប័ត្រជាប្រចាំ
- ផ្តល់ព័ត៌មានឧស្សាហកម្មថ្មីដល់សមាជិក
- វគ្គបណ្តុះបណ្តុះស្តីពីនីតិវិធី និងប្រតិបត្តិការសណ្ឋាគារ
- កម្មវិធីបណ្តុះបណ្តាលប្រកបដោយគុណភាព និងការគ្រប់គ្រង
- សិក្ខាសាលាស្តីពីប្រធានបទទាក់ទងនឹងវិស័យឧស្សាហកម្ម
- លិខិតអញ្ជើញចូលរួមព្រឹត្តិការណ៍សង្គម និងបណ្តាញការងារ
- តំណាងឱ្យរដ្ឋាភិបាលកម្ពុជាស្តីពី បញ្ហាដែលប៉ះពាល់ដល់សមាជិក
- ចូលរួមគ្រប់បញ្ហាទាំងអស់ទាក់ទងនឹងឧស្សាហកម្ម ក្នុងក្រុមដែលមានអំណាចជាងសហគ្រាសឯកជន
- ប្រឹក្សាយោបល់ បកប្រែ និង សេវាកម្មកាត់ដេរផ្សេងទៀត

## ៥. សហព័ន្ធសហជីពសេវាកម្មទេសចរណ៍កម្ពុជា [63] (CTSWF)

សហព័ន្ធសហជីពសេវាកម្មទេសចរណ៍កម្ពុជា CTSWF ត្រូវបានបង្កើតឡើងដោយសហជីពចំនួន ៩[៦៤] ។ The American Centre International for Labour Solidarity (ACILS) ជាអ្នកសម្របសម្រួលធ្វើការទម្រង់ទិសលើកទីមួយដល់សហជីពទាំងនោះ ។ អ្នកបង្កើត CTSWF ភាគច្រើនមានបទពិសោធន៍ក្នុងការធ្វើអាជីវកម្មដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ព្រលានយន្តហោះ និងកន្លែងរមណីយដ្ឋាននានា ។

ទិសដៅរបស់សហព័ន្ធសហជីព[65] គឺដើម្បី:

- បង្កើនអំណាចចរចារដល់សមាជិករបស់សហព័ន្ធសហជីព ជាមួយនិយោជក និងអ្នកសម្រេចគោលនយោបាយ
- រៀបចំចាត់ចែងកម្មករ សេវាកម្មទេសចរណ៍ដែលមិនទាន់មានសហជីព
- ធ្វើឱ្យប្រសើរឡើងនូវលក្ខខ័ណ្ឌការងារប្រាក់បៀវត្ស និងអត្ថប្រយោជន៍របស់បុគ្គលិកធ្វើការនៅគ្រប់ផ្នែកទាំងអស់នៅទូទាំងប្រទេសកម្ពុជា
- លើកទឹកចិត្តដល់សហជីពដែលប្តេជ្ញា:
    - o រៀបចំសហជីពធំ
    - o ចរចារជាសមូហភាព
    - o លទ្ធិប្រជាធិបតេយ្យពិតប្រាកដ ក្នុងរចនាសម្ព័ន្ធសហជីព និងការសម្រេចចិត្ត
    - o ប្រព័ន្ធហិរញ្ញវត្ថុមានតម្លាភាព
- ជួយដល់សមាជិកសហជីព និងចូលរួមជាមួយសមាជិកសហជីពក្នុងការដោះស្រាយជម្លោះជាមួយ និយោជកក្រុមឧស្សាហកម្ម ការចរចារជាសមូហភាព និងផ្តល់សេវាកម្មនានាដល់សមាជិកសហជីព ។ សហព័ន្ធសហជីពនេះចូលរួមជាមួយសមាជិកសហជីព តាមការអញ្ជើញ ។
- ដឹកនាំកម្មវិធីអប់រំ បង្កើត និង ផលិតឯកសារសម្រាប់សមាជិកសហជីព
- តស៊ូមតិឱ្យមានគោលនយោបាយល្អសម្រាប់កម្មករនិយោជិត សហជីព ក្នុងវិស័យសេវាកម្មទេសចរណ៍ ប៉ុន្តែមិនគាំទ្រចំពោះបក្សនយោបាយទេ
- រក្សាទំនាក់ទំនងជាមួយអង្គការសហជីពជាតិ និងអន្តរជាតិ

---

[៦៣] សំភាសន៍ជាមួយលោក Mr. Nou Chandy, Chief Educational Committee CTSWF

[៦៤] ១. សហជីពកម្មករឯករាជ្យព្រលានយន្តហោះអន្តរជាតិ ២. សហជីពកម្មករសណ្ឋាគារកាំបូឌីយ៉ាណា ៣. សហជីពកម្មករសណ្ឋាគារអាំងទែកុងទីណង់តាល់ ៤. សហជីពកម្មករសណ្ឋាគារសាន់វេ ៥. សហជីពកម្មករសណ្ឋាគារឡឺរ៉ូយាល់ ៦. សហជីពកម្មករកាស៊ីណូណាហ្គា ៧.សហជីពកម្មករសណ្ឋាគារសូហ្វីតែលរូយ៉ាល់អង្គរ ៨. សហជីពកម្មករសណ្ឋាគាររ៉ាហ្វប្រ្លេនអង្គរ ៩. សហជីពកម្មករអង្គរភេនស៊ី

[៦៥] ធម្មនុញ្ញនៃសហព័ន្ធសហជីពសេវាទេសចរណ៍កម្ពុជា, កញ្ញា 2003

- រក្សាទំនាក់ទំនងជាមួយក្រសួងឧស្សាហកម្មសេវាទេសចរណ៍
- គាំទ្រដល់ការរីកចម្រើន និងការអនុវត្តវិធានការការងារនៅកម្ពុជា

បច្ចុប្បន្ននេះ CTSWF មានសមាជិកសហជីពចំនួន ២០ (សហជីពចំនួន១២ មកពីក្រុងភ្នំពេញ ចំនួន៧ មកពីខេត្តសៀមរាប និង ចំនួន១ មកពីប៉ោយប៉ែត) ។ CTSWF មានសមាជិកជាង ៣០០០ នាក់ ។

CTSWF មានសកម្មភាពបណ្ដុះបណ្ដាលសម្រាប់ប្រធានសហជីពសណ្ឋាគារ និងសហជីពសហគ្រាសក្នុងគោលបំណងដើម្បីកសាងជាសហជីពរួម ព្រមទាំងមានសិទ្ធិ ការទទួលខុសត្រូវ និងតួនាទីទៅតាមសហជីព លទ្ធិប្រជាធិបតេយ្យ និងសេរី។ សហព័ន្ធសហជីព មានកម្មវិធីលើកទឹកចិត្តដល់សហជីពនានា ឱ្យចេះតស៊ូមតិ ដើម្បីអត្ថប្រយោជន៍របស់កម្មករ និងដើម្បីឱ្យរដ្ឋាភិបាល និងនិយោជកទទួលស្គាល់ និងការពារសិទ្ធិជាមូលដ្ឋានរបស់កម្មករនៅតាមវិស័យនានាផងដែរ ។ កម្មវិធីទាំងនេះ អាចជួយដល់សហជីព និងកម្មករ ធ្វើតេស្តសាកល្បង ទៅលើប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធផ្នែកច្បាប់របស់ខ្លួន ដូចជាជម្លោះការងារចរចារជាសហមូហភាព ការចរចារ ដោះស្រាយជម្លោះផ្នែកការងារ។ ប្រការនេះមានន័យថា បង្កើតការអនុវត្តន៍ច្បាប់ការងារឱ្យបានខ្លាំងក្លា ដោយមានការចូលរួមពីអ្នកអនុវត្តច្បាប់ ស្ដីពីការងារ។ មានកម្មវិធីជាច្រើនដែលលើកទឹកចិត្តដល់ប្រធានសហជីព ឱ្យចេះកសាងទំនាក់ទំនងជាមួយផ្នែកផ្សេងទៀតនៅក្នុងវិស័យសេដ្ឋកិច្ច ។

## ៦. អង្គការ COSECAM [66]

COSECAM គឺជាអង្គការចំរុះមួយដែលមានសមាជិកអង្គការចំនួន ២៣ ធ្វើការស្ដីពី ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា ។ ភារកិច្ចចំបងរបស់អង្គការ គឺដើម្បីសម្របសម្រួលសកម្មភាព/គម្រោងរបស់អង្គការជាសមាជិក និង ដើម្បីផ្ដល់ការជួយគាំទ្រផ្នែកអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិកនៃអង្គការជាសមាជិក ។

សកម្មភាពនៃ COSECAM មាន៖

- កសាងសមត្ថភាព
  - ជំនាញប្រឹក្សាយោបល់
  - ជំនាញគ្រប់គ្រងសម្រាប់មន្ត្រីគម្រោងនៃថ្នាក់គ្រប់គ្រងរបស់អង្គការ
  - ការអនុវត្តន៍គម្រោង

---

[៦៦] ១៩ តុលា ២០០៩ សំភាសន៍ជាមួយលោក Mr. Em Poul, IHRD program officer and Ms KAO Sokdeth, Assistant of IHRD

  - o វគ្គទី៧: ដោះស្រាយជម្លោះ ប្រឹក្សាយោបល់ចិត្តសាស្រ្ត-សង្គម (ប្រឹក្សាយោបល់ចិត្តសាស្រ្ត-សង្គម ត្រូវបានធ្វើឡើង ១ វគ្គរួចទៅហើយ ហើយវានឹងមានវគ្គបន្តនៅក្នុងខែមករា ឆ្នាំ ២០០៦)
- តស៊ូមតិ (សម្របសម្រួលកាត់បន្ថយករណីរំលោភសេពសន្ថវៈលើកុមារ)
- ជនរងគ្រោះនៃការជួញដូរ
  - o ធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មនៃសមត្ថភាពផ្នែកច្បាប់
  - o ផ្តល់ជំនាញដល់កុមារ
  - o ផ្តល់ការបណ្តុះបណ្តាលដល់កុមារទាក់ទងទៅនឹងការរំលោភផ្លូវភេទ និងការជួញដូរ

អង្គការចម្រុះ មិនផ្តល់ការបណ្តុះបណ្តាលដោយខ្លួនឯងទេ។ អ្នកជំនាញការលើប្រធានបទ/វិស័យសម្រាប់ការបណ្តុះបណ្តាលត្រូវបានអញ្ជើញឱ្យធ្វើការលើកកម្ពស់ការយល់ដឹងដល់សមាជិក ។ ភារកិច្ចសំខាន់នៃ COSECAM គឺសម្របសម្រួលសកម្មភាពបណ្តុះបណ្តាល ឧទា. ត្រួតពិនិត្យតម្រូវការបណ្តុះបណ្តាលរបស់សមាជិក អង្គការរៀបចំ/សម្របសម្រួលលំហាត់បណ្តុះបណ្តាលឆ្លើយតប និងត្រួតពិនិត្យទៅលើការអភិវឌ្ឍន៍សមត្ថភាពរួមរបស់សមាជិក ។

អង្គការសមាជិករបស់ COSECAM មានគម្រោងទាក់ទងនឹងកុមារ។ អង្គការទាំងនេះប្រមូលផ្តុំ និងបង្កើតជាក្រុមកុមារ បន្ទាប់មកទៀតធ្វើសិក្ខាសាលាក្នុងក្រុមនោះតែម្តង។ គោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺធ្វើឱ្យកុមារយល់ពីគ្រោះថ្នាក់ដែលពួកគេអាចប្រឈមមុខបាន។ វាស្រដៀងគ្នាទៅនឹងការងាររបស់ក្រុមអ្នកអប់រំមិត្ត គឺថាក្មេងដែលយល់អាចបន្តផ្សព្វផ្សាយចំណេះដឹងដល់ក្មេងដទៃទៀតនៅក្នុងសហគមន៍របស់ខ្លួន។ សិក្ខាសាលានេះត្រូវបានធ្វើឡើងរៀងរាល់ ៦ ខែម្តង ។ មកដល់ពេលនេះ មានសិក្ខាសាលាចំនួន ២ ដែលបានធ្វើ: មួយនៅក្រុងព្រះសីហនុ ហើយមួយទៀតនៅខេត្តសៀមរាប ។

អង្គការ COSECAM បានចូលរួមក្នុងការសិក្សាស្រាវជ្រាវស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៅក្នុងក្រុងព្រះសីហនុ។ អង្គការនេះ បានចូលរួមសិក្ខាសាលាដែលរៀបចំដោយអង្គការ ILO-IPEC ។ ក្នុងពេលជាមួយគ្នានេះដែរ អង្គការ COSECAM បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលដល់សមាជិករបស់ខ្លួន ព្រមទាំងលើកទឹកចិត្តឱ្យស្ថាប័នរដ្ឋាភិបាល និង ស្ថាប័នមិនមែនរដ្ឋាភិបាលចូលរួមក្នុងសិក្ខាសាលាទាំងនេះ ។

## ៧. គម្រោងភាពវៃឆ្លាតលើកុមារ ECPAT[៦៧]

ECPAT បានធ្វើការជាមួយក្រសួងទេសចរណ៍ចាប់តាំងពីឆ្នាំ ២០០១ នៅក្នុងគម្រោងនៃកម្មវិធីភាពវៃឆ្លាតរបស់កុមារដែលបានជួយគាំទ្រដោយអង្គការ Child Wise Australia ។

គម្រោង Child Wise មានក្របខ័ណ្ឌការងាររយៈពេល ២ ឆ្នាំ ដោយផ្តល់ការបណ្តុះបណ្តាលចំនួន ៥ ដល់តំបន់ដែលបានជ្រើសរើសផ្សេងៗគ្នា ។ ការបង្រៀនជនបង្គោលត្រូវបានធ្វើឡើងនៅក្នុងខេត្តបន្ទាយមានជ័យក្នុង ខែមិថុនា ប្រហែលជា២-៣ ឆ្នាំមុន។ មានអ្នកបណ្តុះបណ្តាលប្រមាណជា ១០ នាក់មកពីក្រសួង និង ថ្នាក់ខេត្ត។ ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងជាភាសាអង់គ្លេសដែលត្រូវបានបកប្រែទៅជាភាសាខ្មែរដោយគ្រូបណ្តុះបណ្តាលបង្គោលក្នុងរយៈពេល ១ ថ្ងៃកន្លះ ។ តំណាងផ្នែកអាជីវកម្មទេសចរណ៍ ក៏បានមកចូលរួមនៅថ្ងៃទី ១ នៃវគ្គបណ្តុះបណ្តាលនេះផងដែរ) ។

បច្ចុប្បន្ននេះ ECPAT កំពុងធ្វើការជាមួយអង្គការ World Vision នៅក្នុងគម្រោងស្តីពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ដែលបានបោះពុម្ពសៀវភៅខិតប័ណ្ណចំនួន ១០,០០០ក្បាល សម្រាប់ផ្សព្វផ្សាយបន្តទៅកាន់ភ្ញៀវទេសចរ និងកន្លែងអាជីវកម្មទេសចរណ៍នានា ។

សកម្មភាពមួយផ្សេងទៀត គឺការផលិតផ្ទាំងរូបភាព និងផ្លាកសញ្ញា ។ ផ្ទាំងរូបភាពចំនួន ២ និង ផ្លាកសញ្ញាចំនួន ១០ ត្រូវបានគ្រោងនឹងផលិត។ ផ្ទាំងរូបភាពចំនួន ២ ខាងលើ កំពុងត្រូវបានស្នើសុំដោយ ECPAT ទៅដាក់នៅខេត្តស្វាយរៀង និងឃុំប៉ោយប៉ែត ប៉ុន្តែទីកន្លែងដាក់លាក់សម្រាប់ដាក់ នឹងត្រូវបានកំណត់ដោយក្រសួង/ មន្ទីរទេសចរណ៍ ។

ការជួយគាំទ្រដល់វគ្គបណ្តុះបណ្តាល/សិក្ខាសាលា ក៏ជាសកម្មភាពមួយរបស់ ECPAT ដែរ ។ ក្នុងខែ សីហា ឆ្នាំ ២០០៥ មានសិក្ខាសាលាបណ្តុះបណ្តាលមួយបានធ្វើឡើងក្នុងខេត្តក្រចេះសម្រាប់ផ្នែកអាជីវកម្ម។ អ្នកបណ្តុះបណ្តាលគឺជាបុគ្គលិកមកពីក្រសួងទេសចរណ៍ ព្រោះសៀវភៅណែនាំដែលបានប្រើទទួលបានពីក្រសួងទេសចរណ៍ ហើយមានតែអ្នកបណ្តុះបណ្តាលមកពីក្រសួងទេសចរណ៍ប៉ុណ្ណោះដែលអាចប្រើវាបាន។ បុគ្គលិកមកពី ECPAT មិនត្រូវបានអនុញ្ញាតឱ្យផ្តល់ការបណ្តុះបណ្តាល ឬ ប្រើប្រាស់សៀវភៅបណ្តុះបណ្តាលនេះទេ ។

សកម្មភាពនៅពេលអនាគតរបស់អង្គការ ECPAT ស្តីពីភាពវៃឆ្លាតរបស់កុមារក្នុងវិស័យទេសចរណ៍ មានដូចខាងក្រោមនេះ:

---

[៦៧] ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ បទសំភាសន៍ជាមួយលោក Chin Chan Veasna អ្នកសម្របសម្រួល ECPAT

- ECPAT គ្រោងធ្វើការចរចារជាមួយអាកាសចរវៀតណាម និងអាកាសចរថៃដែលហោះហើរមកកាន់ប្រទេសកម្ពុជា ឱ្យចាក់បញ្ចាំងឈុតវីដេអូស្តីពីការលុបបំបាត់ការជួញដូរ តាមកញ្ចក់ទូរទស្សន៍នៅក្នុងយន្តហោះ ។
- ECPAT កំពុងព្យាយាមចាក់បញ្ចាំងឈុតរយៈពេល ៣ នាទី ដោយមានឃ្លានិយាយថា "អ្នកនឹងត្រូវដាក់ទណ្ឌកម្មឱ្យជាប់គុកចាប់ពី ១០ ឆ្នាំឡើងទៅ ប្រសិនបើអ្នករំលោភសេពសន្ថវៈលើកុមារ"
- ECPAT គ្រោងនឹងផលិតឯកសារខិត្តប័ណ្ណចំនួន ៣០,០០០ ច្បាប់ថែមទៀត នឹងបកប្រែនូវខ្លឹមសារនៃខិតប័ណ្ណនេះទៅជាភាសាកូរ៉េ ។

គោលដៅចម្បងនៃគម្រោងគឺសម្រាប់ភ្ញៀវទេសចរជនជាតិកូរ៉េ ព្រោះបច្ចុប្បន្ននេះមានចំនួនជនជាតិកូរ៉េ កើនឡើងយ៉ាងច្រើន ក្នុងចំណោមភ្ញៀវទេសចរអន្តរជាតិទាំងអស់នៅក្នុងប្រទេសកម្ពុជា។ មានការរាយការណ៍ថាប្រជាជនកូរ៉េភាគច្រើន ក៏បានចូលរួមប្រព្រឹត្តិបទរំលោភបំពានទៅលើកុមារកម្ពុជាផងដែរ ។ ដើម្បីឆ្លើយតបចំពោះបញ្ហានេះ រដ្ឋាភិបាលនៃប្រទេសកូរ៉េ បាននឹងកំពុងរៀបចំកម្មវិធីស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍អន្តរជាតិ ដែលមានសមាជិកមកពីប្រទេសជប៉ុន ប្រទេសអូស្ត្រាលី តៃវ៉ាន់ និង កូរ៉េ ហើយ ប្រទេសកម្ពុជាក៏ជាប្រទេសសមាជិកនៅក្នុងគម្រោងនេះផងដែរ។ ក្នុងកម្មវិធីអន្តរជាតិនេះ រដ្ឋាភិបាលកម្ពុជា ត្រូវបានអញ្ជើញឱ្យចូលរួមបង្ហាញពីសកម្មភាពដែលបានធ្វើ និងកំពុងកើតឡើងនៅក្នុងប្រទេសទាក់ទងទៅនឹងភាពវៃឆ្លាតរបស់កុមារក្នុងវិស័យទេសចរណ៍ ។

## ៨. គម្រោងការពារសិទ្ធិកុមារក្នុងវិស័យទេសចរណ៍ - *អង្គការមិត្តសំឡាញ់/FI*

នៅថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៥ ក្រសួងទេសចរណ៍ និងអង្គការមិត្តសំឡាញ់ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់សម្រាប់អនុវត្តគម្រោងមួយឈ្មោះថា "គម្រោងការពារសិទ្ធិកុមារក្នុងវិស័យទេសចរណ៍"។ គម្រោងត្រូវបាននឹងកំពុងអនុវត្តនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ ហើយមានរយៈពេល ៣ឆ្នាំ ដោយមានគោលបំណងសំខាន់ ដើម្បី:

- ការពារសិទ្ធិកុមារអនាថា
- ប្រយុទ្ធប្រឆាំងនឹងកត្តាដែលសម្របសម្រួលចំពោះការរីករាលដាលនៃការរំលោភផ្លូវភេទលើកុមារ ឬការរីករាលដាលនៃបញ្ហាកុមារនៅក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៃប្រទេសកម្ពុជា

ម្ចាស់ជំនួយចំបងនៃគម្រោងនេះគឺអង្គការ UNICEF និងស្ថានទូតអង់គ្លេស ដោយរួមមានថវិកាសរុបចំនួន ៣៨,៨៣០ ដុល្លារអាមេរិក ។ សកម្មភាពចម្បងនៃគម្រោង គឺដើម្បីបណ្តុះបណ្តាលក្រុមសេវាទេសចរណ៍ (មានដូចជាអ្នករត់ម៉ូតូឌុប ម្ចាស់ផ្ទះសំណាក់ សណ្ឋាគារ និងហាងលក់វត្ថុអនុស្សាវរីយ៍ ។ល។) និងកុមារអានាថាក្រុងភ្នំពេញ ស្តីពីរបៀបសង្កេត និងការពារសិទ្ធិរបស់កុមារ។ អ្នកដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលនេះ នឹងក្លាយទៅជាផ្នែកមួយនៃ

បណ្តាញរបស់អង្គការមិត្តសំឡាញ់អន្តរជាតិ ហើយទទួលបាននូវឯកសណ្ឋាន និងក្រដាសផ្សព្វផ្សាយ ។ ដូចគ្នានេះដែរ ការវាយតម្លៃត្រូវបានធ្វើឡើងក្នុងចំណោមកន្លែងអាជីវកម្មទេសចរណ៍ ដើម្បីពិនិត្យមើលទៅលើកម្រិតនៃការគោរពទៅតាមស្តង់ដារ/បទបញ្ញត្តិស្តីពី សុវត្ថិភាពកុមារនៅតាមកន្លែងអាជីវកម្ម/សេវាកម្មរបស់ខ្លួន ។

បុគ្គលិកក្រសួងទេសចរណ៍ បានចូលរួមក្នុងការធ្វើផែនការ និងការអនុវត្តនីគម្រោងជាមួយគ្នានឹងបុគ្គលិក អង្គការមិត្តសំឡាញ់ ដើម្បីធានាចែករំលែកជំនាញ និងដើម្បីពង្រឹងនូវជំនាញ និងសមត្ថភាពបច្ចេកទេសរបស់បុគ្គលិកក្រសួងទេសចរណ៍។ ការប្រជុំជាប្រចាំនឹងត្រូវបានធ្វើឡើងជាមួយក្រសួងទេសចរណ៍ ដើម្បីសម្របសម្រួលសកម្មភាពគម្រោងដែលកំពុងអនុវត្ត ដើម្បីចែករំលែកព័ត៌មាន និងដើម្បីធ្វើការរួមគ្នាដោះស្រាយបញ្ហាដែលបានជួបប្រទះ ក្នុងការអនុវត្តនីគម្រោង ។

ការចូលរួមដ៏សំខាន់ពីសំណាក់ក្រសួងទេសចរណ៍ទៅក្នុងគម្រោង មានគោលបំណង ២ ធំៗ។ ការទទួលខុសត្រូវចម្បងរបស់ក្រសួង គឺផ្តល់ការជួយគាំទ្រផ្នែករដ្ឋបាល និងផ្នែកបញ្ញត្តិនានាដល់បុគ្គលិកគម្រោងនៃអង្គការមិត្តសំឡាញ់ និងផ្តល់អាជ្ញាប័ណ្ណដល់កន្លែងអាជីវកម្មទេសចរណ៍ ដូចជាសណ្ឋាគារ និងភោជនីយដ្ឋាននានាដែលគម្រោងបានវាយតម្លៃជាវិជ្ជមាន ។

នៅចុងបញ្ចប់គម្រោង និងប្រសិនបើមានការយល់ព្រមថាគម្រោងនឹងមិនពង្រីកបន្ថែមទេ នោះអង្គការមិត្តសំឡាញ់ នឹងប្រគល់គម្រោងនេះទៅឱ្យក្រសួងទេសចរណ៍អនុវត្តតែម្តង ។ ដើម្បីធ្វើឱ្យព្រឹត្តិការណ៍នេះកើតឡើងជា ការពិត នោះក្រសួងទេសចរណ៍ត្រូវចូលរួមជាប្រចាំក្នុងការអនុវត្តគម្រោង ជាពិសេសក្នុងការត្រួតពិនិត្យគម្រោង ហើយក្រសួងទេសចរណ៍ត្រូវលើកឡើងនូវគំនិតនេះទៅក្នុងអនុស្សរណៈនៃការយោគយល់គ្នា (MoU) ។

នៅពេលបច្ចុប្បន្ន អង្គការមិត្តសំឡាញ់កំពុងធ្វើការលើកកម្ពស់ការយល់ដឹងជាមួយអ្នករត់ម៉ូតូឌុបស្តីពី សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៅកន្លែងទេសចរណ៍សំខាន់ៗចំនួន ៣ ហើយបន្ទាប់មកទៀត គឺក្រុមអ្នកបើកបរតាក់ស៊ីគោលដៅ។ នៅពេលបច្ចុប្បន្ននេះ មានអ្នករត់ម៉ូតូឌុបប្រមាណជា ១០០នាក់នៅក្នុងទីក្រុងភ្នំពេញ បានចូលរួមក្នុងការលើកកម្ពស់ការយល់ដឹងនេះ ។

## ៩. គម្រោងកម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៃអង្គការ World Vision Cambodia [៦៨]

គម្រោងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍របស់អង្គការ World Vision ចាប់ផ្តើមតាំងពីខែតុលា ឆ្នាំ២០០១។ មិនមានផែនការយុទ្ធសាស្ត្រ ត្រូវបានបង្កើតឡើងជាវេទិការបស់គម្រោងនោះទេ ប៉ុន្តែចាប់ផ្តើមដោយមានការប្តេជ្ញាទៅ

[៦៨] នាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥ កិច្ចប្រជុំជាមួយលោក នួន ឫទ្ធីនិរន្ត័ អង្គការ World Vision

លើផែនការសកម្មភាពជាតិ ៥ឆ្នាំ ស្តីពី NPA-TSEC របស់ CNCC ។ សកម្មភាពនៃគម្រោង មានការទាក់ទងទៅនឹងការទប់ស្កាត់ និងការលើកកម្ពស់ការយល់ដឹង ដែលជាសមាសភាគរងមាននៅក្នុងផែនការ NPA-TSEC ។

គោលបំណងនៃគម្រោង គឺដើម្បីអនុវត្តសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ទៅតាមដំណាក់កាល ឧទាហរណ៍ ដំណាក់កាលទី១ ផ្តោតជាពិសេសទៅលើកម្មវិធីទប់ស្កាត់ ហើយដំណាក់កាលទី២ សង្កត់ធ្ងន់ទៅលើការអប់រំ និង ដំណាក់កាលទី៣ ផ្តោតទៅលើការធ្វើឱ្យប្រសើរឡើងនូវវិធានការរដ្ឋបាល ។ កម្មវិធីខាងក្រោមនេះត្រូវបានអនុវត្តតាមលំដាប់លំដោយដូចខាងក្រោមនេះ:

- ការស្រាវជ្រាវ (ជាមួយ CNCC និងក្រសួងទេសចរណ៍) ការងារកុមារ និងការកំសាន្តរបស់មនុស្សធំពេញវ័យ
- គម្រោងកុមារអានាថានៅទីក្រុងភ្នំពេញ ឆ្នាំ ១៩៩២
- គម្រោងស្តារឡើងវិញ ឆ្នាំ ១៩៩៤
- គម្រោងពលកម្មកុមារ ឆ្នាំ ១៩៩៤
- គម្រោងកុមារប្រឈមមុខនឹងគ្រោះថ្នាក់ គឺជាកម្មវិធីអភិវឌ្ឍន៍តំបន់ដែលអនុវត្ត នៅក្នុងខេត្តចំនួន៦ ដែលត្រូវបានចាត់ទុកថាជាខេត្តដើមកំណើត ឬ ខេត្តទទួលកុមារ និងស្ត្រីដែលត្រូវបានជួញដូរ

ជាទីបញ្ចប់ កម្មវិធីបានជំរុញឱ្យមានការបង្កើតបណ្តាញការពារកុមារ (CPN) ដែលបានបង្កើតឡើងនៅតាមថ្នាក់ស្រុក និង ការបង្កើតក្រុម Task Forces នៅថ្នាក់ខេត្ត-ក្រុង ។

គម្រោងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ត្រូវបានផ្តួចផ្តើមជាមួយក្រសួងទេសចរណ៍ក្នុងឆ្នាំ២០០១ បង្កឱ្យមានការបង្កើតគណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍នៅក្នុងខេត្ត-ក្រុងទាំង ២៤ ។ គណៈកម្មការទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលរងខេត្តទទួលបន្ទុកទេសចរណ៍ ហើយតួនាទីជាអនុប្រធានប្រចាំការជាទូទៅត្រូវបានកំណត់សម្រាប់ប្រធានមន្ទីរទេសចរណ៍នៅតាមខេត្ត-ក្រុង ។ ក្រោមការផ្តួចផ្តើមជាមួយក្រសួងទេសចរណ៍ អង្គការទទួលបាននូវសមិទ្ធិផល នៃសកម្មភាពរបស់ខ្លួន ដូចខាងក្រោមនេះ:

- ការបង្កើតប្រព័ន្ធខ្សែទូរស័ព្ទ (ដោយមានការសហការជាមួយគម្រោង LEASEC) ក្នុងឆ្នាំ ១៩៩៨ នៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត-ក្រុងចំនួន ៦ (ក្រុងភ្នំពេញ ខេត្តបន្ទាយមានជ័យ ក្រុងព្រះសីហនុ និងខេត្តសៀមរាប)

- ការបង្កើតផ្នែកការពារកុមារជាមួយក្រសួងមហាផ្ទៃ តាមរយៈការិយាល័យប្រឆាំងនឹងការជួញដូរមនុស្ស និង ការពារអនីតិជន (DAHTJP) នៅក្នុងខេត្ត-ក្រុងចំនួន ៦ (បច្ចុប្បន្ននេះ សកម្មនៅក្នុងខេត្ត-ក្រុងចំនួន ៣-៤) ។

ការផ្តួចផ្តើមនេះ មានលក្ខណៈអន្តរភ្នាក់ងារ (ដឹកនាំដោយប៉ូលីស) ជាមួយតុលាការ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។ ភ្នាក់ងារ/អង្គការជួយគាំទ្រមានដូចជា អង្គការ UNICEF, Red Banner Organization, UNCHR, IOM, និង អង្គការ WV ។

- ការបង្កើតក្រុមមិត្តអប់រំមិត្តរបស់កុមារ (CPET) នៅថ្នាក់សហគមន៍ - បង្កើតឡើងនៅក្នុងខេត្តសៀមរាប ក្រុងព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រៃវែង និងខេត្តកោះកុង (ដែលជាខេត្តដើមកំណើត និងខេត្តទទួលកុមារ និងស្ត្រីដែលត្រូវបានគេជួញដូរ)

ការកសាងសមត្ថភាព និងការផលិតសំភារៈផ្សព្វផ្សាយស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ គឺជាចំណុចសំខាន់របស់អង្គការទស្សនៈពិភពលោក នៅក្នុងពេល ៣ឆ្នាំ ចុងក្រោយនេះ ។ សមិទ្ធិផលរបស់អង្គការទស្សនៈពិភពលោក មានបង្ហាញជាសង្ខេបនៅក្នុងតារាង ៣ ខាងក្រោមនេះ ។

តារាង ៣. សមិទ្ធិផលរបស់ WVC-CST

| សកម្មភាពគម្រោង | ក្របខ័ណ្ឌពេលវេលារបស់គម្រោង | | |
|---|---|---|---|
| | ២០០៣ | ២០០៤ | ២០០៥ |
| ការកសាងសមត្ថភាព | • កុមារចំនួន ៤៧៥ នាក់ (ស្រី ៣៣១)<br>• គ្រូចំនួន ៧៩ នាក់ (ប្រុស ៤៨)<br>• មន្ត្រីអាជ្ញាធរដែនដីចំនួន ៧៨ នាក់ (ប្រុស ៧៣)<br>• សមាជិកទេសចរណ៍សុវត្ថិភាពលើកុមារចំនួន ៦៥ នាក់ | • អ្នកបណ្តុះបណ្តាលចំនួន ៦០ នាក់ (ប្រុស ៤៣) - បុគ្គលិកក្រសួងទេសចរណ៍ និងផ្នែកឯកជន<br>• អ្នកបណ្តុះបណ្តាលចំនួន ៨៣៦ នាក់ពីគ្រួសារក្រីក្រ<br>• អ្នកបណ្តុះបណ្តាលកុមារចំនួន ៦៨ នាក់ដែលជាអ្នកលក់ដូរកុមារ<br>• អ្នកបណ្តុះបណ្តាលកុមារចំនួន ៥១ នាក់មកពីគ្រួសារងាយទទួលរងគ្រោះថ្នាក់<br>• មន្ត្រីមូលដ្ឋានចំនួន ៦២ នាក់ដែលបានចូលរួមជាអ្នកសង្កេតការ និងជាអ្នកជួយ<br>• គ្រូបង្រៀនចំនួន ៣២ នាក់<br>• ឳពុកម្តាយចំនួន ៤២២ នាក់ពីគ្រួសារងាយទទួលរងគ្រោះថ្នាក់ | • ក្រសួងទេសចរណ៍ និងផ្នែក ឯកជន - ជនបង្គោលចំនួន ៦៥ នាក់<br>• វគ្គបណ្តុះបណ្តាលជនបង្គោលនៅថ្នាក់សហគមន៍ : កុមារ ៩៩៤ នាក់ (ស្រី ៥៦០) ឳពុកម្តាយ ៣ នាក់ គ្រូបង្រៀន ២ នាក់ និង អាជ្ញាធរមូលដ្ឋាន ៦៩ នាក់ (ស្រី ១៨) |

| | | | |
|---|---|---|---|
| | | • បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣ នាក់<br>• ក្រុមមិត្តអប់រំមិត្តជាកុមារចំនួន ៨ ក្រុម ត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍ទេសចរណ៍ក្នុងខេត្តឧត្តរមានជ័យ<br>• ក្រុមល្ខោន ១ ក្រុមត្រូវបានបង្កើតឡើង ក្នុងខេត្តសៀមរាបដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារ | |
| ការផលិតសំភារៈផ្សព្វផ្សាយ | • សៀវភៅណែនាំកម្មវិធីបណ្តុះបណ្តាលចំនួន ១៥០០ សម្រាប់កុមារ<br>• សៀវភៅណែនាំកម្មវិធីបណ្តុះបណ្តាលចំនួន ៣២០ សម្រាប់បុគ្គលិកក្រសួងទេសចរណ៍<br>• ខិតប័ណ្ណស្តីពីទេសចរណ៍សុវត្ថិភាពនៅក្នុងប្រទេសកម្ពុជាចំនួន ១៣,០០០ | | • ខិតប័ណ្ណស្តីពីទេសចរណ៍សុវត្ថិភាពចំនួន ៩៥០០ |
| ការបង្កើតយន្តការ | • គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៃក្រសួងទេសចរណ៍<br>• គណៈកម្មការខេត្តចំនួន ១០ | | |

ផែនការសកម្មភាពរបស់អង្គការ WVC សម្រាប់ឆ្នាំ ២០០៥ រួមមានសកម្មភាពចំបងៗចំនួន ៤ ដោយបន្តអនុវត្តសកម្មភាពបច្ចុប្បន្នរបស់គម្រោង ។ សកម្មភាពទាំងនេះមានៈ

- បុគ្គលិកក្រសួងទេសចរណ៍ និងផ្នែកឯកជន ទទួលបានការបណ្តុះបណ្តាលស្តីពីការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង ស្តីពីបទបញ្ញត្តិវិស័យទេសចរណ៍ដែលពាក់ព័ន្ធនានា ឧទាហរណ៍

  - ការពិនិត្យឡើងវិញ និង ការពង្រីកកម្មវិធីសិក្សាដល់ជនបង្គោលសម្រាប់ក្រសួងទេសចរណ៍ និងសហគមន៍
  - ការបង្កើត និងការចែកចាយសំភារៈស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
  - ការប៉ាន់ប្រមាណពីតម្រូវការគ្រូបង្គោលឱ្យបានជាមុន
  - ការបង្រៀនគ្រូបង្គោលសម្រាប់អ្នកអប់រំមិត្តនៃក្រសួងទេសចរណ៍ និងផ្នែកឯកជន
  - ការបង្កើតក្រុមគ្រូបង្គោលនៅតាមមន្ទីរទេសចរណ៍
  - ការត្រួតពិនិត្យ និងការតាមដានក្រុមគ្រូបង្គោល និងក្រុមអ្នកអប់រំមិត្ត
- ពង្រឹងសមត្ថភាពគណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
  - អនុស្សរណៈស្តីពីការឃោគយល់គ្នា
  - រៀបចំសិក្ខាសាលាស្តីពី ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
  - បង្កើតទម្រង់បែបបទនៃការរាយការណ៍ពាក្យបណ្តឹង
  - ពិនិត្យទៅលើពាក្យបណ្តឹង
  - ផ្តល់ដំបូន្មានបច្ចេកទេសជាបន្តបន្ទាប់ (ការផលិតសំភារៈសម្រាប់ធ្វើយុទ្ធនាការ)
- កសាងសមត្ថភាព និងភាពជាដៃគូជាមួយបណ្តាញសហគមន៍មូលដ្ឋាន
  - ជ្រើសរើស និងបណ្តុះបណ្តាលអ្នកអប់រំមិត្តនៅក្នុងសហគមន៍ទេសចរណ៍
  - បង្កើតបណ្តាញសហគមន៍
  - ជួយគាំទ្រក្រុមល្ខោននៅតាមសហគមន៍
- ការស្រាវជ្រាវ និង ការតស៊ូមតិ

មុនពេលអនុវត្តសមាសភាគកសាងសមត្ថភាព កម្មវិធីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ បានប៉ាន់ប្រមាណជាមុនទៅលើក្រុមគោលដៅ ។ សិក្ខាសាលាតម្រង់ទិស ក៏ត្រូវបានធ្វើឡើងមុនវគ្គបណ្តុះបណ្តាលក្នុងចំណោមបុគ្គលិកទេសចរណ៍ ប៉ូលីស យោធា មន្ត្រីអន្តោប្រវេសន៍ ក្រសួងសង្គមកិច្ច អតីតយុទជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងពាណិជ្ជកម្ម និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ និងបារ/ខារ៉ាអូខេ ។ គោលដៅនៃការកសាងសមត្ថភាពមានអ្នកចូលរួមប្រមាណជា ៦០នាក់ សម្រាប់វគ្គបណ្តុះបណ្តាលនីមួយៗ ដែលមានរយៈពេល ២ ថ្ងៃ ហើយ អ្នកបណ្តុះបណ្តាល ត្រូវបានរំពឹងថានឹងលើកឡើងវិញនូវមេរៀនរបស់ខ្លួនដល់បុគ្គលិក ។

ដោយមានការអនុវត្តន៍សកម្មភាព និងកម្មវិធីជាច្រើនស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ចាប់ពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៥ ចំណេះដឹងនានាដែលទទួលបានអាចធ្វើជាចំណុចចាប់ផ្តើមសម្រាប់កែលំអនូវការចែកចាយសកម្មភាពនានាក្នុងការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។ ចំណេះដឹងមួយចំនួននៃចំណេះដឹងទាំងនេះមានដូចខាងក្រោម៖

- ដំណើរការសម្របសម្រួល មានលក្ខណៈយឺតយ៉ាវបន្តិច និងស្ទុកស្ទាញជាមួយគណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។ គណៈកម្មការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដែលមានបុគ្គលិកប្រមាណជា ៦ រូប ប៉ុន្តែទើបបានបង្កើតឡើងនៅពេលថ្មីៗនេះ (ក្នុងឆ្នាំ ២០០៥) ។ សម្រាប់គណៈកម្មការអន្តរភ្នាក់ងារ (ខេត្ត-ក្រុង) ជាទូទៅ មិនមានផែនការច្បាស់លាស់ទេ ព្រោះកិច្ចប្រជុំគណៈកម្មការមានលក្ខណៈជាវេទិកាសម្រាប់ភ្នាក់ងារជាច្រើនឱ្យមកជួបជុំគ្នា និងឡើងបង្ហាញនូវបញ្ហានានា ដែលបានជួបប្រទះដោយមន្ទីរ/អង្គការរៀងៗខ្លួន។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងម្តងក្នុង ១ខែ ហើយជាទូទៅធ្វើជាប្រភេទ "វេទិកាសម្រាប់អ្នកដឹកនាំ" (ដែលមានន័យថា អ្វីៗទាំងអស់សម្រេចទៅលើអ្នកដឹកនាំក្នុងការដោះស្រាយបញ្ហា ហើយដំណើរការនេះមិនសូវឆ្លើយចំគោលដៅ និងមិនសូវមានប្រសិទ្ធិភាពនោះទេ) ។ ស្ថានការណ៍នេះប្រហែលជាអាចបណ្តាលមកពីកង្វះខាតដំណើរការធ្វើផែនការ ។ ជាទូទៅមិនមានផែនការនៅតាមខេត្តនោះទេ ប៉ុន្តែមន្ទីរនានាមានផែនការទាក់ទងទៅនឹងផែនការមេនៅថ្នាក់ក្រសួងរបស់ខ្លួន ។

- ចំណេះដឹងផ្សេងទៀត អាចទទួលបានពីការប៉ាន់ប្រមាណទៅលើលទ្ធផល/បទពិសោធន៍ផ្ទៃក្នុងនៃការងារសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដែលធ្វើឡើងដោយអង្គការ World Vision ។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលមិនទាន់បានទទួលពេញលេញនៅឡើយទេ ទោះជាមានទម្រង់បែបបទជាសេចក្តីព្រាងក៏ដោយ ។ ការប៉ាន់ប្រមាណនេះ ឆ្លើយតបចំពោះភាពពាក់ព័ន្ធ ប្រព័ន្ធនៃការគ្រប់គ្រង ប្រសិទ្ធិភាព និងការសម្របសម្រួលសកម្មភាពផ្សេងៗទាក់ទងទៅនឹងការងារសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។

គម្រោងភាពជាដៃគូដ៏សំខាន់ និងមានតម្លៃរបស់អង្គការ World Vision Cambodia ជាមួយនឹងក្រសួងទេសចរណ៍ នឹងបន្តសម្រាប់ ៣ ឆ្នាំខាងមុខទៀត ។